# យើងរួបរួមគ្នា លើកតម្កើងព្រះជាម្ចាស់



សូមបងប្អូនរួមចិត្តគំនិតជាមួយគ្នា សូត្រទំនុកតម្កើង
និងច្រៀងថ្វាយ កោតសរសើរព្រះជាម្ចាស់ ដោយស្មោះអស់ពីដួងចិត្ត ។
ចូរអរព្រះគុណព្រះជាម្ចាស់ ជាព្រះបិតាក្នុងព្រះនាមព្រះយេស៊ូគ្រីស្តជាអម្ចាស់
នៃយើងលើគ្រប់ប្រការ និងគ្រប់ពេលវេលាផង ។
(លិខិតគ្រីស្តទូតប៉ូល ផ្ញើជូនគ្រីស្តបរិស័ទក្រុង អេភេសូ ៥,១៩-២០)

# ពិធីអភិបូជា



# មាតិកាសង្ខេប

**លរ មាតិកា** **ទំព័រ**


**ភាគ ១-អភិបូជា.......................................... ១**

**ភាគ ២-ចម្រៀង និងទំនុកតម្កើង.......................... ១២៣**

១-ពេលប្រជុំគ្នា ព្រឹក ល្ងាច .......................... ១២៥
៣- ចម្រៀងពេលចូល.......................... ១៤៦
៤- ហែព្រះបន្ទូល.......................... ១៥២
៥- ថ្វាយតង្វាយ .......................... ១៦២
៦- ទទួលព្រះកាយ.......................... ១៦៨
៧- ចម្រៀងពេលចេញ.......................... ២៣២
៨- កោតសរសើរព្រះនាងម៉ារី.......................... ២៣៥
៩- កោតសរសើរសន្តយ៉ូសែប.......................... ២៥០
១០- រដូវរង់ចាំ.......................... ២៥២
១១- អបអរសាទរបុណ្យព្រះយេស៊ូប្រសូត.......................... ២៥៥
១២- រដូវសែសិបថ្ងៃ.......................... ២៦៥
១៣- រដូវបុណ្យចម្លង.......................... ២៧៩
១៤- បុណ្យព្រះវិញ្ញាណយាងមក .......................... ២៨៨
១៥- ចម្រៀងតេហ្សេ.......................... ២៩២

១៦- បុណ្យចូលឆ្នាំ.................................................... ២៩៧
១៧- អាពាហ៍ពិពាហ៍................................................ ២៩៨
១៨- ផ្សេងៗ........................................................... ៣០០
១៩- ទំនុកតម្កើង .................................................... ៣៥០
២០- ពាក្យអធិដ្ឋានប្រចាំថ្ងៃ........................................ ៣៧៣
២១- លើកតម្កើងព្រះបរមនាមព្រះយេស៊ូ ...................... ៣៧៤
២២- ពាក្យអង្វរសន្ដបុគ្គលទាំងឡាយ............................ ៣៨០
២៣- មាតិកា បទចម្រៀង......................................... ៣៨៣

# យើងរួបរួមគ្នា លើកតម្កើងព្រះជាម្ចាស់

បងប្អូនគ្រីស្តបរិស័ទទាំងបីភូមិភាគជាទីស្រឡាញ់ !

យើងជាលោកអភិបាលព្រះសហគមន៍ទាំងបីភូមិភាគ មានអំណរសប្បាយបាន រៀបចំសៀវភៅចម្រៀងថ្មីនេះជូនដល់បងប្អូន ។ សៀវភៅនេះមានពាក្យអធិដ្ឋាន សម្រាប់អភិបូជាតាមរបៀបថ្មី ដែលនឹងជួយឲ្យបងប្អូនចូលរួមយ៉ាងសកម្មនៅ ពេលថ្វាយអភិបូជា ។ សៀវភៅនេះ មានបទចម្រៀងពីដើម និងបទចម្រៀង បច្ចុប្បន្នដែរ ។

យើងជាអ្នកស្វែងរកព្រះជាម្ចាស់ តាមរយៈភាពស្ងប់ស្ងាត់ផង តាមរយៈព្រឹត្តិការណ៍ ផ្សេងៗផង តាមរយៈការអធិដ្ឋានផ្សេងៗផង និងព្រមទាំងតាមរយៈបទចម្រៀងដ៏ ពីរោះៗដែរ ។ ពេលយើងភ្ជាប់ជាមួយព្រះជាម្ចាស់ ដែលគង់នៅក្នុងដួងចិត្តរបស់ យើងម្នាក់ៗ នោះបទចម្រៀងប្រែទៅជាពីរោះ និងមានអត្ថន័យ ។

គ្រប់ពេលយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ នោះយើងរួមគ្នាកោតសរសើរ ព្រះអង្គ អរព្រះគុណព្រះអង្គដែលបានប្រទានព្រះអំណោយទានផ្សេងៗមកយើង ទាំងអស់គ្នា ហើយយើងក៏មានបំណងចង់អង្វរព្រះអង្គឲ្យអ្នកតូចតាច អ្នកក្រីក្រ អ្នកជំងឺ និងមនុស្សគ្រប់វ័យ រួមជាមួយព្រះសហគមន៍របស់យើងដែរ ។

យើងសង្ឃឹមថា សៀវភៅនេះជួយឲ្យបងប្អូនចាប់អារម្មណ៍ស្វែងរកព្រះជាម្ចាស់ ថែមទៀត តាមរយៈការច្រៀងនិងសូត្រ ដែលព្រះវិញ្ញាណប្រទានឲ្យបងប្អូន ទាំងអស់គ្នា ។

| លោកអភិបាលអូលីវីយេ | លោកអភិបាលគីកេ | លោកភិបាលអង់តូនី |
|---|---|---|
| ភូមិភាគភ្នំពេញ | ភូមិភាគបាត់ដំបង | ភូមិភាគកំពង់ចាម |
| + Olivier Schmitthaeusler | + E. Figaredo sj | S. Antony Samy |

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧

# ពិធីប្រារព្ធ

## បទដើមដំបូង

*   គ្រីស្តបរិស័ទដែលជាអ្នកបាត់បែងក្នុងពិធី ត្រូវជ្រើសរើសយក បទចម្រៀងឲ្យស្របទៅតាមអត្ថន័យ នៃពិធីបុណ្យថ្ងៃនោះ។ ការច្រៀងជាមួយគ្នា នាំឲ្យគ្រីស្តបរិស័ទប្រមូលអារម្មណ៍ និងរួមគ្នាឲ្យមានចិត្តថ្លើមតែមួយ។

## ការគោរពព្រះសហគមន៍ដែលជាព្រះកាយរបស់ព្រះគ្រីស្ត

*   **ដើម្បីសម្រួល យើងសរសេរអក្សរកាត់ដូចតទៅ ៖**

| | |
|---|---|
| ប.= | បូជាចារ្យ |
| គ្រ.= | គ្រីស្តបរិស័ទ ឬ អង្គប្រជុំ |

ប.   ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ។

គ្រ.   **អាម៉ែន។**

*បន្ទាប់មក បូជាចារ្យគោរពព្រះសហគមន៍*
*ដោយរើសរបៀបមួយ ក្នុងរបៀបទាំងបីខាងក្រោមនេះ។*

១.   ប.   សូមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនឹងការរួមរស់ជាធ្លុងតែមួយ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ គង់នៅជាមួយបងប្អូន។

គ្រ.   **ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង។**

២. **ប.** សូមព្រះហឫទ័យប្រណីសន្ដោស
និងសេចក្ដីសុខសាន្ដរបស់ព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំ
ហើយនឹងព្រះអម្ចាស់យេស៊ូគ្រីស្ដគង់នៅជាមួយបងប្អូន ។

**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

៣. **ប.** សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

*ជំនួសពាក្យ សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន លោកអភិបាលពោលថា ៖* សូមសេចក្ដីសុខសាន្ដគង់នៅជាមួយបងប្អូន ។

**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

លោកបូជាចារ្យ ឬលោកឧបដ្ឋាក ឬអ្នកបម្រើពិធីបុណ្យអាចសង្ខេបខ្លឹមសារនៃពិធីបុណ្យនៅថ្ងៃនេះជូនគ្រីស្ដបរិស័ទ ។

# ពិធីសូមទទួលសារភាព

១. ប. បងប្អូនជាទីស្រឡាញ់ !
ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន
ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

គ្រ. *ខ្ញុំសូមទទួលសារភាព*
*ចំពោះព្រះដ៏មានឫទ្ធានុភាពសព្វប្រការ*
*ហើយចំពោះអស់បងប្អូនផងថា*
*ខ្ញុំបានប្រព្រឹត្តអំពើបាបច្រើន*
*ដោយកាយ វាចា ចិត្ត*
*និងដោយខានបំពេញកិច្ចការរបស់ខ្ញុំ*
(គក់ទ្រូង)
*ទោសខ្ញុំអើយ ទោសខ្ញុំអើយ ទោសខ្ញុំអើយធ្ងន់ណាស់ ។*
*ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី*
*អស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ព្រមទាំងអស់បងប្អូន*
*សូមជួយអង្វរព្រះជាអម្ចាស់ឲ្យខ្ញុំផង ។*

ប. សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។

គ្រ. **អាម៉ែន ។**

២.	**ប.**	បងប្អូនជាទីស្រឡាញ់ ! ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

*អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយលោកបូជាចារ្យពោលថា ៖*

ប.	ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរយើងខ្ញុំ ។

**គ្រ.**	**ដ្បិតយើងខ្ញុំបានធ្វើខុសនឹងព្រះហឫទ័យព្រះអង្គ ។**

**ប.**	ឱ ព្រះអម្ចាស់អើយ ! សូមប្រោសប្រណីដល់យើងខ្ញុំ ។

**គ្រ.**	**ហើយសូមសង្គ្រោះយើងខ្ញុំផង ។**

**ប.**	សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំផង ។

**គ្រ.**	**អាម៉ែន ។**

*លោកបូជាចារ្យសូត្រដូចខាងក្រោមនេះ៖*

ប.	ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។
**គ្រ.**	**ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។**
**ប.**	ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។
**គ្រ.**	**ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។**
**ប.**	ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។
**គ្រ.**	**ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។**

ឬ

Kyrie, eleison គីរីយេ. អេឡេអ៊ីសុន
Christe, eleison គ្រីស្តេ. អេឡេអ៊ីសុន
Kyrie, eleison គីរីយេ. អេឡេអ៊ីសុន

៣.　ប.　បងប្អូនជាទីស្រឡាញ់ ! ចូរយើងទទួលស្គាល់អំពើបាបរបស់ខ្លួន ដើម្បីថ្វាយអភិបូជាដោយសមរម្យ ។

*អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយលោកបូជាចារ្យពោលតាមពាក្យអង្វរខាងក្រោម ។*

ប.　ឱ ព្រះយេស៊ូជាអម្ចាស់អើយ ! ព្រះបិតាបានចាត់ព្រះអង្គឲ្យយាងមកព្យាបាលមនុស្សដែលបាក់ទឹកចិត្ត ។
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

គ្រ.　**ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។**

ប.　ឱ ព្រះយេស៊ូគ្រីស្តអើយ !
ព្រះអង្គយាងមកហៅរកអស់អ្នកបាប ។
ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។

គ្រ.　**ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ ។**

ប.　ឱ ព្រះយេស៊ូជាអម្ចាស់អើយ !
ព្រះអង្គគង់ខាងស្តាំព្រះបិតា សូមជួយអង្វរឲ្យយើងខ្ញុំ ។
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។

គ្រ.　**ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ ។**

ប.　សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
មេត្តាលើកលែងទោសឲ្យយើងខ្ញុំបានរួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំផង ។

គ្រ.　**អាម៉ែន ។**

# ពិធីបាចទឹក

*ក្រុមគ្រីស្តបរិស័ទខ្លះមានប្រពៃណីបាចទឹក នៅពេលចាប់ផ្តើមប្រារព្ធអភិបូជា ។ ពិធីនេះញ៉ាំងគ្រីស្តបរិស័ទឲ្យនឹកអំពីបុណ្យជ្រមុជទឹក ដែលធ្វើឲ្យខ្លួនគេបានរួចពីបាប ដោយចូលរួមជាមួយព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ ។ ក្នុងពេលបាចទឹក គួរច្រៀងបទមួយ ដែលមានទំនាក់ទំនងនឹងបុណ្យជ្រមុជទឹក និងជីវិតថ្មីដែលព្រះអង្គប្រទានឲ្យ ។ ប្រសិនបើលោកបូជាចារ្យចង់ប្រសិទ្ធព្រះពរលើទឹក សូមយកពាក្យប្រសិទ្ធពរក្នុងពិធីបុណ្យជ្រមុជទឹក ឬក្នុងបុណ្យចម្លង ។*

**(រដូវធម្មតា ប្រចាំឆ្នាំ)**

១- ឱ ! ព្រះជាអម្ចាស់អើយ សូមទ្រង់ព្រះមេត្តា ប្រោសទឹកលើខ្ញុំ
នោះខ្ញុំនឹងបានជ្រះស្អាត សូមព្រះអង្គលាងជម្រះបិត្តខ្ញុំ
នោះចិត្តខ្ញុំនឹងបានស្អាតល្អ សជាងសំឡីទៅទៀត ។

២- ឱ ! ព្រះជាអម្ចាស់អើយ សូមទ្រង់ព្រះមេត្តាលើកលែងទោស
ប្រោសបាបឲ្យខ្ញុំផង ហើយសូមទ្រង់ព្រះមេត្តា
បំភ្លឺចិត្តគំនិតខ្ញុំឲ្យមានកម្លាំង និងជៀសវាងអំពើបាបតរៀងទៅ ។

៣- ឱព្រះជាអម្ចាស់អើយ សូមព្រះអង្គប្រទាន ទឹកដែលផ្តល់ជីវិត
នោះខ្ញុំមានជីវិតអស់កល្ប សូមព្រះអង្គប្រណីមេត្តា
ប្រទានព្រះអំណោយទានឲ្យយើងខ្ញុំ មានជំនឿកាន់តែមាំមួនឡើង ។

## (រដូវបុណ្យចម្លង)

## (អគ ៤៧,១)

១-ខ្ញុំបានឃើញទឹកខ្វាយចេញពីខាងស្ដាំព្រះវិហារ អាលេលូយ៉ា
ហើយជនទាំងឡាយណាដែលបានទទួលទឹកនេះ ក៏បានទទួលការសង្គ្រោះដែរ
ជនទាំងនោះនឹងច្រៀងថា អាលេលូយ៉ា អាលេលូយ៉ា ។

២-ចូរយើងទាំងអស់គ្នាច្រៀងលើកតម្កើង ព្រះជាអម្ចាស់ដ្បិតព្រះអង្គមានហឫទ័យល្អ
ហើយព្រះមេត្តាករុណារបស់ព្រះអង្គ ក៏ស្ថិតនៅជានិច្ច ។

៣-សិរីរុងរឿងមានដល់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលព្រះអង្គគង់នៅតាំងពីដើមរៀងមក ហើយជាដរាបតរៀងទៅ ។
អាម៉ែន ។ អាលេលូយ៉ា ។

*រៀងរាល់ថ្ងៃអាទិត្យ និងបុណ្យសំខាន់ៗ សូមសូត្រ ឬច្រៀងធម៌លើក តម្កើងសិរីរុងរឿង លើកលែងតែក្នុងរដូវរង់ចាំ និងរដូវសែសិបថ្ងៃ ។*

## ធម៌លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់

សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត
ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
បានសេចក្តីសុខសាន្តនៅលើផែនដី ។
យើងខ្ញុំសូមកោតសរសើរព្រះអង្គ លើកតម្កើងព្រះអង្គ
ក្រាបប្រណិប័តន៍ព្រះអង្គ លើកតម្កើងសិរីរុងរឿងព្រះអង្គ
អរព្រះគុណព្រះអង្គ ដែលប្រកបដោយសិរីរុងរឿងដ៏ធំទូលំទូលាយ ។
ឱព្រះជាម្ចាស់ជាស្តេចស្ថានបរមសុខ
ហើយជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ឱ ព្រះយេស៊ូគ្រីស្តជាអម្ចាស់ ជាព្រះបុត្រាតែមួយ !
ឱ ព្រះជាអម្ចាស់ ជាកូនចៀមរបស់ព្រះជាម្ចាស់ ជាព្រះបុត្រានៃព្រះបិតា!
ព្រះអង្គដែលដកបាបនៃពិភពលោក សូមអាណិតអាសូរយើងខ្ញុំ !
ព្រះអង្គដែលដកបាបនៃពិភពលោក សូមទទួលពាក្យអង្វរយើងខ្ញុំ !
ព្រះអង្គដែលគង់ខាងស្តាំព្រះបិតា សូមអាណិតអាសូរយើងខ្ញុំ !
ឱ ព្រះយេស៊ូគ្រីស្តអើយ !
មានតែព្រះអង្គទេ ជាព្រះដ៏វិសុទ្ធ ជាព្រះអម្ចាស់ ហើយជាព្រះដ៏ឧត្តមបំផុត
ព្រះអង្គរួមជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធក្នុងសិរីរុងរឿងនៃព្រះបិតា ។
**អាម៉ែន ។**

**ប.** សូមបងប្អូនតាំងចិត្តអធិដ្ឋាន ។

*អង្គប្រជុំនៅស្ងៀមស្ងាត់បន្តិច រួចលោកបូជាចារ្យពោលពាក្យអធិដ្ឋានសរុបក្នុងនាមបងប្អូនទាំងអស់ ។ លោកបញ្ចប់ពាក្យអធិដ្ឋានថា ៖*

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់ ដែលសោយរាជ្យរួមជាមួយព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

*ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះបិតា មានថែងអំពីព្រះគ្រីស្តនៅខាងចុងនោះ លោកបូជាចារ្យបញ្ចប់ ដោយពោលថា៖*

...ដែលសោយរាជ្យរួមជាមួយព្រះបិតា
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

*ប្រសិនបើពាក្យអធិដ្ឋានទៅកាន់ព្រះគ្រីស្ត លោកបូជាចារ្យបញ្ចប់ ដោយពោលថា ៖*

យើងខ្ញុំសូមអង្វរព្រះអង្គដែលសោយរាជ្យរួមជាមួយព្រះបិតា
និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

# ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

**អត្ថបទទី១ ៖** សូមថ្លែងព្រះគម្ពីរ...

*ព្រះជាម្ចាស់មានព្រះបន្ទូលដល់យើងសព្វថ្ងៃនេះ ដូចទ្រង់មានព្រះបន្ទូលដល់ប្រជាជនអ៊ីស្រាអែលពីដើម ។ អ្នកអានបញ្ចប់អត្ថបទដោយ*

*ប្រកាសថា ៖* **នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។**

គ្រ. **សូមអរព្រះគុណព្រះជាម្ចាស់ ។**

គួរឲ្យអង្គប្រជុំស្មូតទំនុកតម្កើងឆ្លើយឆ្លងគ្នា ។

**អត្ថបទទី២ ៖** សូមថ្លែងព្រះគម្ពីរ...

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។

គ្រ. **សូមអរព្រះគុណព្រះជាម្ចាស់ ។**

*បន្ទាប់មកអង្គប្រជុំច្រៀង អាលេលូយ៉ា ឬបទរមួយតាមរដូវបុណ្យ ។*

**ព្រះគម្ពីរដំណឹងល្អ ៖**

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. **ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប. សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត...

គ្រ. **សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអម្ចាស់ ។**

*ពេលបញ្ចប់ លោកបូជាចារ្យប្រកាសថា ៖*

នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

**គ្រ. សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត ។**

*លោកបូជាចារ្យបកស្រាយអត្ថន័យគម្ពីររាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ ។*

*រួចព្រះសហគមន៍ប្រកាសជំនឿដូចខាងក្រោម ៖*

## ធម៌ជឿរបស់មហាសន្និបាតក្រុងនីសេ/ កុងស្តង់ទីណូប

*ខ្ញុំជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ*
*ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ*
*ជាព្រះបង្កើតមេឃ និងដី ទាំងអ្វីៗដែលមើលឃើញ*
*និងមើលមិនឃើញ ។*

*ខ្ញុំជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តតែមួយ*
*ជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់*
*ហើយកើតពីព្រះបិតា មុនកាលសម័យទាំងអស់ ។*
*ព្រះអង្គជាព្រះជាម្ចាស់ចេញពីព្រះជាម្ចាស់*
*ជាព្រះពន្លឺចេញពីព្រះពន្លឺ*
*ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ចេញពីព្រះជាម្ចាស់ដ៏ពិតប្រាកដដែរ ។*
*ព្រះអង្គទទួលព្រះជន្មពីព្រះបិតា*
*ហើយមិនកកើតដូចសត្វលោកឡើយ*
*ព្រះអង្គរួមសភាពជាមួយព្រះបិតា*
*ហើយអ្វីៗសព្វសារពើក៏កើតមក ដោយសារព្រះអង្គដែរ ។*
*ព្រះអង្គយាងមកពីស្ថានបរមសុខដើម្បីមនុស្សយើង*
*និងដើម្បីសង្គ្រោះយើងខ្ញុំ ។*

*(អង្គប្រជុំឱនកាយបន្តិចរហូតដល់ "ព្រះអង្គទៅជាមនុស្ស")*

ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះអង្គបានទទួលរូបកាយពីព្រះនាងព្រហ្មចារិនីម៉ារី
ហើយព្រះអង្គទៅជាមនុស្ស ។

ព្រះអង្គត្រូវគេឆ្កាងនៅជំនាន់លោកប៉ុនពីឡាត
ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ ។
ព្រះអង្គសោយទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះ ។
លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ស្របតាមគម្ពីរ ។
ព្រះអង្គយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះបិតា ។
ព្រះអង្គនឹងយាងមកវិញយ៉ាងរុងរឿង
ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ ទាំងស្លាប់
ហើយព្រះរាជ្យព្រះអង្គ នឹងនៅស្ថិតស្ថេរឥតទីបញ្ចប់ឡើយ ។

ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះអម្ចាស់ដែលប្រទានជីវិត
ព្រះអង្គហូរចេញពីព្រះបិតា និងព្រះបុត្រា ។
ព្រះអង្គទទួលការក្រាបថ្វាយបង្គំ និងលើកតម្កើងសិរីរុងរឿង
ស្មើនឹងព្រះបិតា និងព្រះបុត្រា ។
ព្រះអង្គបានថ្លែងព្រះបន្ទូល តាមរយៈអស់លោកព្យាការី ។

ខ្ញុំជឿលើព្រះសហគមន៍តែមួយដ៏វិសុទ្ធ
និងកាតូលិក ដែលបន្តជំនឿពីក្រុមគ្រីស្តទូត ។
ខ្ញុំប្រកាសថា មានអគ្គសញ្ញាជ្រមុជទឹកតែមួយ
ដែលលើកលែងទោសឲ្យរួចពីបាប ។
ខ្ញុំរង់ចាំពេលដែលមនុស្សស្លាប់នឹងរស់ឡើងវិញ
និងជីវិតនៅលោកខាងមុខផង ។
អាម៉ែន ។

## ធម៌ជឿរបស់ក្រុមគ្រីស្តទូត

ខ្ញុំជឿលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ជាព្រះបង្កើតមេឃ និងដី ។
ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា
ហើយជាព្រះអម្ចាស់យើងខ្ញុំ ។

*(អង្គប្រជុំឱនកាយបន្តិចរហូតដល់ "ព្រះនាងព្រហ្មចារិនីម៉ារី")*

ព្រះអង្គមានកំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់លោកប៉ុនពីឡាត ។
ព្រះអង្គត្រូវគេឆ្កាង សោយទិវង្គត
ហើយព្រះសពព្រះអង្គ ត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ។
ព្រះអង្គបានយាងចុះទៅស្ថានក្រោម
លុះដល់ថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ពីចំណោមមនុស្សស្លាប់
ព្រះអង្គបានយាងឡើងស្ថានបរមសុខ
ទៅគង់ខាងស្តាំព្រះជាម្ចាស់ជាព្រះបិតា
ដ៏មានឫទ្ធានុភាពសព្វប្រការ ។
ព្រះអង្គនឹងយាងមកវិញ
ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ ទាំងស្លាប់ ។
ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ
ខ្ញុំជឿលើព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ
និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ។
ខ្ញុំជឿថា មានការលើកលែងទោសមនុស្សឲ្យរួចពីបាប
ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ
ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង ។ អាម៉ែន ។

# ខ្ញុំជឿព្រះជាម្ចាស់

**បន្ទរ-ខ្ញុំជឿព្រះជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។**

១- ខ្ញុំជឿព្រះ ជាព្រះបិតា ទ្រង់បានបង្កើតមេឃនិងដី
ទ្រង់ស្រឡាញ់មនុស្សទាំងឡាយ ។

២- ខ្ញុំជឿព្រះ ជាព្រះបុត្រា ទ្រង់បានយាងមកក្នុងឋានលោក
បានសង្គ្រោះមនុស្សទាំងឡាយ ។

៣- ខ្ញុំជឿព្រះ ជាព្រះវិញ្ញាណ ទ្រង់គង់នៅជាមួយយើងខ្ញុំ
នាំយើងខ្ញុំទៅព្រះបិតា ។

ក្រោយមក មានពាក្យអង្វរសកលរបស់គ្រីស្តបរិស័ទ ។

# បន្ទរពាក្យអង្វរសកល

**បន្ទរ-**

១- សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ

២- ឱ !ព្រះជាម្ចាស់អើយ សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់ ។

៣- ឱ ព្រះអង្គអើយ សូមព្រះសណ្តាប់ សូមទ្រង់អាណិតឆ្លើយតបមកកូន ។

៤- កូនសូមស្រែកទូល អស់ពីដួងចិត្ត សូមព្រះជាម្ចាស់ស្តាប់សំឡេងកូន ។

៥- សូមមេត្តាប្រោសយើងខ្ញុំ ឱ !ព្រះជាអម្ចាស់ ដែលបានរងទុក្ខ
និងសង្គ្រោះលោកា ។

៦- ឱ ព្រះជាម្ចាស់ កូនសូមអង្វរ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យកូនផង
ដោយអនុគ្រោះ សូមប្រោសប្រណី ។

៧- ខ្ញុំស្វែងរកព្រះអង្គ ដោយចិត្តសង្ឃឹម ឱ!ព្រះជាម្ចាស់អើយ
សូមមេត្តាឆ្លើយតបមកខ្ញុំផង ។

៨- ឱ!ព្រះគ្រីស្តជាអម្ចាស់ សូមទ្រង់ព្រះមេត្តា ទទួលពាក្យអង្វរយើងខ្ញុំ
ដោយព្រះហឫទ័យប្រណីសន្តោសផង ។

៩- ឱ!ព្រះអម្ចាស់អើយ សូមទ្រង់មេត្តាស្តាប់ពាក្យអង្វររបស់យើងខ្ញុំ ។

១

១០-ឱអេម៉ានូអែលព្រះជាម្ចាស់គង់ជាមួយយើង
សូមមេត្តាសណ្តាប់ពាក្យអង្វររបស់យើង ។

២

១១-ឱអេម៉ានូអែលព្រះជាម្ចាស់គង់ជាមួយយើង
សូមមេត្តាសណ្តាប់ពាក្យអង្វររបស់យើងខ្ញុំ ។

១២- ព្រះម្ចាស់យើងអង្វរ សូមទ្រង់ស្ដាប់អង្វរ ពេលយើងទូលសូមមេត្តា ។
ព្រះម្ចាស់យើងអង្វរ សូមទ្រង់ស្ដាប់អង្វរ សូមមេត្តាគង់ជាមួយយើង ។

## ធម៌សកលសម្រាប់រដូវបុណ្យចម្លង

ទី១

១៣-ឱ!ព្រះគ្រីស្ដ ដែលមានព្រះជន្មរស់ឡើងវិញអើយ
សូមទ្រង់មេត្តា ស្ដាប់ពាក្យអង្វររបស់យើងខ្ញុំ ។

# ពិធីអរព្រះគុណដ៏វិសុទ្ធ

**ពិធីរៀបចំតង្វាយ**

*អ្នកបម្រើពិធីបុណ្យ រៀបចំតុសក្ការៈសម្រាប់ដាក់តង្វាយ ។ គ្រីស្តបរិស័ទយក នំប៉័ង និងស្រាជូនលោកបូជាចារ្យ ។ លោកបូជាចារ្យកាន់ចានព្រះកាយដែលមាន នំប៉័ង ដោយដៃទាំងពីរលើកបន្តិច ទាំងពោលថា ៖*

ប. បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល !
យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ
ដ្បិតយើងខ្ញុំទទួលនំប៉័ងនេះ ពីព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។
យើងខ្ញុំសូមលើកនំប៉័ងនេះ ដែលជាផលផ្លែនៃទឹកដី
និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ ។
សូមឲ្យនំប៉័ងនេះ ទៅជាអាហារដែលផ្តល់ជីវិតសម្រាប់យើងខ្ញុំ ។

*លោកបូជាចារ្យ ដាក់ចានព្រះកាយដែលមាននំប៉័ង លើកន្សែងព្រះកាយ ។ ប្រសិនបើគ្មានចម្រៀងថ្វាយតង្វាយ លោកបូជាចារ្យពោលពាក្យខាងលើ ដោយសំឡេងខ្លាំងៗ ។*

**គ្រ. សូមសរសើរតម្កើងព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ ។**

*លោកបូជាចារ្យ ចាក់ស្រា និងចាក់ទឹកបន្តិចចូលក្នុងពែងព្រះលោហិត ដោយពោលខ្សឹបៗថា ៖*

*ដូចទឹកលាយជាមួយស្រានេះ ដោយគម្រោងការដ៏អស្ចារ្យយ៉ាងណា*
*សូមប្រោសយើងខ្ញុំឲ្យចូលរួមក្នុងសភាពជាព្រះជាម្ចាស់របស់ព្រះគ្រីស្ត*
*ដែលបានបន្ទាបខ្លួនចូលរួមក្នុងសភាពជាមនុស្សយ៉ាងនោះដែរ ។*

ប. បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល !
យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ
ដ្បិតយើងខ្ញុំទទួលស្រាទំពាំងបាយជូរ
ពីព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។
យើងខ្ញុំសូមលើកស្រានេះ ដែលជាផលផ្លែនៃដើមទំពាំងបាយជូរ
និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ ។
សូមឲ្យស្រាតង្វាយនេះទៅជាភេសជ្ជៈ
ដែលផ្តល់ការសង្គ្រោះសម្រាប់យើងខ្ញុំ ។

**គ្រ. សូមសរសើរតម្កើងព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ ។**

ប. ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាទទួលយើងខ្ញុំ ដែលមានចិត្តសុភាពរាបសា
និងសោកស្តាយដោយបានប្រព្រឹត្តអំពើបាប ។
សូមព្រះអង្គប្រោសឲ្យសក្ការបូជាដែលយើងខ្ញុំថ្វាយនៅថ្ងៃនេះ
បានគាប់ព្រះហឫទ័យព្រះជាអម្ចាស់ផង ។

*លោកបូជាចារ្យឈរលាងដៃនៅចំហៀងតុសក្ការៈ ទាំងពោលខ្សឹបៗថា ៖*
*ឱ ព្រះអម្ចាស់អើយ ! សូមលុបលាងកំហុសរបស់ខ្ញុំឲ្យបានស្អាតទាំងស្រុង*
*សូមជម្រះខ្ញុំឲ្យបានបរិសុទ្ធរួចពីបាប ។*

ប. សូមបងប្អូនតាំងចិត្តអធិដ្ឋាន សូមឲ្យសក្ការបូជារបស់ខ្ញុំ
និងរបស់បងប្អូនបានគាប់ព្រះហឫទ័យព្រះជាម្ចាស់
ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ។

គ្រ. **សូមព្រះអម្ចាស់ទទួលសក្ការបូជាពីដៃរបស់លោក ទុកជាការលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ និងជាប្រយោជន៍ដល់យើងខ្ញុំ ព្រមទាំងព្រះសហគមន៍ទាំងមូលរបស់ព្រះអង្គផង ។**

*លោកបូជាចារ្យលាតដៃ ដោយពោលពាក្យអធិដ្ឋានថ្វាយតង្វាយ ។*
*លោកបូជាចារ្យបញ្ចប់ពាក្យថ្វាយតង្វាយដោយពោលថា ៖*

ប. យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ ។

គ្រ. **អាម៉ែន ។**

## ធម៌អរព្រះគុណដ៏វិសុទ្ធ ទី១

ប.  សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

**គ្រ.  ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប.  សូមលើកចិត្តថ្វាយព្រះអង្គ ។

**គ្រ.  យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**

ប.  សូមអរព្រះគុណព្រះជាអម្ចាស់នៃយើងខ្ញុំ ។

**គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង ។**

*ពេលនេះ លោកបូជាចារ្យសូត្រធម៌ប្រារព្ធស្របតាមពាក្យពន្យល់ក្នុងពិធី ។*
*ក្រោយសូត្រធម៌ប្រារព្ធចប់ លោកច្រៀង ឬអាន រួមជាមួយគ្រីស្តបរិស័ទ ៖*

***ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !***
***ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល***
***មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត***
***សូមលើកតម្កើងព្រះអង្គ***
***ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។***

*លោកបូជាចារ្យលាតដៃ ដោយពោលថា ៖*

ឱ ព្រះបិតាប្រកបដោយព្រះហប្ញទ័យសប្បុរសយ៉ាងក្រៃលែងអើយ !
យើងខ្ញុំសូមអង្វរព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

សូមព្រះអង្គមេត្តាទទួល ហើយប្រទានព្រះពរ ✠ លើអំណោយ
តង្វាយ និងសក្ការបូជាដ៏វិសុទ្ធនេះ ។
យើងខ្ញុំសូមថ្វាយតង្វាយទាំងនេះ
ជាដំបូង ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍កាតូលិក ។
សូមព្រះអង្គមេត្តាប្រទានសេចក្តីសុខសាន្ត
ដល់ព្រះសហគមន៍នៅលើផែនដីទាំងមូល ។
សូមព្រះអង្គថែរក្សាការពារ ណែនាំ
និងបង្រួបបង្រួមព្រះសហគមន៍ជាធ្លុងតែមួយ
រួមជាមួយអ្នកបម្រើរបស់ព្រះអង្គ សម្តេចប៉ាបយើងខ្ញុំ (**នាម...**)
និងលោក (**ឈ្មោះ...**) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
ព្រមទាំងអស់លោកអភិបាល ដែលថែរក្សាសេចក្តីពិត
និងជំនឿកាតូលិក ដែលបន្តមកពីក្រុមគ្រីស្តទូត ។

សូមព្រះអម្ចាស់ប្រោសប្រណី
ដល់អស់អ្នកបម្រើរបស់ព្រះអង្គ (**ឈ្មោះ...**)
និងអស់អ្នកដែលរួបរួមគ្នានៅទីនេះ មានតែព្រះអង្គទេដែលជ្រាបថា
បងប្អូនទាំងអស់នេះ មានជំនឿ និងចិត្តភក្តីយ៉ាងណាចំពោះព្រះអង្គ ។
យើងខ្ញុំសូមថ្វាយអភិបូជានេះ សម្រាប់បងប្អូនទាំងនោះ
ហើយបងប្អូនក៏ថ្វាយអភិបូជាសម្រាប់ខ្លួនគេ
និងញាតិមិត្តរបស់គេដែរ ។

បងប្អូនសង្ឃឹមថា ព្រះអង្គរំដោះពួកគេឲ្យរួចពីបាប
ឲ្យមានសុខភាពល្អ និងឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង
ហេតុនេះ គេអាចបំពេញតាមពាក្យសន្យាចំពោះព្រះអង្គ
ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ដោយរួមជាមួយព្រះសហគមន៍ទាំងមូល យើងខ្ញុំទាំងអស់គ្នាសូមគោរព
ជាបឋម ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយសិរីរុងរឿង
ជាព្រះមាតាព្រះជាម្ចាស់ និងព្រះអម្ចាស់យេស៊ូគ្រីស្តនៃយើងខ្ញុំ
† បន្ទាប់មក សន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាងព្រហ្មចារិនី
គ្រីស្តទូត និងមរណសាក្សី
សន្តសិលា និងសន្តប៉ូល, សន្តអន់ដ្រេ
(**សន្តយ៉ាកុប, សន្តយ៉ូហាន,**
**សន្តថូម៉ាស, សន្តភីលីព,**
**សន្តបារថូឡូមេ, សន្តម៉ាថាយ,**
**សន្តស៊ីម៉ូន និងសន្តយូដា,**
**សន្តលីណូ, សន្តក្លេ, សន្តក្លេម៉ង់**
**សន្តស៊ីស, សន្តក័រណេ, សន្តស៊ីព្រីយ៉ាំង,**
**សន្តឡូរ៉ង, សន្តគ្រីសូកូន,**
**សន្តយ៉ូហាន និងសន្តប៉ូល,**
**សន្តកូស្មា និងសន្តដាមីយ៉ាំង**) និងសន្តបុគ្គលទាំងឡាយ ។
ដោយពាក្យអង្វររបស់សន្តបុគ្គលទាំងអស់នោះ
សូមព្រះអង្គមេត្តាជួយ និងការពារយើងខ្ញុំគ្រប់ពេលវេលា និងគ្រប់ទិសទី

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ **អាម៉ែន ។**)

*សូមជ្រើសរើសអត្ថបទខាងក្រោមនេះ ឲ្យត្រូវតាមរដូវបុណ្យ*

*ឬតាមកាលៈទេសៈ ។*

បពិត្រព្រះអម្ចាស់ !
សូមទទួលតង្វាយនេះ ពីយើងខ្ញុំជាអ្នកបម្រើ
និងពីគ្រួសារទាំងមូលរបស់ព្រះអង្គ ដោយអនុគ្រោះ ។
សូមប្រទានសេចក្ដីសុខសាន្តរបស់ព្រះអង្គដល់យើងខ្ញុំជារៀងរាល់ថ្ងៃ ។
សូមរំដោះយើងខ្ញុំឲ្យរួចពីទោសអស់កល្បជានិច្ច
ហើយសូមទទួលយើងខ្ញុំចូលក្នុងចំណោមអស់អ្នក
ដែលព្រះអង្គបានជ្រើសរើស ។
(ដោយរួមជាមួយព្រះគ្រីស្ដ ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

**ប.** ឱ ព្រះអម្ចាស់អើយ !
សូមព្រះអង្គមេត្តាយល់ព្រមទទួលស្គាល់
និងប្រទានពរលើតង្វាយនេះ
ឲ្យបានវិសុទ្ធ និងជាទីគាប់ព្រះហឫទ័យព្រះអង្គ ។
សូមប្រោសឲ្យតង្វាយនេះ
បានទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះអម្ចាស់យេស៊ូគ្រីស្ដ
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
ដើម្បីជាប្រយោជន៍ដល់យើងខ្ញុំ ។

នៅថ្ងៃ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គយកនំបុ័ងមកកាន់ក្នុងព្រះហស្ដដ៏វិសុទ្ធជាទីគោរព
ព្រះអង្គងើបព្រះភក្ត្រទតទៅលើមេឃ
ឆ្ពោះទៅកាន់ព្រះជាម្ចាស់
ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ
ព្រះអង្គអរព្រះគុណ និងសរសើរតម្កើង
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គកាន់ពែងដ៏ប្រសើរនេះ
ក្នុងព្រះហស្តដ៏វិសុទ្ធ ជាទីគោរព
អរព្រះគុណ និងសរសើរតម្កើងម្តងទៀត
ហើយប្រទានឲ្យក្រុមសាវ័កទាំងមានព្រះបន្ទូលថា៖

**សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។**

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

**គ្រ. ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

*គ្រ. ឱ ព្រះអម្ចាស់អើយ !*

**រឿងរាល់ពេលយើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

**គ្រ. ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

ប. បពិត្រព្រះអម្ចាស់ !
យើងខ្ញុំជាអ្នកបម្រើព្រះអង្គ
រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ
នាំគ្នានឹករឭកដល់ព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងជាព្រះអម្ចាស់យើងខ្ញុំ
គឺព្រះអង្គសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញពីស្ថានក្រោម
ហើយព្រះអង្គយាងឡើងស្ថានបរមសុខយ៉ាងរុងរឿង ។
ក្នុងចំណោមអ្វីៗដែលព្រះអង្គបានប្រទាន
យើងខ្ញុំសូមថ្វាយព្រះអង្គនូវ
សក្ការបូជាដ៏បរិសុទ្ធ
សក្ការបូជាដ៏ពិសិដ្ឋ
សក្ការបូជាដ៏និម្មល ជាព្រះកាយដែលផ្តល់ជីវិតអស់កល្បជានិច្ច
និងព្រះលោហិត ដែលផ្តល់ការសង្គ្រោះជានិរន្តរ៍ ។
កាលពីដើម ព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយរបស់

លោកអាបែ៊ល ជាមនុស្សសុចរិត
និងយញ្ញបូជា របស់លោកអប្រាហាំ ជាបុព្វបុរសយើងខ្ញុំ
ព្រមទាំងយញ្ញបូជារបស់ស្ដេចមែលគីសេដែក
ជាមហាបូជាចារ្យរបស់ព្រះអង្គយ៉ាងណា
សូមព្រះអង្គមេត្ដាទទួលសក្ការបូជានេះ
ទុកជាយញ្ញបូជាដ៏ពិសិដ្ឋ និងជាសក្ការបូជាដ៏និម្មលយ៉ាងនោះផង ។

ឱ ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមឱនកាយអង្វរព្រះអង្គ
សូមមេត្ដាឲ្យទេវទូតដ៏ពិសិដ្ឋនាំយកសក្ការបូជានេះ
ទៅថ្វាយព្រះអង្គនៅលើតុសក្ការៈឯស្ថានបរមសុខ
នៅចំពោះព្រះភក្ត្រនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត ។
សូមឲ្យយើងខ្ញុំដែលទទួលព្រះកាយ
និងព្រះលោហិតដ៏វិសុទ្ធរបស់ព្រះបុត្រាពីតុសក្ការៈនេះ
បានពោរពេញដោយព្រះហឫទ័យប្រណីសន្ដោស
និងព្រះពរយ៉ាងបរិបូរណ៍ ។
(ដោយរួមជាមួយព្រះគ្រីស្ដ ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

សូមព្រះអម្ចាស់មេត្ដានឹកដល់អ្នកបម្រើព្រះអង្គ (**នាម...** និង**នាម...**)
ដែលបានដៅដោយសញ្ញានៃជំនឿ
ពួកគាត់បានលាចាកលោកនេះមុនយើងខ្ញុំ
និងកំពុងសម្រាកយ៉ាងសុខសាន្ដ ។

សូមព្រះជាអម្ចាស់មេត្ដាប្រោសប្រទានបុគ្គលទាំងនោះ
និងអស់អ្នកដែលសម្រាកក្នុងអង្គព្រះគ្រីស្ដ
បានត្រជាក់ត្រជុំ ពោរពេញដោយពន្លឺ និងសេចក្ដីសុខសាន្ដ ។

(ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។)

ទោះបីយើងខ្ញុំជាអ្នកបាបក៏ដោយ
ក៏យើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ
ដែលជឿសង្ឃឹមលើព្រះហឫទ័យមេត្តាករុណាដ៏លើសលប់
របស់ព្រះអង្គដែរ ។
សូមព្រះអង្គមេត្តាប្រោសឲ្យយើងខ្ញុំ
បានចូលរួមក្នុងសហភាពជាមួយគ្រីស្តទូត និងមរណសាក្សី
ជាមួយសន្តយ៉ូហានបាទីស្ត, សន្តស្តេផាន
សន្តម៉ាធីយ៉ា, សន្តបារណាបាស
(សន្តអ៊ីញ៉ាស, សន្តអឡិចសាំង
សន្តម៉ាសេឡាំង និងសិលា
សន្តីភេលីស៊ីតា និងពែពេទូអា
សន្តីអាហ្គាត, សន្តីលូស៊ី
សន្តីអាញ៉ែស, សន្តីសេស៊ីល
សន្តីអាណាស្តាស៊ី) និងសន្តបុគ្គលទាំងឡាយផង ។
យើងខ្ញុំសូមទទូចអង្វរព្រះអង្គ
សូមឲ្យយើងខ្ញុំបានចូលរួមក្នុងសហភាពរបស់ជនជីវិសុទ្ធទាំងនេះ ។
សូមព្រះអង្គកុំរាប់អំពើល្អរបស់យើងខ្ញុំឡើយ
តែសូមលើកលែងទោសឲ្យយើងខ្ញុំវិញ
ដោយសារព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ ។
គឺដោយសារព្រះគ្រីស្តនេះហើយ
បានជាព្រះអង្គនៅតែបង្កើតអ្វីៗដ៏ល្អទាំងអស់នេះ
ប្រោសឲ្យបានវិសុទ្ធ ឲ្យមានជីវិត និងប្រទានពរ

ហើយប្រគល់ឲ្យយើងខ្ញុំ ។

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

## ធម៌អរព្រះគុណដ៏វិសុទ្ធ ទី២

ប.	សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ.	ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**
ប.	សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ.	យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**
ប.	សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ.	ពិតជាការគួរណាស់ ហើយប្រពៃផង ។**

ប.	បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។
ព្រះបិតាបានបង្កើតសត្វលោក និងអ្វីៗសព្វសារពើទាំងអស់
ដោយព្រះយេស៊ូគ្រីស្តជាព្រះបន្ទូលរបស់ព្រះអង្គ ។
ព្រះបិតាចាត់ឲ្យព្រះយេស៊ូគ្រីស្តយាងមកសង្គ្រោះ និងរំដោះយើងខ្ញុំ
គឺព្រះអង្គបានទទួលរូបកាយជាមនុស្ស
ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ។
ដោយបំពេញបំណងរបស់ព្រះបិតា
និងប្រមូលប្រជារាស្ត្រមួយដ៏វិសុទ្ធថ្វាយព្រះអង្គ
ព្រះបុត្រាសព្វព្រះហឫទ័យត្រដាងព្រះហស្តរងទុក្ខលំបាក

ដើម្បីបំផ្លាញចំណងនៃសេចក្ដីស្លាប់
និងសម្ដែងអំពីជីវិតរស់ឡើងវិញ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួម
ជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ រួមគ្នាលើកតម្កើង
សិរីរុងរឿងរបស់ព្រះអង្គ ដោយសូរស័ព្ទតែមួយថា ៖

**ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !**
**ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល**
**មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។**
**ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត**
**សូមលើកតម្កើងព្រះអង្គ**
**ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។**
**ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។**

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ និងជាប្រភពនៃភាពដ៏វិសុទ្ធគ្រប់យ៉ាង ។
យើងខ្ញុំសូមទូលអង្វរព្រះអង្គ
សូមប្រោះព្រះវិញ្ញាណរបស់ព្រះអង្គដូចទឹកសន្សើម
មកញ៉ាំងតង្វាយទាំងនេះឲ្យបានវិសុទ្ធ គឺសូមឲ្យតង្វាយនេះ
បានទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះអម្ចាស់យេស៊ូគ្រីស្ត
សម្រាប់យើងខ្ញុំ ។

នៅគ្រាដែលព្រះយេស៊ូគ្រីស្តសព្វព្រះហឫទ័យ
ឲ្យគេបញ្ជូនព្រះអង្គទៅសោយទុក្ខលំបាក
ព្រះអង្គយកនំប៉័ងមកកាន់ អរព្រះគុណព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល ព្រះអង្គលើកពែងឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ នេះជាលោហិតរបស់ខ្ញុំ
ដែលចងសម្ពន្ធមេត្រីថ្មី និងគង់វង្សអស់កល្បជានិច្ច
ហើយដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាស**
**រហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

**គ្រ.  ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេលយើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

**គ្រ.  ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

ប.  បពិត្រព្រះអម្ចាស់ !
ក្នុងពេលដែលយើងខ្ញុំនឹករឭក
ដល់ព្រះបុត្រាសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
យើងខ្ញុំសូមថ្វាយព្រះកាយដែលផ្ដល់ជីវិត
និងព្រះលោហិតដែលផ្ដល់ការសង្គ្រោះ
ព្រមទាំងអរព្រះគុណព្រះអង្គ
ដ្បិតទ្រង់សព្វព្រះហឫទ័យឲ្យយើងខ្ញុំ
សមនឹងស្ថិតនៅចំពោះព្រះភក្ត្រ និងបម្រើព្រះអង្គ ។
យើងខ្ញុំសូមលំទោនកាយទូលអង្វរ
សូមព្រះអង្គប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធប្រមូលផ្ដុំយើងខ្ញុំ
ដែលចូលរួមក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ដ
ឲ្យទៅជាធ្លុងតែមួយផង ។
បពិត្រព្រះអម្ចាស់ !
សូមព្រះអង្គនឹកដល់ព្រះសហគមន៍

ដែលមាននៅសព្វអន្លើក្នុងពិភពលោកទាំងមូល
សូមប្រោសឲ្យព្រះសហគមន៍
បានគ្រប់លក្ខណៈក្នុងសេចក្តីស្រឡាញ់
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ (**នាម...**)
លោក(**នាម...**) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងអស់លោកអ្នកដែលមានបន្ទុកដឹកនាំប្រជារាស្ត្រព្រះអង្គ ។

ឱ ព្រះបិតាយើងខ្ញុំអើយ !សូមព្រះអង្គនឹកដល់
(**ឈ្មោះ...**) ជាអ្នកបម្រើរបស់ព្រះអង្គ
ដែលព្រះអង្គត្រាស់ហៅឲ្យលាចាកលោកនេះទៅឯព្រះអង្គ
(**នៅថ្ងៃនេះ**) ។
សូមព្រះអង្គប្រោសប្រណី (**ឈ្មោះ...**)
បានរួមស្លាប់ជាមួយព្រះបុត្រា ដែលសោយទិវង្គត សូមឲ្យ
គាត់បានរួមរស់ជាមួយព្រះបុត្រា
ដែលមានព្រះជន្មរស់ឡើងវិញផង ។

សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ
ដែលសម្រាន្តលក់ដោយមានចិត្តសង្ឃឹមនឹងរស់ឡើងវិញ
ព្រមទាំងបុគ្គលទាំងអស់ដែលបានលាចាកលោកនេះ
ក្នុងធម៌មេត្តាករុណារបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសប្រទានឲ្យបុគ្គលទាំងនោះ
បានចូលក្នុងពន្លឺនៃព្រះភក្ត្រព្រះអង្គ ។
សូមព្រះអង្គអាណិតអាសូរយើងខ្ញុំទាំងអស់គ្នា
បានទទួលជីវិតអស់កល្បជានិច្ច

រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គល
ជាព្រះមាតារបស់ព្រះជាម្ចាស់
រួមជាមួយសន្តយ៉ូសែប ជាស្វាមីព្រះនាង ជាមួយអស់គ្រីស្តទូត
និងអស់សន្តបុគ្គលនៅគ្រប់សម័យ ដែលគាប់ព្រះហឫទ័យព្រះអង្គ ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។
ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

គ្រ. **អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

## ធម៌អរព្រះគុណដ៏វិសុទ្ធ ទី៣

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

**គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**

ប. សូមអរព្រះគុណព្រះជាអម្ចាស់នៃយើងខ្ញុំ ។

**គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។**

*បន្ទាប់មក ត្រូវប្រើធម៌ប្រារព្ធណាមួយស្របតាមពាក្យណែនាំពិធី ហើយបន្តតាមរបៀបខាងក្រោមនេះ ៖*

***ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !***
***ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល***
***មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត***
***សូមលើកតម្កើងព្រះអង្គ***
***ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។***

ឱ ព្រះអម្ចាស់អើយ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន
ហើយអ្វីៗសព្វសារពើដែលព្រះអង្គបានបង្កើត
សូមកោតសរសើរព្រះអង្គ ។
តាមរយៈព្រះអម្ចាស់យេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
ទ្រង់ប្រទានឲ្យអ្វីៗសព្វសារពើមានជីវិត និងបានវិសុទ្ធ ។
ព្រះអង្គតែងតែប្រមូលផ្ដុំប្រជារាស្ត្រសម្រាប់ព្រះអង្គ
ដើម្បីថ្វាយតង្វាយដ៏បរិសុទ្ធចំពោះព្រះនាមព្រះអង្គ
ចាប់ពីថ្ងៃរះរហូតដល់ថ្ងៃលិច ។

ឱ ព្រះអម្ចាស់អើយ !ហេតុនេះហើយ
បានជាយើងខ្ញុំសូមលំទោនកាយទូលអង្វរព្រះអង្គ
សូមចាត់ព្រះវិញ្ញាណព្រះអង្គ មកប្រសិទ្ធពរលើតង្វាយ
ដែលយើងខ្ញុំលើកថ្វាយនេះ ឲ្យបានវិសុទ្ធ
និងបានទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ
ដែលបានផ្ដាំឲ្យយើងខ្ញុំថ្វាយអភិបូជានេះ ។

នៅរាត្រីដែលគេបញ្ជូនព្រះយេស៊ូ ទៅសោយទុក្ខលំបាក
ព្រះអង្គយកនំប៉័ងមកកាន់
អរព្រះគុណ និងលើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងឡើង
អរព្រះគុណ និងលើកតម្កើងព្រះបិតា
ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្ម**
**រស់ឡើងវិញ ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេល**
**ព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេលយើងខ្ញុំពិសានំបុ័ង**
**និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

ប. ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំនឹករឭកដល់ព្រះបុត្រាព្រះអង្គ
សោយទិវង្គតដើម្បីសង្គ្រោះយើងខ្ញុំ
ព្រះអង្គមានព្រះជន្មរស់ឡើងវិញដ៏អស្ចារ្យ
និងយាងឡើងស្ថានបរមសុខ
ហើយយើងខ្ញុំក៏ទន្ទឹងរង់ចាំព្រះបុត្រាព្រះអង្គយាងមកវិញ ។
យើងខ្ញុំសូមថ្វាយសក្ការបូជាជីវិសុទ្ធដែលមានជីវិតនេះ
ដើម្បីអរព្រះគុណព្រះអង្គ ។
សូមព្រះអង្គមេត្តាទតមើលតង្វាយរបស់ព្រះសហគមន៍
ទុកជាសក្ការបូជារបស់ព្រះបុត្រា ។
សូមប្រោសឲ្យយើងខ្ញុំដែលទទួលកម្លាំងពីព្រះកាយ
និងព្រះលោហិតរបស់ព្រះបុត្រា
ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
បានមូលផ្តុំគ្នាទៅជារូបកាយតែមួយ
និងមានចិត្តថ្លើមតែមួយក្នុងអង្គព្រះគ្រីស្ត ។

*សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ*
*បានទៅជាតង្វាយគង់វង្សអស់កល្បជានិច្ចចំពោះព្រះបិតា*
*ដូច្នេះ យើងខ្ញុំសមនឹងទទួលមរតក*
*រួមជាមួយអស់អ្នកដែលព្រះអង្គបានជ្រើសរើស*
*ជាបឋម រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី*

*ដែលពោរពេញដោយសុភមង្គលដ៏លើសលប់*
*ជាព្រះមាតានៃព្រះជាម្ចាស់*
*ជាមួយសន្តយ៉ូសែបជាស្វាមីព្រះនាង*
*ជាមួយអស់គ្រីស្តទូត និងអស់មរណសាក្សី*
*(ជាមួយសន្ត...ឬសន្តី...ប្រចាំថ្ងៃ ឬឧបការី...)*
*ព្រមទាំងជាមួយសន្តបុគ្គលទាំងឡាយ*
*ដែលជួយអង្វរព្រះអង្គឲ្យយើងខ្ញុំឥតឈប់ឈរ ។*

*ឱ ព្រះអម្ចាស់អើយ !*
*សូមឲ្យសក្ការបូជានេះ*
*ដែលផ្សះផ្សាយើងខ្ញុំបានជានាជាមួយព្រះអង្គ*
*សូមប្រោសឲ្យពិភពលោកទាំងមូល*
*បានប្រកបដោយសេចក្ដីសុខសាន្ត*
*និងទទួលការសង្គ្រោះ ។*
*សូមពង្រឹងព្រះសហគមន៍របស់ព្រះអង្គ*
*ដែលកំពុងធ្វើដំណើរនៅក្នុងលោកនេះ*
*ឲ្យមានជំនឿ និងសេចក្ដីស្រឡាញ់*
*រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ(នាម...)*
*ជាអ្នកបម្រើព្រះអង្គ*
*លោក(នាម...) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ*
និងលោកអភិបាលព្រះសហគមន៍នានាក្នុងសកលលោក
អស់លោកបូជាចារ្យ អស់លោកឧបដ្ឋាក
និងប្រជារាស្ត្រទាំងមូលដែលជាកម្មសិទ្ធិរបស់ព្រះអង្គផង ។
សូមព្រះអង្គសណ្ដាប់នូវពាក្យអង្វររបស់ក្រុមគ្រួសារនេះ
ដែលព្រះអង្គបានត្រាស់ហៅឲ្យជួបជុំនៅចំពោះព្រះភក្ត្រព្រះអង្គ ។

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង !
សូមប្រោសឲ្យអស់បុត្រធីតាព្រះអង្គ
ដែលខ្ចាត់ខ្ចាយបានចូលរួមជាមួយព្រះអង្គផង ។
†សូមព្រះអង្គមេត្តាដល់អស់បងប្អូនយើងខ្ញុំ ដែលទទួលមរណភាព
និងដល់បុគ្គលទាំងអស់ដែលគាប់ព្រះហឫទ័យព្រះអង្គ
ហើយបានលាចាកលោកនេះ
សូមទទួលបុគ្គលទាំងនោះ ចូលក្នុងព្រះរាជ្យរបស់ព្រះអង្គ ។
នៅទីនោះ យើងខ្ញុំសង្ឃឹមថា នឹងបានពោរពេញទៅដោយ
សិរីរុងរឿងរបស់ព្រះអង្គជានិច្ចនិរន្តរ៍
ដោយរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់យើងខ្ញុំ
គឺដោយព្រះគ្រីស្តនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក ។ †

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

ធម៌ខាងក្រោមនេះ អាចប្រើនៅពេលថ្វាយអភិបូជានឹករឭកដល់មរណបុគ្គល ។

† សូមព្រះបិតានឹករឭកដល់ (**ឈ្មោះ...**) ជាអ្នកបម្រើព្រះអង្គ
ដែលព្រះអង្គត្រាស់ហៅ (នៅថ្ងៃនេះ)
ឲ្យលាចាកពីលោកនេះទៅឯព្រះអង្គ ។
ដោយគាត់បានរួមស្លាប់ជាមួយព្រះបុត្រាដែលសោយទិវង្គត
សូមប្រោសឲ្យគាត់បានរួមជាមួយព្រះបុត្រា
ដែលមានព្រះជន្មរស់ឡើងវិញ
ក្នុងពេលដែលព្រះគ្រីស្តជាស់អ្នកស្លាប់ឲ្យក្រោកពីដី
និងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងខ្ញុំនេះ ឲ្យបានដូច
ព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ ។

សូមព្រះអង្គមេត្តាដល់អស់បងប្អូនយើងខ្ញុំដែលទទួលមរណភាព
និងដល់បុគ្គលទាំងអស់ដែលគាប់ព្រះហឫទ័យព្រះអង្គ
ហើយបានលាចាកលោកនេះ សូមទទួលបុគ្គលទាំងនោះ
ចូលក្នុងព្រះរាជ្យរបស់ព្រះអង្គ ។
នៅទីនោះ យើងខ្ញុំសង្ឃឹមថា នឹងបានពោរពេញ
ទៅដោយសិរីរុងរឿងរបស់ព្រះអង្គជានិច្ចនិរន្តរ៍ ។
នៅពេលព្រះអង្គជូតទឹកភ្នែកយើងខ្ញុំ
ពេលនោះ យើងខ្ញុំនឹងមើលឃើញព្រះភក្ត្រព្រះជាម្ចាស់យ៉ាង
ជាក់ស្តែង យើងខ្ញុំនឹងបានដូចព្រះអង្គជាអង្វែងតរៀងទៅ
ហើយយើងខ្ញុំលើកតម្កើងព្រះអង្គឥតឈប់ឈរ
រួមជាមួយព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
គឺដោយសារព្រះគ្រីស្តនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក ។ †

# ធម៌អរព្រះគុណដ៏វិសុទ្ធទី ៤

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**
ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត !
ពិតជាការគួរណាស់ ដែលយើងខ្ញុំអរព្រះគុណព្រះអង្គ
ហើយពិតជាការប្រពៃណាស់ ដែលយើងខ្ញុំលើកតម្កើង
សិរីរុងរឿងព្រះអង្គ ព្រោះព្រះអង្គជាព្រះជាម្ចាស់តែមួយគត់
ដែលមានព្រះជន្មរស់ និងជាព្រះដ៏ពិតប្រាកដ ។
ព្រះអង្គគង់នៅមុនកាលសម័យទាំងអស់ និងអស់កល្បជានិច្ច
ហើយគង់នៅក្នុងពន្លឺដែលគ្មាននរណាអាចចូលជិតបាន
មិនតែប៉ុណ្ណោះ ព្រះអង្គមានព្រះហឫទ័យសប្បុរសដ៏លើសលប់
និងជាប្រភពនៃជីវិតគ្រប់យ៉ាង ។

ព្រះអង្គបានបង្កើតពិភពលោក ដើម្បីឲ្យស្នាព្រះហស្ដរបស់ព្រះអង្គ
បានពោរពេញដោយព្រះពរ និងមានអំណរសប្បាយ
ដោយសារពន្លឺដ៏ត្រចះត្រចង់របស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាទេវទូតដ៏ច្រើនឥតគណនា
ដែលគោរពបម្រើព្រះអង្គទាំងយប់ទាំងថ្ងៃ
ឈរនៅខាងមុខព្រះអង្គ សម្លឹងមើលរស្មីចែងចាំងនៃព្រះភក្ត្រ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គជានិរន្តរ៍ ។
ក្នុងនាមសត្វលោកទាំងអស់ យើងខ្ញុំត្រេកអរ
សូមលើកតម្កើងព្រះនាមព្រះអង្គ រួមជាមួយទេវទូតទាំងឡាយ
ដោយច្រៀងថា ៖

គ្រ. *ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល*
*មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមលើកតម្កើងព្រះអង្គ*
*ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។*

**ប.** បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមប្រកាសថា ព្រះអង្គជាព្រះដ៏ប្រសើរឧត្ដម
ព្រះអង្គបានបង្កើតអ្វីៗសព្វសារពើទាំងអស់
ដោយព្រះប្រាជ្ញាញាណ និងធម៌មេត្តាករុណា ។
ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ
ហើយទ្រង់ប្រទានពិភពលោកឲ្យមនុស្សថែរក្សាស្នាព្រះហស្ត
របស់ព្រះជាម្ចាស់ ដោយគោរពបម្រើព្រះអង្គជាព្រះអាទិករ ។
នៅពេលមនុស្សលោកបានផ្ដាច់ចំណងមេត្រីជាមួយព្រះអង្គ

ដោយមិនស្តាប់បង្គាប់ព្រះអង្គ ទ្រង់មិនបណ្តោយឲ្យមនុស្សលោក
ស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ឡើយ ។
ព្រះអង្គតែងតែមានព្រះហឫទ័យមេត្តាករុណាជួយមនុស្សទាំងអស់
ដើម្បីឲ្យអស់អ្នកដែលស្វែងរក បានជួបព្រះអង្គ ។
ជាច្រើនលើក ច្រើនគ្រា ព្រះអង្គប្រទានចំណងមេត្រីដល់មនុស្សលោក
ហើយតាមរយៈព្យាការីទាំងឡាយ
ព្រះអង្គអប់រំគេឲ្យមានសេចក្តីសង្ឃឹមថា ព្រះអង្គនឹងសង្គ្រោះគេ ។

បពិត្រព្រះបិតាជីវិសុទ្ធ !
ព្រះអង្គស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង
ទ្រង់ចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមកសង្គ្រោះយើងខ្ញុំ
តាមពេលកំណត់ដែលព្រះអង្គបានសម្រេចមកហើយ ។

ព្រះបុត្រាទទួលរូបកាយជាមនុស្សមកពីព្រះវិញ្ញាណជីវិសុទ្ធ
ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គរស់នៅជាមនុស្សដូចយើងខ្ញុំក្នុងគ្រប់ប្រការ
តែមិនប្រព្រឹត្តអំពើបាបសោះឡើយ ។
ព្រះបុត្រានាំដំណឹងល្អប្រាប់ជនក្រីក្រថា គេនឹងទទួលការសង្គ្រោះ
ប្រាប់ជនជាប់ឃុំឃាំងថា គេនឹងមានសេរីភាព
ហើយប្រាប់ជនកើតទុក្ខថា គេនឹងបានអំណរសប្បាយវិញ ។

បពិត្រព្រះបិតា !
ដើម្បីបំពេញបំណងព្រះអង្គ ព្រះបុត្រាបានប្រគល់ខ្លួនឲ្យគេធ្វើគុត
ហើយដោយក្រោកឡើងពីចំណោមមនុស្សស្លាប់
ព្រះអង្គបំផ្លាញសេចក្តីស្លាប់ និងធ្វើឲ្យមានជីវិតឡើងវិញ ។

បពិត្រព្រះបិតាជាម្ចាស់ !
ព្រះបុត្រាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះអង្គ
ដើម្បីប្រោសឲ្យយើងខ្ញុំលែងរស់សម្រាប់ខ្លួនឯងទៀតហើយ
គឺរស់សម្រាប់ព្រះបុត្រាដែលសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញសម្រាប់យើងខ្ញុំ ។

ព្រះបុត្រាបានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ
ជាព្រះអំណោយទានដំបូងបង្អស់ដល់អស់អ្នកជឿ
គឺព្រះវិញ្ញាណដែលបំពេញកិច្ចការរបស់ព្រះបុត្រាក្នុងលោកនេះ
ឲ្យបានវិសុទ្ធជាស្ថាពរ ។

ឱ ព្រះអម្ចាស់អើយ ! យើងខ្ញុំសូមអង្វរព្រះអង្គ
សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ មកញ៉ាំងតង្វាយទាំងនេះ ឲ្យបានវិសុទ្ធ
ហើយបានទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត
ជាព្រះអម្ចាស់យើងខ្ញុំ
ក្នុងពិធីលើកតម្កើងគម្រោងការដ៏អស្ចារ្យនេះ
ដែលព្រះគ្រីស្តផ្ទាល់បានតាំងទុកជាចំណងមេត្រី
អស់កល្បជានិច្ចសម្រាប់យើងខ្ញុំ ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
ដល់ពេលកំណត់ ដែលព្រះបុត្រាបានទទួលសិរីរុងរឿងពីព្រះបិតា
ដោយទ្រង់ស្រឡាញ់សាវ័ករបស់ព្រះអង្គដែលរស់នៅក្នុងលោកនេះ
ព្រះអង្គក៏ស្រឡាញ់គេរហូតដល់ទីបំផុត ។
នៅពេលជប់លៀង
ព្រះអង្គយកនំបុ័ងមកកាន់
លើកតម្កើងព្រះបិតា ហើយកាច់ប្រទានឲ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

បន្ទាប់មក ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងស្រាទំពាំងបាយជូរឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ**

**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

ប. ឱ ព្រះអម្ចាស់អើយ !
ហេតុនេះហើយ បានជាយើងខ្ញុំរួមគ្នានៅពេលនេះ
ធ្វើពិធីរំឭកដល់ព្រះបុត្រាសង្គ្រោះយើងខ្ញុំ
គឺយើងខ្ញុំនឹករឭកដល់ព្រះគ្រីស្តសោយទិវង្គត
និងយាងចុះទៅស្ថានក្រោម
យើងខ្ញុំសូមប្រកាសថា ព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ហើយយាងឡើងទៅគង់ខាងស្តាំព្រះបិតា ។
នៅពេលយើងខ្ញុំទន្ទឹងរង់ចាំ ព្រះអង្គយាងមកប្រកបដោយសិរីរុងរឿង
យើងខ្ញុំសូមថ្វាយទៅព្រះបិតានូវព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ទុកជាសក្ការបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ
និងសង្គ្រោះពិភពលោកទាំងមូល ។

បពិត្រព្រះបិតាជាអម្ចាស់ !
សូមព្រះអង្គសព្វព្រះហឫទ័យទតមកសក្ការបូជា
ដែលព្រះអង្គផ្ទាល់បានប្រទានដល់ព្រះសហគមន៍ព្រះអង្គ ។
សូមព្រះអង្គមេត្តាប្រោសឲ្យបងប្អូន
ដែលហៀបនឹងទទួលចំណែកពីនំប៉័ងតែមួយ និងពីពែងតែមួយនេះ
រួបរួមគ្នាទៅជារូបកាយតែមួយដោយព្រះវិញ្ញាណដ៏វិសុទ្ធ

បានទៅជាសក្ការបូជាដ៏ល្អឥតខ្ចោះ ដ៏មានជីវិតក្នុងអង្គព្រះគ្រីស្ត
ដើម្បីលើកតម្កើងសិរីរុងរឿងព្រះអង្គ ។

បពិត្រព្រះបិតាជាអម្ចាស់ !
សូមព្រះអង្គប្រោសប្រណីដល់អស់បងប្អូន
ដែលយើងខ្ញុំនឹករឭកនៅពេលថ្វាយសក្ការបូជានេះ
ជាបឋម សម្តេចប៉ាបយើងខ្ញុំព្រះ( **នាម...** ) ជាអ្នកបម្រើព្រះអង្គ
លោក( **នាម...** ) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងក្រុមលោកអភិបាលទាំងឡាយ
អស់លោកបូជាចារ្យ លោកឧបដ្ឋាក
អស់អ្នកដែលរួមថ្វាយអភិបូជានៅទីនេះ
និងប្រជារាស្ត្រព្រះអង្គទាំងមូល
ដែលស្វែងរកព្រះអង្គដោយចិត្តស្មោះត្រង់ ។

សូមព្រះអង្គនឹករឭកដល់អស់បងប្អូនយើងខ្ញុំ
ដែលទទួលមរណភាពក្នុងសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត
និងដល់អស់មរណបុគ្គល
មានតែព្រះអង្គទេដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។

ឱ ព្រះបិតាដ៏មានព្រះហឫទ័យសន្តោសមេត្តាអើយ !
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំទាំងអស់គ្នា ដែលជាបុត្រធីតាព្រះអង្គ
បានទទួលជីវិតបរមសុខ ទុកជាមរតក
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គល ជាព្រះមាតាព្រះជាម្ចាស់
ជាមួយសន្តយ៉ូសែបជាស្វាមីព្រះនាង
ជាមួយក្រុមគ្រីស្តទូត

និងអស់សន្តបុគ្គលនៅក្នុងព្រះរាជ្យព្រះអង្គ ។
នៅទីនោះ រួមជាមួយសត្វលោកទាំងឡាយ
ដែលរួចចាកពីការវិនាសអន្តរាយរបស់អំពើបាប និងសេចក្តីស្លាប់
យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
តាមរយៈព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ
គឺដោយព្រះគ្រីស្តនេះហើយ
ដែលព្រះបិតាប្រទានអ្វីៗដ៏ល្អគ្រប់បែបយ៉ាងដល់ពិភពលោក ។

ប. ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

# ធម៌អរព្រះគុណដ៏វិសុទ្ធ
# « ផ្សះផ្សាមនុស្សលោក »

## ទី ១

ប.　សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ.　ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប.　សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ.　យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**

ប.　សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ.　ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះអម្ចាស់ !
ជាព្រះបិតាដ៏វិសុទ្ធបំផុត ជាព្រះជាម្ចាស់ដែលមានឫទ្ធានុភាព
និងព្រះជន្មគង់នៅ
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមថ្លែងអំណរព្រះគុណព្រះអង្គគ្រប់ពេលវេលា ។

ព្រះអង្គតែងតែជំរុញយើងខ្ញុំ ឲ្យទទួលជីវិតពេញបរិបូណ៌
ហើយដោយសារព្រះហឫទ័យអាណិតអាសូរច្រើនពន់ប្រមាណ
ព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំ ព្រមទាំងអញ្ជើញអ្នកបាប
ឲ្យជឿសង្ឃឹមតែលើព្រះអង្គ ដែលអត់ទោសជានិច្ច ។

ព្រះអង្គមិនដែលបែរព្រះភក្ត្រចេញពីយើងខ្ញុំទេ

ទោះបីយើងខ្ញុំបានផ្ដាច់សម្ពន្ធមេត្រីជាមួយព្រះអង្គច្រើនដង
ក៏ព្រះអង្គនៅតែចងចំណងជាមួយមនុស្សលោក
ជាសម្ពន្ធមេត្រីដ៏រឹងមាំដែលគ្មានអ្វីអាចផ្ដាច់បាន
គឺដោយសារព្រះយេស៊ូជាព្រះបុត្រា និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ឥឡូវនេះ ព្រះអង្គនៅតែផ្ដល់ឲ្យប្រជារាស្ត្រព្រះអង្គ
មានឱកាសទទួលការប្រណីសន្ដោស
និងឲ្យគេជម្រះជម្រាជាមួយព្រះអង្គ ។
នៅពេលគេបែរមករកព្រះអង្គវិញ
ទ្រង់ប្រទានឲ្យគេមានសេចក្ដីសង្ឃឹមក្នុងអង្គព្រះគ្រីស្ដ
និងឲ្យគេចង់បម្រើមនុស្សទាំងអស់
ដោយទុកចិត្តកាន់តែខ្លាំងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមស្ញើចសរសើរ
និងលើកតម្កើងឫទ្ធានុភាពនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ
ទាំងប្រកាសអំណរសប្បាយ
ព្រោះយើងខ្ញុំបានទទួលការសង្គ្រោះ ។
យើងខ្ញុំសូមចូលរួមជាមួយសន្ដបុគ្គលទាំងឡាយ
ដោយច្រៀងឥតឈប់ឈរថា ៖

គ្រ. *ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល*
*មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមលើកតម្កើងព្រះអង្គ*
*ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។*

**ប.** ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធមែន
តាំងពីដើមរៀងមក ព្រះអង្គតែងតែប្រព្រឹត្តការដ៏ល្អប្រសើរ
ដើម្បីឲ្យមនុស្សបានវិសុទ្ធដូចព្រះអង្គជាព្រះដ៏វិសុទ្ធដែរ ។
សូមព្រះអង្គមេត្តាទទួលតង្វាយប្រជារាស្ត្រព្រះអង្គដោយអនុគ្រោះ
សូមចាក់បង្ហូរព្រះវិញ្ញាណប្រកបដោយឫទ្ធានុភាព
មកញ៉ាំងតង្វាយទាំងនេះ
ឲ្យទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
គឺក្នុងអង្គព្រះបុត្រានេះ យើងខ្ញុំក៏ជាបុត្រធីតារបស់ព្រះអង្គដែរ ។

បពិត្រព្រះបិតា !
កាលពីមុនយើងខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គ
ពុំអាចវិលមករកព្រះអង្គវិញបានទេ ។
ពេលនោះ ព្រះអង្គស្រឡាញ់យើងខ្ញុំយ៉ាងខ្លាំងបំផុត
គឺព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ជាមនុស្សសុចរិតតែម្នាក់គត់
បានប្រគល់ខ្លួនរហូតដល់សោយទិវង្គតដោយមិនរួញរា
ឲ្យគេបោះដែកគោលភ្ជាប់លើឈើឆ្កាងដើម្បីសង្គ្រោះយើងខ្ញុំ ។
តែមុននឹងព្រះយេស៊ូត្រដាងព្រះហស្ត
ជាចំណងរវាងស្ថានបរមសុខ និងផែនដី
ដើម្បីធ្វើជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីអស់កល្បជានិច្ច
ទ្រង់សព្វព្រះហឫទ័យ ធ្វើពិធីបុណ្យចម្លងរួមជាមួយក្រុមសាវ័ក ។

ពេលព្រះយេស៊ូជប់លៀង
ព្រះអង្គយកនំបុ័ងមកកាន់
អរព្រះគុណ និងលើកតម្កើងព្រះបិតា
រួចកាច់នំបុ័ងប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

**ប.** នៅពេលចុងក្រោយនៃពិធីជប់លៀងនេះ
ព្រះយេស៊ូជ្រាបថា ទ្រង់នឹងផ្សះផ្សាអ្វីៗទាំងអស់ឲ្យជានានឹងព្រះអង្គ
ដោយសារព្រះលោហិតព្រះអង្គ ដែលត្រូវបង្ហូរនៅលើឈើឆ្កាង
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតាម្តងទៀត
ហើយប្រទានពែងស្រាឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

**ប.** នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

**គ្រ.** **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

**ឬ**

**គ្រ.** **ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

**ឬ**

**គ្រ.** **ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

ប. បពិត្រព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះត្រង់ជានិច្ច !
នៅពេលនេះ យើងខ្ញុំនាំគ្នានឹករឭកដល់ព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រារបស់ព្រះអង្គ ជាសក្ការបូជានៃបុណ្យចម្លង
និងជាសេចក្តីសុខសាន្តជាស្ថាពររបស់យើងខ្ញុំ
យើងខ្ញុំក៏សូមលើកតម្កើងព្រះអង្គដែលសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញពីចំណោមមនុស្សស្លាប់ ។

ពេលយើងខ្ញុំទន្ទឹងរង់ចាំថ្ងៃពោរពេញដោយអំណរ
ដែលព្រះគ្រីស្តយាងមក

យើងខ្ញុំសូមថ្វាយសក្ការបូជាដែលធ្វើឲ្យមនុស្សលោក
និងព្រះជាម្ចាស់មានមេត្រីភាពឡើងវិញ ។

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យសប្បុរសយ៉ាងលើសលប់ !
សូមព្រះអង្គមេត្តាទតមើលអស់អ្នក
ដែលព្រះអង្គបានបង្រួបបង្រួម
តាមរយៈសក្ការបូជារបស់ព្រះបុត្រាព្រះអង្គ ។
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
សូមប្រោសអ្នកទាំងនោះ ដែលទទួលចំណែកពីនំបុ័ងតែមួយ
និងពែងតែមួយ ឲ្យទៅជារូបកាយតែមួយក្នុងអង្គព្រះគ្រីស្ដ
គឺក្នុងព្រះកាយព្រះគ្រីស្ដនេះ
មនុស្សលែងបាក់បែកគ្នាទៀតហើយ ។

បពិត្រព្រះជាអម្ចាស់ !
សូមព្រះអង្គប្រោសយើងខ្ញុំឲ្យមានចិត្តថ្លើមតែមួយ
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ (**នាម**...)
និងលោក(**នាម**...) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ ។
សូមជួយយើងខ្ញុំឲ្យរៀបចំផ្លូវទទួលព្រះរាជ្យព្រះអង្គ
រហូតដល់ពេលយើងខ្ញុំទៅជាសន្ដបុគ្គលនៅចំពោះព្រះភក្ត្រព្រះអង្គ
ក្នុងចំណោមសន្ដបុគ្គលទាំងឡាយនៅឯស្ថានបរមសុខ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ អស់គ្រីស្ដទូត និងជនដ៏វិសុទ្ធទាំងឡាយ
ព្រមទាំងបងប្អូនដែលបានទទួលមរណភាព ជាអស់អ្នកដែលយើងខ្ញុំ

សូមផ្ញើទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ។
ពេលនោះ ព្រះអង្គរំដោះយើងខ្ញុំឲ្យរួចផុតពីរបួសនៃសភាពរលួយ
ហើយបង្កើតយើងខ្ញុំឲ្យមានជីវិតថ្មីពេញលក្ខណៈ ។
យើងខ្ញុំនឹងច្រៀងដោយអំណរ និងអរព្រះគុណព្រះបិតា
ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ។

ប. ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ដ ជាមួយព្រះគ្រីស្ដ និងក្នុងអង្គព្រះគ្រីស្ដ
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

គ្រ. **អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

## ធម៌អរព្រះគុណដ៏វិសុទ្ធ
## «ផ្សះផ្សាមនុស្សលោក»

### ទី ២

**ប.** សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**
ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។**

ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមថ្លែងអំណរព្រះគុណ និងលើកតម្កើងព្រះអង្គ
ដោយសារអ្វីៗទាំងអស់
ដែលព្រះអង្គប្រព្រឹត្តក្នុងពិភពលោកនេះ
តាមរយៈព្រះយេស៊ូគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ ។

ទោះបីមនុស្សបាក់បែកគ្នា ហែកហួរគ្នាក៏ដោយ
យើងខ្ញុំដឹងច្បាស់ថា តាមរយៈការពិសោធទាំងនេះ
ព្រះអង្គប្រែចិត្តគំនិតយើងខ្ញុំឲ្យប្រុងប្រៀបផ្សះផ្សាគ្នាវិញ ។
ប្រាកដមែន ព្រះវិញ្ញាណព្រះអង្គជំរុញចិត្តមនុស្ស

ធ្វើឲ្យខ្មាំងសត្រូវនិយាយរកគ្នា ឲ្យអ្នកប្រឆាំងគ្នាចាប់ដៃគ្នា
ឲ្យប្រជាជនដែលទាស់ទែងគ្នា
សុខចិត្តចាប់ផ្ដើមធ្វើដំណើរជាមួយគ្នាវិញ ។

បពិត្រព្រះអម្ចាស់ !
គឺឫទ្ធានុភាពរបស់ព្រះអង្គ
ដែលណែនាំឲ្យមនុស្សសុខចិត្តស្រឡាញ់គ្នា ជាជាងស្អប់គុំកួនគ្នា
សុខចិត្តអត់ទោសឲ្យគ្នា ជាជាងសងសឹកគ្នា
សុខចិត្តរាប់អានគ្នា ជាជាងបាក់បែកគ្នា ។
ហេតុនេះហើយ បានជាយើងខ្ញុំសូមអរព្រះគុណ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ឥតឈប់ឈរ
រួមជាមួយមហាជនដ៏ច្រើនកុះករនៅស្ថានបរមសុខ
ដោយប្រកាសថា ៖

គ្រ. *ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល*
*មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមលើកតម្កើងព្រះអង្គ*
*ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។*

ប. បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
យើងខ្ញុំសូមលើកតម្កើងព្រះអង្គ
តាមរយៈព្រះយេស៊ូគ្រីស្ដជាព្រះបុត្រា

ដែលយាងមកក្នុងព្រះនាមព្រះអង្គ ។
ព្រះយេស៊ូពិតជាព្រះបន្ទូលដែលសង្គ្រោះមនុស្សលោក
ព្រះយេស៊ូពិតជាព្រះហស្តរបស់ព្រះបិតា ឈោងទៅរកអ្នកបាប ។
ព្រះយេស៊ូពិតជាមាគ៌ា ដែលប្រទានសេចក្តីសុខសាន្ត
របស់ព្រះបិតាឲ្យយើងខ្ញុំ ។

បពិត្រព្រះអម្ចាស់ !
នៅពេលយើងខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គ ព្រោះតែអំពើបាប
ទ្រង់បាននាំយើងខ្ញុំវិលមកវិញ ឲ្យផ្សះផ្សាជាមួយព្រះអង្គ
គឺដោយសារព្រះបុត្រា ដែលព្រះអង្គបានបញ្ជូនឲ្យគេធ្វើគុត
យើងខ្ញុំបានបែរមករកព្រះអង្គ
ហើយអាចស្រឡាញ់គ្នាទៅវិញទៅមក ។

ឥឡូវនេះ យើងខ្ញុំនាំគ្នាលើកតម្កើងព្រះគ្រីស្ត
ដែលបានផ្សះផ្សាយើងខ្ញុំជាមួយព្រះអង្គ
យើងខ្ញុំក៏សូមអង្វរព្រះអង្គ
សូមទ្រង់ព្រះមេត្តាប្រោសព្រះវិញ្ញាណរបស់ព្រះអង្គ
យាងមកញ៉ាំងតង្វាយទាំងនេះ ឲ្យបានវិសុទ្ធ
និងឲ្យទៅជាព្រះកាយ ✠ និងព្រះលោហិតព្រះបុត្រាព្រះអង្គ
ដែលបានបង្គាប់ឲ្យយើងខ្ញុំ ធ្វើពិធីលើកតម្កើង
គម្រោងការដ៏អស្ចារ្យនេះ ។
មុនបូជាព្រះជន្មដើម្បីរំដោះយើងខ្ញុំ
ព្រះយេស៊ូជប់លៀង
ព្រះអង្គយកនំបុ័ងមកកាន់

អរព្រះគុណព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

> សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
> ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

ប. នៅពេលយប់នោះ ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គយកពែងស្រាមកកាន់
អរព្រះគុណ និងលើកតម្កើងព្រះបិតា
ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

> សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
> នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
> និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
> ដើម្បីលើកលែងទោសអ្នករាល់គ្នា
> និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
> សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

**គ្រ. ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

**គ្រ. ឱ ព្រះអម្ចាស់អើយ !**
**វេៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

**គ្រ. ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

នៅពេលយើងខ្ញុំនឹករឭកដល់ព្រះបុត្រាព្រះអង្គ
សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ធ្វើជាសញ្ញាបញ្ជាក់ពីសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះយើងខ្ញុំ
យើងខ្ញុំសូមថ្វាយទៅព្រះអង្គនូវអ្វី
ដែលព្រះអង្គបានប្រទានឲ្យយើងខ្ញុំ
គឺសក្ការបូជារបស់ព្រះគ្រីស្ត
ដែលផ្សះផ្សាយើងខ្ញុំនឹងព្រះអង្គបានល្អឥតខ្ចោះ ។
បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមព្រះអង្គមេត្តាទទួលយើងខ្ញុំ
រួមជាមួយព្រះបុត្រាព្រះអង្គ
ហើយក្នុងពិធីជប់លៀងដែលផ្តល់ការសង្គ្រោះនេះ
សូមព្រះអង្គមេត្តាប្រទានព្រះវិញ្ញាណរបស់ព្រះបុត្រាឲ្យយើងខ្ញុំ
សូមព្រះវិញ្ញាណបំបាត់ហេតុទាំងឡាយ
ដែលបណ្តាលឲ្យយើងខ្ញុំបាក់បែកគ្នា ។

សូមព្រះវិញ្ញាណប្រោសឲ្យព្រះសហគមន៍ ទៅជាសញ្ញានៃការរួបរួមគ្នា
ហើយជាឧបករណ៍ដែលនាំសេចក្ដីសុខសាន្ត
របស់ព្រះអង្គដល់មនុស្សលោក ។
សូមឲ្យយើងខ្ញុំរួបរួមជាធ្លុងតែមួយ
ជាមួយសម្ដេចប៉ាបយើងខ្ញុំ (**នាម...**)
និងលោក(**នាម...**) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
ជាមួយលោកអភិបាលទាំងអស់
ព្រមទាំងជាមួយប្រជារាស្ត្រទាំងមូលរបស់ព្រះអង្គផង ។

នៅពេលនេះ ព្រះអង្គបានប្រមូលផ្ដុំយើងខ្ញុំ
ឲ្យចូលរួមតុសក្ការៈរបស់ព្រះបុត្រាព្រះអង្គ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានចូលរួម
ជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ពោរពេញដោយសិរីរុងរឿង ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយក្រុមគ្រីស្ដទូត និងសន្ដបុគ្គលទាំងអស់
ព្រមទាំងបងប្អូនយើងខ្ញុំ និងមនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសា
ដែលបានលាចាកលោកនេះ ក្នុងមេត្រីភាពរបស់ព្រះអង្គ ។
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំ បានចូលរួមជាមួយអស់អ្នកទាំងនោះ
ក្នុងពិធីជប់លៀងរួមគ្នាឥតឈប់ឈរ
នៅឯផ្ទៃមេឃថ្មី និងផែនដីថ្មី
ដែលពោរពេញ ដោយសេចក្ដីសុខសាន្ដដ៏ភ្លឺស្វាងរបស់ព្រះអង្គ
ក្នុងអង្គព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់យើងខ្ញុំ ។

**ប.** ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ.** **អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

# ធម៌អរព្រះគុណដ៏វិសុទ្ធប្រើក្នុងឱកាសផ្សេងៗ

## ទី១

## ព្រះសហគមន៍កំពុងធ្វើដំណើរទៅរកឯកភាព

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប. សូមលើកចិត្តថ្វាយព្រះអង្គ ។

**គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**

ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

**គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏សប្បុរសយ៉ាងក្រៃលែង !
ពិតជាការគួរណាស់ ហើយប្រពៃផង
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គ
និងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដ្បិតតាមព្រះបន្ទូលដំណឹងល្អរបស់ព្រះបុត្រាព្រះអង្គ
ទ្រង់បានប្រមូលផ្តុំមនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសា
គ្រប់អរិយធម៌ឲ្យទៅជាព្រះសហគមន៍តែមួយ ។

ព្រះអង្គបានប្រទានឲ្យព្រះសហគមន៍មានជីវិតរស់រវើក
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយតាមរយៈព្រះសហគមន៍នេះ
ព្រះអង្គតែងតែប្រមែប្រមូលមនុស្សទាំងអស់

ឲ្យទៅជាគ្រួសារតែមួយ ។
ព្រះសហគមន៍តែងតែបង្ហាញសម្ពន្ធមេត្រី
នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។

ដូច្នេះជារៀងរហូត ព្រះសហគមន៍ផ្ដល់សេចក្ដីសង្ឃឹមនៃព្រះរាជ្យ
និងធ្វើជាសញ្ញាដ៏ភ្លឺស្វាងនៃព្រះហឫទ័យស្មោះត្រង់
ដែលព្រះអង្គបានសន្យាថា នឹងស្ថិតស្ថេរអស់កល្បជានិច្ច
តាមរយៈព្រះយេស៊ូគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំនៅលើផែនដី
រួមជាមួយព្រះសហគមន៍ទាំងអស់
និងឫទ្ធានុភាពទាំងឡាយឯស្ថានបរមសុខ
សូមលើកតម្កើងព្រះអង្គឥតឈប់ឈរ ដោយសូរសព្ទតែមួយថា ៖

គ្រ. *ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល*
*មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។*

ប. បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
ហើយគួរកោតសរសើរ
ព្រះអង្គស្រឡាញ់មនុស្សលោក
រួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង

ព្រះអង្គគង់នៅកណ្ដាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំប៉័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ
ទៅជាព្រះកាយ ✠ និងព្រះលោហិត
ព្រះអម្ចាស់យេស៊ូគ្រីស្ដសម្រាប់យើងខ្ញុំ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់
ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក
និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ
ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ
នូវនំបុ័ងដែលផ្តល់ជីវិត និងពែងនៃព្រះពរ ។
សូមទ្រង់ទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសរីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គ
ដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះអម្ចាស់ ! សូមប្រោសឲ្យព្រះសហគមន៍ព្រះអង្គ (**នៅ...**)
មានកម្លាំងថ្មី ដោយសារពន្លឺនៃព្រះបន្ទូលដំណឹងល្អ ។
សូមពង្រឹងចំណងមេត្រីរវាងគ្រីស្តបរិស័ទ
និងអ្នកដែលនាំប្រជារាស្ត្រព្រះអង្គ
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ (**នាម...**)

ជាមួយលោក (**នាម...**) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងជាមួយក្រុមអភិបាលទាំងមូល ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះអង្គ
ទៅជាពន្លឺក្នុងពិភពលោកដែលបាក់បែកគ្នា
ជាសញ្ញាសម្គាល់នៃឯកភាព និងការស្រុះស្រួលគ្នា ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (**ឈ្មោះ...** និង**ឈ្មោះ...**)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ដ
ព្រមទាំងអស់មរណបុគ្គល
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។
សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតារបស់ព្រះជាម្ចាស់ ជាមួយអស់គ្រីស្ដទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងអស់
តាមរយៈព្រះយេស៊ូគ្រីស្ដជាព្រះបុត្រាព្រះអង្គ ។

ប.	ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ.	អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

# ទី២
# ព្រះជាម្ចាស់ណែនាំព្រះសហគមន៍តាមមាគ៌ានៃការសង្គ្រោះ

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**
ប. សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ. យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**
ប. សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ. ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធ !
ព្រះអង្គជាព្រះបង្កើតពិភពលោក និងជាប្រភពនៃជីវិតទាំងអស់
ពិតជាការគួរណាស់ហើយប្រពៃជង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ព្រះអង្គមិនដែលបោះបង់អ្វីៗ
ដែលកើតពីព្រះប្រាជ្ញាញាណរបស់ព្រះអង្គឡើយ
ដ្បិតព្រះអង្គជាព្រះឧបការគុណ
ដែលគង់នៅកណ្ដាលចំណោមយើងខ្ញុំ ។

កាលពីជំនាន់ដើម ព្រះអង្គដឹកដៃជនជាតិអ៊ីស្រាអែល
ជាប្រជារាស្ត្ររបស់ព្រះអង្គឲ្យឆ្លងកាត់វាលរហោស្ថាន

សព្វថ្ងៃ ព្រះអង្គនៅតែរួមដំណើរជាមួយព្រះសហគមន៍ក្នុងលោកនេះ
ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។
ព្រះបិតាណែនាំព្រះសហគមន៍ តាមរយៈព្រះគ្រីស្តជាព្រះអម្ចាស់យើងខ្ញុំ
ឲ្យឆ្លងកាត់សម័យកាលទាំងឡាយ
ទៅកាន់អំណរសប្បាយអស់កល្បជានិច្ចក្នុងព្រះរាជ្យព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយប្រកាសឥតឈប់ឈរថា ៖

***ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !***
***ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល***
***មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត***
***សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។***

ឱ ព្រះជាម្ចាស់អើយ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
ព្រះអង្គស្រឡាញ់មនុស្សលោក
ទ្រង់រួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង
ព្រះអង្គគង់នៅកណ្តាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំប៉័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គបាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ
ទៅជាព្រះកាយ ✠ និងព្រះលោហិត
ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់
ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត**
**និងមានព្រះជន្មរស់ឡើងវិញ**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះអម្ចាស់អើយ !**
**រៀងរាល់ពេល យើងខ្ញុំពិសានំបុ័ង និងពិសាពីពែងនេះ**
**យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត**
**ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។**

ឬ

គ្រ. **ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !**
**ព្រះអង្គសោយទិវង្គតលើឈើឆ្កាង**
**និងមានព្រះជន្មរស់ឡើងវិញ**
**ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។**

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក
និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ
ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ
នូវនំប៉័ងដែលផ្តល់ជីវិត និងពែងនៃព្រះពរ ។
សូមព្រះអង្គទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គ ដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសវីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គ
ដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះអម្ចាស់ !
ព្រះអង្គបានត្រាស់ហៅយើងខ្ញុំឲ្យរួមតុជាមួយព្រះអង្គ
សូមព្រះអង្គពង្រឹងឯកភាពឲ្យយើងខ្ញុំរួមជាធ្លុងតែមួយ
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ (**នាម...**)

ជាមួយលោក(**នាម...**)ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងជាមួយក្រុមអភិបាលទាំងឡាយ
ជាមួយលោកបូជាចារ្យ និងលោកឧបដ្ឋាក
ព្រមទាំងប្រជារាស្ត្រទាំងអស់របស់ព្រះអង្គ ។
នៅពេលយើងខ្ញុំធ្វើដំណើរតាមមាគ៌ារបស់ព្រះអង្គ
ទាំងមានជំនឿ និងសេចក្ដីសង្ឃឹម
យើងខ្ញុំអាចនាំអំណរសប្បាយ
និងការទុកចិត្តគ្នាចូលក្នុងពិភពលោកបាន ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (**ឈ្មោះ**...និង**ឈ្មោះ**...)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត
ព្រមទាំងអស់មរណបុគ្គល
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។

សូមព្រះអង្គទទួលបុគ្គលទាំងនោះ
ឲ្យគេមានអំណរសប្បាយក្នុងពន្លឺ នៃព្រះភក្ត្រព្រះអង្គ
ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំបានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។

យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត

និងមរណសាក្សី
(ជាមួយសន្ត... ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

**ប.** ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ.** **អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

# ទី ៣
# ព្រះយេស៊ូជាមាគ៌ាទៅកាន់ព្រះបិតា

ប.  សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។
**គ្រ.  ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**
ប.  សូមលើកចិត្តថ្វាយព្រះអង្គ ។
**គ្រ.  យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**
ប.  សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។
**គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះបិតាដ៏វិសុទ្ធ ជាព្រះអម្ចាស់នៃផ្ទៃមេឃ និងផែនដី !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា
និងគ្រប់ទិសទី តាមរយៈព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ ។
ព្រះអង្គបានបង្កើតពិភពលោកដោយព្រះបន្ទូលព្រះអង្គ
ហើយព្រះអង្គគ្រប់គ្រងអ្វីៗទាំងអស់ដោយសេចក្តីសុចរិត ។
ព្រះអង្គប្រោសប្រទានឲ្យព្រះបន្ទូលនេះប្រសូតជាមនុស្ស
ដើម្បីជាស្ពាននៃសម្ពន្ធមេត្រីថ្មីសម្រាប់យើងខ្ញុំ ។
ព្រះបុត្រាបានថ្លែងព្រះបន្ទូលក្នុងនាមព្រះបិតា
ហើយត្រាស់ហៅយើងខ្ញុំឲ្យដើរតាមព្រះអង្គ ។

ព្រះបុត្រាជាមាគ៌ាដែលនាំយើងខ្ញុំទៅកាន់ព្រះបិតា

ព្រះអង្គជាសេចក្ដីពិតដែលប្រទានសេរីភាព
ហើយជាជីវិតដែលផ្ដល់អំណរសប្បាយឲ្យយើងខ្ញុំ ។
តាមរយៈព្រះបុត្រា ព្រះបិតាបានបង្រួបបង្រួមមនុស្សលោក
ឲ្យទៅជាមហាគ្រួសារតែមួយ គឺមនុស្សដែលព្រះបិតាបានបង្កើត
ដើម្បីលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ
ព្រះអង្គរំដោះគេដោយព្រះលោហិត
ដែលព្រះបុត្រាបានបង្ហូរនៅលើឈើឆ្កាង
ហើយដៅសញ្ញាសម្គាល់លើគេដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ចាប់ពីពេលនេះរហូតតរៀងទៅ
ដោយប្រកាសទាំងអំណរសប្បាយថា ៖

គ្រ. ***ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !***
***ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល***
***មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត***
***សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។***
***ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។***

ប. បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
យើងខ្ញុំសូមកោតសរសើរ ព្រះអង្គស្រឡាញ់មនុស្សលោកខ្លាំងណាស់
ដោយរួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង

ទ្រង់គង់នៅកណ្ដាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នាក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។
ព្រះអង្គបកស្រាយព្រះគម្ពីរ និងកាច់នំបុ័ងប្រទានឲ្យយើងខ្ញុំ
ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំបុ័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ
ទៅជាព្រះកាយ ✠ និងព្រះលោហិត
ព្រះអម្ចាស់យេស៊ូគ្រីស្ដសម្រាប់យើងខ្ញុំ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

ព្រះអង្គយកនំបុ័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង
ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ
នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

គ្រ. ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

គ្រ. ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង
និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្ដជាព្រះបុត្រាព្រះអង្គ
និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក
និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្ដាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្ដយាងមកវិញ
ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គ
នូវនំប៉័ងដែលផ្ដល់ជីវិត និងពែងនៃព្រះពរ ។

សូមព្រះអង្គទតមើលតង្វាយរបស់ព្រះសហគមន៍ដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ដ
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសវីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ
ដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
នៅពេលយើងខ្ញុំចូលរួមក្នុងគម្រោងការដ៏អាថ៌កំបាំងនេះ
សូមទ្រង់ប្រោសប្រទានជីវិតឲ្យយើងខ្ញុំ

ដោយព្រះវិញ្ញាណរបស់ព្រះអង្គ
សូមឲ្យយើងខ្ញុំមានលក្ខណៈដូចព្រះបុត្រាព្រះអង្គ
សូមទ្រង់ពង្រឹងឯកភាពឲ្យយើងខ្ញុំរួមជាធ្លុងតែមួយ
រួមជាមួយសម្ដេចប៉ាបយើងខ្ញុំ (**នាម**...)
ជាមួយលោក(**នាម**...) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងជាមួយក្រុមអភិបាលទាំងឡាយ ជាមួយលោកបូជាចារ្យ
និងលោកឧបដ្ឋាក ព្រមទាំងប្រជារាស្ដ្រទាំងអស់របស់ព្រះអង្គ ។
សូមព្រះបិតាប្រទានពន្លឺនៃជំនឿ បំភ្លឺដល់គ្រីស្ដបរិស័ទទាំងឡាយ
ឲ្យថ្វាយខ្លួនដើម្បីបម្រើព្រះបន្ទូលដំណឹងល្អជានិច្ច
ដោយយល់ពីទីសម្គាល់នៃសម័យកាល ។

សូមឲ្យយើងខ្ញុំយកចិត្តទុកដាក់
ចំពោះសេចក្ដីត្រូវការរបស់មនុស្សគ្រប់ៗរូប
ដោយចែករំលែកសេចក្ដីទុក្ខព្រួយ និងការឈឺចាប់
អំណរសប្បាយ និងសេចក្ដីសង្ឃឹម
សូមឲ្យយើងខ្ញុំនាំដំណឹងល្អនៃការសង្គ្រោះដល់បងប្អូនទាំងនោះ
ហើយរួមគ្នាទៅមុខតាមមាគ៌ានៃព្រះរាជ្យរបស់ព្រះអង្គ ។

សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (**ឈ្មោះ**...និង**ឈ្មោះ**...)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ដ
ព្រមទាំងមរណបុគ្គលទាំងឡាយ
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។
សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។

ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ
សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។
យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតារបស់ព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

ប. ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

## ទី៤
## ព្រះយេស៊ូយាងទៅគ្រប់ទីកន្លែងទាំងប្រព្រឹត្តអំពើល្អ

ប.　សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

**គ្រ.　ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប.　សូមលើកចិត្តថ្វាយព្រះអង្គ ។

**គ្រ.　យើងលើកចិត្តថ្វាយព្រះអង្គហើយ ។**

ប.　សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ ។

**គ្រ.　ពិតជាការគួរណាស់ ហើយប្រពៃផង ។**

បពិត្រព្រះបិតាជាព្រះជាម្ចាស់ដ៏មានព្រះហឫទ័យមេត្តាករុណា
និងស្មោះត្រង់ !
ពិតជាការគួរណាស់ហើយប្រពៃផង
ពិតជាត្រឹមត្រូវ និងជាការសង្គ្រោះមែន
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី ។
ព្រះអង្គបានប្រទានព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ
មកជាព្រះអម្ចាស់ និងជាព្រះប្រោសលោះយើងខ្ញុំ ។
ព្រះអង្គតែងតែបង្ហាញធម៌មេត្តាករុណាដល់អ្នកតូចតាច
និងអ្នកក្រីក្រ អ្នកជំងឺ និងអ្នកបាប
ហើយព្រះអង្គជិតស្និទ្ធជាមួយអ្នកដែលត្រូវគេជិះជាន់
និងអ្នកដែលមានទុក្ខព្រួយ ។

ព្រះបុត្រាបានប្រកាសដល់ពិភពលោក

តាមព្រះបន្ទូល និងកិច្ចការរបស់ព្រះអង្គថា
ព្រះជាម្ចាស់ជាព្រះបិតារបស់យើងខ្ញុំ
ហើយព្រះបិតាសព្វព្រះហឫទ័យថែទាំបុត្រធីតាទាំងអស់របស់ព្រះអង្គ ។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងសន្តបុគ្គលទាំងឡាយ សូមលើកតម្កើង
និងអរព្រះគុណព្រះនាមព្រះអង្គ
ទាំងច្រៀងបទកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គ
ដោយឥតឈប់ឈរថា ៖

*ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល*
*មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមលើកតម្កើងព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់ ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។*

**ប.** ឱ ព្រះជាម្ចាស់ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ
ព្រះអង្គស្រឡាញ់មនុស្សលោកគ្រប់ជាតិសាសន៍
ហើយរួមដំណើរជាមួយយើងខ្ញុំជារៀងរាល់ថ្ងៃ ។
ព្រះបុត្រាប្រកបដោយព្រះពរគ្រប់បែបយ៉ាង
ព្រះអង្គគង់នៅកណ្តាលចំណោមយើងខ្ញុំ
នៅពេលយើងខ្ញុំជួបជុំគ្នា ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
ទ្រង់បកស្រាយព្រះគម្ពីរ និងកាច់នំប៉័ងប្រទានឲ្យយើងខ្ញុំ

ដូចព្រះអង្គបានប្រព្រឹត្តចំពោះក្រុមសាវ័កកាលពីដើម ។

ឱ ព្រះបិតាប្រកបដោយធម៌មេត្តាករុណា !
សូមព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ
មកញ៉ាំងនំប៉័ង និងស្រាតង្វាយនេះឲ្យបានវិសុទ្ធ

ទៅជាព្រះកាយ ✠ និងព្រះលោហិត
ព្រះអម្ចាស់យេស៊ូគ្រីស្តសម្រាប់យើងខ្ញុំ ។

នៅយប់ មុនព្រះយេស៊ូសោយទុក្ខលំបាក
ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយបង្អស់

ព្រះអង្គយកនំប៉័ងមកកាន់
លើកតម្កើងព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ
ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ។

នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងស្រាឡើង
អរព្រះគុណព្រះបិតា ហើយប្រទានឲ្យក្រុមសាវ័ក
ទាំងមានព្រះបន្ទូលថា ៖

សូមអ្នករាល់គ្នាយកពែងនេះ
ហើយពិសាចុះនេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ពន្ធមេត្រីថ្មី
និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសអ្នករាល់គ្នា
និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប ។
សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ ។

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

គ្រ. ឱ ព្រះអម្ចាស់អើយ !
យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញ
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

គ្រ. ឱ ព្រះអម្ចាស់អើយ !
រៀងរាល់ពេល យើងខ្ញុំពិសានំប៉័ង និងពិសាពីពែងនេះ
យើងខ្ញុំបញ្ជាក់ថា ព្រះអង្គសោយទិវង្គត
ហើយយើងខ្ញុំសូមប្រកាសរហូតដល់ពេលព្រះអង្គយាងមក ។

ឬ

គ្រ. ឱ ព្រះសង្គ្រោះនៃមនុស្សលោកអើយ !
ព្រះអង្គសោយទិវង្គតលើឈើឆ្កាង
និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីរំដោះយើងខ្ញុំ សូមសង្គ្រោះយើងខ្ញុំ ។

បពិត្រព្រះបិតាដ៏វិសុទ្ធ !
យើងខ្ញុំសូមនឹករឭកដល់ព្រះគ្រីស្តជាព្រះបុត្រាព្រះអង្គ
និងជាព្រះសង្គ្រោះយើងខ្ញុំ ។
ក្រោយពេលព្រះបុត្រាឆ្លងកាត់ទុក្ខលំបាក
និងសោយទិវង្គតនៅលើឈើឆ្កាង
ព្រះបិតាបានប្រោសព្រះបុត្រាឲ្យមានព្រះជន្មរស់ឡើងវិញ
ប្រកបដោយសិរីរុងរឿង និងគង់ខាងស្តាំព្រះអង្គ ។
យើងខ្ញុំសូមប្រកាសពីកិច្ចការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ
រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ
ហើយយើងខ្ញុំក៏សូមថ្វាយព្រះអង្គនូវនំប៉័ងដែលផ្តល់ជីវិត
និងពែងនៃព្រះពរ ។

សូមទ្រង់ទតមើលតង្វាយរបស់ព្រះសហគមន៍ព្រះអង្គដោយអនុគ្រោះ
យើងខ្ញុំសូមបង្ហាញពីសក្ការបូជានៃបុណ្យចម្លងរបស់ព្រះគ្រីស្ត
ដែលយើងខ្ញុំបានទទួលបន្តពីជំនាន់មុនៗ ។
ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់
សូមរាប់បញ្ចូលយើងខ្ញុំទៅក្នុងចំណោមសរីរាង្គរបស់ព្រះបុត្រាព្រះអង្គ
ចាប់ពីឥឡូវនេះ រហូតដល់ថ្ងៃយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ច
គឺនៅក្នុងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត
ដែលយើងខ្ញុំរួបរួមគ្នាជាធ្លុងតែមួយ ។

**ប.** ឱ ព្រះអម្ចាស់អើយ !
សូមឲ្យព្រះសហគមន៍របស់ព្រះអង្គមានជំនឿ
និងសេចក្តីស្រឡាញ់ឥតខ្ចោះ
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ (**នាម...**)
ជាមួយលោក (**នាម...**) ជាអភិបាលព្រះសហគមន៍យើងខ្ញុំ

និងជាមួយលោកអភិបាលទាំងឡាយ
ជាមួយលោកបូជាចារ្យ និងលោកឧបដ្ឋាក
ព្រមទាំងប្រជារាស្ត្រទាំងអស់
ដែលព្រះអង្គបានលោះធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ ។

សូមទ្រង់បើកភ្នែកយើងខ្ញុំ
ឲ្យស្គាល់ពីសេចក្ដីត្រូវការរបស់បងប្អូនយើងខ្ញុំ
សូមបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យពោលពាក្យ និងប្រព្រឹត្តកិច្ចការ
ដើម្បីលើកទឹកចិត្តអស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់ ។
សូមប្រោសឲ្យយើងខ្ញុំបម្រើបងប្អូនទាំងនោះ ដោយចិត្តស្មោះត្រង់
តាមគំរូ និងសេចក្ដីប្រៀនប្រដៅរបស់ព្រះគ្រីស្ត ។

សូមឲ្យព្រះសហគមន៍របស់ព្រះអង្គផ្តល់សក្ខីភាពដ៏រស់រវើក
អំពីសេចក្ដីពិត និងសេរីភាព
អំពីសន្តិភាព និងយុត្តិធម៌
ដើម្បីឲ្យមនុស្សគ្រប់ៗរូបភ្ញាក់រឭកក្នុងសេចក្ដីសង្ឃឹមថ្មី ។
សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ (**ឈ្មោះ**...និង**ឈ្មោះ**...)
ដែលសម្រាន្តលក់ក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត
ព្រមទាំងមរណបុគ្គលទាំងឡាយ
មានតែព្រះអង្គទេ ដែលស្គាល់ជំនឿរបស់អ្នកទាំងនោះ ។

សូមព្រះអង្គទទួលបុគ្គលទាំងនោះ ឲ្យគេមានអំណរសប្បាយ
ក្នុងពន្លឺនៃព្រះភក្ត្រព្រះអង្គ ហើយនៅពេលគេរស់ឡើងវិញ
សូមប្រទានឲ្យគេមានជីវិតពេញបរិបូណ៌ ។
ពេលយើងខ្ញុំបញ្ចប់ដំណើរនៅនាលោកនេះ

សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំ
បានទទួលលំនៅស្ថានដ៏ស្ថិតស្ថេរ
និងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច ។

យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ និងលើកតម្កើងព្រះអង្គ
រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ដែលពោរពេញដោយសុភមង្គល
ជាមាតាព្រះជាម្ចាស់ ជាមួយអស់គ្រីស្តទូត និងមរណសាក្សី
(ជាមួយសន្ត...ដែលយើងខ្ញុំគោរពក្នុងថ្ងៃនោះ ឬជាឧបការី)
ព្រមទាំងសន្តបុគ្គលទាំងឡាយ
តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ ។

ប. ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !
គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត
រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង
បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ ។

**គ្រ. អាម៉ែន ។**

**(ពិធីទទួលព្រះកាយ និងព្រះលោហិត ទំព័រ ៩៣)**

# ពិធីទទួលព្រះកាយ និងព្រះលោហិត

តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ
និងតាមការប្រៀនប្រដៅរបស់ព្រះអង្គ យើងខ្ញុំហ៊ានទូលថា ៖

គ្រ. **ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !**
**សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ**
**សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់**
**សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី**
**ដូចនៅស្ថានបរមសុខដែរ ។**
**សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។**
**សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក**
**ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។**
**សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ ។**
**តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច ។**

ប. ឱ ព្រះអម្ចាស់អើយ !
សូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់គ្រប់យ៉ាង
សូមឲ្យយើងខ្ញុំបានប្រកបដោយសេចក្តីសុខសាន្តក្នុងពេលរស់នៅសព្វថ្ងៃ
ដោយសារធម៌មេត្តាករុណារបស់ព្រះអង្គ
សូមឲ្យយើងខ្ញុំរួចពីបាបជានិច្ច និងផុតពីទុក្ខលំបាកទាំងឡាយ ។
យើងខ្ញុំទន្ទឹងរង់ចាំសុភមង្គលតាមសេចក្តីសង្ឃឹមរបស់យើង
គឺជាថ្ងៃដែលព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះទ្រង់យាងមក ។

ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព
និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ ។

ប. ឱ ព្រះអម្ចាស់យេស៊ូគ្រីស្តអើយ !
ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតថា ៖
«ខ្ញុំទុកសេចក្ដីសុខសាន្តឲ្យអ្នករាល់គ្នា
ខ្ញុំផ្ដល់សេចក្ដីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់គ្នា» ។
សូមព្រះអង្គកុំប្រកាន់ទោសរបស់យើងខ្ញុំឡើយ
តែសូមទ្រង់ឈ្វេងយល់ នូវជំនឿរបស់ព្រះសហគមន៍ព្រះអង្គវិញ ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រទានឲ្យព្រះសហគមន៍
បានប្រកបដោយសេចក្ដីសុខសាន្ត និងបានមូលផ្ដុំគ្នាជាធ្លុងតែមួយ ។

ព្រះអង្គមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែង
តរៀងទៅ ។

គ្រ. **អាម៉ែន ។**

ប. សូមឲ្យសេចក្ដីសុខសាន្តរបស់ព្រះអម្ចាស់ គង់នៅជាមួយបងប្អូន ។

គ្រ. **ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប. សូមបងប្អូនជូនសេចក្ដីសុខសាន្ត ចំពោះគ្នាទៅវិញទៅមក ។
សូមឲ្យព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត
ជាអម្ចាស់យើងខ្ញុំ ដែលរួមគ្នាក្នុងពែងនេះ
ផ្ដល់ជីវិតអស់កល្បជានិច្ច ដល់យើងខ្ញុំជាអ្នកទទួលព្រះកាយ ។

គ្រ. ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូរយើងខ្ញុំ ។

ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូរយើងខ្ញុំ ។
**ឱ កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបនៃពិភពលោក**
**សូមប្រទានសេចក្ដីសុខសាន្ដឲ្យយើងខ្ញុំ ។**

**ប.** ឱ ព្រះអម្ចាស់យេស៊ូគ្រីស្ដ !
ជាព្រះបុត្រានៃព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ
ព្រះអង្គប្រទានជីវិតឲ្យពិភពលោកទាំងមូល
ដោយសោយទិវង្គត តាមព្រះហឫទ័យព្រះបិតា
និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។
សូមរំដោះខ្ញុំឲ្យរួចផុតពីបាប និងសេចក្ដីអាក្រក់ទាំងឡាយ
ដោយសារព្រះកាយ និងព្រះលោហិតដ៏វិសុទ្ធបំផុតរបស់ព្រះអង្គ ។
សូមឲ្យខ្ញុំប្រព្រឹត្ដតាមឱវាទរបស់ព្រះអង្គជានិច្ច កុំឲ្យខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គឡើយ ។

**ឬ**

**ប.** បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ដ !
សូមឲ្យខ្ញុំដែលទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ
មិនមានទោស និងមិនទទួលទណ្ឌកម្មឡើយ
ផ្ទុយទៅវិញ តាមព្រះហឫទ័យមេត្ដាករុណារបស់ព្រះអង្គ
សូមឲ្យព្រះកាយ និងព្រះលោហិតទៅជាឱសថការពារ
និងព្យាបាលវិញ្ញាណព្រមទាំងរូបកាយរបស់ខ្ញុំ ។

**ប.** នេះជាកូនចៀមរបស់ព្រះជាម្ចាស់
នេះជាព្រះអង្គដែលដកបាបនៃពិភពលោក ។
អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម
អ្នកនោះពិតជាមានសុភមង្គលហើយ ។

**គ្រ. ឱ ព្រះអម្ចាស់អើយ !**
**ខ្ញុំមិនសមនឹងទទួលព្រះអង្គក្នុងផ្ទះខ្ញុំទេ**
**តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក**
**នោះព្រលឹងខ្ញុំនឹងជាសះស្បើយ ។**

**ប.** សូមព្រះកាយព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច ។
សូមព្រះលោហិតព្រះគ្រីស្តរក្សាខ្ញុំទុកក្នុងជីវិតអស់កល្បជានិច្ច ។

| |
|---|
| **ប.** ព្រះកាយព្រះគ្រីស្ត ។ (ព្រះលោហិតព្រះគ្រីស្ត) |
| **គ្រ. អាម៉ែន !** |

**ប.** បពិត្រព្រះអម្ចាស់ !
សូមឲ្យយើងខ្ញុំទទួលដោយចិត្តបរិសុទ្ធ
នូវអ្វីដែលយើងខ្ញុំបានទទួលតាមមាត់
សូមឲ្យព្រះអំណោយទាននាបច្ចុប្បន្ននេះ
ទៅជាឱសថផ្តល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ ។

**ប.** សូមបងប្អូនតាំងចិត្តអធិដ្ឋាន...
**គ្រ. អាម៉ែន ។**

# ពិធីបញ្ចប់

*បើមានព័ត៌មាន សូមប្រកាសនៅពេលនេះ ។*

ប.	សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ.	**ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

ប.	សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានព្រះពរដល់អស់បងប្អូន
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

គ្រ.	**អាម៉ែន ។**

*ពេលលោកអភិបាល ជាអធិបតីក្នុងពិធីបុណ្យឱទ្បារិក*
*លោកពាក់មួកអភិបាល ហើយលាតដៃទាំងពោលថា ៖*

អភិ.	សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ.	**ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។**

អភិ.	សូមលើកតម្កើងព្រះនាមព្រះអម្ចាស់ ។

គ្រ.	**តាំងពីពេលនេះ រហូតតទៅ ។**

អភិ.	យើងខ្ញុំទទួលការសង្គ្រោះ មកពីព្រះនាមព្រះអម្ចាស់ ។

គ្រ.	**ជាព្រះដែលបានបង្កើតមេឃ និងដី ។**

*ប្រសិនបើក្នុងពិធីមានដំបងគង្វាល លោកអភិបាលជាអធិបតីកាន់ដំបងគង្វាលនោះ ហើយពោលថា ៖*

**អភិ.** សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានព្រះពរដល់អស់បងប្អូន
គឺព្រះបិតា ✠ និងព្រះបុត្រា ✠ និងព្រះវិញ្ញាណ ✠ ដ៏វិសុទ្ធ ។

**គ្រ.** **អាម៉ែន ។**

**ប.** អភិបូជាចប់ហើយ ព្រះជាម្ចាស់បាត់បងប្អូនឲ្យទៅ ។

ឬ

សូមអញ្ជើញទៅ និងប្រកាសដំណឹងល្អរបស់ព្រះអម្ចាស់ ។

ឬ

សូមអញ្ជើញឲ្យបានសុខសាន្ត
និងលើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ ក្នុងជីវិតរបស់បងប្អូន ។

ឬ

សូមអស់បងប្អូនអញ្ជើញឲ្យបានសុខសាន្ត ។

**គ្រ.** **សូមអរព្រះគុណព្រះជាម្ចាស់ ។**

# ពិធីនមស្ការព្រះកាយព្រះគ្រីស្ត

**ចូរយើងឱនកាយក្រាបថ្វាយបង្គំ**

១- ចូរយើងគ្រប់គ្នាក្រាបថ្វាយបង្គំ អគ្គសញ្ញាដ៏ពិសិដ្ឋ
គឺព្រះកាយានៃព្រះយេស៊ូ ទ្រង់ចងសម្ពន្ធមេត្រីថ្មី
ទោះបីជាភ្នែកយើងមើលមិនឃើញ តែយើងជឿទ្រង់គង់ទីនេះ ។
២- ចូរយើងសរសើរតម្កើងព្រះអម្ចាស់ ព្រះបិតា និងព្រះបុត្រា
ទាំងព្រះវិញ្ញាណជាព្រះត្រៃឯក ព្រះអង្គមានសិរីរុងរឿង
តេជានុភាពពេញទាំងមេឃដី វិសុទ្ធអស់កល្បអង្វែងអើយ ។

1- Tantum ergo Sacramentum Veneremur cernui
Et antiquum documentum Novo cedat ritui
Praestet fides supplementum Sensuum defectui.
2- Genitori, Genitoque Laus et Jubilatio,
Salus, honor, virtus quoque Sit et benedictio
Procedenti ab utroque Compar sit laudatio. **Amen.**

ប. បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់! ព្រះអង្គបានប្រទានអគ្គសញ្ញា នៃព្រះកាយព្រះអង្គទុកជាការនឹករឭកពីទុក្ខលំបាករបស់ព្រះអង្គ ។ សូមទ្រង់ព្រះមេត្តាប្រោសយើងខ្ញុំ ឲ្យយកចិត្តទុកដាក់ គោរពអគ្គសញ្ញាដ៏ប្រសើរឧត្តមនេះ និងទទួលស្គាល់សេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះអង្គផង ។ ព្រះអង្គដែលមានព្រះជន្មគង់នៅអស់កល្បជាអង្វែងតរៀងទៅ ។ អាម៉ែន ។

**ប្រទានពរ** *(រួចហើយសូមថាឡើងវិញក្រោយបូជាចារ្យ ៖ )*

- សូមលើកតម្កើង ព្រះជាម្ចាស់!
- សូមលើកតម្កើង ព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ!
- សូមលើកតម្កើងព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ដ៏ពិតប្រាកដ និងជាមនុស្សដ៏ពិតប្រាកដ!
- សូមលើកតម្កើង ព្រះនាមព្រះយេស៊ូ!
- សូមលើកតម្កើង ព្រះបេះដូងដ៏សក្ការៈរបស់ព្រះអង្គ!
- សូមលើកតម្កើង ព្រះលោហិតដ៏ពិសិដ្ឋរបស់ព្រះអង្គ!
- សូមលើកតម្កើង ព្រះកាយព្រះយេស៊ូដែលគង់នៅលើអាសនៈ!
- សូមលើកតម្កើង ព្រះវិញ្ញាណដ៏វិសុទ្ធដែលជួយសម្រាលទុក្ខ!
- សូមលើកតម្កើង ព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធ ជាព្រះមាតានៃព្រះជាម្ចាស់ដែលគ្មានអ្វីប្រៀបផ្ទឹមបាន!
- សូមលើកតម្កើង ភាពដ៏វិសុទ្ធ និងភាពគ្មានជំពាក់បាបរបស់ព្រះនាង!
- សូមលើកតម្កើង ការឡើងស្ថានបរមសុខដ៏រុងរឿងរបស់ព្រះនាង!
- សូមលើកតម្កើង ព្រះនាមនៃព្រះនាងម៉ារី ជាព្រះមាតា និងជាព្រហ្មចារិនី!
- សូមលើកតម្កើង សន្តយ៉ូសែបជាស្វាមីដ៏ស្មោះត្រង់របស់ព្រះនាង!
- សូមលើកតម្កើងព្រះជាម្ចាស់ក្នុងចំណោមពពួកទេវទូត និងសន្តបុគ្គលរបស់ព្រះអង្គ!

ឱ! ព្រះជាម្ចាស់អើយ! សូមប្រទានបូជាចារ្យមកយើងខ្ញុំ!

ឱ! ព្រះជាម្ចាស់អើយ! សូមប្រទានបូជាចារ្យជាច្រើនមកយើងខ្ញុំ!

ឱ! ព្រះជាម្ចាស់អើយ! សូមប្រទានបូជាចារ្យដ៏វិសុទ្ធជាច្រើនមកយើងខ្ញុំ!

# ពាក្យជូនពរចុងបញ្ចប់នៃអភិបូជា

## ពាក្យជូនពរដ៏ឱឡារិក

ពាក្យជូនពរនេះ ប្រើក្នុងឱកាសអភិបូជា ឬពិធីលើកតម្កើងព្រះបន្ទូលព្រះអង្គ ឬពេលសូត្រទំនុកតម្កើងតាមកាលកំណត់ ឬនៅពេលប្រារព្ធអគ្គសញ្ញាផ្សេងៗ ។ លោកឧបដ្ឋាក ឬបូជាចារ្យម្នាក់អញ្ជើញអង្គប្រជុំដោយពោលថា សូមបងប្អូនឱនក្បាលត្រៀមខ្លួនទទួលព្រះពរ ។ បន្ទាប់មកលោកបូជាចារ្យទ្រាប់ដៃលើអង្គប្រជុំ ដោយពោលពាក្យជូនពរ ហើយឆ្លើយ ៖ **អាម៉ែន** ។

## I. ពិធីប្រារព្ធតាមរដូវផ្សេងៗ

### ១. រដូវរង់ចាំព្រះគ្រីស្តយាងមក

ឱព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
និងពោរពេញដោយធម៌មេត្តាករុណាអើយ !
ព្រះអង្គចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមកសង្គ្រោះយើងខ្ញុំ
និងប្រោសឲ្យអស់អ្នកជឿរង់ចាំព្រះបុត្រាយាងត្រឡប់មកវិញ ។
ដោយសារព្រះគ្រីស្តយាងមកយ៉ាងរុងរឿង
សូមបន្សុទ្ធយើងខ្ញុំ និងប្រោសឲ្យយើងខ្ញុំបានទទួលព្រះពរយ៉ាងបរិបូណ៌ផង ។
**ឆ្លើយ ៖ អាម៉ែន!**

សូមព្រះជាម្ចាស់ពង្រឹងជំនឿបងប្អូន
និងប្រទានអំណរសប្បាយ ក្នុងសេចក្តីសង្ឃឹម
និងប្រោសឲ្យបងប្អូនមានចិត្តមេត្តាករុណាក្នុងដំណើរជីវិតជារៀងរាល់ថ្ងៃ ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យបងប្អូនដែលមានអំណរសប្បាយ ដោយជាប់ចិត្តនឹងព្រះសង្គ្រោះ
ដែលយាងមកក្នុងសាច់ឈាមជាមនុស្ស
បានទទួលរង្វាន់នៃជីវិតអស់កល្បជានិច្ច
នៅពេលដែលព្រះអង្គយាងមកម្តងទៀតប្រកបដោយឫទ្ធានុភាព ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ២- ព្រះអម្ចាស់យេស៊ូប្រសូត

ដោយសារព្រះបុត្រាបានចាប់កំណើតជាមនុស្ស
ព្រះអង្គកម្ចាត់ភាពងងឹតចេញពីពិភពលោក
ដោយសារព្រះបុត្រាប្រសូតយ៉ាងរុងរឿង
ព្រះអង្គបំភ្លឺយប់ (ថ្ងៃ)ដ៏វិសុទ្ធនេះ
សូមព្រះជាម្ចាស់ដ៏សប្បុរសក្រៃលែង
កម្ចាត់ភាពងងឹតនៃគ្រប់អំពើអាក្រក់ឲ្យឆ្ងាយពីបងប្អូន
និងបំភ្លឺចិត្តគំនិតបងប្អូនឲ្យប្រកបដោយរស្មីនៃគុណធម៌ ។
**ឆ្លើយ ៖ អាម៉ែន**

បពិត្រព្រះជាម្ចាស់
ព្រះអង្គសព្វព្រះហឫទ័យឲ្យទេវទូតប្រកាសអំពីអំណរសប្បាយ
ដល់ពួកគង្វាលថា ព្រះបុត្រាបានប្រសូតហើយ ។
សូមព្រះអង្គបំពេញចិត្តគំនិតរបស់បងប្អូនឲ្យមានអំណរសប្បាយ
ដែលមកពីព្រះអង្គ និងប្រោសឲ្យបងប្អូនទៅជាអ្នកប្រកាសដំណឹងល្អ
របស់ព្រះអង្គ ។
**ឆ្លើយ ៖ អាម៉ែន**

បពិត្រព្រះជាម្ចាស់ ដោយសារព្រះបុត្រាបានប្រសូតជាមនុស្ស
ព្រះអង្គបានភ្ជាប់ផែនដីជាមួយនឹងស្ថានបរមសុខ
និងប្រោសឲ្យបងប្អូនបានពោរពេញទៅដោយសេចក្ដីសុខសាន្ត ។
សូមព្រះអង្គប្រោសឲ្យបងប្អូនចូលរួមក្នុងព្រះសហគមន៍
នៅស្ថានបរមសុខផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៣-ចូលឆ្នាំថ្មី

បពិត្រព្រះជាម្ចាស់ ព្រះអង្គជាប្រភពនៃព្រះពរទាំងអស់
សូមព្រះអង្គចាក់បង្ហូរព្រះពរយ៉ាងបរិបូណ៌លើបងប្អូន
និងសូមថែរក្សាការពារបងប្អូនឲ្យបានសុខសាន្ត

ក្នុងរយៈពេលពេញមួយឆ្នាំនេះ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គប្រទានឲ្យបងប្អូនមានចិត្តស្មោះត្រង់ក្នុងជំនឿ
បេះស៊ូទ្រាំក្នុងសេចក្ដីសង្ឃឹម និងមានចិត្តសប្បុរសធម៌យ៉ាងខ្ជាប់ខ្ជួន
ដោយអត់ធ្មត់រហូតដល់ទីបញ្ចប់នៃជីវិត ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គប្រទានសេចក្ដីសុខសាន្ដដល់បងប្អូន
គ្រប់ពេលវេលា និងគ្រប់កិច្ចការរបស់បងប្អូន ។
សូមព្រះអង្គសណ្ដាប់ពាក្យទូលអង្វររបស់បងប្អូននៅទីនេះ
និងនៅគ្រប់ទីកន្លែង ហើយសូមនាំបងប្អូនទៅកាន់ជីវិតអស់កល្បជានិច្ច
ទាំងមានចិត្តរីករាយ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៨-បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

បពិត្រព្រះជាម្ចាស់ ព្រះអង្គបានត្រាស់ហៅបងប្អូនឲ្យចេញពីភាពងងឹត
ចូលទៅក្នុងពន្លឺដ៏អស្ចារ្យរបស់ព្រះអង្គ ។
សូមព្រះអង្គសព្វព្រះហឫទ័យបាក់បង្ហូរព្រះពរលើបងប្អូន
និងប្រោសឲ្យបងប្អូនមានចិត្តរឹងមាំក្នុងជំនឿ សេចក្ដីសង្ឃឹម
និងធម៌មេត្តាករុណា ។
**ឆ្លើយ ៖ អាម៉ែន**

ដោយហេតុថាបងប្អូនអង់អាចដើរតាមព្រះគ្រីស្ត
ដែលទ្រង់សម្តែងព្រះអង្គក្នុងលោកនេះ ជាពន្លឺបំភ្លឺក្នុងភាពងងឹត
សូមព្រះជាម្ចាស់ប្រោសបងប្អូនឲ្យទៅជាពន្លឺដល់អស់មនុស្សលោក ។
**ឆ្លើយ ៖ អាម៉ែន**

នៅពេលដែលបងប្អូនបានបញ្ចប់បូជនីយចរណ៍
សូមឲ្យបងប្អូនបានវិលទៅរកព្រះអង្គ គឺព្រះគ្រីស្តជាព្រះអម្ចាស់
ជាពន្លឺដែលមកពីពន្លឺ ដូចហោរាចារ្យបានស្វែងរកដោយធ្វើដំណើរតាមផ្កាយ
ហើយគេបានឃើញដោយចិត្តអំណរសប្បាយ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៥-ព្រះអម្ចាស់សោយទុក្ខលំបាក

បពិត្រព្រះជាម្ចាស់ ជាព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណា
ព្រះអង្គបានប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ
ឲ្យសោយទុក្ខលំបាក ទុកជាគំរូនៃសេចក្ដីស្រឡាញ់សម្រាប់បងប្អូន ។
សូមព្រះអង្គប្រទានព្រះអំណោយទានដែលជាព្រះពរ
ដល់បងប្អូនដែលបម្រើព្រះជាម្ចាស់ និងអ្នកដទៃ ។
**ឆ្លើយ ៖ អាម៉ែន**

តាមរយៈព្រះបុត្រាសោយទិវង្គតនៅលើផែនដីនេះ
បងប្អូនជឿថា បងប្អូនជៀសផុតពីមរណភាពអស់កល្បជានិច្ច
សូមព្រះអង្គប្រទានរង្វាន់នៃជីវិតអស់កល្បជានិច្ចដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**

ដោយបងប្អូនដើរតាមគំរូដែលព្រះបុត្រាបានបន្ទាបខ្លួន
សូមឲ្យបងប្អូនរស់ឡើងវិញរួមជាមួយព្រះអង្គ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៦- រដូវបុណ្យចម្លង

បពិត្រព្រះជាម្ចាស់
តាមរយៈព្រះបុត្រាតែមួយរបស់ព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ព្រះអង្គគាប់ព្រះហឫទ័យប្រទានព្រះអំណោយទាន
គឺលោះ និងប្រោសឲ្យបងប្អូនទៅជាបុត្រធីតារបស់ព្រះអង្គ ។
សូមព្រះអង្គប្រទានពរឲ្យបងប្អូនមានអំណរសប្បាយ ។
**ឆ្លើយ ៖ អាម៉ែន**

បងប្អូនបានទទួលសេរីភាពអស់កល្បជានិច្ច ដែលជាព្រះអំណោយទាន
ដោយព្រះអង្គបានលោះបងប្អូន ។
សូមព្រះអង្គប្រទានមរតកអស់កល្បជានិច្ចដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**

តាមរយៈជំនឿ បងប្អូនបានរស់ឡើងវិញរួមជាមួយព្រះគ្រីស្ត
នៅក្នុងអគ្គសញ្ញាជ្រមុជទឹក ។
ដោយបងប្អូនរស់នៅតាមរបៀបសុចរិតនៅលើផែនដីនេះ
សូមព្រះអង្គប្រោសឲ្យបងប្អូនបានរស់នៅរួមជាមួយព្រះអង្គ
នៅឯស្ថានបរមសុខ ដែលជាមាតុភូមិរបស់ព្រះអង្គផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៧- បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានពរដល់បងប្អូននៅថ្ងៃនេះ
ជាថ្ងៃដែលព្រះបុត្រាតែមួយគត់របស់ព្រះអង្គ
បានទម្លុះទម្លាយចូលស្ថានបរមសុខ និងបើកផ្លូវឲ្យបងប្អូនឡើង
ទៅកាន់កន្លែងដែលព្រះអង្គគង់នៅ ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះជាម្ចាស់បានប្រោសឲ្យគ្រីស្តទូតឃើញព្រះគ្រីស្តយ៉ាងច្បាស់
បន្ទាប់ពីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ។
នៅពេលយាងមកកាត់ក្តី
សូមឲ្យព្រះគ្រីស្តសម្តែងព្រះហឫទ័យប្រណីសន្តោស
អស់កល្បជានិច្ចដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**

បងប្អូនជឿថា ព្រះគ្រីស្តគង់នៅជាមួយព្រះបិតា ក្នុងព្រះរាជ្យព្រះអង្គ
សូមឲ្យបងប្អូនមានអំណរសប្បាយដោយដឹងថា
ព្រះបន្ទូលសន្យាបានកើតជារូបរាងហើយ
គឺព្រះគ្រីស្តគង់នៅជាមួយបងប្អូនរហូតដល់អវសានកាល ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៨- ព្រះវិញ្ញាណដ៏វិសុទ្ធ

បពិត្រព្រះជាម្ចាស់ជាព្រះបិតាប្រកបដោយពន្លឺ
ព្រះអង្គសព្វព្រះហឫទ័យបំភ្លឺចិត្តគំនិតក្រុមគ្រីស្តទូត
ដោយបង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធលើគេ ។
សូមព្រះអង្គប្រទានឲ្យបងប្អូនមានអំណរសប្បាយ
និងប្រោសឲ្យបងប្អូនបានពោរពេញដោយព្រះអំណោយទានផ្សេងៗ
ដែលមកពីព្រះវិញ្ញាណតែមួយ ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យអណ្តាតភ្លើងដ៏អស្ចារ្យ ដែលចុះមកសណ្ឋិតលើគ្រីស្តទូត
ជម្រះចិត្តគំនិតបងប្អូនឲ្យរួចផុតពីអំពើអាក្រក់ទាំងឡាយ
និងឲ្យបានពោរពេញដោយពន្លឺដ៏បរិសុទ្ធ ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះអង្គគាប់ព្រះហឫទ័យឲ្យអណ្តាតទាំងឡាយប្រកាសជំនឿតែមួយ ។
សូមព្រះអង្គប្រោសឲ្យបងប្អូនមានចិត្តស៊ប់ក្នុងជំនឿតែមួយ
និងធ្វើដំណើរពីសេចក្តីសង្ឃឹមឈានទៅមានទស្សនវិស័យច្បាស់លាស់ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ៩- រដូវធម្មតាទី ១

សូមព្រះជាម្ចាស់ប្រទានពរ និងថែរក្សាការពារបងប្អូន ។

**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គបំភ្លឺនៃព្រះភក្ត្រព្រះអង្គលើបងប្អូន
និងបង្ហាញធម៌មេត្តាករុណាដល់បងប្អូនផង ។

**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គបែរព្រះភក្ត្រទៅរកបងប្អូន
និងផ្តល់សេចក្តីសុខសាន្តដល់បងប្អូនផង ។

**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។

**ឆ្លើយ ៖ អាម៉ែន**

## ១០- រដូវធម្មតាទី ២

សូមព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដែលហួសពីចំណេះដឹង
ដោយព្រះអង្គរក្សាដួងចិត្តនិងគំនិតរបស់បងប្អូន ក្នុងព្រះហឫទ័យ
និងក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងព្រះយេស៊ូគ្រីស្តជាអម្ចាស់
ជាព្រះបុត្រារបស់ព្រះអង្គ ។

**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១១- រដូវធម្មតាទី ៣

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានពរដល់បងប្អូន ឲ្យរស់នៅក្នុងព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ
និងសូមបាក់បង្ហូរព្រះប្រាជ្ញាញាណនៃការសង្គ្រោះពីលើបងប្អូនផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គបីបាច់ថែរក្សាបងប្អូនជានិច្ច
ដោយប្រៀនប្រដៅតាមជំនឿ
និងប្រោសឲ្យបងប្អូនមានចិត្តតស៊ូក្នុងកិច្ចការប្រចាំថ្ងៃផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះអង្គប្រោសបងប្អូនឲ្យវិលត្រឡប់ទៅរកព្រះអង្គ
ហើយសូមបង្ហាញមាគ៌ានៃធម៌មេត្តាករុណា
និងសេចក្ដីសុខសាន្តដល់បងប្អូនផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១២- រដូវធម្មតាទី ៤

បពិត្រព្រះជាម្ចាស់ ដែលតែងតែលើកទឹកចិត្តបងប្អូន
សូមព្រះអង្គប្រទានសេចក្តីសុខសាន្តជាប្រចាំ
និងអំណោយទានផ្សេងៗដែលជាព្រះពររបស់ព្រះអង្គដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រោសបងប្អូន
ឲ្យរួចផុតពីទុក្ខព្រួយទាំងឡាយ គ្រប់ពេលវេលា
និងរក្សាដួងចិត្តរបស់បងប្អូនទុកក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យបងប្អូនមានជោគជ័យក្នុងគ្រប់កិច្ចការ
ពោរពេញទៅដោយសេចក្តីសង្ឃឹម ជំនឿក្នុងដំណើរជីវិត
និងមានចិត្តមេត្តាករុណា ព្រមទាំងមានអំណរសប្បាយ
ឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ច ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១៣- រដូវធម្មតាទី ៥

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ប្រោសបងប្អូន
ឲ្យឃ្លាតឆ្ងាយពីទុក្ខលំបាកគ្រប់បែបយ៉ាង

និងដោយព្រះហឫទ័យដ៏សប្បុរស
សូមព្រះអង្គបង្ហូរព្រះអំណោយទានដែលជាព្រះពរដល់បងប្អូនផង ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រោសឲ្យបងប្អូនយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូល
ព្រះអង្គ និងឲ្យបងប្អូនមានអំណរសប្បាយអស់កល្បជានិច្ច ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យបងប្អូនយល់ដឹងនូវអ្វីដែលល្អ និងត្រឹមត្រូវ
ហើយរួសរាន់ស្វែងរក តាមមាគ៌ានៃវិន័យរបស់ព្រះជាម្ចាស់
ដើម្បីទទួលមរតករួមជាមួយប្រជារាស្ត្ររបស់ព្រះអង្គក្នុងស្ថានបរមសុខ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១៤- រដូវធម្មតាទី ៦

សូមព្រះជាម្ចាស់ប្រទានពរគ្រប់បែបយ៉ាងពីស្ថានបរមសុខដល់បងប្អូន
ដើម្បីឲ្យបងប្អូនទៅជាជនដ៏វិសុទ្ធ និងស្អាតស្អំនៅចំពោះព្រះភក្ត្រព្រះអង្គ ។
សូមព្រះអង្គបង្ហូរសិរីរុងរឿងដ៏លើសលប់របស់ព្រះអង្គលើបងប្អូន
និងប្រៀនប្រដៅបងប្អូនដោយសេចក្ដីពិត ។
សូមព្រះអង្គបង្រៀនបងប្អូនអំពីព្រះបន្ទូលដំណឹងល្អនៃការសង្គ្រោះ
និងប្រទានឲ្យបងប្អូនមានចិត្តមេត្តាករុណាចំពោះគ្នាទៅវិញទៅមក ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## II. **បុណ្យគោរពសន្តបុគ្គល**

### ១៩- បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី

ឱព្រះជាម្ចាស់អើយ!
ព្រះអង្គសព្វព្រះហឫទ័យលោះមនុស្សជាតិ
តាមរយៈព្រះនាងព្រហ្មចារិនីម៉ារីបានប្រសូតព្រះបុត្រា ។
សូមព្រះអង្គប្រទានព្រះពរយ៉ាងបរិបូណ៌ដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យបងប្អូនទទួលស្គាល់ថា ព្រះនាងម៉ារីជួយថែរក្សាបងប្អូន
គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។
សូមព្រះអង្គប្រោសឲ្យបងប្អូនមានកិត្តិយស
សមនឹងទទួលព្រះបុត្រាជាប្រភពនៃជីវិតតាមរយៈព្រះនាងម៉ារី ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យបងប្អូនដែលរួបរួមគ្នាដោយជាប់ចិត្តនឹងព្រះអង្គនៅថ្ងៃនេះ
បានទទួលព្រះអំណោយទាននៃអំណរសប្បាយខាងវិញ្ញាណ
និងទទួលរង្វាន់នៃស្ថានបរមសុខនៅពេលត្រឡប់ទៅវិញ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១៦- សន្តសិលា និងសន្តប៉ូលជាគ្រីស្តទូត

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ព្រះអង្គបានប្រោសឲ្យបងប្អូនមានភាពខ្ជាប់ខ្ជួនក្នុងជំនឿ
តាមរបៀបដែលសន្តសិលាបានប្រកាសជំនឿអំពីការសង្គ្រោះ ។
តាមរយៈការប្រកាសជំនឿនោះ
សូមព្រះអង្គប្រោសឲ្យបងប្អូនស្ថិតនៅលើផ្ទាំងសិលាដ៏រឹងមាំ
នៃជំនឿរបស់ព្រះសហគមន៍ផង ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះជាម្ចាស់បានប្រោសសន្តប៉ូលឲ្យប្រកាសព្រះបន្ទូលព្រះអង្គ
ដោយគ្មាននឿយណាយឡើយ ។
សូមព្រះអង្គប្រៀនប្រដៅ ឲ្យបងប្អូនចេះប្រមែប្រមូលអ្នកឯទៀតៗ
មករកព្រះគ្រីស្តតាមគំរូសន្តប៉ូលផង ។
**ឆ្លើយ ៖ អាម៉ែន**

តាមរយៈកូនសោររបស់សន្តសិលា
និងដោយការប្រៀនប្រដៅរបស់សន្តប៉ូល
រួមជាមួយពាក្យទូលអង្វររបស់លោកទាំងពីរ
សូមព្រះជាម្ចាស់ណែនាំបងប្អូនឲ្យមានអំណរសប្បាយ

ឆ្ពោះទៅកាន់មាតុភូមិដែលសន្តសិលាបានទទួលដោយសារឈើឆ្កាង
និងសន្តប៉ូលបានបូជាជីវិតដោយមុខដាវ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១៧- ក្រុមគ្រីស្តទូត

បពិត្រព្រះជាម្ចាស់ដែលបានប្រោសបងប្អូន
ឲ្យឈរយ៉ាងរឹងមាំលើគ្រឹះរបស់គ្រីស្តទូត
សូមព្រះអង្គប្រទានពរដល់បងប្អូន
តាមរយៈពាក្យទូលអង្វររបស់(**នាម និងនាម...**)
ជាគ្រីស្តទូតដ៏វិសុទ្ធ ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះជាម្ចាស់បានប្រទានការប្រៀនប្រដៅ
និងគំរូរស់នៅរបស់ក្រុមគ្រីស្តទូតដល់បងប្អូន ។
សូមព្រះអង្គប្រោសឲ្យបងប្អូនធ្វើជាសាក្សីនៃសេចក្តីពិត
នៅចំពោះមុខមនុស្សលោក
ដោយមានការគាំទ្រពីក្រុមគ្រីស្តទូតផង ។
**ឆ្លើយ ៖ អាម៉ែន**

តាមរយៈពាក្យទូលអង្វរ និងការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត

សូមឲ្យបងប្អូនទទួលមាតុភូមិអស់កល្បជានិច្ចទុកជាមរតក
និងមានជំនឿរឹងមាំ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ១៨. សន្តបុគ្គលទាំងឡាយ

បពិត្រព្រះជាម្ចាស់ប្រកបដោយសិរីរុងរឿង
និងជាអំណរសប្បាយនៃសន្តបុគ្គលទាំងឡាយ
ព្រះអង្គបានប្រោសបងប្អូនឲ្យមានភាពរឹងមាំ
តាមរយៈពាក្យទូលអង្វររបស់សន្តបុគ្គល ។
សូមព្រះអង្គប្រទានពរ
គឺជាព្រះពរអស់កល្បជានិច្ចដល់បងប្អូន ។
**ឆ្លើយ ៖ អាម៉ែន**
តាមរយៈពាក្យទូលអង្វររបស់សន្តបុគ្គលទាំងឡាយ
សូមឲ្យបងប្អូនរួចផុតពីគ្រប់ការលំបាកនាពេលសព្វថ្ងៃ
និងសូមឲ្យបងប្អូនរស់នៅតាមគំរូ
នៃរបៀបរស់នៅដ៏វិសុទ្ធរបស់សន្តបុគ្គល ។
សូមប្រោសឲ្យបងប្អូនជាប់ចិត្តនឹងព្រះជាម្ចាស់
ដោយបម្រើព្រះអង្គ និងអ្នកដទៃ ។
**ឆ្លើយ ៖ អាម៉ែន**

រួមជាមួយសន្តបុគ្គលទាំងឡាយ
សូមឲ្យបងប្អូនទទួលអំណរសប្បាយនៅក្នុងមាតុភូមិ
ជាកន្លែងដែលព្រះសហគមន៍មានអំណរសប្បាយ
ដោយដឹងថា អស់អ្នកជឿបានចូលរួមក្នុងសេចក្ដីសុខសាន្តអស់កល្បជានិច្ច
រួមជាមួយប្រជារាស្ត្រនៃស្ថានបរមសុខ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## III. **ពាក្យជូនពរផ្សេងៗ**

### **១៩. បុណ្យឆ្លងព្រះវិហារ**

ព្រះជាម្ចាស់ដែលជាព្រះអម្ចាស់នៃស្ថានបរមសុខ និងផែនដី
បានប្រមូលបងប្អូននៅថ្ងៃនេះ ដើម្បីចូលរួមបុណ្យឆ្លងព្រះវិហារនេះ ។
សូមឲ្យបងប្អូនទទួលព្រះពរដ៏បរិបូណ៌ពីស្ថានបរមសុខផង ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រមែប្រមូលបុត្រធីតាព្រះអង្គ
ដែលបានខ្ចាត់ខ្ចាយ ឲ្យត្រឡប់មករួមគ្នាក្នុងអង្គព្រះបុត្រាវិញ ។
សូមឲ្យបងប្អូនធ្វើជាព្រះដំណាក់របស់ព្រះជាម្ចាស់
ដែលជាលំនៅដ្ឋាននៃព្រះវិញ្ញាណដ៏វិសុទ្ធ ។
**ឆ្លើយ ៖ អាម៉ែន**

ព្រះជាម្ចាស់បានគង់សណ្ឋិតក្នុងដួងចិត្តបងប្អូន
បន្ទាប់ពីបងប្អូនបានជម្រះឲ្យស្អាត រួចផុតពីភាពសៅហ្មង ។
សូមព្រះជាម្ចាស់ប្រោសឲ្យបងប្អូនទទួលសុភមង្គលអស់កល្បជានិច្ច
ទុកជាមរតករួមជាមួយសន្តបុគ្គលទាំងឡាយ ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

## ២០. បុណ្យមរណបុគ្គល

បពិត្រព្រះជាម្ចាស់
ព្រះអង្គតែងតែលើកទឹកចិត្តបងប្អូនជានិច្ច
សូមព្រះអង្គប្រទានពរដល់បងប្អូន ។
ព្រះអង្គបានបង្កើតមនុស្សលោក
ដោយព្រះហឫទ័យសប្បុរសហួសពីការស្មាន
និងដោយសារព្រះបុត្រាតែមួយមានព្រះជន្មរស់ឡើងវិញ
សូមព្រះអង្គប្រោសអស់អ្នកជឿឲ្យមានសេចក្ដីសង្ឃឹមថា
នឹងរស់ឡើងវិញ ។
**ឆ្លើយ ៖ អាម៉ែន**

ចំពោះយើងខ្ញុំដែលមានជីវិតរស់នៅ
សូមព្រះជាម្ចាស់លើកលែងទោសយើងខ្ញុំឲ្យរួចពីបាប
ហើយចំពោះមរណបុគ្គលទាំងឡាយ

សូមព្រះអង្គប្រទានទីស្ថានដែលប្រកបដោយពន្លឺ
និងសេចក្ដីសុខសាន្ត ។
**ឆ្លើយ ៖ អាម៉ែន**

សូមឲ្យយើងខ្ញុំរស់នៅដោយអំណរសប្បាយអស់កល្បជានិច្ច
រួមជាមួយព្រះគ្រីស្ដដែលយើងខ្ញុំជឿថា
ព្រះអង្គពិតជាមានព្រះជន្មរស់ឡើងវិញ
ពីចំណោមមនុស្សស្លាប់មែន ។
**ឆ្លើយ ៖ អាម៉ែន**

សូមព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការប្រទានពរ
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ យាងចុះមក
គង់នៅជាមួយបងប្អូនអស់កល្បជាអង្វែងតរៀងទៅ ។
**ឆ្លើយ ៖ អាម៉ែន**

# អធិដ្ឋានតាមមាលា

អ្នកអធិដ្ឋានតាមមាលារួមចិត្តគំនិត ជាមួយនាងម៉ារី ដែលជាគ្រីស្ដបរិស័ទដើមដំបូង និងជាគ្រីស្ដបរិស័ទគំរូ នឹកសញ្ជឹងអំពីព្រឹត្តិការណ៍សំខាន់ៗនៃការសង្គ្រោះ ។

តាមប្រពៃណីព្រះសហគមន៍ត្រូវសូត្រធម៌ «ឱព្រះបិតា» ១ដង រួចធម៌ «បពិត្រព្រះនាងម៉ារី» ១០ដង និងធម៌ «កោតសរសើរ» ១ដង ។

ពេលសូត្រធម៌«បពិត្រព្រះនាងម៉ារី»ត្រូវនឹកសញ្ជឹងអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យមួយចំនួនក្នុងចំណោមព្រឹត្តិការណ៍ទាំង ៤ ដែលព្រះជាម្ចាស់បានប្រព្រឹត្តដើម្បីសង្គ្រោះមនុស្សលោក ។

ព្រឹត្តិការណ៍ដ៏អស្ចារ្យទាំង ៤ ដែលគ្រីស្ដបរិស័ទធ្លាប់អធិដ្ឋានតាមថ្ងៃមានដូចខាងក្រោមនេះ គឺ៖

## I. ព្រឹត្តិការណ៍នាំឲ្យអរសប្បាយ

១- ព្រះជាម្ចាស់បាត់ទេវទូតមកជូនដំណឹងព្រះនាងម៉ារី

២- ព្រះនាងម៉ារីទៅជម្រាបសួរនាងអេលីសាបិត

៣- ព្រះយេស៊ូប្រសូតមកក្នុងលោកយើងនេះ

៤- ព្រះនាងម៉ារីបីព្រះឱរសយេស៊ូ ទៅថ្វាយព្រះជាម្ចាស់

៥- នាងម៉ារីនិងលោកយ៉ូសែបរកឃើញព្រះកុមារយេស៊ូ ក្នុងព្រះវិហារ ។

## II-ព្រឹត្តិការណ៍សម្តែងព្រះពន្លឺ

១- ព្រះយេស៊ូទទួលពិធីជ្រមុជទឹក

២-ព្រះយេស៊ូប្រែទឹកឲ្យក្លាយជាស្រា

៣-ព្រះយេស៊ូប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់

៤-ព្រះជាម្ចាស់បង្ហាញសិរីរុងរឿងរបស់ព្រះយេស៊ូ

៥-ព្រះយេស៊ូតែងតាំងនំប៉័ងជាព្រះកាយព្រះគ្រីស្ត

## III. ព្រឹត្តិការណ៍នៃទុក្ខលំបាក

១- ព្រះយេស៊ូស្តុតរន្ធត់នៅក្នុងសួនច្បារកេតសេម៉ានី

២- ព្រះយេស៊ូត្រូវគេវាយនឹងរំពាត់

៣- គេបំពាក់មកុដបន្លាលើព្រះយេស៊ូ

៤- ព្រះយេស៊ូលីឈើឆ្កាង

៥- ព្រះយេស៊ូសោយទិវង្គត

## IV.ព្រឹត្តិការណ៍សម្តែងសិរីរុងរឿង

១- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

២-ព្រះយេស៊ូយាងឡើងស្ថានបរមសុខ

៣-ព្រះវិញ្ញាណយាងសណ្ឋិតលើក្រុមសាវ័ក

៤-ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ

៥-ព្រះជាម្ចាស់ប្រទានសិរីរុងរឿងឲ្យនាងម៉ារី

# ចម្រៀង



# និង



# ទំនុកតម្កើងសម្រាំង



# ១- កាលណា ២ ឬ ៣ នាក់ជួបជុំគ្នា

បន្ទរ- ព្រះជាអម្ចាស់មានព្រះបន្ទូលថា កាលណាពីរ ឬ បីនាក់
ជួបជុំគ្នាក្នុងនាមខ្ញុំ នោះខ្ញុំស្ថិតនៅជាមួយផង ។

១- ឱ ! ព្រះយេស៊ូអើយ សូមទ្រង់គង់ជាមួយយើងខ្ញុំ
ក្នុងពេលយើងខ្ញុំ កោតសរសើរព្រះអង្គ
ក្នុងពេលយើងខ្ញុំ ប្រកាសសេចក្តីស្រឡាញ់
មកពីព្រះហឫទ័យ ស្រឡាញ់របស់ព្រះអង្គ ។

២- ឱ ! ព្រះយេស៊ូអើយ សូមទ្រង់គង់ជាមួយយើងខ្ញុំ
ក្នុងពេលយើងខ្ញុំ ស្តាប់ព្រះបន្ទូលព្រះអង្គ
សូមទ្រង់បំភ្លឺ ចិត្តគំនិតយើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំ ឮព្រះសូរសៀងព្រះអង្គ ។

៣- ឱ ! ព្រះយេស៊ូអើយ សូមទ្រង់គង់ជាមួយយើងខ្ញុំ
សូមនឹកដល់យើងខ្ញុំ ពីស្ថានបរមសុខមក
ព្រះអង្គដែលគង់ ជាមួយយើងខ្ញុំ
នៅពេលនេះហើយ ជាអង្វែងតរៀងទៅ ។

៤- ឱ ! ព្រះយេស៊ូអើយ សូមទ្រង់គង់ជាមួយយើងខ្ញុំ
ក្នុងពេលយើងខ្ញុំ រួមថ្វាយយញ្ញបូជា
ហើយយើងខ្ញុំកាច់ ចែកគ្នាទទួលទាន
នូវនំប៉័ងដែលផ្តល់ ជីវិតដ៏អនន្ត ។

## ២- ខ្ញុំនឹកស្រណោះវិហារព្រះម្ចាស់

### ទំនុកតម្កើងលេខ ៨៤(៨៣)

បន្ទរ- ខ្ញុំនឹកស្រណោះវិហារព្រះម្ចាស់ គួរស្រឡាញ់ណាស់នៅលើលោកា
ទ្រង់មានព្រះជន្មរុងរឿងថ្លៃថ្លា ខ្ញុំមានចិន្តរីករាយស្មោះត្រង់ ។

១- បក្សាបក្សីតែងមានសំបុក ដែលផ្តល់ក្តីសុខស្ថិតស្ថេរគង់វង្ស
ខ្ញុំស្រឡាញ់ព្រះដំណាក់ព្រះអង្គ ហើយសូមយកទ្រង់ជាទីពំនាក់ ។

២- មានក្តីអំណរមានក្តីសប្បាយ អស់ជនទាំងឡាយដែលបានទៅស្នាក់
ក្នុងព្រះវិហារដោយចិត្តស្មោះស្ម័គ្រ បានធ្វើគារវៈគោរពព្រះអង្គ ។

៣- មានក្តីអំណរមានក្តីសប្បាយ អស់ជនទាំងឡាយដែលមានបំណង
ចូលក្នុងវិហារដោយចិត្តស្មោះត្រង់ ស្វែងរកព្រះអង្គដែលផ្តល់ជន្មា ។

៤- សូមទ្រង់សណ្តាប់ពាក្យអង្វរខ្ញុំ ឱ ! ព្រះឧត្តមជាម្ចាស់សួគ៌ា
សូមទ្រង់មេត្តាទតរាស្ត្រប្រជា ហើយសូមការពារនិងជួយប្រោសលោះ ។

៥- បើរស់មួយថ្ងៃនៅក្បែរខ្លោងទ្វារ នៃព្រះវិហារព្រះអង្គសង្គ្រោះ
ហាក់មានតម្លៃប្រសើរខ្ពង់ខ្ពស់ ស្មើបាននៅរស់រាប់ពាន់ឆ្នាំផង ។

៦- រស់ក្រោមសំយ៉ាបវិហារព្រះម្ចាស់ វិសេសពេកណាស់ថ្លៃថ្លាកន្លង
ប្រសើរជាងរស់ជាមួយអ្នកផង ដែលផ្តល់សៅហ្មងនាំឲ្យអាស្រូវ ។

៧- ទ្រង់សព្វព្រះហឫទ័យជនសុចរិត មេត្តាអាណិតជួយឲ្យស្គាល់ផ្លូវ
ស្គាល់ក្តីសុខសាន្តរាល់ពេលរដូវ ស្គាល់ផ្លូវដើរទៅជួបព្រះអង្គបាន ។

៨- សូមកោតសរសើររាល់ពេលរដូវ ស្គាល់ផ្លូវដើរទៅជួបព្រះអង្គបាន
ដែលគង់ស្ថិតស្ថេរប្រសើរថ្កើងថ្កាន នៅគ្រប់ទីស្ថានដរាបរៀងទៅ ។

## ៣- ខ្ញុំសែនសប្បាយទៅព្រះដំណាក់

(ដកស្រង់ពីទំនុកតម្កើងលេខ ១១២ )

ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា

បន្ទរ- ខ្ញុំសែនសប្បាយណាស់ ពេលឮច្បាស់គេប្រាប់ថា
ចូរយើងទៅដំណាក់ ព្រះជាម្ចាស់នៅសាឡឹម ។

១- យេរូសាឡឹមអើយ យើងដល់ហើយឈានជើងចូល
យើងមកដល់មាត់ទ្វារ ដល់ទីធ្លានៃក្រុងអ្នក ។

២- យេរូសាឡឹមអើយ អ្នកជាក្រុងដ៏រឹងមាំ
មានកំពែងដ៏ល្អ ល្អប្រណីតព័ទ្ធជុំវិញ ។

៣- កុលសម្ព័ន្ធនានា នៃព្រះជាអម្ចាស់យើង
នាំគ្នាឡើងទីនេះ តម្កើងព្រះនាមព្រះអង្គ ។

៤- ទីនេះមានបល្ល័ង្ក ព្រះរាជវាំងស្ដេចដាវីឌ
គ្រប់គ្រងប្រជារាស្ដ្រ ដោយក្ដីយុត្ដិធម៌ណាស់ ។

៥- សូមព្រះម្ចាស់ប្រទាន សន្ដិភាពដល់ក្រុងនេះ
អ្នកស្រឡាញ់សាឡឹម សូមឲ្យរស់បានសុខសាន្ដ ។

៦- ដោយយល់ដល់បងប្អូន និងញាតិមិត្ដរបស់ខ្ញុំ
ខ្ញុំសូមព្រះអម្ចាស់ ឲ្យសាឡឹមបានសុខសាន្ដ ។

៧- ដោយយល់ដល់ដំណាក់ នៃព្រះម្ចាស់របស់យើង
ខ្ញុំទូលសូមឲ្យអ្នក បានក្ដីសុភមង្គល ។

## ៤- គោរពព្រះត្រៃឯក

## លំនាំទំនុកតម្កើងកោតសរសើរព្រះបាទដាវីឌ

(១ របាក្សត្រ ២៩,១០-១២)

**បន្ទរ-ឱ ! ព្រះជាម្ចាស់ យើងខ្ញុំគោរព សរសើរព្រះនាម ទាំងថ្វាយចម្រៀង ចំពោះព្រះអង្គ ។**

១- ឱ ! ព្រះបិតា មានឫទ្ធិចេស្ដា អស្ចារ្យពេកក្រៃ មានធម៌សប្បុរស
ពេញដោយបារមី ព្រះនាមឮល្បី គ្រប់ទីទាំងឡាយ ។

២- ឱ ! ព្រះយេស៊ូ បន្ទូលថ្លៃថ្លា នៃព្រះបិតា ទ្រង់ជាជីវិត
ជាសេចក្ដីពិត មាគ៌ានាំយើង ឆ្ពោះព្រះបិតា ។

៣- ឱ ! ព្រះវិញ្ញាណ ព្រះប្រាជ្ញាញាណ វិសុទ្ធថ្លៃថ្លា ជាជ្រោះស្នេហា
ជាធម៌មេត្តា រក្សាការពារ យើងខ្ញុំគ្រប់គ្នា ។

៤- ឱ ! ព្រះជាម្ចាស់ យើងត្រេតអរណាស់ សូមបង្គំថ្វាយ ព្រះពរជោគជ័យ
សិរីទាំងឡាយ ទៅព្រះពណ្ណរាយ អម្ចាស់យើងខ្ញុំ ។

៥- កិត្តិយសបារមី ជោគជ័យសិរី យើងសូមបង្គំ តេជានុភាព
ព្រះម្ចាស់ឧត្ដម រុងរឿងសុខុម លើផែនលោកា ។

៦- ឱ ! ព្រះសង្គ្រោះ ព្រះនាមខ្ពង់ខ្ពស់ ជាស្ដេចស្ថានបរមសុខ ជាម្ចាស់លោកីយ៍
គ្រប់គ្រងពសុធា រក្សាការពារ សត្វលោកទាំងឡាយ ។

៧- ឱ ! ព្រះម្ចាស់អើយ នៅលោកនេះហើយ យើងសច្ចាស្មោះ គោរពព្រះអង្គ
ជាព្រះសង្គ្រោះ ដែលជួយរំដោះ មនុស្សគ្រប់គ្នា ។

៨- យើងខ្ញុំប្រណម្យ ក្រាបថ្វាយបង្គំ សូមថ្លែងពណ៌នា អំណរព្រះគុណ
ឆ្ពោះព្រះត្រៃឯក ទ្រង់គង់ការពារ យើងខ្ញុំជានិច្ច ។

## ៥- ចូរច្រៀងប្រាប់ភ្នំ

### ដកស្រង់ពីទំនុកតម្កើងលេខ ១១៨ (១១៧)

**បន្ទរ- ចូរច្រៀងប្រាប់ភ្នំ ប្រាប់សមុទ្រធំ ចូរលើកចិត្តឡើង**
**តម្កើងព្រះម្ចាស់ ដ្បិតនេះជាថ្ងៃ ម្ចាស់ថ្លៃបង្កើត**
**សូមឲ្យផែនដី បានក្ដីអំណរ អាលេលូយ៉ា(៤ដង) ។**

១- ខ្ញុំនឹងតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គត្រាស់ដោយច្បាស់ជាក់
តបឆ្លើយមកខ្ញុំដោយរាក់ទាក់ ថែមទាំងថ្នមថ្នាក់ខ្ញុំជិតដល់ ។

២- ខ្ញុំត្រូវនៅរស់មានជីវិត មិនត្រូវស្លាប់បាកផុតលោកីយ៍
ដើម្បីរៀបរាប់ពីសេចក្ដី ស្នាព្រះហស្ដថ្លៃព្រះអម្ចាស់ ។

៣- ចូរនាំគ្នាបើកទ្វារឲ្យមនុស្ស សុចរិតស្រីប្រុសមកប្រញាប់
ខ្ញុំនឹងចូលទៅឲ្យបានឆាប់ នឹងថ្លែងរៀបរាប់អរគុណទ្រង់ ។

៤- ព្រះអម្ចាស់សម្រេចការអស្ចារ្យ ដោយឫទ្ធិថ្លៃថ្លានៃព្រះអង្គ
អស្ចារ្យពេកក្រៃយើងឃើញច្បាស់ គួរស្ញប់ស្ញែងណាស់គួរគោរព ។

៥- ថ្ងៃនេះជាថ្ងៃដែលព្រះម្ចាស់ កំណត់ទុកច្បាស់ឲ្យយើងឈប់
នាំគ្នាសប្បាយកុំនៅជ្រប់ ខេត្តស្រុកភូមិគ្រប់អរទាំងអស់ ។

៦- ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះហឫទ័យអាណិត
សប្បុរសករុណាទ្រង់សុចរិត អស់កល្បស្ថេរស្ថិតរហូតទៅ ។

## ៦- ចូរច្រៀងបទថ្មីថ្វាយព្រះជាម្ចាស់

**បន្ទរ- ចូរច្រៀងបទថ្មី ថ្វាយព្រះជាម្ចាស់ ព្រះអង្គបានសម្រេច**
**ការអស្ចារ្យ អាលេលូយ៉ា ។**

១- ចូរច្រៀងបទថ្មី ថ្វាយព្រះម្ចាស់ថ្លៃ កុំភ្លេចឡើយណា ដ្បិតទ្រង់ប្រព្រឹត្ត
សព្វកិច្ចអស្ចារ្យ ទ្រង់មានឫទ្ធា ជាព្រះវិសុទ្ធ ។

២- ព្រះអង្គសង្គ្រោះ ទាំងស្រីទាំងប្រុស ឥតមានគេចផុត ចម្រើនគ្រប់គ្នា
បានឡើងជាបុត្រ ធីតាបរិសុទ្ធ ដោយអានុភាព ។

៣- មិនតែប៉ុណ្ណោះ ព្រះអង្គបំផុស សម្តែងហឫទ័យ សុចរិតស្មោះត្រង់
ជនជាតិផ្សេងក្តី បានឃើញស្មើ ដូចគ្នាទាំងអស់ ។

៤- ឯអ៊ីស្រាអែល ព្រះអង្គមិនដែល ភ្លេចម្តងណាសោះ ប្រទានហឫទ័យ
ករុណាដ៏ស្មោះ មេត្តាចំពោះ កូនចៅព្រះអង្គ ។

៥- ឱ ! មនុស្សសត្វអើយ កុំបីតោះតើយ រៀបចំអង្គា អបអរសាទរ
ថ្វាយព្រះនាមា ស្រែកហ៊ោខ្ញៀវខ្ញារ ដោយក្តីអំណរ ។

៦- ចូរដេញចាប៉ី សព្វភ្លេងតន្ត្រី ប៉ីពកប៉ីអ ឃឹមរនាតដែក
ឈិងគងត្រែស្គរ ចង្រ្កង់ស្នែងទ្រ ឲ្យលាន់ពីរោះ ។

## ៧- ចូរអ្នកស្រឡាញ់ព្រះអម្ចាស់

បន្ទរ- ចូរអ្នកស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីកម្លាំងកាយ ចូរអ្នកស្រឡាញ់បងប្អូនឯទៀត ឲ្យដូចស្រឡាញ់ខ្លួនឯង។

១- ឱ ! បងប្អូនអើយចូរអ្នកបំស្ដាប់ មានតែព្រះអម្ចាស់
ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់ ។

២- ចូរអ្នកទុកឲ្យព្រះបន្ទូល ដែលខ្ញុំប្រគល់ឲ្យអ្នក
នៅក្នុងថ្ងៃនេះដក់ជាប់ក្នុងចិត្ត របស់អ្នកជានិច្ច ។

៣- ចូរអ្នកបង្រៀនឲ្យកូនចៅអ្នក ពីព្រះបន្ទូលនេះ ពេលអ្នកនៅក្នុងផ្ទះ
ពេលដើរពេលចូលដេក និងពេលក្រោកពីដំណេក ។

## ៨- ទូលព្រះបង្គំខ្ញុំទៅដល់ដំណាក់ព្រះម្ចាស់

**បន្ទរ- ទូលព្រះបង្គំខ្ញុំ ទៅដល់ដំណាក់ព្រះម្ចាស់ ទ្រង់ធ្វើឲ្យខ្ញុំរីករាយ ។**

១- សូមព្រះអម្ចាស់បំភ្លឺចិត្តទូលបង្គំ ហើយលើកលែងទោសឲ្យទូលបង្គំ ។

២- ព្រះអង្គបានផ្ដល់កម្លាំងឲ្យខ្ញុំមែន តើហេតុអ្វីក៏ខ្ញុំធ្លាក់ខ្លួនទន់ខ្សោយ ។

៣- សូមព្រះម្ចាស់បំភ្លឺចិត្តខ្ញុំឲ្យជឿ ដឹកនាំខ្ញុំដើរតម្រង់រកព្រះអង្គ ។

៤- ទូលបង្គំសូមសរសើរដល់ព្រះអង្គ ព្រះអង្គមានជោគសិរីសព្វប្រការ ។

៥- ចូរសង្ឃឹមលើព្រះម្ចាស់អស់ពីចិត្ត ព្រលឹងអើយព្រោះទ្រង់ជាព្រះសង្គ្រោះ ។

៦- កោតសរសើរព្រះបិតាព្រះបុត្រា ព្រះវិញ្ញាណជាដរាបតរៀងទៅ ។

## ៩- ផែនដីទាំងមូលអើយ

(ដកស្រង់ពីទំនុកតម្កើងលេខ ៣៣(៣២))

**បន្ទរ- ផែនដីទាំងមូលអើយ ចូរអបអរហើយសរសើរ ព្រះម្ចាស់គ្មានអ្វីស្មើ ច្រៀងបទថ្មីថ្វាយព្រះអង្គ អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា ។**

១- ចូរច្រៀងទំនុកថ្មី ទាំងតន្ត្រីកុំជិនណាយ
សូរសៀងពិរោះក្រៃ ពេលសប្បាយអបអរទ្រង់ ។

២- ដ្បិតព្រះជាអម្ចាស់ បន្ទូលប្បាស់ពិតទៀងត្រង់
ព្រះអង្គតែងផ្ចិតផ្ចង់ ហើយតម្រង់តាមសន្យា ។

៣- ព្រះអង្គសព្វព្រះហឫទ័យ នឹងសេចក្ដីពិតសត្យា
សុចរិតគ្រប់ប្រការ ហើយរក្សាយុត្តិធម៌ ។

៤- ផែនដីទាំងមូលថ្លែង ខំសម្ដែងដោយអំណរ
ពីហឫទ័យបវរ ករុណាល្អព្រះជាម្ចាស់ ។

៥- ផ្ទៃមេឃហ្វូងតារា កើតដោយសារបន្ទូលច្បាស់
ដោយបញ្ជារបស់ ព្រះជាអម្ចាស់នៃយើង ។

៦- ព្រះអង្គបានធ្វើឲ្យ សមុទ្រថយផ្ដុំគ្នាឡើង
រួចទ្រង់ក៏បង្ខាំង សមុទ្រគាំងមួយកន្លែង ។

៧- សូមឲ្យមនុស្សទាំងអស់ ដែលនៅរស់កោតស្ញប់ស្ញែង
ព្រះមានឫទ្ធិក្រៃលែង គួរស្ញប់ស្ញែងកោតព្រះអង្គ ។

៨- ដ្បិតពេលមានបន្ទូល អ្វីមកមូលមិនរេរង់
តាមមានឫទ្ធិក្រៃលែង គួរស្ញប់ស្ញែងកោតព្រះអង្គ ។

៩- យើងខ្ញុំសែនរីករាយ ចិត្តសប្បាយអរពេកក្រៃ
សូមបង្គាប់ព្រះអង្គ សព្វអ្វីផងមានទាំងអស់ ។

## ១០- ពេលសូរិយាលន់លិច

១- នៅវេលាដែលសូរិយាលន់លិច យើងខ្ញុំទាំងឡាយរួមគ្នានៅទីនេះ
ដើម្បីសូមព្រះជាម្ចាស់យាងមក រក្សាដោយព្រះហឫទ័យប្រណីមេត្តា ។
២- យើងខ្ញុំសូមថ្វាយឆ្ពោះព្រះជាម្ចាស់ នូវការងារដែលយើងខ្ញុំធ្វើថ្ងៃនេះ
បើយើងខ្ញុំប្រព្រឹត្តខុសនឹងព្រះអង្គ សូមទ្រង់មេត្តាលើកលែងទោសឲ្យយើងខ្ញុំ ។
៣- យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានរក្សាយើងខ្ញុំក្នុងថ្ងៃនេះ
សូមការពារយើងខ្ញុំក្នុងរាត្រីនេះ សូមឲ្យយើងខ្ញុំបានឈ្នះកិច្ចកលអារក្ស ។

## ១១- ព្រះគ្រីស្តជាទីសង្ឃឹម

**បន្ទរ- ព្រះគ្រីស្តជាទីសង្ឃឹម ជាអង្គគាំទ្រនៃជីវិតខ្ញុំ ។**

១- ទូលបង្គំខ្ញុំ ទៅដល់អាសនៈ ដោយចិត្តរីករាយ
សូមវិនិច្ឆ័យ តាមសប្បុរសភាព ឱ ! ព្រះអង្គអើយ ។
២- សូមថ្វាយចិន្តា និងជីវភាព សូមទ្រង់ជម្រះ
ឲ្យជ្រះសៅហ្មង ដើម្បីគាប់គួរ រួមថ្វាយបូជា ។
៣- នេះខ្ញុំសង្ឃឹម ជឿជាក់ស្រឡាញ់ បម្រើព្រះអង្គ
អស់មួយជីវិត តបស្នងសងគុណ អស់កល្បជានិច្ច ។

## ១២- មនុស្សលើផែនដី

(ដកស្រង់ពីទំនុកតម្កើងលេខ ៩៦)

**បន្ទរ- មនុស្សលើផែនដី ទាំងប្រុសទាំងស្រី ចូរអបអរឡើង**
**តម្កើងព្រះម្ចាស់ ជាព្រះថ្កុំថ្កើង ព្រះម្ចាស់នៃយើង ។**

១- ចូរច្រៀងបទថ្មីថ្វាយ ព្រះម្ចាស់ថ្លៃកុំឈរឈប់
មនុស្សនៅលើពិភព ច្រៀងកុំឈប់ថ្វាយព្រះអង្គ ។

២- ចូរច្រៀងថ្វាយព្រះម្ចាស់ តម្កើងព្រះនាមត្រចង់
ប្រកាសរាល់ថ្ងៃផង ពីបំណងដ៏ថ្លៃថ្លា ។

៣- ចូរប្រកាសនៅក្នុង ចំណោមក្រុមជាតិដទៃ
នូវរុងរឿងសិរី ព្រះហស្តថ្លៃដ៏អស្ចារ្យ ។

៤- ដ្បិតព្រះម្ចាស់ឧត្តម យើងត្រូវខំសរសើរថា
អស់ពីដួងចិន្តា ព្រះក្សត្រាប្រសើរខ្ពស់ ។

៥- ប្រជាទាំងឡាយអើយ កុំកន្តើយចូរតម្រង់
លើកតម្កើងព្រះអង្គ ថ្លៃឥតហ្មងពីឫទ្ធា ។

៦- លើកតម្កើងសិរី រុងរឿងជ័យព្រះនាមា
យកតង្វាយគ្រប់គ្នា ទៅព្រះវិហារថ្វាយក្សត្រា ។

៧- សូមឲ្យអស់ផ្ទៃមេឃ ផែនដីស្រែកកុំសំចៃ
សមុទ្រមានទឹកប្រៃ និងអ្វីៗមានសង្ឃឹម ។

៨- សូមឲ្យស្រែចម្ការ អ្វីសព្វសារអរញញឹម
ឲ្យដើមឈើរេរាំ លោតទន្ទ្រាំមុខព្រះម្ចាស់ ។

៩- ដ្បិតព្រះអង្គយាងមក វិនិច្ឆ័យរកយុត្តិធម៌ណាស់
កាត់ក្តីប្រជាច្បាស់ គ្មានក្រឡាស់ដោយទៀងត្រង់ ។

# ១៣- យើងទៅដំណាក់ព្រះអង្គ

**បន្ទរ- យើងសែនសប្បាយ យាត្រាឆ្ងាយទៅព្រះដំណាក់**
**ទាំងយើងច្រៀងបទថ្មី សរសើរព្រះម្ចាស់អាលេលូយ៉ា ។**

១- មហាជនគ្រប់ប្រទេស ចូរអ្នកអបអរសាទរ
ហើយថ្វាយស័ព្ទវាចា ថ្វាយព្រះអម្ចាស់របស់យើង ។

២- ចូរបម្រើព្រះអង្គ មានចិត្តត្រេកអរសប្បាយឡើង
ចូរទៅរកទាំងច្រៀង បទសប្បាយថ្វាយជរាប ។

៣- ចូរទទួលស្គាល់ចុះ ព្រះអង្គប្រោសសន្ដោសជាប់
ព្រះអង្គជាទីគាប់ ទ្រង់បានបង្កើតយើងមក ។

៤- យើងជាស្នាព្រះហស្ត របស់ព្រះថ្លៃពន្លក
ជាប្រជាជនសុខ ដែលព្រះអង្គដែណែនាំ ។

៥- ចូរចូលក្នុងព្រះវិហារ ព្រះពន្លាជាព្រះដំណាក់
ព្រះអង្គស័ក្តិសមណាស់ ចូលទៅថ្លែងអរព្រះគុណ ។

៦- ព្រះជាម្ចាស់ទ្រង់មាន ព្រះហឫទ័យមេត្តា
សប្បុរសករុណា ដែលស្ថិតនៅជាប់អស់កល្ប ។

## ១៤- យើងខ្ញុំទាំងអស់គ្នាអររីករាយ

១- យើងខ្ញុំទាំងអស់គ្នាអររីករាយ ដោយបានជួបជុំគ្នានៅទីនេះ
ដើម្បីបន្លឺសូរស័ព្ទចម្រៀង ច្រៀងថ្វាយព្រះម្ចាស់អស់ពីឱរា ។

២- យើងខ្ញុំសូមជឿជាក់ប្រាកដមែន ព្រះអង្គគង់សណ្ឋិតនៅទីនេះ
យើងខ្ញុំសូមលើកហត្ថឡើងវន្ទា ក្រាបថ្វាយបង្គំព្រះមហាក្សត្រ ។

៣- យើងខ្ញុំសូមស្រឡាញ់ព្រះអម្ចាស់ ដែលបានផ្ដល់ជីវាឲ្យយើងខ្ញុំ
ហេតុនេះយើងខ្ញុំសូមធ្វើសច្ចា ស្រឡាញ់ព្រះម្ចាស់ស្រឡាញ់បងប្អូន ។

៤- យើងខ្ញុំសូមសង្ឃឹមលើព្រះអង្គ សង្ឃឹមថាព្រះអង្គរំដោះទុក្ខ
សង្ឃឹមបានចូលស្ថានបរមសុខ សប្បាយរីករាយអស់កល្បជានិច្ច ។



# ១៥- យើងអរសប្បាយ

១- **ស.** ឱ ! ព្រះអម្ចាស់អើយ យើងអរសប្បាយ
**ប.** ឱ ! ព្រះអម្ចាស់អើយ យើងអរសប្បាយ
**ស.** ដោយបានជួបជុំនៅក្នុងទីនេះ **ប.** ដោយបានជួបជុំនៅក្នុងទីនេះ
**រួម:** ហើយរួបរួមគ្នា ក្រោមម្លប់បារមីរបស់ព្រះអង្គ ។

២- **ស.** ព្រះអង្គណែនាំផ្លូវជីវិតយើង **ប.**ព្រះអង្គណែនាំផ្លូវជីវិតយើង
**ស.** នៅក្នុងលោកនេះយើងខ្ញុំត្រូវការ **ប.**នៅក្នុងលោកនេះយើងខ្ញុំត្រូវការ
**រួម:** ព្រះហឫទ័យអាណិតមេត្តារបស់ព្រះអង្គ ។

៣- **ស.** ព្រះអង្គទ្រង់ជ្រាបពេលមានទុក្ខព្រួយ
**ប.** ព្រះអង្គទ្រង់ជ្រាបពេលមានទុក្ខព្រួយ
**ស.** ព្រះអង្គជួយយើងឲ្យមានសង្ឃឹម **ប.** ព្រះអង្គជួយយើងឲ្យមានសង្ឃឹម
**រួម:** ហើយគង់ជិតយើងដោយក្តីស្រឡាញ់របស់ព្រះអង្គ ។

៤- **ស.** ថ្ងៃនេះជាថ្ងៃរបស់ព្រះអង្គ **ប.** ថ្ងៃនេះជាថ្ងៃរបស់ព្រះអង្គ
**ស.** យើងទាំងអស់គ្នាប្រុងស្តាប់ព្រះបន្ទូល **ប.**យើងទាំងអស់គ្នាប្រុងស្តាប់ព្រះបន្ទូល
**រួម:** ដើម្បីរស់នៅក្នុងក្តីស្រឡាញ់របស់ព្រះអង្គ ។

៥- **ស.** ឱ ! ព្រះអង្គអើយ យើងនឹងរួមថ្វាយ
**ប.** ឱ ! ព្រះអង្គអើយ យើងនឹងរួមថ្វាយ
**ស.** ថ្វាយនំនឹងស្រាដែលទ្រង់ប្រទាន **ប.**ថ្វាយនំនឹងស្រាដែលទ្រង់ប្រទាន
**រួម:** ឲ្យយើងរួបរួមក្នុងក្តីស្រឡាញ់របស់ព្រះអង្គ ។

## ១៦- រស់ជាមួយគ្នា

១- រស់ជាមួយគ្នាដូចបងប្អូនគ្នា ជាការប្រពៃថ្លៃថ្លាឧត្តម
ប្រៀបដូចសួនច្បារពេញដោយបុប្ផា មានទាំងចម្ប៉ាមានទាំងចំប៉ី ។
២- មានទាំងផ្កាម្លិះមានទាំងណាគ្រី ក្រអូបពេកក្រៃនាអរុណរះ
ប្រៀបដូចសន្សើមនៅព្រឹកព្រលឹម ធ្លាក់លើវាលស្រែលើច្បារដំណាំ ។
៣- ហ្នឹងហើយតំបន់ដែលព្រះបវរ ផ្តល់នូវព្រះពរជីវិតអនន្ត
សូមថ្វាយពរជ័យដល់ព្រះត្រៃឯក ដែលគង់ជានិច្ចជរាបរៀងទៅ ។

## ១៧- លើកតម្កើងព្រះបន្ទូល

១- បន្ទូលព្រះអង្គ ពន្លឺថ្លាយង់ បំភ្លឺខ្ញុំម្ចាស់ ឲ្យខ្ញុំឃើញច្បាស់
មាគ៌ាត្រចះ ត្រចង់ឥតខ្វះ របស់ព្រះអង្គ ។
២- បន្ទូលព្រះអង្គ ដំបូន្មានត្រង់ វិសេសល្អណាស់ ទូលបង្គំខ្ញុំ
ខំរៀនចាំច្បាស់ បន្ទូលថ្លៃថ្លា របស់ព្រះអង្គ ។
៣- បន្ទូលព្រះអង្គ ស្រង់ផុតលិចលង់ ជីវិតខ្ញុំម្ចាស់ ទូលបង្គំខ្ញុំ
សង្ឃឹមជឿជាក់ លើបន្ទូលព្រះ ជានិច្ចនិរន្ត ។
៤- បន្ទូលព្រះអង្គ ដំបូន្មានត្រង់ វិសេសល្អណាស់ ទូលបង្គំខ្ញុំ
ខំរៀនចាំច្បាស់ បន្ទូលថ្លៃថ្លា របស់ព្រះអង្គ ។
៥- បន្ទូលព្រះអង្គ សន្យាឧត្តម សម្រេចហើយណា ទូលបង្គំខ្ញុំ
ស្រឡាញ់ស្មោះស្ម័គ្រ បន្ទូលព្រះម្ចាស់ នៅក្នុងហត្ថា ។
៦- បន្ទូលព្រះអង្គ គោលការណ៍នៃទ្រង់ ជាសេចក្តីពិត ព្រះអង្គសម្រេច
ដោយសុចរិត គង់វង្សស្ថេរស្ថិត រហូតតទៅ ។

## ១៨- វិញ្ញាណព្រះម្ចាស់

១- វិញ្ញាណព្រះម្ចាស់ បានជ្រើសតាំងខ្ញុំ ឲ្យលាតសន្ធឹង ព្រះរាជ្យព្រះអង្គ
ទ្រង់បានចាត់ខ្ញុំ ឲ្យប្រកាសផ្សាយ នូវដំណឹងល្អ ដល់ជនក្រីក្រ ។

**បន្ទរ-ដោយសារហេតុនេះ ឱ! ព្រះបវរ ខ្ញុំសែនត្រេកអរ ក្នុងព្រះជាម្ចាស់ ។**

២- ព្រះដ៏ខ្ពង់ខ្ពស់ ទ្រង់សម្រាំងខ្ញុំ ដើម្បីបំភ្លឺ ជនដែលវង្វេង
មនុស្សក្នុងលោកា ពេញដោយទុក្ខសោក ទ្រង់ចាត់ខ្ញុំមក សម្រាលទុក្ខគេ ។

៣- ព្រះម្ចាស់បានជ្រើស ក្នុងព្រះវិញ្ញាណ ព្រះអង្គប្រទាន ឲ្យបម្រើទ្រង់
មនុស្សក្រខ្សត់ តម្អូញទុក្ខព្រួយ ទ្រង់ឲ្យខ្ញុំជួយ រំលែកទុក្ខគេ ។

៤- ខ្ញុំជាសាវ័ក នៃព្រះជាម្ចាស់ សូមស្ម័គ្រប្រកាស ផ្សាយដំណឹងល្អ
សន្តតិតខំ បង្ហាញមាគ៌ា ឲ្យមនុស្សគ្រប់គ្នា យល់ការសង្គ្រោះ ។

៥- ព្រះដ៏សប្បុរស សព្វព្រះហឫទ័យ ឲ្យខ្ញុំទាសា បម្រើព្រះអង្គ
ខ្ញុំសូមសច្ចា ថានឹងប្រកាស ដោគជ័យត្រចះ ព្រះអង្គតទៅ ។

## ១៩- សូមក្រាបបង្គំព្រះជាម្ចាស់

១- សូមក្រាបបង្គំព្រះម្ចាស់ ជាព្រះបិតា ដ៏មានឫទ្ធានុភាព
ទ្រង់បានបង្កើតមេឃដី ប្រទានជីវី ឲ្យសព្វសត្វលោកទាំងឡាយ ។
**បន្ទរ- យើងខ្ញុំសូមក្រាបបង្គំព្រះអង្គ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។**

២- កោតសរសើរព្រះយេស៊ូ ជាព្រះបន្ទូល នៃព្រះជាម្ចាស់ថ្លៃថ្លា
ព្រះអង្គយាងមករួមរស់ ព្រមទាំងប្រោសលោះ យើងរស់ដោយជីវិតថ្មី ។
**បន្ទរ- យើងខ្ញុំសូមកោតសរសើរព្រះអង្គ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។**

៣- សូមលើកតម្កើងព្រះវិញ្ញាណ ទ្រង់ជាជង្ហើម ផ្តល់ជីវិតនៃព្រះម្ចាស់
ទ្រង់បានយាត្រាយាងមក ប្រមូលមនុស្សលោក ឲ្យទៅជាផ្លូងមួយ ។
**បន្ទរ- យើងខ្ញុំសូមលើកតម្កើងព្រះអង្គ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។**

៤- កោតសរសើរព្រះត្រៃឯក ព្រះវរបិតា ព្រះបុត្រាព្រះវិញ្ញាណ
ដែលព្រះអង្គទ្រង់គង់នៅ តាំងតែពីដើម ដរាបរហូតរៀងទៅ ។
**បន្ទរ- យើងខ្ញុំសូមក្រាបបង្គំព្រះអង្គ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។**

## ២០- សូរិយាចែងរស្មីភ្លឺថ្លា

១- សូរិយាចែងរស្មីភ្លឺថ្លា បំភ្លឺលោកាសែនស្រស់ញញឹម
យើងខ្ញុំសង្ឃឹមពន្លឺបរមសុខ ។

២- ឱ! ព្រះជាម្ចាស់ប្រសើរថ្លៃថ្លា បំភ្លឺដំណើរឲ្យយើងគ្រប់គ្នា
ដល់កោះដល់ត្រើយបានសុខក្សេមក្សាន្ត ។

៣- សូមក្រាបបង្គំឆ្ពោះព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណវិសុទ្ធ
ពោរពេញញាណឥតរលត់ឡើយ ។

## ២១- អបអរសាទរខួបទី ៤៥០ ឆ្នាំ

### លំនាំបទ “មនុស្សលើផែនដី”

**បន្ទរ- សូមអរព្រះគុណ ព្រះម្ចាស់ពេកពន់ ទ្រង់បានប្រទាន**
**ឲ្យយើងខ្ញុំមាន អំណរថ្លៃថ្លា បានស្គាល់ព្រះម្ចាស់ ។**

១- យើងសូមអបអរសាទរ ខួប ៤៥០ ឆ្នាំ
វត្តមានព្រះសហគមន៍ លើទឹកដីកម្ពុជា ។

២- សូមអរព្រះគុណព្រះម្ចាស់ ទ្រង់បាត់សាសនទូតមក
បង្ហាញឲ្យអ្នកស្វែងរក ភក្ដិព្រះម្ចាស់ជាបិតា ។

៣- សូមអរព្រះគុណព្រះម្ចាស់ ទ្រង់បានរក្សាយើងខ្ញុំ
ព្រមទាំងបានប្រមូលផ្ដុំ យើងខ្ញុំក្នុងក្ដីស្រឡាញ់ ។

៤- សូមទ្រង់មេត្តាប្រទាន ព្រះវិញ្ញាណដ៏វិសុទ្ធ
មកគង់សណ្ឋិតក្នុងចិត្ត គ្រីស្តបរិស័ទគ្រប់គ្នា ។

៥- សូមឲ្យយើងចេះកសាង ក្ដីសុខសាន្តក្ដីយុត្តិធម៌
ឲ្យចេះស្រឡាញ់យ៉ាងស្មោះ ចេះបម្រើអ្នកដទៃ ។

៦- សូមឲ្យយើងក្លាយជាពន្លឺ បំភ្លឺក្នុងភាពងងឹត
ផ្ដល់ដល់អស់អ្នកឆ្ងាយជិត សេចក្ដីពិតដ៏ត្រចង់ ។

## ២២- អស់មួយជីវិត

**បន្ទរ- អស់មួយជីវិត ខ្ញុំច្រៀងសរសើរ ព្រះយេស៊ូគ្រីស្ត**
**ឱ ! ព្រះម្ចាស់អើយ មួយជីវិតខ្ញុំ ខ្ញុំលើកតម្កើងតែព្រះនាមនេះ ។**

១- ព្រះម្ចាស់ផ្តល់ឲ្យ នូវអំណោយទាន ជារៀងរាល់ថ្ងៃ
ហើយព្រះអង្គបាន អត់ទោសឲ្យខ្ញុំ ដោយហឫទ័យស្មោះ ។

២- សូមរាជ្យព្រះអង្គ មកលើផែនដី ដូចនៅលើមេឃ
សូមឲ្យមនុស្សលោក ចេះស្រឡាញ់គ្នា ដូចជាបងប្អូន ។

៣- សូមឲ្យយើងខ្ញុំ បាកក្តីស្រេកឃ្លាន និងភ្លើងសង្គ្រាម
សូមឲ្យផែនដី បាកផុតពីក្តី អាក្រក់ទាំងឡាយ ។

## ២៣- ឱ ! ជនទាំងឡាយ

**(ទំនុកតម្កើងលេខ ១០០)**

១- ឱ ! ជនទាំងឡាយ នៅគ្រប់បូរី ចូរអរសាទរ បម្រើព្រះអង្គ
ដោយចិត្តស្មោះសរ ចូរខំស្វែងរក ទ្រង់ដោយសោមនស្ស ។

២- ចូរយល់ឲ្យច្បាស់ ថាព្រះជាម្ចាស់ ប្រសើរខ្ពង់ខ្ពស់ ហើយទ្រង់បង្កើត
ពួកយើងទាំងអស់ ជាស្នាព្រះហស្ត របស់ព្រះអង្គ ។

៣- យើងខ្ញុំទៅកាន់ ព្រះដំណាក់ឋាន ដ៏ល្អត្រចង់ ហើយចូលទៅក្នុង
វិហារព្រះអង្គ ទាំងត្រេកអរផង និងកោតបេស្តា ។

៤- ព្រះម្ចាស់លោកីយ៍ ទ្រង់មានព្រះទ័យ សប្បុរសអស្ចារ្យ ទ្រង់មានហឫទ័យ
ប្រណីមេត្តា ហើយព្រះចិន្តា ស្មោះត្រង់កន្លង ។

៥- សូមថ្លែងជ័យា នៃព្រះបិតា និងបុត្រាផង ទាំងព្រះវិញ្ញាណ
ជាព្រះតែឯក ថ្កើងថ្កានឥតហ្មង ដែលគង់ជានិច្ច ។

## ២៤- ឱ ! ព្រះគ្រីស្តអើយ

១- ឱ! ព្រះគ្រីស្តអើយ អារុណរះឡើងហើយ យើងរួបរួមគ្នា
ក្រាបថ្វាយបង្គំ ដល់ព្រះថ្លៃឧត្តម ដោយចិត្តជ្រះថ្លា
យើងសប្បាយណាស់ ដោយបានជួបព្រះម្ចាស់ សារជាថ្មីទៀត ។
២- យើងថ្លែងអំណរគុណ នូវចិន្តាស្មោះសរ និងចិត្តភក្តី
ដែលទ្រង់ប្រទាន ឲ្យយើងសុខក្សេមក្សាន្ត អស់មួយរាត្រី
ឥឡូវយើងភ្ញាក់ ចិត្តយើងនៅស្មោះស្ម័គ្រ ចូលគាល់បម្រើ ។
៣- យើងសូមរួបរួមថ្វាយ ទាំងព្រួយទាំងសប្បាយ ដល់ព្រះម្ចាស់ថ្លៃ
សូមជួយយើងខ្ញុំ ឲ្យបាត់ក្តីបារម្ភ ទោះទាំងយប់ថ្ងៃ
សូមជួយរក្សា នៅពេលធ្វើកិច្ចការ ឲ្យបានសម្រេច ។
៤- សូមទ្រង់មេត្តា អាសូរដល់ចិន្តា អង្វរព្រះអង្គ
សូមក្តីសន្តោស សូមទាំងសេចក្តីស្មោះ សូមកុំបោះបង់
សូមទ្រង់មេត្រី នូវបទចម្រៀងថ្មី ដែលយើងច្រៀងថ្វាយ ។

## ២៥- ឱ ! ព្រះជាម្ចាស់

១- ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ ថ្ងៃរះឡើងហើយ សូមប្រោសប្រណី
ឲ្យខ្ញុំបានឃើញជោគសិរី យល់ព្រះហឫទ័យ ប្រោសមេត្តា ។
២- ពួកជនក្រីក្រដែលស្រេកឃ្លាន ត្រាច់ចរសុំទាន តាមមាត់ផ្លូវ
សូមជួយខ្ញុំឲ្យផ្តល់អាហារ ដោយចិត្តជ្រះថ្លា តាមធនធាន ។
៣- សូមជួយឲ្យខ្ញុំចេះគិតគូរ ចេះខំតស៊ូ ដើរតាមដាន
ទោះបីយ៉ាប់យ៉ឺនលំបាកប្រាណ លុះដល់ឈើឆ្កាង បានជោគជ័យ ។
៤- សូមជួយខ្ញុំឲ្យចេះស្តាប់ឮ សម្តីដែលឈឺ ចាប់ពេកក្រៃ
នៃអស់បងប្អូនទាំងប្រុសស្រី ដោយចិត្តភក្តី មេត្រីផង ។
៥- ពេលថ្ងៃខ្ញុំធ្វើការហត់នឿយ យប់ដល់ហើយ ចិត្តខ្ញុំប៉ង
ចូលរួមជាមួយព្រះអង្គផង នេះជាបំណង ដ៏ថ្លៃថ្លា ។

## ២៦- ឱ ! ព្រះជាម្ចាស់ សូមការពារខ្ញុំ

**បន្ទរ- ឱ ! ព្រះជាម្ចាស់ ខ្ញុំសូមព្រះអង្គការពារខ្ញុំ**
**ខ្ញុំសូមជ្រកកោន ក្រោមម្លប់បារមីព្រះអង្គ ។**

១- ខ្ញុំសូមទូលថា ព្រះអង្គជាព្រះអម្ចាស់នៃខ្ញុំ
មានតែព្រះអង្គទេ ដែលជាសុភមង្គលរបស់ខ្ញុំ
គ្រប់ពេលវេលា ព្រះអង្គគង់នៅជាមួយយើងខ្ញុំ
ខ្ញុំមិនភ្លេចស្មារតី ខ្ញុំមិនឃ្លាតឆ្ងាយពីព្រះអង្គឡើយ ។

២- ឱ ! ព្រះអង្គអើយ ទ្រង់ជាសម្បត្តិមរតកខ្ញុំ
ខ្ញុំយល់ប្រត្យក្ស ព្រះអង្គស្រឡាញ់ខ្ញុំពិតមែន
ព្រះអង្គទ្រង់សម្ដែង ឲ្យខ្ញុំបានស្គាល់ផ្លូវជីវិត
ព្រះអង្គប្រោសប្រទាន ឲ្យខ្ញុំបានឃើញព្រះភក្ត្រព្រះអង្គ ។

៣- ខ្ញុំសែនសប្បាយ ដ្បិតទ្រង់ស្រឡាញ់ខ្ញុំជានិច្ច
ព្រះអង្គត្រាស់ហៅខ្ញុំ ឲ្យរស់នៅជាមួយព្រះអង្គ
សូមលំទោនកាយ សូមថ្វាយសិរីរុងរឿងដ្បិតជោគជ័យ
ឆ្ពោះព្រះជាអម្ចាស់ ដែលទ្រង់គង់នៅជាដរាប ។

# ២៧- ឱ ! ព្រះបិតាដ៏ឧត្តមអើយ

១- ឱ ! ព្រះបិតាដ៏ឧត្តមអើយ ថ្ងៃជិតលិចហើយសូមទ្រង់មេត្តា
ណែនាំយើងខ្ញុំឲ្យខំធ្វើការ ដល់យប់កាលណានឹងបានធូរស្បើយ ។

២- សូមជួយយើងខ្ញុំឲ្យបេះកែខ្លួន កាន់ចិត្តមាំមួនកុំរលាយឡើយ
កុំឲ្យធុញទ្រាន់ក្នុងការហត់នឿយ តែខំបង្ហើយដោយក្តីឧស្សាហ៍ ។

៣- សូមជួយយើងខ្ញុំឲ្យមានចិត្តត្រង់ ជឿតែព្រះអង្គគ្រប់ពេលវេលា
បើយើងខ្ញុំភ្លេចមួយដងមួយគ្រា សូមទ្រង់មេត្តាកុំចាប់ទោសពៃរ៍ ។

៤- សូមព្រះបិតាទ្រង់ប្រោសប្រទាន ឲ្យអ្នកស្រែកឃ្លានបានភោជន៍ចំណី
បានឆ្អែតគ្រប់គ្នាជាប្រក្រតី បានសុខសួស្តីសិរីមង្គល ។



# ២៨- ខ្ញុំស្រឡាញ់ដំណាក់ព្រះជាម្ចាស់ណាស់

(ដកស្រង់ពីទំនុកតម្កើងលេខ ៨៤)

**បន្ទរ- អុំះឱ! ព្រះជាអម្ចាស់ ខ្ញុំស្រឡាញ់ណាស់ ព្រះដំណាក់ដ៏ថ្លៃថ្លា**
**ខ្ញុំអន្ទើងអន្ទះសា ចិត្តខ្ញុំប្រាថ្នាចង់ ចូលវិហារព្រះអង្គ ។**

១- ឱ! ព្រះម្ចាស់ពិភពលោកអើយ! សូម្បីចាបហើរត្រចៀកកាំ
ក៏រកទីធ្វើសំបុកបាន ទុកដាក់កូនចៅជិតអាសនៈ ។

២- មានសុភមង្គលហើយណា អស់អ្នកណារស់នៅក្នុងដំណាក់
គេនឹងសរសើរតម្កើងជាក់ ព្រះអង្គរហូតតរៀងទៅ ។

៣- អ្នកពឹងផ្អែកលើព្រះជាម្ចាស់ ពិតមានសុភមង្គលហើយ
គេធ្វើដំណើរឡើងដល់ត្រើយ ដំណាក់ព្រះអង្គដោយអំណរ ។

៤- ពេលគេដើរកាត់ជ្រោះរីងស្ងួត ទ្រង់ប្រែវាជាប្រភពទឹក
ភ្លៀងដើមរដូវក៏ធ្លាក់មក ជាព្រះពរលើទីនោះដែរ ។

៥- មួយថ្ងៃក្នុងវិហារព្រះអង្គ ល្អជាងមួយពាន់ឆ្នាំទីផ្សេង
ហេតុនេះខ្ញុំសម្រេចឈរនៅ មាត់ទ្វារដំណាក់ព្រះម្ចាស់ថ្លៃ ។

៦- ដ្បិតព្រះអង្គជាពន្លឺថ្ងៃ ជាខែលការពារយើងទាំងឡាយ
ព្រះអង្គសន្តោសប្រោសប្រណី ប្រទានពរជ័យគ្រប់អាត្មា ។

៧- ខ្ញុំស្រឡាញ់ព្រះជាអម្ចាស់ ដ្បិតព្រះអង្គជាធម៌មេត្តា
ព្រះអង្គទ្រង់សណ្ដាប់ខ្ញុំម្ចាស់ អស់មួយជីវាខ្ញុំអង្វរ ។

## ២៩- ចូរច្រៀងលើកតម្កើង

បន្ទរ- ចូរច្រៀងលើកតម្កើង ព្រះម្ចាស់យើងអស់ពីដួងចិត្ត
អរព្រះគុណព្រះបិតា គ្រប់កិច្ចការគ្រប់វេលា
ព្រះនាមព្រះគ្រីស្តយេស៊ូ ទូទាំងផែនដីព្រះជាម្ចាស់តែមួយ ។

១- ព្រះម្ចាស់ជាបិតា មានឫទ្ធាមានមេត្តា
ប្រទានព្រះបុត្រា ហឫទ័យប្រណីសង្គ្រោះ
ចូរយើងរួមចិត្តគំនិត ច្រៀងតម្កើងព្រះជាម្ចាស់
ប្រកាសឲ្យខ្ពង់ៗថា មានបិតាតែមួយ ។

២- ព្រះគ្រីស្តជាបុត្រា មានមេត្តាករុណា
យាងមកក្នុងលោកា សង្គ្រោះមនុស្សថ្វាយបិតា
ចូរយើងរួមចិត្តគំនិត ច្រៀងសរសើរថ្វាយព្រះគ្រីស្ត
ថ្វាយតង្វាយអរព្រះគុណ ព្រះគ្រីស្តដ៏ឧត្តម ។

៣- ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រោសគំនិតទាំងស្មារតី
ផ្តល់ប្រាជ្ញាថ្លាថ្លៃ ឲ្យស្រីប្រុសគ្រប់ៗគ្នា
ចូរយើងប្រុសស្រីគ្រប់វ័យ ស្មារតីប្រគុំភ្លេងថ្វាយ
ថ្វាយព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គអស្ចារ្យក្រៃ ។

## ៣០- ជយោ ជយោ និទានជីវិតព្រះយេស៊ូ

- ជយោ ជយោ និទានជីវិត ព្រះយេស៊ូគ្រីស្ត ក្នុងជីវិតយើង
  ជយោ ជយោ និទានជីវិត ព្រះយេស៊ូគ្រីស្ត ។
- ជយោ ជយោ ព្រះយេស៊ូគ្រីស្ត ទ្រង់មានព្រះជន្ម រស់ឡើងវិញមែន
  ជីវិតរុងរឿង នៃព្រះបិតា អាលេលូយ៉ា ។
- ជយោ ជយោ យើងជឿព្រះជាម្ចាស់ ជាព្រះបិតា ជាព្រះបុត្រា
  ជាព្រះវិញ្ញាណ ជាព្រះតែមួយ ដែលស្រឡាញ់យើង ។
- ជយោ ជយោ ព្រះរាជវង្ស ព្រះបាទដាវីឌ សូមព្រះជាម្ចាស់
  ទ្រង់ប្រទានពរ ដល់ព្រះយេស៊ូគ្រីស្ត ដែលទ្រង់យាងមក ។

## ៣១- ដូចភ្នំព័ទ្ធជុំយេរូសាឡឹម...

### ដកស្រង់ពីទំនុកតម្កើង ១២៥(១២៤)

**បន្ទរ-ដូចភ្នំព័ទ្ធជុំ ទីក្រុងយេរូ សាឡឹមយ៉ាងណា**
**ឯព្រះជាម្ចាស់ គង់ជុំឥតប្រែ រាស្ត្រយ៉ាងនោះដែរ**
**នៅពេលឥឡូវ រហូតតទៅ ។**

១- អ្នកផ្ញើជីវិត លើព្រះម្ចាស់ពិត អ្នកនោះប្រៀបបាន នឹងភ្នំស៊ីយ៉ូន
  ស្រស់បស់កុំជាន ស្ថិតស្ថេរសុខសាន្ត រហូតតទៅ ។

២- ឱ ! ព្រះជាម្ចាស់ សូមសម្តែងព្រះ ហឫទ័យសប្បុរស ទៅលើអស់អ្នក
  មានចិត្តត្រង់ស្មោះ ល្អឥតមានទាស់ ជាមនុស្សទៀងត្រង់ ។

៣- ឯអ្នកបូលបិត្ត ដើរផ្លូវទុច្ចរិត វៀចវេរសៅហ្មង សូមព្រះអង្គទ្រង់
  ដេញគេទៅផង ឲ្យទៅរស់ក្នុង ហ្វូងមនុស្សគម្រក់ ។

៤- សូមទ្រង់ប្រទាន អ៊ីស្រាអែលបាន ផុតគ្រោះអាក្រក់ រួចពីមនុស្សបាប
  ភូតភរកុហក ផុតមនុស្សគម្រក់ សុខសាន្តតទៅ ។

## ៣២- ព្រះជាម្ចាស់ទទួលយើងក្នុងដំណាក់ព្រះអង្គ

បន្ទរ- ព្រះជាម្ចាស់ទ្រង់ទទួលយើង ក្នុងដំណាក់ថ្កើងថ្កានព្រះអង្គ
ព្រះអង្គក៏អញ្ជើញយើងផង ឲ្យចូលរួមពិធីជប់លៀង
នេះហើយជាថ្ងៃសែនសប្បាយ អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា

១- ខ្ញុំមានចិត្តអំណរ សប្បាយអរពេលឮថា
ចូរយើងចរយាត្រាឡើង ដំណាក់ព្រះម្ចាស់យើង ។

២- យេរូសាឡឹមអើយ ចូររីករាយសប្បាយឡើង
ព្រះជាម្ចាស់ជ្រើសរើសអ្នក ទ្រង់គង់នៅក្នុងអ្នកហើយ ។

៣- ចូរតម្កើងព្រះម្ចាស់ ព្រះអង្គសប្បុរសណាស់
ដ្បិតទ្រង់មានមេត្តា ករុណាអស់កប្បកល្ប ។

៤- ចូរបរិភោគអាហារ ដែលព្រះជាម្ចាស់បានរៀបចំ
ឲ្យកូនចៅព្រះអង្គ អាហារដែលផ្ដល់ជីវិត ។

៥- ប្រសិនបើអ្នកស្គាល់ អំណោយទានព្រះជាម្ចាស់
ជឿលើទ្រង់ស្រឡាញ់ អ្នកនឹងមិនខ្លាចអ្វីឡើយ ។

៦- សូមព្រះគ្រីស្ដប្រមូល ឲ្យយើងចូលជាធ្លុងមួយ
យើងបានបរិភោគ អាហារតែមួយរួមគ្នា ។

## ៣៣- យើងរួមគ្នាបម្រើបងប្អូន

**ស)-** ជាមួយព្រះគ្រីស្តអម្ចាស់ យើងរួមគ្នាដើរចូលក្នុងជីវិតថ្លៃថ្លា
យកតាមគ្រប់ទិសទិសា មេត្តាករុណាស្មារតី នៃអ្នកបម្រើវាចារ
កិច្ចការចលនារបស់យើង បម្រើបងប្អូន ។

**ប)-** បម្រើដោយចិត្តស្មោះស្ម័គ្រ ដោយចិត្តជ្រះថ្លា ដោយមិនទាមទារគុណអ្វី
បម្រើដោយចិត្តលះបង់ ដោយចិត្តទូលាយ តស៊ូសព្វគ្រប់បែបយ៉ាង
បម្រើដោយចិត្តស្រឡាញ់ ក្នុងអង្គព្រះគ្រីស្ត ជាមួយបងប្អូន ។

**បន្ទរ- (រួម) គ្រប់ពេលវេលា គ្រប់ទីកន្លែង ស្មារតីមេត្តា ស្មារតីបម្រើ**
**បំភ្លឺផ្លូវ យើងឲ្យលុបហិង្សា ប្រណែនឈ្នានីស ។**
**ក្នុងក្តីស្រឡាញ់ យើងរួបរួមគ្នា ជាធ្លុងតែមួយ**
**កសាងសន្តិភាព លុបបំបាត់ នូវរនាំងបែងចែករវាងជាតិសាសន៍ ។**

## ៣៤- សូមអញ្ជើញមក...

១- សូមអញ្ជើញមករស់ក្នុងពន្លឺ ចែងចាំងបំភ្លឺដោយក្តីអំណរ
ដោយក្តីសប្បុរសស្រឡាញ់បវរ នៃព្រះជាម្ចាស់ដ៏ថ្លាថ្លៃ ។

**បន្ទរ- ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យកសាងយុត្តិធម៌**
**ឲ្យស្រឡាញ់ដោយចិត្តស្មោះសរ ឲ្យបម្រើអ្នកដទៃ**
**ឲ្យដើរក្នុងស្មារតី រាបសាមុខព្រះជាម្ចាស់ ។**

២- សូមអញ្ជើញមកបើកដួងចិន្តា បង្ហាញមេត្តាដល់អ្នកទន់ខ្សោយ
ផ្តល់ក្តីសង្ឃឹមដល់អ្នកអភ័ព្វ បំបាត់ក្តីស្អប់និងភាពងងឹត ។

៣- យើងត្រូវបានត្រាស់ហៅឲ្យក្លាយទៅ ជាពន្លឺនៅក្នុងព្រះរាជ្យព្រះ
ត្រាស់ហៅឲ្យរស់ក្នុងសេរីភាព ក្នុងទីក្រុងនៃព្រះជាអម្ចាស់ ។

៤- ចូរច្រៀងបទថ្មីនៅថ្ងៃដែលមនុស្ស បានរួបរួមគ្នាជាធ្លុងតែមួយ
ថ្ងៃដែលព្រះជាម្ចាស់ទ្រង់គ្រងរាជ្យ យើងដើររួមគ្នាក្នុងក្តីស្រឡាញ់ ។

# ៣៥- ឱ ! ព្រះជាម្ចាស់ទ្រង់ព្រះនាមល្បី

## (ទំនុកតម្កើងលេខ ៨)

១- ឱ ! ព្រះជាម្ចាស់ទ្រង់ព្រះនាមល្បី មនុស្សក្នុងលោកីយ៍កោតសរសើរទ្រង់
ក្មេងទាំងប្រុសស្រីច្រៀងថ្វាយព្រះអង្គ ថ្វាយភាពត្រចង់រុងរឿងចិញ្ចាច ។

២-ព្រះអង្គប្រៀបដូចកំពែងការពារ ឲ្យផុតពីមារសត្រូវកំណាច
ទ្រង់ជួយឲ្យឈ្នះពួកមនុស្សកោងកាច ដោយព្រះអំណាចស្រឡាញ់អាណិត ។

៣-កាលយើងពិនិត្យមើលផ្ទៃមេឃា មើលដួងចន្ទ្រា និងផ្កាយឆ្ងាយជិត
តើមនុស្សយ៉ាងណាទើបទ្រង់ស្នេហ៍ស្និទ្ធ ហើយទ្រង់អាណិត និងថែរក្សា ។

៤- ទ្រង់លើកតម្កើងមនុស្សឲ្យខ្ពង់ខ្ពស់ ប្រទានកិត្តិយស និងជោគជ័យា
ទ្រង់តាំងឲ្យមនុស្សមានភ័ព្វវាសនា ជាអ្នករក្សាសព្វសត្វទាំងឡាយ ។

៥- ទាំងហ្វូងសត្វស្រុកសត្វព្រៃទាំងអស់ ជាស្នាព្រះហស្តនៃព្រះពណ្ណរាយ
ទ្រង់បានប្រគល់ឲ្យមនុស្សទាំងឡាយ ខិតខំខ្វល់ខ្វាយគ្រប់គ្រងត្រួតត្រា ។

៦- អស់ទាំងហ្វូងសត្វបក្សាបក្សី អស់ទាំងហ្វូងត្រីនៅក្នុងគង្គា
អស់ទាំងសត្វលូននិងហ្វូងសត្វវារ ស្ថិតក្រោមបញ្ជាអំណាចមនុស្សលោក ។

៧-ឱ ! ព្រះជាម្ចាស់ទ្រង់ព្រះនាមល្បី មនុស្សក្នុងលោកីយ៍កោតសរសើរទ្រង់
ក្មេងទាំងប្រុសស្រីច្រៀងថ្វាយព្រះអង្គ ថ្វាយភាពត្រចង់រុងរឿងចិញ្ចាច ។

៨-សូមកោតសរសើរឆ្ពោះព្រះបិតា ទាំងព្រះបុត្រា និងព្រះវិញ្ញាណ
ដែលគង់ស្ថិតស្ថេរប្រសើរថ្កើងថ្កាន នៅគ្រប់ទីស្ថានជរាបរៀងទៅ ។

## ៣៦- ចូររៀបចំផ្លូវថ្វាយព្រះម្ចាស់

(រដូវរង់ចាំ)

**អាលេលូយ៉ា !   អាលេលូយ៉ា !   អាលេលូយ៉ា !**

ចូររៀបចំផ្លូវថ្វាយព្រះម្ចាស់   ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ
នោះមនុស្សទាំងអស់មុខជានឹងឃើញ   ការសង្គ្រោះរបស់ព្រះម្ចាស់ ។

## ៣៧- សូមលើកតម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់

(រដូវបុណ្យណូអែល)

**អាលេលូយ៉ា!   អាលេលូយ៉ា !   អាលេលូយ៉ា !**

សូមលើកតម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់ ដែលគង់ឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត
ហើយឲ្យមនុស្សលោកបានក្ដីសុខសាន្ត ។

## ៣៨- អាលេលូយ៉ាព្រះពន្លឺ

(រដូវបុណ្យណូអែល)

**បន្ទរ- អាលេលូយ៉ា!   អាលេលូយ៉ា!   អាលេលូយ៉ា!**

១-នៅថ្ងៃនេះ ព្រះពន្លឺបានបំភ្លឺមនុស្សលោក ប្រជាជន ទាំងឡាយនៅលើ
ភពផែនដីអើយ! សូមអញ្ជើញចូល មកក្នុងពន្លឺរបស់ព្រះជាម្ចាស់
សូមអញ្ជើញមក ក្រាបថ្វាយបង្គំព្រះជាម្ចាស់! ។

២- នៅថ្ងៃនេះ ព្រះបន្ទូលកើតជារូបរាងហើយ ប្រជាជន ទាំងឡាយអើយ
ចូរស្ដាប់ព្រះបន្ទូល សូមអញ្ជើញចូល ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមអញ្ជើញមក ស្ដាប់ព្រះបន្ទូលផ្ដល់ជីវិត ។

## ៣៩- សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត

(រជូវអប់រំពិសេស)

**បន្ទរ-សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត**
**ព្រះអង្គជាព្រះពន្លឺ (បន្ទូល-ប្រាជ្ញា)**
**នៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ ។**

ឱ ! ព្រះជាម្ចាស់ សូមព្រះមេត្តាអាណិតអាសូរកែប្រែដួងចិត្ត
គំនិតយើងខ្ញុំ...ដើម្បីទទួលព្រះសង្គ្រោះយើង ។

## ៤០- សូមលើកតម្កើងព្រះយេស៊ូ

(រដូវបុណ្យចម្លង)

**អាលេលូយ៉ា! អាលេលូយ៉ា ! អាលេលូយ៉ា !**

សូមលើកតម្កើងព្រះយេស៊ូ(**២ដង**) ដែលទ្រង់បានឈ្នះសេចក្ដីស្លាប់(**២ដង**)
ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ ។

## ៤១- អាលេលូយ៉ា ! ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!
ព្រះអម្ចាស់យាងឡើង ប្រជាជន ស្រែកជ័យឃោស អាលេលូយ៉ា! អាលេលូយ៉ា!
ព្រះអង្គយាងឡើងទៅទីដ៏ខ្ពង់ខ្ពស់បំផុត អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

## ៤២- វិញ្ញាណព្រះម្ចាស់សណ្ឋិតលើខ្ញុំ

**(បុណ្យព្រះវិញ្ញាណយាងមក)**

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

វិញ្ញាណព្រះម្ចាស់សណ្ឋិតលើខ្ញុំ ទ្រង់បានចាក់ប្រេងអភិសេកខ្ញុំ
ទ្រង់ចាត់ខ្ញុំឲ្យផ្សាយដំណឹងល្អ ផ្សាយដំណឹងល្អ ដល់ជនក្រីក្រ ។

## ៤៣- ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

នៅថ្ងៃនេះទ្វារស្ថានបរមសុខបើកហើយ អាលេលូយ៉ា! អាលេលូយ៉ា!
នៅថ្ងៃនេះព្រះនាងម៉ារីទទួលសិរីរុងរឿងពីព្រះអម្ចាស់ហើយ
អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

## ៤៤- ព្រះវិញ្ញាណយាងចុះមក

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

ឱ ! ព្រះវិញ្ញាណដ៏វិសុទ្ធ សូមយាងមក អាលេលូយ៉ា !
សូមជ្រួតជ្រាបចិត្តគំនិតអ្នកបម្រើព្រះអង្គ អាលេលូយ៉ា !
សូមប្រោសប្រទានសេចក្ដីស្រឡាញ់ឲ្យយើងខ្ញុំផង ។

## ៤៥- ព្រះនាងម៉ារីជាមាតា

ច្រៀងលើកតម្កើង ច្រៀងកោតសរសើរ ថ្វាយព្រះជាម្ចាស់
អាលេលូយ៉ា! អាលេលូយ៉ា!
ថ្ងៃនេះយើងអបអរព្រះអង្គប្រទានពរ ដល់ព្រះនាងម៉ារី មាតានៃព្រះយេស៊ូ
ថ្ងៃនេះយើងរួមគ្នា លើកតម្កើងព្រះនាមព្រះអង្គ ។

## ៤៦- អាលេលូយ៉ា! ព្រះបន្ទូលព្រះយេស៊ូ

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

បពិត្រព្រះនាងព្រហ្មចារិនីម៉ារី សូមព្រះនាងមានអំណរសប្បាយ
ព្រះអម្ចាស់គង់ជាមួយនាងព្រះអង្គប្រទានពរ ដល់នាងលើសស្ត្រីទាំងឡាយ ។

## ៤៧- ចូរកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អ

ចូរកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អ ។(**២ដង**)

## ៤៨- អាលេលូយ៉ា! ព្រះនាងទទួលព្រះបន្ទូល

**បន្ទរ-អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

១- បពិត្រព្រះនាងព្រហ្មចារិនីម៉ារី! សូមព្រះនាងមានអំណរសប្បាយ
ព្រះអម្ចាស់គង់ជាមួយនាង ព្រះអង្គប្រទានពរឲ្យព្រះនាង
លើសស្ត្រីទាំងឡាយ ។

២- ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ នាងនឹងសម្រាលបានបុត្រមួយ
ដែលគេនឹងថ្វាយព្រះនាមថា អេម៉ាន់នូអែលគឺព្រះជាម្ចាស់
គង់ជាមួយយើង ។

៣- ព្រះនាងម៉ារីទទួលព្រះបន្ទូល ហើយបានមានប្រសាសន៍តបថា៖
នាងខ្ញុំជាអ្នកបម្រើព្រះម្ចាស់ សូមឲ្យសម្រេចតាម
ព្រះហប្ញទ័យព្រះអង្គចុះ ។

## ៤៩- ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់

**អាលេលូយ៉ា អាលេលូ អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា(២ដង)**

ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងក្តីសុចរិតរបស់ព្រះអង្គជាមុនសិន
ទើបព្រះអង្គប្រទានរបស់ទាំងនោះមកថែមទៀត
ដ្បិតព្រះបិតាអ្នកជ្រាបនូវអ្វីដែលអ្នកត្រូវការ ។

## ៥០- អាលេលូយ៉ា អ្នកឈ្មោះសិលា

អាលេលូយ៉ា អាលេ អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា
អ្នកឈ្មោះសិលានៅលើផ្ទាំងសិលា នេះខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ សេចក្តី
ស្លាប់ពុំមានអំណាចលើព្រះសហគមន៍នេះបានឡើយ ។

## ៥១- ផ្ទៃមេឃ និង ផែនដី

ផ្ទៃមេឃ និងផែនដី នឹងរលាយបាត់ទៅ
តែព្រះបន្ទូលរបស់ព្រះអម្ចាស់ មិនរលាយបាត់ទេ ។
អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា ។

## ៥២- ព្រះគ្រីស្តជាពន្លឺបំភ្លឺលោកា

ព្រះគ្រីស្តជាពន្លឺបំភ្លឺលោកា ឲ្យយើងដើរតាមព្រះអង្គ ព្រះគ្រីស្តគឺជាជីវិត
ព្រះគ្រីស្តគឺជាពន្លឺ ព្រះអង្គគឺជាផ្លូវ ឲ្យយើងដើរត្រង់
ស្វែងររកអស់អ្នក ដែលគេវង្វេង អស់អ្នកដែលគេរងទុក្ខវេទនា
បង្ហាញសេចក្តីមេត្តា យើងជាបុត្រធីតា របស់ព្រះបិតាដែលស្រឡាញ់យើង ។

## ៥៣- ចូរអ្នកស្វះស្វែងរកព្រះរាជ្យ

**អាលេលូយ៉ា! អាលេលូយ៉ា ! អាលេលូយ៉ា !**

ចូរអ្នកស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់
នឹងសេចក្តីសុចរិតរបស់ព្រះអង្គជាមុនសិន
ទើបព្រះអង្គប្រទានរបស់ទាំងនោះមកថែមទៀត
ដ្បិតព្រះបិតាអ្នកជ្រាបនូវអ្វីដែលអ្នកត្រូវការ អាលេលូយ៉ា!(**៣ដង**)

## ៥៤- ច្រៀងអាលេលូយ៉ាថ្វាយព្រះអម្ចាស់

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

១-**ស**- ច្រៀងអាលេលូយ៉ាថ្វាយព្រះម្ចាស់ **ប**-ច្រៀងអាលេលូយ៉ាថ្វាយព្រះម្ចាស់
**រួម**-ច្រៀងអាលេលូយ៉ា! ច្រៀងអាលេលូយ៉ា! ច្រៀងអាលេលូយ៉ា ថ្វាយព្រះម្ចាស់!

២-**ស**- ច្រៀងអាលេលូយ៉ាកោតសរសើរ **ប**-ច្រៀងអាលេលូយ៉ាកោតសរសើរ
**រួម**-ច្រៀងអាលេលូយ៉ា! ច្រៀងអាលេលូយ៉ា! ច្រៀងអាលេលូយ៉ា កោតសរសើរ! **រួម**-ច្រៀងអាលេលូយ៉ា កោតសរសើរ!

## ៥៥- បពិត្រព្រះបិតា

(រដូវធម្មតា ប្រចាំឆ្នាំ)

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

បពិត្រព្រះបិតា ជាអម្ចាស់ស្ថានបរមសុខ ជាអម្ចាស់ផែនដី
ទូលបង្គំតម្កើងព្រះអង្គ ទ្រង់លាក់ការណ៍ទាំងនេះ មិនឲ្យអ្នកប្រាជ្ញយល់ដឹង
តែទ្រង់បានសម្តែង ឲ្យមនុស្សទន់ទាបយល់វិញ ។

## ៥៦- ព្រះអម្ចាស់មានព្រះបន្ទូល

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

១-ព្រះអម្ចាស់មានព្រះបន្ទូលថា អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់
ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាសម្រាក ។

## ៥៧- អញ្ជើញស្ដាប់ព្រះបន្ទូលព្រះអម្ចាស់

**អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា**

អញ្ជើញស្ដាប់ព្រះបន្ទូលព្រះអម្ចាស់ ហើយសូមឲ្យយើងអនុវត្តតាម ។
អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា

## ៥៨- អាលេលូយ៉ាព្រះបន្ទូលជាជីវិត

**អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា**

ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត ។

## ៥៩- អាលេលូយ៉ា យើងច្រៀងសរសើរព្រះជាអម្ចាស់

**បន្ទរ- អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា**
**យើងច្រៀងសរសើរ ព្រះជាអម្ចាស់ ។ (២ដង)**

សូមព្រះបន្ទូលព្រះអង្គ ចូលក្នុងដួងចិត្តយើង
ឲ្យយើងពោរពេញ ដោយសេចក្ដីស្រឡាញ់
យើងសូមលើកតម្កើង ព្រះបន្ទូលព្រះអង្គ
សូមព្រះអម្ចាស់ គង់នៅជាមួយយើង ។ **(បន្ទរ)**

## ៦០- អាលេលូយ៉ា

**អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា**

អ្នកណាស្តាប់ៗ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ អនុវត្តតាមៗ

អ្នកនោះហើយមានសុភមង្គលមែន

**អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា**

## ៦១- អាលេលូយ៉ា! ចូរអ្នកស្រឡាញ់ព្រះអម្ចាស់

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

ចូរអ្នកស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្ត

អស់ពីស្មារតី អស់ពីកម្លាំងកាយ ចូរអ្នកស្រឡាញ់បងប្អូនឯទៀត

ឲ្យដូចស្រឡាញ់ ស្រឡាញ់ ខ្លួនឯង ។

## ៦២- វិន័យព្រះយេស៊ូ

**ព្រះអម្ចាស់មានបន្ទូលថា៖**

"ខ្ញុំប្រទានក្រឹត្យវិន័យថ្មី ឲ្យអ្នករាល់គ្នា គឺអ្នករាល់គ្នា ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" ។

## ៦៣- អាលេលូយ៉ា ! ព្រះបន្ទូលព្រះអម្ចាស់

**អាលេលូយ៉ា! អាលេលូយ៉ា ! អាលេលូយ៉ា !**

ឱ ! ព្រះអម្ចាស់អើយ !

ព្រះបន្ទូលព្រះអង្គ ជាពន្លឺ អាលេលូយ៉ា!

ព្រះបន្ទូលព្រះអង្គ ជាជីវិត អាលេលូយ៉ា!

ព្រះបន្ទូលព្រះអង្គ ជាសេចក្ដីពិត អាលេលូយ៉ា!

មានសុភមង្គលហើយ អស់អ្នកដែលស្ដាប់

និងអនុវត្តតាមព្រះបន្ទូលព្រះអង្គ ។

## ៦៤- ឱ ! ព្រះបិតាអើយ

**អាលេលូយ៉ា! អាលេលូយ៉ា ! អាលេលូយ៉ា !**

ឱ ! ព្រះបិតាអើយ សូមឲ្យអស់អ្នកដែលជឿលើទូលបង្គំ រួមគ្នាជាធ្លុងតែមួយ

ដើម្បីឲ្យមនុស្សលោក ដឹងថាព្រះអង្គបានចាត់ ទូលបង្គំឲ្យមកមែន

**អាលេលូយ៉ា! អាលេលូយ៉ា ! អាលេលូយ៉ា !**



## ៦៥- ជុំវិញអាសនៈ

១- យើងជួបជុំដោយភក្តី នៅជុំវិញព្រះអាសនៈ និងដើម្បីថ្វាយបង្គំ
ព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណ ដែលគង់នៅលើអាសនៈ ។

២-យើងទាំងអស់រួបរួមចិត្ត និងថ្វាយដល់ព្រះជាម្ចាស់ នូវនំស្រាជាតង្វាយ
ដ៏ស្លូតស្មើងនៃយើងខ្ញុំ សូមព្រះបិតាមេត្តាសព្វព្រះហឫទ័យ ។

៣- យើងទាំងអស់រួបរួមចិត្ត និងថ្វាយដល់ព្រះជាម្ចាស់ នូវជីវិតចិត្តគំនិត
រួមជាមួយនឹងតង្វាយ សូមព្រះបិតាមេត្តាសព្វព្រះហឫទ័យ ។

## ៦៦- តង្វាយពេលនេះ

១- នេះធូបទៀនផ្កា ចិត្តកូនស្មោះស្ម័គ្រ ព្រះពរប្រទាន កូនសូមលើកថ្វាយ
រួមចិត្តគំនិត ជាមួយព្រះគ្រីស្ត ថ្វាយព្រះបិតា ជីវិតសុទ្ធថ្លៃថ្លា ។

**បន្ទរ- សូមព្រះបិតាប្រណីមេត្តា ទទួលតង្វាយ**
**កូនបានលើកថ្វាយ ក្នុងពេលនេះផង ។**

២- នេះជានំស្រា គឺជាអាហារ ដែលទ្រង់ប្រទាន កូនសូមលើកថ្វាយ
រួមចិត្តគំនិត ជាមួយព្រះគ្រីស្ត ថ្វាយព្រះបិតា ជីវិតសុទ្ធថ្លៃថ្លា ។

៣- នេះផលផ្លែផ្កា ពីស្រែចម្ការ ទ្រង់ប្រោសប្រទាន កូនសូមលើកថ្វាយ
រួមចិត្តគំនិត ជាមួយព្រះគ្រីស្ត ថ្វាយព្រះបិតា ជីវិតសុទ្ធថ្លៃថ្លា ។

៤- នេះទំនុកច្រៀង រួមភ្លេងតន្ត្រី ច្រៀងជាតង្វាយ កូនសូមលើកថ្វាយ
រួមចិត្តគំនិត ជាមួយព្រះគ្រីស្ត ថ្វាយព្រះបិតា ជីវិតសុទ្ធថ្លៃថ្លា ។

៥- នេះគ្រឿងតង្វាយ ថ្វាយអរព្រះគុណ បងប្អូនជិតឆ្ងាយ យកមកលើកថ្វាយ
រួមចិត្តគំនិត ជាមួយព្រះគ្រីស្ត ថ្វាយព្រះបិតា ជីវិតសុទ្ធថ្លៃថ្លា ។

## ៦៧- តង្វាយភក្តី

១- យើងខ្ញុំសូមថ្វាយតង្វាយ ដែលកើតមកពីការងារនៃមនុស្ស
ទៅដល់ព្រះម្ចាស់សូមសព្វព្រះហឫទ័យ សូមសព្វព្រះហឫទ័យទទួលតង្វាយយើងខ្ញុំ ។

**បន្ទរ- សូមសព្វព្រះហឫទ័យ ចំពោះតង្វាយនេះផង**
**ដែលយើងរាល់គ្នាថ្វាយទៅ ដោយចិត្តសុភាព និងជ្រះថ្លា ។**

២-បើសិនទ្រង់សព្វព្រះហឫទ័យ ក៏សូមប្រណីលើកលែងកំហុស
ដែលយើងបានធ្វើក្នុងពេលមួយថ្ងៃ ឲ្យបានជ្រះស្អាតដូចជាតង្វាយយើងខ្ញុំ ។

៣-តង្វាយយើងខ្ញុំថ្វាយនេះ ចំនួនតិចតួចស្តួចស្តើងពេកក្រៃ
មិនធួននឹងក្តីអាក្រក់យើងខ្ញុំ ប៉ុន្តែយើងថ្វាយ ដោយចិត្តថ្លាសប្បុរស ។

## ៦៨- តង្វាយរួមនឹងព្រះគ្រីស្តយេស៊ូ

១- រូបកាយខ្មៅចខ្ទាំជីវិតស៊ូទ្រាំ សង្គ្រោះមនុស្សលោក ថ្វាយព្រះបិតា
ព្រះគុណសង្គ្រោះ កូនរួមចិត្តស្មោះ លើកតង្វាយថ្វាយ
រួមនឹងព្រះគ្រីស្តយេស៊ូ ។

**បន្ទរ- សូមព្រះយេស៊ូ ជាព្រះបុត្រា ជួយអង្វរព្រះបិតា ដោយក្តីមេត្តា**
**សូមឲ្យតង្វាយ យើងខ្ញុំលើកថ្វាយ បានទទួលហឫទ័យ**
**ប្រណីសន្តោសផង ។**

២- លោហិតបង្ហូរ ជីវិតទ្រង់ប្តូរ សង្គ្រោះមនុស្សលោក ថ្វាយព្រះបិតា ។
ព្រះគុណសង្គ្រោះ កូនរួមចិត្តស្មោះ លើកតង្វាយថ្វាយ រួមនឹងព្រះគ្រីស្តយេស៊ូ ។

៣- លោហិតថ្លាថ្លៃ ចងសម្ពន្ធថ្មី និងមនុស្សលោកិយ៍ ថ្វាយព្រះបិតា
មេត្រីថ្មីពិត កូនរួមគំនិត ចិត្តថ្វាយតង្វាយ រួមនឹងព្រះគ្រីស្តយេស៊ូ ។

៤- ជីវិតវិសុទ្ធ បូជាឧត្តម រំដោះមនុស្សលោក តាមហឫទ័យបិតា
ព្រះគុណករុណា កូនលើកតង្វាយ ថ្វាយអរព្រះគុណ រួមនឹងព្រះគ្រីស្តយេស៊ូ ។

## ៦៩- តង្វាយស្ដួចស្ដើង

១- យើងរួបរួមគ្នាក្នុងព្រះសហគមន៍ យើងប្រជុំគ្នារួមថ្វាយតង្វាយទៅព្រះម្ចាស់
មានធូបមានទៀននិងផ្កាក្រអូបពេកក្រៃ ដែលជាកម្លាំងរបស់យើង ។

**បន្ទរ-សូមទ្រង់ព្រះមេត្តាទទួលតង្វាយនេះ ព្រោះអ្វីៗដែលកូនមាន**
**ទាំងជីវិតទាំងព្រះអំណោយទាន ជាកម្មសិទ្ធរបស់ព្រះអង្គ ។**

២- យើងរួបរួមគ្នាក្នុងដំណាក់ព្រះម្ចាស់ យើងប្រជុំគ្នារួមថ្វាយតង្វាយទៅព្រះអង្គ
យើងថ្វាយនំបុ័ងនិងស្រាទំពាំងបាយជូរ ដែលជាជីវិតរបស់យើង ។

៣- យើងរួបរួមគ្នាក្នុងព្រះនាមព្រះគ្រីស្ដ ជាមួយព្រះយេស៊ូថ្វាយតង្វាយទៅព្រះជាម្ចាស់
តង្វាយយើងថ្វាយទោះបីទាំងចិត្តទាំងកាយ តិចតួចតែកូនទូលអង្វរ ។

## ៧០- នេះជាតង្វាយ

បន្ទរ- នេះជាតង្វាយ យើងនឹងថ្វាយ ថ្វាយព្រះបិតា ទ្រង់គង់នៅស្ថានដ៏សុខា
សូមព្រះបិតាសព្វព្រះហឫទ័យ ។

១- តង្វាយកូនស្ដួចស្ដើងណាស់ សូមព្រះម្ចាស់សព្វព្រះហឫទ័យ
សូមទ្រង់កុំរេរាបង្អង់ សូមជួយទ្រទ្រង់កុំបោះបង់កូនឡើយ ។

២- កូនបានខំរួបរួមគ្នា ថ្វាយបូជាទៅព្រះបិតា
សូមព្រះម្ចាស់បែរព្រះភក្ត្រា ឈ្វេងព្រះនេត្រាមកទតអាហារនេះ ។

៣- សូមថ្វាយទាំងចិត្តទាំងកាយ លើកតង្វាយថ្វាយព្រះបិតា
សូមទ្រង់ជួយអស់មនុស្សលោកីយ៍ ឲ្យរួចពីទុក្ខភ័យដោយសារតង្វាយនេះ ។

## ៧១- យើងលើកហត្ថាថ្វាយតង្វាយ

១- ឱ! ព្រះបិតា យើងលើកហត្ថា សូមថ្វាយជីវិត ថ្វាយចិត្តគំនិត
ជាមួយនំស្រា ដែលទ្រង់ប្រទាន ហើយជាញើសឈាម នៃអស់មនុស្សលោក ។

**បន្ទរ-សូមទ្រង់មេត្តា ប្រោសឲ្យនំស្រា ក្លាយជាព្រះកាយ ព្រះលោហិតព្រះគ្រីស្ត សម្រាប់យើងខ្ញុំ ។**

២- យើងខ្ញុំសូមថ្វាយ កិច្ចការទាំងឡាយ អំណរសប្បាយ កង្វល់ទុក្ខព្រួយ
នៃអស់មនុស្សលោក រួមនឹងតង្វាយ ដែលព្រះគ្រីស្តថ្វាយ ឆ្ពោះព្រះបិតា ។

៣- សូមទ្រង់មេត្តា ប្រោសយើងខ្ញុំម្ចាស់ ឲ្យស្អាតបរិសុទ្ធ ដូចជាតង្វាយ
ដែលយើងលើកថ្វាយ ហើយសូមប្រទាន ចិត្តគំនិតថ្មី ឲ្យយើងខ្ញុំផង ។

## ៧២- យើងរួបរួមគ្នា

១- យើងរួបរួមគ្នា ថ្វាយបូជាទៅព្រះបិតា
សូមព្រះអង្គផ្ទៀងព្រះនេត្រា លើសក្ការៈនៃអស់យើងខ្ញុំ ។

២- យើងខ្ញុំទាំងឡាយ រួបរួមថ្វាយដោយចិត្តស្មោះស្ម័គ្រ
សូមព្រះអង្គមេត្តាជម្រះ ចិត្តខ្ញុំឲ្យស្អាតដូចតង្វាយ ។

៣- យើងខ្ញុំរាល់គ្នា ព្រមជឿថាមានព្រះតែឯក
គង់សណ្ឋិតលើយើងរាល់គ្នា យើងរាល់គ្នាកោតខ្លាចព្រះអង្គ ។

## ៧៣- សូមព្រះបិតាទទួលដំណើរជីវិតយើងខ្ញុំ

១-សូមព្រះបិតាទទួលតង្វាយ ដែលយើងខ្ញុំថ្វាយទៅព្រះអង្គ
ជាមួយដំណើរជីវិតរបស់យើងខ្ញុំ នៅក្នុងថ្ងៃនេះសូមទ្រង់មេត្តាអាណិតដល់យើងខ្ញុំ ។

**បន្ទរ-សូមព្រះគ្រីស្តអម្ចាស់ ទ្រង់ជួយមេត្តាជម្រះ ដួងចិត្តព្រលឹងខ្ញុំ ពីអំពើបាប**
**ពីក្តីអាក្រក់ឲ្យយើងខ្ញុំទាំងឡាយ រួមថ្វាយតង្វាយ ទៅព្រះបិតា ។**

២-យើងថ្វាយទៅព្រះជាវរបិតា ការប្រចំាថ្ងៃជាតង្វាយ គឺសូមព្រះវរបិតា
ជាព្រះវិសុទ្ធសង្គ្រោះលោកា ជួយដល់អស់មនុស្សសត្វលោកផងទាំងឡាយ ។

## ៧៤-សូមព្រះអង្គមេត្តាទទួលតង្វាយ

| | | |
|---|---|---|
| ១- យើងខ្ញុំសែនសប្បាយ | លើកតង្វាយថ្វាយព្រះម្ចាស់ | |
| ព្រះបិតាលោកា | ម្ចាស់ជីវាសព្វសត្វលោក | ។ |
| បន្ទរ-សូមព្រះអង្គមេត្តា | មេត្តាទទួលតង្វាយ | |
| ដែលយើងខ្ញុំលើកថ្វាយ | រួមនឹងតង្វាយព្រះគ្រីស្ត | ។ |
| ២-យើងខ្ញុំសូមរួមថ្វាយ | ទាំងចិត្តកាយទុក្ខសប្បាយ | |
| ជីវិតប្រចាំថ្ងៃ | រួមនឹងតង្វាយព្រះគ្រីស្ត | ។ |
| ៣-យើងខ្ញុំសូមជឿជាក់ | ព្រះម្ចាស់ពិតជាត្រែឯក | |
| ជាសេចក្ដីស្រឡាញ់ | ជាធម៌មេត្តាករុណា | ។ |

## ៧៥- សូមមេត្តាឆ្លៀងព្រះនេត្រា

| | | | |
|---|---|---|---|
| **បន្ទរ-** | **ឱ ! ព្រះបិតាជាអម្ចាស់** | **ក្នុងចិត្តរាបសាចិត្តសប្បាយ** | |
| | **យើងខ្ញុំសូមលើកតង្វាយថ្វាយ** | **សូមមេត្តាឆ្លៀងព្រះនេត្រា** | **។** |
| ១- | នេះជានំដែលទ្រង់ប្រទានៗ | ឲ្យយើងមានជីវិតរស់រានៗ | |
| | សូមទ្រង់មេត្តាប្រោសឲ្យនំៗ | ក្លាយជាកាយាព្រះបុត្រាៗ | ។ |
| ២- | នេះជាស្រាដែលទ្រង់ប្រទានៗ | ឲ្យយើងមានអំណររីករាយៗ | |
| | សូមទ្រង់មេត្តាប្រោសឲ្យស្រាៗ | ក្លាយជាលោហិតព្រះបុត្រាៗ | ។ |
| ៣- | នេះជាជីវិតនៃយើងខ្ញុំៗ | ដែលទ្រង់មេត្តាប្រោសប្រទានៗ | |
| | យើងខ្ញុំសូមយកមកលើកថ្វាយៗ | រួមនឹងតង្វាយព្រះបុត្រាៗ | ។ |

## ៧៦- សូមលើកតង្វាយថ្វាយព្រះបិតា

១- ឱ ! ព្រះបិតា ជាព្រះជាម្ចាស់ លើសកលលោក យើងខ្ញុំទាំងឡាយ
សូមលើកតង្វាយ រួមទាំងចិត្តកាយ ថ្វាយព្រះបិតា ។

២- យើងខ្ញុំសូមថ្វាយ នំស្រាតង្វាយ ដែលទ្រង់ប្រទាន សូមទ្រង់មេត្តា
ប្រោសឲ្យនំស្រា ក្លាយជាព្រះកាយ ព្រះលោហិតព្រះគ្រីស្ត ។

៣- សូមទ្រង់មេត្តា ទទួលដំណើរ ជីវិតយើងខ្ញុំ សូមប្រោសយើងខ្ញុំ
ឲ្យស្អាតបរិសុទ្ធ ដូចជាតង្វាយ ដែលយើងលើកថ្វាយ ។

## ៧៧- សូមទទួលតង្វាយពីកូនទាំងឡាយ

**បន្ទរ- សូមទទួលតង្វាយពីកូនទាំងឡាយ ដែលរួបរួមគ្នាដោយចិត្តស្មោះស្ម័គ្រ**

១- ឱ ! ព្រះបិតាដ៏មានឫទ្ធិសព្វប្រការ យើងខ្ញុំសូមថ្វាយតង្វាយនេះ
ដើម្បីលុបលាងកំហុសយើង សូមអាណិតអាសូរយើងខ្ញុំ ។

២- យើងខ្ញុំទាំងអស់គ្នាសូមថ្វាយតង្វាយនេះទៅ សម្រាប់បងប្អូនទាំងប្រុសស្រី
ដែលអធិដ្ឋានថ្វាយព្រះជាម្ចាស់ ដើម្បីជួយអស់អ្នកដែលងងឹត ។

៣- សូមទ្រង់ទទួលតង្វាយដ៏តូចតាចនេះ ជាប្រយោជន៍ដល់អស់ព្រលឹង
ដែលឃ្លាតចេញពីឋានលោកនេះ សូមព្រលឹងនោះចូលក្នុងវិមាន ។

៤- យើងខ្ញុំបានខិតខំធ្វើការអស់កម្លាំង ដើម្បីនឹងចិញ្ចឹមជីវិត
រួមទុក្ខព្រួយនឹងបងប្អូនស្លាប់ សូមទ្រង់អាណិតសម្រាលបន្ទុក ។

## ៧៨- កាលនោះ ព្រះគ្រីស្ដមានព្រះបន្ទូល

១- ប. កាលនោះព្រះគ្រីស្ដមានព្រះបន្ទូល កាន់សាវ័កថា ៖
រួម. ខ្ញុំជាមាគ៌ា ៗ ជាសេចក្ដីពិត ៗ ខ្ញុំជាជីវិត ៗ
រួម. អាលេលូយ៉ា !
ស. យើងខ្ញុំបានដើរ ក្នុងទីងងឹត បានជួបមុសា ប៉ុន្ដែថ្ងៃនេះ
រួម. អាលេលូយ៉ា ផ្កាយក្ដីសង្ឃឹម បានផុសចេញពីផ្នូរ ។

**បន្ទរ-រួម. អាលេលូយ៉ាៗៗ**
**រួម. ព្រះយេស៊ូគ្រីស្ដ ទ្រង់មានព្រះជន្ម ដ៏រុងរឿងហើយ**
**រួម. អាលេលូយ៉ាៗៗ**

២- ប. កាលណាព្រះគ្រីស្ដមានព្រះបន្ទូល កាន់សាវ័កថា ៖
រួម. ខ្ញុំជាសន្ដិភាព ៗ ហើយខ្ញុំប្រទាន ៗ អំណរសប្បាយ ៗ
រួម. អាលេលូយ៉ា !
ប. យើងសាបព្រោះភ្លើង យើងសាបព្រោះខ្យល់ បង្ករសង្គ្រាម ប៉ុន្ដែថ្ងៃនេះ
រួម. អាលេលូយ៉ា អម្ចាស់សន្ដិភាព បានផុសចេញពីផ្នូរ ។

៣- ប. កាលនោះព្រះគ្រីស្ដមានព្រះបន្ទូល កាន់សាវ័កថា ៖
រួម. ខ្ញុំជាអាហារ ៗ ចិញ្ចឹមជីវិត ៗ ចុះពីស្ថានសុខ ៗ
រួម. អាលេលូយ៉ា !
ស. យើងបរិភោគ អាហារល្វីងចត់ នៃក្ដីទុក្ខទោស ប៉ុន្ដែថ្ងៃនេះ
រួម. អាលេលូយ៉ា អាហារឧត្ដម បានផុសចេញពីផ្នូរ ។

៤- ប. កាលនោះព្រះគ្រីស្ដមានព្រះបន្ទូល កាន់សាវ័កថា ៖
រួម. ខ្ញុំជាជីវិត ៗ ជាសេចក្ដីពិត ៗ ខ្ញុំឈ្នះមច្ចុរាជ ៗ
រួម. អាលេលូយ៉ា !
ប. យើងខ្ញុំបានស្លាប់ ដោយទុក្ខឲ្យភ្លើង ស្រឡាញ់រលត់ ប៉ុន្ដែថ្ងៃនេះ
រួម. អាលេលូយ៉ា ប្រភពជីវិត បានផុសចេញពីផ្នូរ ។

៥- **ប.** កាលនោះព្រះគ្រីស្ដមានព្រះបន្ទូល កាន់សាវ័កថា ៖
**រួម.** អស់អ្នកនឿយហត់ៗ ចូរមករកខ្ញុំៗ ខ្ញុំឲ្យសម្រាកៗ (**រួម**) អាលេលូយ៉ា!
**ស.** យើងគ្មានកម្លាំង គ្មានចិត្តតតាំង ដើម្បីព្រះរាជ្យ ប៉ុន្តែថ្ងៃនេះ
**រួម.** អាលេលូយ៉ា កម្លាំងព្រះម្ចាស់ បានផុសចេញពីផ្នូរ ។

## ៧៩- ក្នុងដំណើរជីវិត

១- ក្នុងដំណើរជីវិត ព្រះគ្រីស្ដបូជាជីវិតឲ្យលោកា
ដោយចិត្តស្រឡាញ់ ឲ្យយើងក្រោកឡើង
ធ្វើតាមព្រះបន្ទូលព្រះអម្ចាស់ ។

២- ខ្ញុំសូមដើរតាមព្រះគ្រីស្ដ ព្រះបន្ទូលជាជីវិតរបស់យើង
ដោយមានព្រះយេស៊ូ ដែលជាកម្លាំង
សូមធ្វើតាមព្រះបន្ទូលរហូតទៅ ។

៣- ទ្រង់ត្រាស់ហៅយើង ធ្វើការងារព្រះជាអម្ចាស់
ក្នុងស្រែព្រះអង្គរៀងរាល់ថ្ងៃ ប្រកាសព្រះបន្ទូល
ដោយចិត្តជឿសង្ឃឹម ដោយស្រឡាញ់អ្នកដទៃដូចបងប្អូន ។

៤- ក្នុងដំណើរជីវិត ខ្ញុំសូមប្រគល់ជីវិតថ្វាយព្រះអង្គ
ព្រះគ្រីស្ដជាផ្លូវ ក្ដីពិត ជាជីវិត សូមដើរតាមព្រះគ្រីស្ដរហូតទៅ ។

# ៨០- ខ្ញុំជាដើមទំពាំងបាយជូរ

(យ៉ូហាន ១៥,១-៨)

១- ស. ខ្ញុំជាដើមទំពាំងបាយជូរ
ព្រះបិតាជាម្ចាស់ចម្ការ
មែកណាដែលមិនបង្កើតផល
ព្រះបិតាកាត់មែកនោះចោល

ប. ខ្ញុំជាដើមទំពាំងបាយជូរ
ព្រះបិតាជាម្ចាស់ចម្ការ
មែកណាដែលមិនបង្កើតផល
ព្រះបិតាកាត់មែកនោះចោល ។

២- ស. ខ្ញុំជាដើមទំពាំងបាយជូរ
ព្រះបិតាជាម្ចាស់ចម្ការ
មែកណាដែលបង្កើតផលផ្លែ
ព្រះបិតាលួសឲ្យផលល្អ

ប. ខ្ញុំជាដើមទំពាំងបាយជូរ
ព្រះបិតាជាម្ចាស់ចម្ការ
មែកណាដែលបង្កើតផលផ្លែ
ព្រះបិតាលួសឲ្យផលល្អ ។

៣- ស. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ
អ្នកនោះបង្កើតផលផ្លែល្អ

ប. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ
អ្នកនោះបង្កើតផលផ្លែល្អ ។

៤- ស. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
បើអ្នករាល់គ្នាជាប់នឹងខ្ញុំ
អ្នករាល់គ្នាបង្កើតផលល្អ

ប. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
បើអ្នករាល់គ្នាជាប់នឹងខ្ញុំ
អ្នករាល់គ្នាបង្កើតផលល្អ ។

៥- ស. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
សិរីរុងរឿងព្រះបិតា
គឺអ្នកបង្កើតផលឲ្យល្អ

ប. ខ្ញុំជាដើមទំពាំងបាយជូរ
រីឯអ្នករាល់គ្នាជាមែក
សិរីរុងរឿងព្រះបិតា
គឺអ្នកបង្កើតផលឲ្យល្អ ។

## ៨១- ខ្ញុំជាប្រភពនៃជីវិត

**បន្ទរ- ខ្ញុំជាប្រភពនៃជីវិត ខ្ញុំប្រោសមនុស្សឲ្យរស់ឡើងវិញ**
**អ្នកណាជឿសង្ឃឹមលើខ្ញុំ ទោះបីអ្នកនោះស្លាប់ទៅហើយ**
**ក៏នឹងបានរស់ជាមិនខាន ។**

១- ព្រះគ្រីស្តមានបន្ទូលថា អ្នកណាដែលបានរស់នៅ
ដោយជឿសង្ឃឹមលើខ្ញុំ អ្នកនោះមិនត្រូវស្លាប់ទេ ។

២- ព្រះគ្រីស្តមានបន្ទូលថា អ្នកស្តាប់ពាក្យរបស់ខ្ញុំ
ហើយជឿសង្ឃឹមលើខ្ញុំ អ្នកនោះឆ្លងផុតក្តីស្លាប់ ។

## ៨២- ខ្ញុំជាអាហារផ្តល់ជីវិត

**(យ៉ូហាន ៦/៣៥,៥៥-៥៨)**

**បន្ទរ-ខ្ញុំជាអាហារ ដែលផ្តល់ជីវិត អ្នកមករកខ្ញុំ នឹងមិនឃ្លានទៀត**
**អ្នកជឿលើខ្ញុំ នឹងមិនស្រេកទៀត ខ្ញុំនឹងប្រោសគេ ឲ្យរស់ឡើងវិញ។**

១- អាហារដែលខ្ញុំនឹងប្រោសប្រទាន គឺសាច់ហើយនិងលោហិតខ្ញុំណា
សម្រាប់ជីវិតមនុស្សលោកា ជីវិតអស់កល្បជានិច្ចមែនពិត ។

២- អ្នកពិសាសាច់និងលោហិតខ្ញុំ នឹងមានជីវិតអស់កល្បជានិច្ច
អ្នកនោះស្ថិតនៅក្នុងខ្ញុំមែនពិត ហើយខ្ញុំក៏ស្ថិតក្នុងអ្នកនោះដែរ ។

៣- រីឯអ្នកដែលមិនពិសាសាច់ ពិសាលោហិតផងខ្ញុំទេណា
អ្នកនោះនឹងគ្មាននៅក្នុងអាត្មា ជីវិតអស់កល្បជានិច្ចឡើយណា ។

៤- ខ្ញុំជាជីវិតជាសេចក្តីពិត បើអ្នករាល់គ្នាជឿលើខ្ញុំពិត
ទោះអ្នករាល់គ្នាស្លាប់ហើយក៏ដោយ ក៏នឹងបានរស់ឡើងវិញមិនខាន ។

៥- បពិត្រព្រះអម្ចាស់យើងខ្ញុំអើយ យើងខ្ញុំជឿហើយនិងដឹងច្បាស់ថា
ព្រះអង្គពិតជាព្រះជីវិតសុទ្ធ ដែលព្រះជាម្ចាស់បានបាត់ឲ្យមក ។

## ៨៣- ខ្ញុំជាអ្នកគង្វាលដ៏សប្បុរស

បន្ទរ-ខ្ញុំជាអ្នកគង្វាលសប្បុរស(ស្ងួន)    ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ (ស្ងួន)
ចៀមរបស់ខ្ញុំស្គាល់ខ្ញុំ (ស្ងួន)    ខ្ញុំបូជាជីវិតដើម្បីចៀមខ្ញុំ (ស្ងួន)។

១- ឱ ! ព្រះជាម្ចាស់ជាគង្វាល    មើលឥតរយាលណែនាំខ្ញុំ
ឲ្យដើរតាមផ្លូវឥតប្រទាំ    ភោគផលគ្រប់គ្រាន់ឥតខ្វះឡើយ
ព្រះអង្គឲ្យខ្ញុំសម្រាកនៅ    លើវាលមានស្មៅឆ្អែតឥតស្បើយ
នាំខ្ញុំទៅក្បែរមាត់ទឹកហើយ    ប្រទានឲ្យខ្ញុំមានកម្លាំង ។

២- ទោះទូលបង្គំដើរកាត់ប្រក    ភ្នំជ្រលងល្អកងងឹតស្លុង
ឬជួបមជ្ឈរាជកាចយង់ឃ្នង    ខ្ញុំឥតភាន់ភាំងឥតខ្លាចស្លាប់ ។
ដ្បិតមានព្រះអង្គគង់ជាមួយ    បង្គំឥតព្រួយទ្រង់ប្រដាប់
គ្រឿងការពារខ្ញុំហើយសន្ទាប់    ស្ទុះផ្គាញបួងចាប់ខ្ញុំទុកចិត្ត ។

៣- ព្រះអង្គរៀបចំតុដាក់ម្ហូប    ឲ្យខ្ញុំបរិភោគឆ្អែតឆ្អល់ពិត
ឆ្អែតនៅមុខខ្មាំងវាគ្មានលិទ្ធ    ព្រះអង្គអាណិតអភិសេកខ្ញុំ ។
ព្រះអង្គចាក់ប្រេងក្រអូបលាប    ហត្ថាទ្រង់ស្ទាបអង្អែលព្រម
ព្រះអង្គចាក់ស្រាពេញកែវផង    គ្រប់គ្រាន់កន្លងមហាឆ្អែត ។

៤- ព្រះអង្គប្រទានសុភមង្គល    ខ្ញុំឥតខ្វាយខ្វល់ខ្វល់ត្រដែត
អស់មួយជីវិតភ្លឺក្រឡែត    ឲ្យខ្ញុំស្នេហ៍ស្និទ្ធនឹងព្រះអង្គ ។
ខ្ញុំនឹងស្ថិតនៅក្នុងដំណាក់    ជាស្ថានត្រជាក់ឥតសៅហ្មង
ខ្ញុំនៅជរាបឥតផ្សៀងផ្សង    ត្រូវតាមគន្លងឥតឃ្លាតឃ្លា ។

## ៨៤- ខ្ញុំទុកចិត្តលើព្រះជាម្ចាស់

**ស)-** ខ្ញុំទុកចិត្តលើព្រះជាម្ចាស់ ព្រះអង្គមេត្តាដល់យើងខ្ញុំ ទ្រង់បាត់ព្រះគ្រីស្ត
ប្រសូតនៅលោកិយ៍ ហឫទ័យព្រះអង្គ ទ្រង់ស្រឡាញ់ ។

**ប)-** ពេលខ្លះចិត្តខ្ញុំវង្វេងផ្លូវ មិនដឹងត្រូវមិនដឹងខុស ព្រោះវង្វេង
មានតែព្រះគ្រីស្តជាពន្លឺ បំភ្លឺជីវ៉ាលើកលែងទោសា របស់យើង ។

**បន្ទរ-** ស)ឱ!ព្រះគ្រីស្ត ប) ជាជីវិត ស)របស់យើងដែលបានមកសង្គ្រោះ
ប)បាននៅជិតព្រះគ្រីស្ត ជានិច្ចនិរន្តរ៍ ស)មានព្រះអង្គប៉ុណ្ណោះអរសប្បាយ
ប)ក្តីសុខលោកីយ៍ក៏គ្មានតម្លៃអ្វី រួម)ខ្វះព្រះម្ចាស់ធ្វើអ្វីមិនបានឡើយ។(២ដង

## ៨៥- ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ

(យហ ១៥, ៥)

**បន្ទរ-** ខ្ញុំនេះហើយ ជាដើមទំពាំងបាយជូរ ជាដើមទំពាំងបាយជូរ (២ដង)
**ខ្ញុំនេះហើយ...**

១- អ្នករាល់គ្នាជាមែក អ្នករាល់គ្នាជាមែក **(២ដង)**
**ខ្ញុំនេះហើយ ជាដើមទំពាំងបាយជូរ ជាដើមទំពាំងបាយជូរ**
**ខ្ញុំនេះហើយ...**

២- អ្នកណាស្ថិតនៅជាប់ខ្ញុំ ខ្ញុំនៅជាប់នឹងអ្នកនោះ **(២ដង)**
ទើបអ្នកនោះបង្កើតផលបានច្រើន **(២ដង)** ។

## ៨៦- ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ទ

បន្ទរ- ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត ត្រេកអរអំណរសប្បាយរីករាយ
ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត ត្រេកអរសប្បាយណាស់ ។

១- ព្រះបន្ទូលទ្រង់ ខ្ញុំជានំបុ័ង ទុកសម្រាប់ចិញ្ចឹមជីវិត
អ្នកណាដែលបានបរិភោគ អ្នកនោះមិនខ្លាចនូវក្ដីស្លាប់ ។

២- ព្រះបន្ទូលទ្រង់ ខ្ញុំជាដើមឈើ មែកណាមិនជាប់ដើមគឺឥតផល
អ្នកណាដែលនៅជាប់នឹងខ្ញុំ អ្នកនោះអាចបង្កើតផលច្រើន ។

៣- ព្រះបន្ទូលទ្រង់ ខ្ញុំជាជីវិត ឈើឆ្កាងបំផ្លាញសេចក្ដីស្លាប់
អ្នកណាបាននៅជាមួយខ្ញុំ អ្នកនោះមានដៃជើងជាប់ខ្លួន ។

៤- ព្រះបន្ទូលទ្រង់ ខ្ញុំជាផ្លូវពិត ព្រះបិតានៅរង់ចាំអ្នក
អ្នកណាដែលបានដើរតាមខ្ញុំ អ្នកនោះជួបខ្ញុំឯស្ថានបរមសុខ ។

៥- ព្រះបន្ទូលទ្រង់ ខ្ញុំជាពន្លឺ ភ្លឺនៅកណ្ដាលទីងងឹត
អ្នកណាដែលបានទទួលខ្ញុំ អ្នកនោះមានព្រះអង្គនាំផ្លូវ ។

៦- ព្រះបន្ទូលទ្រង់ ខ្ញុំជាសម្លាញ់ ដែលធ្វើឲ្យគេរួបរួមគ្នា
អ្នកណាដែលបានស្គាល់ខ្ញុំមែន អ្នកនោះបបួលគេស្គាល់ផង ។

៧- ព្រះបន្ទូលទ្រង់ ខ្ញុំជាសុខសាន្ត បានប្រយោជន៍ដល់មនុស្សលោក
អ្នកណាដែលស្ម័គ្រដើរតាមខ្ញុំ អ្នកនោះជាបន្ទាល់ពីខ្ញុំ ។

# ៨៧- ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត

បន្ទរ-ប. ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត (ស)ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត

ប. ត្រេកអរអំណរសប្បាយរីករាយ (ស)ត្រេកអរអំណរសប្បាយរីករាយ

ប.ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត (ស)ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត

រួម. ត្រេកអរសប្បាយ សប្បាយកន្លង ។

១- **ស.** ព្រះគ្រីស្តទ្រង់មាន **ប.** ព្រះបន្ទូលថា

**ស.** ខ្ញុំជានំប៉័ង ទុកសម្រាប់ចិញ្ចឹមជីវិត

អ្នកណាដែលបានបរិភោគ អ្នកនោះមិនខ្លាចនូវសេចក្តីស្លាប់ ។

២- **ស.** ព្រះគ្រីស្តទ្រង់មាន **ប.** ព្រះបន្ទូលថា

**ស.** ខ្ញុំជាដើមឈើ មែកណាមិនជាប់ដើមគឺឥតផល

អ្នកណាដែលបាននៅជាមួយខ្ញុំ អ្នកនោះអាចបង្កើតបានផលច្រើន ។

៣- **ស.** ព្រះគ្រីស្តទ្រង់មាន **ប.** ព្រះបន្ទូលថា

**ស.** ខ្ញុំជាជីវិត ឈើឆ្កាងបំផ្លាញនូវសេចក្តីស្លាប់

អ្នកណាដែលបាននៅជាមួយខ្ញុំ អ្នកនោះដូចមានដៃជើងជាប់ខ្លួន ។

៤- **ស.** ព្រះគ្រីស្តទ្រង់មាន **ប.** ព្រះបន្ទូលថា

**ស.** ខ្ញុំជាផ្លូវពិត ព្រះវរបិតានៅរង់ចាំអ្នក

អ្នកណាដែលបានដើរតាមខ្ញុំ អ្នកនោះជួបខ្ញុំឯស្ថានបរមសុខ ។

៥- **ស.** ព្រះគ្រីស្តទ្រង់មាន **ប.** ព្រះបន្ទូលថា

**ស.** ខ្ញុំជាពន្លឺ ភ្លឺនៅកណ្តាលទីងងឹត

អ្នកណាដែលបានទទួលខ្ញុំ អ្នកនោះដូចមានព្រះអង្គនាំផ្លូវ ។

## ៨៨- ខ្ញុំផ្ចង់ចិត្តឆ្ពោះរកព្រះអង្គ

### ដកស្រង់ពីទំនុកតម្កើងលេខ ២៥ (២៤)

**បន្ទរ- ឱ ! ព្រះអម្ចាស់ព្រះសង្គ្រោះ ខ្ញុំផ្ចង់ចិត្តឆ្ពោះរកព្រះអង្គ**
**សូមណែនាំឲ្យខ្ញុំស្គាល់ផង មាគ៌ាត្រឹមត្រូវនៃព្រះអង្គ ។**

១- ឱ ! ព្រះអម្ចាស់ទូលបង្គំ សូមជួយណែនាំ និងបង្រៀន
ឲ្យស្គាល់មាគ៌ាល្អថ្កើងថ្កាន វិសុទ្ធហួសស្មាននៃព្រះអង្គ ។

២- អស់អ្នកសង្ឃឹមលើព្រះអង្គ នឹងមិនត្រូវបង់ខាតបិត្តអ្វី
គឺមានតែអ្នកក្បត់ម្ចាស់ថ្លៃ ទើបខកចិត្តក្រៃអ្វីក៏គ្មាន ។

៣- សូមជួយអប់រំខ្ញុំឲ្យរស់ តាមក្តីពិតស្មោះព្រះអង្គផង
ដ្បិតទ្រង់សង្គ្រោះខ្ញុំឥតហ្មង សង្ឃឹមព្រះអង្គរៀងរាល់ថ្ងៃ ។

៤- ឱ ! ព្រះអម្ចាស់សូមកុំភ្លេច បំរាជាប់ជានិច្ចពេញហឫទ័យ
ដែលធ្លាប់អាណិតពន់ពេកក្រៃ ករុណាប្រណីខ្ញុំជានិច្ច ។

៥- ព្រះអម្ចាស់មានព្រះហឫទ័យ សប្បុរសពេកក្រៃករុណា
សូមជួយបង្ហាញពីមាគ៌ា មនុស្សបាបគ្រប់គ្នាបានស្គាល់ផង ។

៦- ព្រះអង្គនាំមនុស្សដែលមានចិត្ត សុភាពសុចរិតតាមគន្លង
មាគ៌ាត្រឹមត្រូវល្អផូរផង់ មិនឲ្យមានហ្មងស្គាល់ផ្លូវល្អ ។

៧- មាគ៌ារបស់ព្រះអម្ចាស់ សម្តែងយ៉ាងច្បាស់ករុណាធម៌
ដល់អ្នកគោរពទោះក្រីក្រ ខ្ពង់ខ្ពស់បវរតាមសម្ពន្ធ ។

# ៨៩- ខ្ញុំស្រឡាញ់ក្រឹត្យវិន័យ

(ដកស្រង់ពីទំនុកតម្កើងលេខ ១១៩-១១៨)

**បន្ទរ-ខ្ញុំសែនស្រឡាញ់ បន្ទូលព្រះម្ចាស់ ខ្ញុំនឹកសញ្ជឹង រំពឹងជានិច្ច**
**ព្រះបន្ទូលគឺ ពន្លឺបំភ្លឺ ជីវិតខ្ញុំម្ចាស់ ។**

១- វិន័យព្រះអង្គ ឲ្យខ្ញុំត្រឹមត្រង់ ប្រាជ្ញាវាងវៃ ជាងពួកសត្រូវ
ដ្បិតខ្ញុំលកលៃ រិះគិតរំពៃ ពីវិន័យនេះ ។

២- ខ្ញុំវាងវៃឆ្លាត ជាងគ្រូទៅទៀត ព្រោះតែខ្ញុំចេះ យកដំបូន្មាន
ទាំងប៉ុន្មាននេះ មកសញ្ជឹងរិះ គិតពិចារណា ។

៣- កាន់តាមបញ្ញត្តិ វិន័យមិនបាត់ ខ្ញុំយល់ឃើញថា មានប្រាជ្ញាវៃ
ជាងយាយជាងតា ទោះចាស់យ៉ាងណា មិនដល់ខ្ញុំសោះ ។

៤- ខ្ញុំគេចឲ្យឆ្ងាយ ពីផ្លូវអន្តរាយ អាក្រក់ទាំងអស់ គេចចេញឲ្យផុត
ប្រព្រឹត្តតាមព្រះ បន្ទូលអម្ចាស់ នៅជាប់ស្ថិតស្ថេរ ។

៥- បញ្ញានេះណា ប្រៀបបានអាហារ ឆ្ងាញ់ពិសេសហើយ សម្រាប់រូបខ្ញុំ
គ្មានអ្វីស្មើឡើយ ផ្អែមណាស់ព្រះអើយ លើសទឹកឃ្មុំផង ។

៦- គឺធម៌វិន័យ របស់ព្រះម្ចាស់ថ្លៃ ធ្វើឲ្យខ្ញុំត្រង់ ចេះពិចារណា
រិះគិតឥតឆ្គង ស្អប់ផ្លូវសៅហ្មង ជៀសវាងបោកប្រាស់ ។

៧- ខ្ញុំសូមសន្យា ឥតងាករេថា ធ្វើតាមមិនខាន ខ្ញុំនឹងប្រតិបត្តិ
សេចក្ដីប៉ុន្មាន សុចរិតថ្កើងថ្កាន របស់ព្រះអង្គ ។

## ៩០- ខ្ញុំស្រឡាញ់ព្រះបន្ទូល

ខ្ញុំស្រឡាញ់ព្រះបន្ទូល ខ្លាំងឡើងរៀងរាល់ថ្ងៃ ខ្លាំងឡើងរៀងរាល់ថ្ងៃ
រាល់ថ្ងៃ ខ្លាំងឡើងរៀងរាល់ថ្ងៃ ហើយរាល់ថ្ងៃ ។
ពេលវេលាកន្លងទៅ ខ្ញុំនៅតែទុកចិត្តលើហឫទ័យ ទ្រង់ល្អដល់ខ្ញុំ
ហើយល្អដល់មនុស្សទាំងអស់ ។

## ៩១- ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់

**ទំន ៦៣(៦២)**

១- ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់ ដូចសត្វក្តាន់ប្រាថ្នាស្វែងរកទឹកហូរ
ខ្ញុំត្រូវការព្រះជាម្ចាស់ យើងខ្ញុំសូមកោតសរសើរព្រះជាអម្ចាស់
ទ្រង់ជាខែលរនាំងដែលការពារ ព្រះអង្គតែមួយដែលចិត្តយើងស្រឡាញ់
ទ្រង់ជាក្តីប្រាថ្នា ក្នុងដួងចិត្ត យើងសូមកោតសរសើរព្រះអង្គ ។

២- ខ្ញុំស្វែងរកព្រះជាម្ចាស់ ដូចដីស្ងួតបែកក្រហែង ស្រេកឃ្លានទឹកភ្លៀង
ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់ យើងខ្ញុំសូមកោតសរសើរព្រះជាអម្ចាស់
ទ្រង់ជាខែលរនាំងដែលការពារ ព្រះអង្គតែមួយដែលចិត្តយើងស្រឡាញ់
ទ្រង់ជាក្តីស្រឡាញ់ ក្នុងដួងចិត្ត យើងសូមកោតសរសើរព្រះអង្គ ។

៣- ឱ ! ព្រះជាម្ចាស់ខ្ញុំអើយ ព្រះអង្គពិតជាព្រះខ្ញុំស្វែងរកព្រះអង្គ
ខ្ញុំចង់ឃើញព្រះអង្គណាស់ យើងខ្ញុំសូមកោតសរសើរព្រះជាអម្ចាស់
ទ្រង់ជាខែលរនាំងដែលការពារ ព្រះអង្គតែមួយដែលចិត្តយើងស្រឡាញ់
ទ្រង់ជាសេចក្តីសង្ឃឹម ក្នុងដួងចិត្ត យើងសូមកោតសរសើរព្រះអង្គ ។

## ៩២- គោរពព្រះគ្រីស្ដជាអម្ចាស់

**បន្ទរ-គោរពព្រះគ្រីស្ដជាអម្ចាស់ នាំគ្នាប្រកាសយ៉ាងត្រឹកត្រំា**
**លើកតម្កើងសិរីយ៉ាងថ្កើងថ្កុំ បង្គំព្រះម្ចាស់ជាបិតា ។**

១- ទោះបីជាព្រះគ្រីស្ដមានឋានៈ ស្មើព្រះជាម្ចាស់នោះយ៉ាងណា
ក៏ព្រះអង្គមិនយកព្រះបេស្ដា ប្រើជាប្រយោជន៍ព្រះអង្គឡើយ
គឺព្រះអង្គទ្រង់បានលះបង់ អំណាចព្រះអង្គពុំសោកស្ដាយ
ព្រះអង្គទ្រង់បានបន្ទាបកាយ ក្លាយជាខ្ញុំបម្រើព្រះជាម្ចាស់ ។

២- ព្រះគ្រីស្ដទ្រង់ដាក់អង្គជាសាមញ្ញ ឲ្យមនុស្សផងឃើញដោយភ្នែកច្បាស់
មកជាសភាពមនុស្សមិនប្ដូរផ្លាស់ បេះបិទទាំងសព្វគ្រប់ប្រការ
ព្រះគ្រីស្ដបានបន្ទាបអង្គទៀត ធ្វើតាមឱវាទដ៏បវរ
នៃព្រះជាម្ចាស់បានបញ្ជា រហូតផុតជន្មាលើឈើឆ្កាង ។

៣- ដោយហេតុនេះហើយទើបព្រះជាម្ចាស់ តម្កើងព្រះគ្រីស្ដហួសប្រមាណ
ហើយប្រោសប្រទាននូវព្រះនាម ព្រះគ្រីស្ដថ្កើងថ្កានជាអម្ចាស់
ដើម្បីឲ្យសត្វលោកទាំងឡាយ មនុស្សរាល់រូបកាយគ្រប់ជាតិសាសន៍
ទាំងពួកទេវទូតស្ថានបរមសុខ ច្រៀងកោតសរសើរថ្វាយបង្គំ ។

## ៩៣- ចិត្តខ្ញុំពេញដោយអំណរ

ចិត្តខ្ញុំពេញដោយអំណរ រូបខ្ញុំពេញដោយក្ដីស្រឡាញ់
ព្រះអម្ចាស់គ្រប់កន្លែងដែលខ្ញុំទៅ និងគ្រប់ពេលខ្ញុំដកដង្ហើម
សម្រាប់អ្វីដែលខ្ញុំមាន ខ្ញុំដឹងគ្រប់នៅទីនេះ
ខ្ញុំនឹងប្រាប់មិត្តភក្តិខ្ញុំ នូវសេចក្ដីស្រឡាញ់ព្រះអង្គ
ឲ្យខ្ញុំគ្រប់កន្លែងដែលខ្ញុំទៅ ឬកន្លែងខ្ញុំរស់នៅ ។
ប្រសិនបើអ្នកចង់ដឹង ព្រះអម្ចាស់ស្រឡាញ់យើង
មិនថាយើងជានរណា ចូលទៅប្រាប់មនុស្សគ្រប់សាសន៍
អ្វីអ្នកឮនិងឃើញ អ្វីដែលអាចនិងអ្វីអ្នកដឹង
គឺព្រះគ្រីស្ដដែលយើងស្គាល់ ចូលទៅប្រាប់ពិភពលោក
ប្រាប់ជនជាតិអាស៊ីថា ព្រះអម្ចាស់នៅទីនេះ
ផ្ដល់សេចក្ដីស្រឡាញ់ មកមនុស្សគ្រប់គ្នានិងអង្គព្រះគ្រីស្ដជាម្ចាស់ ។

## ៩៤- ចិត្តខ្ញុំរីករាយ

១- ចិត្តខ្ញុំរីករាយសប្បាយពន់ពេកកន្លង ខ្ញុំសង្ឃឹមផងថាបានទទួល
នូវព្រះអំណោយនៃព្រះជាម្ចាស់ ដែលទ្រង់បានទុកសម្រាប់យើងខ្ញុំ
ដែលជាបម្រើរបស់ព្រះអង្គ ។

២- ខ្ញុំបានបរិភោគនំដែលជាព្រះកាយ ចិត្តខ្ញុំសប្បាយថានឹងបានរស់
អស់មួយជីវិតឯស្ថានបរមសុខ ហើយព្រលឹងខ្ញុំបានស្អាតភ្លឺថ្លា
នឹងមានកម្លាំងតតាំងអារក្ស ។

## ៩៥- ចូរចេញទៅ

បន្ទរ- ព្រះគ្រីស្តមានព្រះបន្ទូលថា
ចូរអ្នករាល់គ្នាចេញទៅ ណែនាំមនុស្សគ្រប់ជាតិគ្រប់សាសន៍
ឲ្យទៅជាសាវ័ក ខ្ញុំនឹងស្ថិតនៅជាមួយអ្នករាល់គ្នា
ជារៀងរាល់ថ្ងៃ រហូតដល់អវសាន នៃភពផែនដី ។

១- ចូរប្រគុំបទថ្មីប្រៀងថ្វាយ ឆ្ពោះព្រះពណ្ណរាយស្មោះបំផុត
នឹងលើកតម្កើងនាមវិសុទ្ធ ប្រគុំថ្វាយបទចម្រៀងថ្មី

២- ចូរអ្នកកាន់សាសនានានា ជ្រួតជ្រាបមាគ៌ាសិរីរុងរឿង
បានស្គាល់ព្រឹត្តិការណ៍អស្ចារ្យក្រៃ ដែលមនុស្សលោកពុំអាចផ្ទឹមបាន ។

៣- ចូរខំប្រកាសរៀងរាល់ថ្ងៃ ពីព្រះហឫទ័យព្រះទ្រង់ញាណ
ពីការសង្គ្រោះនិងអំណោយទាន ឲ្យមនុស្សគ្រប់ស្ថាននៅលោកា ។



## ៩៦- ចូរយើងផ្ចង់ស្មារតីនឹក

**បន្ទរ-ចូរយើងទាំងអស់ផ្ចង់ស្មារតីនឹក កុំបីភ្លេចភ្លឹកអំពីព្រះជន្ម**
**នៃព្រះយេស៊ូដែលបានរស់រាន ដោយព្រះវិញ្ញាណវិសេសវិសុទ្ធ ។**

១- ប្រសិនបើយើងស្លាប់ ដោយមានភ័ព្វរួមព្រះគ្រីស្ត
មុខជាមានជីវិតអើយ រួមជាមួយព្រះអង្គដែរ ។

២- ប្រសិនបើយើងទ្រាំ រងទុក្ខលំបាកឥតល្ហែ
យើងមុខជាបានក្បែរអើយ សោយរាជ្យរួមនឹងព្រះអង្គ ។

៣- ប្រសិនយើងវៀចវេរ ចិត្តវេរាមិនស្មោះត្រង់
ព្រះអង្គមិនបោះបង់អើយ នៅតែមានព្រះហឫទ័យស្ម័គ្រ ។

## ៩៧- ចូរយើងរាល់គ្នាបង្គំវន្ទាច្រៀងថ្វាយព្រះម្ចាស់

**បន្ទរ-ចូរយើងរាល់គ្នា បង្គំវន្ទា ច្រៀងថ្វាយព្រះម្ចាស់ ប្រគុំភ្លេងខ្លាយ**
**ពិនស្គរឱនកាយ សរសើរតម្កើង និងអរព្រះគុណ ។**

១- យើងខ្ញុំកោតសរសើរ សិរីបវរដល់ព្រះជាម្ចាស់
ក្នុងចិត្តរីករាយណាស់ ព្រះអង្គជាព្រះបិតានៃយើង ។

២- ព្រះជាអម្ចាស់ប្រកប ឫទ្ធានុភាពថ្លៃថ្លាឧត្តម
ទ្រង់ជាម្ចាស់យើងខ្ញុំ និងទ្រង់គ្រប់គ្រងទាំងរបស់ផង ។

៣- យើងលើកតម្កើងជោគជ័យ ថ្វាយសុខសិរីប្រសើរកន្លង
ចំពោះព្រះភក្ត្រព្រះអង្គ ស្ម័គ្រហៃទ្រង់សមតាមព្រះហឫទ័យ ។

៤- យើងខ្ញុំច្រៀងលើកមង្គល តម្កើងតម្កល់ជាព្រះនរបតី
គ្រប់គ្រងលើលោកីយ៍ អរព្រះគុណថ្លៃរៀងរហូតអើយ ។

# ៩៨- ចូរយើងឱនកាយ

១- ចូរយើងឱនកាយក្រាបថ្វាយបង្គំ ព្រះសញ្ញាយ៉ាងពិសិដ្ឋឧត្ដម
គឺព្រះកាយានៃព្រះយេស៊ូ ទ្រង់ចងសម្ពន្ធមេត្រីថ្មី
ទោះបីភ្នែកយើងខ្ញុំមើលមិនឃើញ តែយើងជឿទ្រង់គង់ទីនេះ ។

**បន្ទរ- ខ្ញុំជាអាហារដែលផ្ដល់ជីវិត ចុះមកពីស្ថានបរមសុខអើយ អ្នកណាបានបរិភោគ អាហារនេះហើយ នឹងបានរស់នៅអស់កល្បជានិច្ចអើយ ។**

២- ចូរយើងឱនកាយក្រាបថ្វាយបង្គំ អរព្រះគុណព្រះគ្រីស្ដថ្លៃថ្លាឧត្ដម
ព្រះអង្គទ្រង់គង់ក្នុងព្រះកាយា ពោរពេញដោយក្ដីអាថ៌កំបាំង
យើងខ្ញុំសូមថ្វាយកាយ និងវាចា ទាំងចិត្តសែនរីករាយសប្បាយ ។

៣- ចូរយើងថ្លែងឡើងសិរីរុងរឿង មានដល់ព្រះបិតាព្រះបុត្រា
ចូរយើងសរសើរពេញទាំងមេឃដី តេជានុភាពព្រះអង្គ
សូមក្ដីថ្កុំថ្កើងរុងរឿងរស្មី មានដល់ព្រះវិញ្ញាណដ៏វិសុទ្ធ ។



## ៩៩- ចូរថ្វាយបង្គំព្រះជាម្ចាស់

១- ឱ ! ព្រះអម្ចាស់ ដ៏មានតេជះ សព្វគ្រប់ប្រការ ព្រះអង្គប្រសើរ
គួរស្ញែងដល់ស្នា ព្រះហស្តខ្លាំងក្លា ឧត្តមឧត្តុង្គពេកក្រៃ ។
២- ឱ ! ព្រះមហាក្សត្រ ខ្ពង់ខ្ពស់ពេកក្តាត់ នៃជាតិទាំងឡាយ ព្រះអង្គដឹកនាំ
ទោះជិតទោះឆ្ងាយ ត្រសុំត្រសាយ យុត្តិធម៌ត្រឹមត្រូវកន្លង ។
៣- ព្រះអម្ចាស់អើយ គ្មានអ្នកកន្តើយ មិនគោរពផង គ្មានអ្នកនៅស្ងៀម
មិនលើកតម្កើង ព្រោះតែព្រះអង្គ ជាព្រះវិសុទ្ធថ្លៃថ្លា ។
៤- មនុស្សគ្រប់ជាតិសាសន៍ ចូលមកប្រជ្រៀត ថ្វាយបង្គំលុត ដ្បិតទ្រង់សម្តែង
វិនិច្ឆ័យដ៏សុច វិតល្អបំផុត មនុស្សលោកឃើញជាក់ស្តែង ។

## ១០០- ចូរនាំពន្លឺពីព្រះជាម្ចាស់ទៅបំភ្លឺពិភពលោកា

ព្រះជាអម្ចាស់ស្រឡាញ់លោកា ទ្រង់បានចាត់ព្រះបុត្រាយាងមក
ព្រះយេស៊ូមកសង្គ្រោះ មនុស្សគ្រប់ជាតិសាសន៍លើលោកា
ព្រះអង្គប្រទាននូវក្តីស្រឡាញ់ ដល់យើងគ្រប់គ្នា
ឲ្យទៅប្រកាសដំណឹងល្អ ដល់មនុស្សដែលកំពុងអស់សង្ឃឹម ។
ចូរពួកយើងទៅប្រាប់នៅលើពិភពលោក នូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ថា
ព្រះអង្គនឹងយាងមកគង់ជាមួយនឹង អស់អ្នកដែលរងទុក្ខលំបាក ។
ចូរយើងនាំពន្លឺដែលមកពីព្រះម្ចាស់ ទៅបំភ្លឺអស់អ្នកដែលអស់សង្ឃឹម
ដោយពន្លឺមកពីព្រះម្ចាស់ ចូរពួកយើងទៅគ្រប់ទិសទី
ហើយប្រាប់ថា ព្រះម្ចាស់ស្រឡាញ់យើង ។
ចូរនាំពន្លឺដែលព្រះម្ចាស់ផ្តល់ឲ្យ ទៅបំភ្លឺលោកា
ដែលកំពុងងងឹត ហូ...ហូ... ចូរមានចិត្តសង្ឃឹមជានិច្ច ។

## ១០១- ចូរពិសោធឲ្យដឹងច្បាស់...

(ដកស្រង់ពីទំនុកតម្កើង ៣៤)

**បន្ទរ-ចូរពិសោធឲ្យដឹងច្បាស់ថា តើព្រះម្ចាស់សប្បុរសយ៉ាងណា ?**
**មានសុភមង្គលហើយណា អស់អ្នកឯណាពឹងព្រះអង្គ ។**

១- ខ្ញុំនឹងលើកតម្កើង ព្រះម្ចាស់យើងគ្រប់វេលា
សូមឲ្យមនុស្សរាបសា ស្ដាប់ហើយសប្បាយរីករាយ ។

២- ប្រកាសនឹងខ្ញុំថា ព្រះជាម្ចាស់ថ្កុំថ្កើងណាស់
ចូរតម្កើងរួមគ្នា ព្រះនាមព្រះអង្គថ្លៃ ។

៣- ខ្ញុំស្វែងរកព្រះម្ចាស់ ទ្រង់តបច្បាស់ដោយមេត្តា
រំដោះខ្ញុំផងណា រួចពីការតក់ស្លុតភ័យ ។

៤- អ្នកសម្លឹងមើលទ្រង់ នឹងពោរពេញដោយអំណរ
រីករាយសប្បាយអរ ហើយមិនខកចិត្តសោះឡើយ ។

៥- មនុស្សទុរគតអង្វរ ទ្រង់តបតដោយមេត្តា
ហប្ញទ័យករុណា សង្គ្រោះគ្រាជុតគ្រោះកាច ។

# ១០២- ចូរមករកខ្ញុំ

**ព្រះគ្រីស្តមានព្រះបន្ទូលថា ៖**

**បន្ទរ- អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ ចូរមករកខ្ញុំហើយ**
**ខ្ញុំនឹងឲ្យអ្នកសម្រាក ចូរយកនឹមនៃខ្ញុំ ហើយចូរខំរៀនពីខ្ញុំ**
**អ្នករាល់គ្នាមុខជា បានស្ងប់ចិត្តជាមិនខាន ដ្បិតខ្ញុំមានចិត្តស្លូត**
**ចិត្តសុភាពរាបសាណាស់ នឹមរបស់ខ្ញុំស្រួល បន្ទុកខ្ញុំក៏ស្រាលដែរ ។**

១- ព្រះអម្ចាស់ជាគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះឡើយ
ព្រះអង្គឲ្យខ្ញុំសម្រាកនៅ លើវាលមានស្មៅក្បែរមាត់ទឹកថ្លា ។

២- ព្រះអម្ចាស់ទ្រង់ប្រោសប្រទាន ឲ្យខ្ញុំមានកម្លាំងឡើងវិញ
ទ្រង់នាំខ្ញុំក្នុងផ្លូវសុចរិត ដោយយល់ដល់កិត្តិនាមព្រះអង្គ ។

៣- ទោះបីរូបខ្ញុំដើរកាត់ភ្នំ ជ្រលងតូចធំស្លាប់ក៏ដោយ
ក៏ខ្ញុំមិនភ័យខ្លាចអ្វីឡើយ ទ្រង់គង់ជាមួយតាមការពារ ។

៤- ព្រះអង្គរៀបចំឲ្យបរិភោគ អាហារគរគោកមុខបច្ចា
ព្រះអង្គចាក់ប្រេងលើសិរសា បំពេញពែងស្រាខ្ញុំហៀរហូរ ។

៥- ខ្ញុំដឹងច្បាស់ថាព្រះអម្ចាស់ មេត្តាប្រទានសុភមង្គល
ប្រណីសន្ដោសយ៉ាងស្និទ្ធស្នោះ ជារៀងរាល់ថ្ងៃមួយជីវិត ។

៦- ដរាបណាខ្ញុំមានជីវិត ខ្ញុំនឹងត្រឡប់មកជានិច្ច
ក្នុងព្រះដំណាក់ដ៏ឧត្ដម នៃព្រះជាម្ចាស់ដ៏វិសុទ្ធ ។

# ១០៣- ចូរមានចិត្តមេត្តាករុណាដូចព្រះបិតា

(ដកស្រង់ពីលូកា ៦:៣៦-៣៨)

បន្ទរ- ចូរមានចិត្តមេត្តាករុណា ដូចព្រះបិតាអ្នករាល់គ្នា
ព្រះអង្គទ្រង់មាន ព្រះហឫទ័យមេត្តាករុណា ។

១- កុំថ្កោលទោសអ្នកដទៃ នោះព្រះជាម្ចាស់ នឹងមិនថ្កោលទោសអ្នកដែរ ។
២-កុំផ្ដន្ទាទោសគេឡើយ នោះព្រះជាម្ចាស់ នឹងមិនផ្ដន្ទាទោសអ្នក ។
៣-ត្រូវលើកលែងទោសឲ្យគេ នោះព្រះជាម្ចាស់ នឹងលើកលែងទោសឲ្យអ្នក ។
៤- ចូរធ្វើអំណោយដល់គេ នោះព្រះជាម្ចាស់ នឹងធ្វើអំណោយដល់អ្នក ។
៥- ព្រះអង្គនឹងប្រទានឲ្យ បរិបូណ៌ហូរហៀរ ដល់អ្នកពិតជាមិនខាន ។
៦- ព្រះម្ចាស់នឹងវាល់ឲ្យអ្នក តាមរង្វាល់ដែល អ្នកវាល់ឲ្យអ្នកដទៃ ។



# ១០៤- ចូរមានចិត្តសប្បុរសដូចព្រះបិតា

(ដកស្រង់ពីលូកា ៦,២៦-៣៥)

បន្ទរ-ចូរអ្នករាល់គ្នា មានចិត្តសប្បុរស ដូចព្រះបិតា
មានព្រះហឫទ័យ សប្បុរសចំពោះ មនុស្សអកត្តញ្ញូ
និងមនុស្សកំណាច ។

១- ចូរអ្នកស្រឡាញ់ខ្មាំងសត្រូវ ចូរធ្វើអំពើល្អដល់គេ
ហើយចូរជូនពរដល់អស់អ្នក ដែលប្រទេចផ្ដាសាអ្នកផង ។

២- ចូរអង្វរព្រះជាអម្ចាស់ ប្រទានពរអ្នកបៀតបៀនខ្លួន
បើមានគេទះកំផ្លៀងម្ខាង ចូរបែរម្ខាងទៀតឲ្យគេចុះ ។

៣- បើគេចង់បានអាវធំអ្នក ចូរប្រគល់អាវក្នុងថែមទៀត
បើមានមនុស្សសុំអ្វីពីអ្នក ចូរឲ្យគេតាមសំណូមពរ ។

៤- ដ្បិតបើអ្នករាល់គ្នាស្រឡាញ់ តែមិត្តសម្លាញ់របស់ខ្លួន
តើនឹងមានគុណបំណាច់អ្វី អ្នកបាបក៏ធ្វើដូច្នេះដែរ ។

៥- ហើយបើអ្នកធ្វើអំពើល្អ ចំពោះមនុស្សធ្វើល្អដល់អ្នក
តើនឹងមានគុណបំណាច់អ្វី អ្នកបាបក៏ធ្វើយ៉ាងនេះដែរ ។

៦- ដូច្នេះចូរស្រឡាញ់សត្រូវ ចូរធ្វើអំពើល្អដល់គេ
ចូរឲ្យខ្ចីដោយមិនសង្ឃឹម នឹងបានសំណងវិញនោះឡើយ ។

៧- ធ្វើដូច្នេះអ្នកមានឈ្មោះថា ជាបុត្រធីតាព្រះបិតា
ដ្បិតព្រះហឫទ័យទ្រង់សប្បុរស ចំពោះមនុស្សគ្រប់ៗរូប ។

## ១០៥- ចូរអ្នកស្វែងរកព្រះរាជ្យព្រះជាម្ចាស់

**បន្ទរ-** ចូរអ្នកស្វះស្វែងរក ព្រះរាជ្យរបស់ព្រះជាម្ចាស់
និងសេចក្ដីសុចរិត របស់ព្រះអង្គជាមុនសិន
ទើបព្រះអង្គប្រទាន របស់ទាំងនោះមកថែមទៀត
ដ្បិតព្រះបិតាអ្នកជ្រាប នូវអ្វីដែលអ្នកត្រូវការ ។

១- ព្រះគ្រីស្ដមានព្រះបន្ទូលថា ចូរអ្នកមើលបក្សាបក្សី
វាមិនដែលសាបព្រោះច្រូតកាត់ តែព្រះបិតាចិញ្ចឹមវា
ចំណែកឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាមានតម្លៃពិត
លើសបក្សាបក្សីទៅទៀត ហេតុនេះចូរអ្នកកុំខ្វល់ខ្វាយ ។

២- ព្រះគ្រីស្ដមានព្រះបន្ទូលថា ចូរអ្នកមើលផ្កាតាមវាលស្រែ
វាមិនដែលនឿយហត់ត្បាញរវៃ តែទោះជាស្ដេចសាឡូមូន
កាលទ្រង់មានសិរីរុងរឿង ក៏ទ្រង់គ្មានព្រះភូសាល្អ
ស្មើនឹងផ្កាមួយទងនេះផង ហេតុនេះចូរអ្នកកុំខ្វល់ខ្វាយ ។

## ១០៦- ដូចសមុទ្រមានខ្យល់ព្យុះខ្លាំងណាស់

១-ដូចសមុទ្រមានខ្យល់ព្យុះខ្លាំងណាស់ ជីវិតយើងក៏ដូច្នេះដែរ
មានទុក្ខជិតស្លាប់ ដូចខ្យល់ព្យុះបក់បោក អស់សង្ឃឹមគ្មានអ្នកណាពឹងផ្អែក ។

២-កុំភ្លេចថាព្រះគ្រីស្ដគង់នៅជាមួយ ព្រះអង្គជួយអ្នកដែលមានកម្លាំងទន់ខ្សោយ
ឲ្យត្រឡប់មកវិញ រកព្រះគ្រីស្ដដែលជាជីវិត ទុកចិត្តលើព្រះគ្រីស្ដនាំចិត្តយើង ។

**បន្ទរ-ពឹងផ្អែកលើព្រះគ្រីស្ដ ទុកចិត្តលើព្រះអង្គ ព្រោះទ្រង់ជាថ្មដារឹងមាំ**
**ព្រះគ្រីស្ដជាព្រះអម្ចាស់ ព្រះគ្រីស្ដជាកម្លាំង ទ្រង់ជាខែល**
**ដែលទ្រង់ជួយការពារយើង ។ តទៅនេះ ខ្ញុំទុកចិត្តថា**
**ព្រះគ្រីស្ដគង់នៅជាមួយយើង ព្រោះព្រះអង្គមានជ័យជម្នះ**
**លើក្ដីស្លាប់ ធ្វើឲ្យយើងមិនភ័យខ្លាចឡើយ ។ (២ដង)**

## ១០៧- តាមគំរូនៃព្រះហឫទ័យស្រឡាញ់

១- ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំប្រទានឲ្យអ្នករាល់គ្នាវិន័យថ្មីមួយ
មិត្តសម្លាញ់ចូរស្រឡាញ់គ្នាទៅវិញទៅមក ចូរស្តាប់ខ្ញុំអ្នកនឹងមានជីវិតអស់កល្ប ។

**បន្ទរ-សូមឲ្យយើងខ្ញុំចេះផ្សាយដំណឹងល្អ ប្រោសយើងខ្ញុំឲ្យចេះបង្រួបបង្រួមបងប្អូន**
**ឲ្យយើងខ្ញុំធ្វើសក្ខីភាពពីការអត់ទោស តាមគំរូនៃហឫទ័យស្រឡាញ់ព្រះអង្គ ។**

២-ពេលមានការប្រមាថស្អប់ខ្ពើមនិងសង្គ្រាម ពេលមានភាពអយុត្តិធម៌និងពេលមានទុក្ខភ័យ
ក្នុងកណ្តាលភាពព្រងើយយើងខ្ញុំនេះ សូមព្រះអង្គរំឭកយើងខ្ញុំនូវព្រះបន្ទូលព្រះអង្គ ។

៣- ព្រះអង្គសោយទិវង្គតឰដ៏ឈើឆ្កាង ដើម្បីប្រោសលោះមនុស្សលោកគ្រប់ជាតិគ្រប់សាសន៍
សូមបង្រៀនឲ្យយើងចេះផ្សះផ្សាគ្នា ដ្បិតយើងខ្ញុំជាបុត្រធីតាព្រះបិតាតែមួយ ។

## ១០៨- តើនរណាអាចរស់នៅក្នុងដំណាក់

**បន្ទរ- ឱ! ព្រះជាម្ចាស់ តើនរណាខ្លះ អាចរស់នៅក្នុង ដំណាក់ម្ចាស់ក្រុង**
**តើនរណាខ្លះ អាចស្ថិតនៅលើ ភ្នំដ៏វិសុទ្ធ នៃព្រះអង្គបាន ។**

១-គឺមានតែមនុស្ស ដែលគ្មានទោស និងប្រព្រឹត្តអំពើសុចរិត និយាយពិតជាដរាប ។

២-អ្នកមិននិយាយមួល បង្កាច់ផ្តួល មិនធ្វើបាប បងប្អូនដែលទន់ទាប មិនបង្អាប់កិត្តិយស ។

៣-អ្នកមិនរាប់រកអ្នក ដែលព្រះម្ចាស់មិនស្ម័គ្រស្មោះ តែគេលើកកិត្តិយស អ្នកគោរពកោតព្រះអង្គ ។

៤-បើគេសន្យាអ្វីឬទោះបី ខូចខាតបង់ ក៏គេមិនបង្អង់ គេគោរពពាក្យសម្តី ។

៥-បើមាននរណាម្នាក់ មករកប្រាក់ គេឲ្យខ្ចី មិនចង់បានកម្រៃ ច្រើនតិចក្តីគេមិនយក ។

៦-អ្នកប្រព្រឹត្តដូច្នេះ ជាមនុស្សចេះ អាចចូលជ្រក ក្រោមបារមីរៀងមក និងបានសុខជានិរន្តរ៍ ។

# ១០៩- តើព្រះជាម្ចាស់ជានរណា ?

## (ចម្រៀងទី ២)

១- តើព្រះជាម្ចាស់ ទ្រង់ជានរណា វិសេសថ្លៃថ្លា ខ្ពង់ខ្ពស់ពេកក្រៃ
តែឆាប់រងការ ឈឺចាប់ជងណា តើព្រះអង្គនេះ ទ្រង់ជានរណា ?

**បន្ទរ-តើព្រះជាម្ចាស់ជានរណា (២ដង) ដែលស្រឡាញ់មនុស្សយើងយ៉ាងនេះ ?**

២-តើព្រះជាម្ចាស់ ទ្រង់ជានរណា ដែលចងសម្ពន្ធ មេត្រីស្នេហ៍ភាព
ទ្រង់ជានរណា ដែលយើងត្រូវការចិត្តក្រីក្រណាស់ ទើបរកទ្រង់ឃើញ?

៣-តើព្រះជាម្ចាស់ ទ្រង់ជានរណា ដែលរួមដំណើរ នឹងយើងទេតើ
ទ្រង់ជានរណា ដែលមកពិសា រួមតុនឹងយើង ដោយគ្មានរអើម?

៤-តើព្រះជាម្ចាស់ ទ្រង់ជានរណា ដែលត្រូវការយើងស្រឡាញ់មនុស្ស
ទើបអាចស្រឡាញ់ ព្រះអង្គជងនោះ តើព្រះអង្គនោះ ទ្រង់ជានរណា ?

៥-តើព្រះជាម្ចាស់ ទ្រង់ជានរណា ដែលយើងធ្វើឲ្យ អាក់អន់ហឫទ័យ
ដោយធ្វើឲ្យមនុស្ស អាក់អន់ចិន្តា តើអង្គនេះណា ទ្រង់ជានរណា?



# ១១០- ទឹកផ្តល់ជីវិត

(ដកស្រង់ពី យហ ៤,៧-១៥)

បន្ទរ-ប្រសិនបើអ្នក ស្គាល់ព្រះអំណោយទាន នៃព្រះជាម្ចាស់
និងស្គាល់អ្នកដែល សុំទឹកពីអ្នក មកទទួលទាន អ្នកមុខជាសុំ
ទឹកពីលោកវិញ ហើយលោកនឹងឲ្យ ទឹកផ្តល់ជីវិត ។

១- អណ្តូងពិតជាជ្រៅ ធ្វើម្តេចទៅដើម្បីដង
បើលោកគ្មានអ្វីដង លោកបានទឹកនោះមកពីណា ? ។

២- អ្នកផឹកទឹកនេះណា នៅតែស្រេកនៅតែឃ្លាន
ឯទឹកខ្ញុំប្រទាន មិនឲ្យឃ្លានស្រេកទៀតឡើយណា ។

៣- ដ្បិតទឹកខ្ញុំប្រទាន នឹងក្លាយជាប្រភពទឹក
ផុសឡើងក្នុងអ្នកផឹក ផ្តល់ជីវិតអស់កល្បជានិច្ច ។

៤- លោកម្ចាស់សូមមេត្តា ប្រទានទឹកឲ្យខ្ញុំម្ចាស់
កុំឲ្យខ្ញុំស្រេកណា ឈប់យាត្រាមកដងទឹកណា ។



# ១១១- ធម៌មេត្តាករុណារបស់ព្រះអង្គ

(ដកស្រង់ពីទំនុកតម្កើង លេខ ១៣៦)

**បន្ទរ-ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះហឫទ័យព្រះអង្គសប្បុរស**
**ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ !។**

១- ចូរលើកតម្កើងព្រះដែលខ្ពង់ខ្ពស់ លើសព្រះនានា
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ចូរសរសើរតម្កើងព្រះអម្ចាស់ ដែលខ្ពង់ខ្ពស់លើសម្ចាស់នានា
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

២- ព្រះអង្គធ្វើការអស្ចារ្យ ដ៏ឧត្តុង្គឧត្តមបំផុត
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ព្រះអង្គបានបង្កើតផ្ទៃមេឃ ដោយព្រះប្រាជ្ញាញាណ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

៣- ព្រះអង្គបានលាតសន្ធឹងផែនដី ពីលើផ្ទៃទឹក
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ព្រះអង្គបង្កើតដុំពន្លឺ សម្រាប់រះបំភ្លឺ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

៤- គឺព្រះអាទិត្យឲ្យគ្រប់គ្រង គ្រប់គ្រងនៅពេលថ្ងៃ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ព្រះច័ន្ទ និងហ្វូងតារា ឲ្យគ្រប់គ្រងនៅពេលយប់
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

៥- ព្រះអង្គនាំជនជាតិអ៊ីស្រាអែល ដើរកាត់បាតសមុទ្រនោះ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ព្រះអង្គដឹកនាំអ៊ីស្រាអែល នៅវាលរហោស្ថាន
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

៦- ព្រះអង្គបានប្រគល់ទឹកដីពួកគេ ឲ្យប្រជារាស្ត្រព្រះអង្គ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ព្រះអង្គរំដោះយើងឲ្យរួច ពីកណ្តាប់ដៃរបស់បច្ចាមិត្ត
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

៧- ព្រះអង្គប្រទានអាហារ ដល់សត្វលោកទាំងឡាយ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។
- ចូរលើកតម្កើងព្រះជាម្ចាស់ ឯស្ថានបរមសុខ
ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ ! ។

## ១១២- ធម៌សន្តអ៊ីញ៉ាស៊ីយ៉ូ នៅឡូយ៉ូឡា

១- សូមព្រះអម្ចាស់ទ្រង់មេត្តា ទទួលប្រាជ្ញានិងស្មារតី
ទាំងសេរីភាពទាំងឆន្ទៈ ដែលជាកម្មសិទ្ធទូលបង្គំ ។

២- គឺព្រះអង្គទ្រង់បានប្រទាន អ្វីៗដែលទូលបង្គំមាន
ទូលបង្គំសូមថ្វាយទ្រង់វិញ សូមទ្រង់បាត់ចែងតាមហឫទ័យ ។

**បន្ទរ- សូមទ្រង់មេត្តាប្រោសប្រទាន ព្រះអំណោយទាន និងក្តីស្រឡាញ់**
**នៃព្រះអង្គឲ្យទូលបង្គំផង ប៉ុណ្ណឹងល្មមឲ្យទូលបង្គំហើយ ។**

## ១១៣- ធម៌របស់សន្តហ្វ្រង់ស៊ីស្កូ ១

បន្ទរ- ឱ ! ព្រះអម្ចាស់អើយ សូមឲ្យខ្ញុំយកចិត្តទុកដាក់រំលែកទុក្ខ
អ្នកឯទៀត ជាជាងឲ្យគេរំលែកទុក្ខខ្ញុំ ។
សូមឲ្យខ្ញុំចេះ យល់ចិត្តអ្នកដទៃ ជាជាងឲ្យគេយល់ចិត្តខ្ញុំ ។
សូមឲ្យខ្ញុំចេះ ស្រឡាញ់អ្នកដទៃ ជាជាងឲ្យគេស្រឡាញ់ខ្ញុំ ។

១-ដ្បិតពេលណាយើងស្ម័គ្របូជាជីវិត ពេលនោះយើងទទួលជីវិតវិញ ។
២-ដ្បិតពេលណាយើងលះបង់ប្រយោជន៍ផ្ទាល់ ពេលនោះយើងទទួលប្រយោជន៍វិញ ។
៣-ដ្បិតពេលយើងអត់ទោសឲ្យអ្នកដទៃ នោះព្រះអម្ចាស់លើកលែងទោសឲ្យយើង ។
៤-ដ្បិតពេលណាយើងលាចាកលោកនេះទៅ ពេលនោះយើងនឹងមានជីវិតជានិច្ច ។

## ១១៤- ធម៌របស់សន្តហ្វ្រង់ស៊ីស្កូ ២

**បន្ទរ- ឱ ! ព្រះអម្ចាស់អើយ សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំចេះ
កសាងសន្តិភាព ដែលមកពីព្រះអង្គ ។**

១- នៅពេលមនុស្សស្អប់គ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំបង្ហាញសេចក្តីស្រឡាញ់
ពេលមនុស្សប្រមាថគ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំចេះនាំគេឲ្យអត់ទោស
គ្នាទៅវិញទៅមក ។

២- ពេលមនុស្សបាក់បែកគ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំចេះសម្រុះសម្រួលគ្នា
ពេលមនុស្សមានសង្ស័យ មិនទុកចិត្តគ្នាសូមព្រះអង្គប្រទានឲ្យខ្ញុំនាំគេ
ឲ្យទុកចិត្តគ្នាវិញ ។

៣- ពេលមនុស្សបាកក្តីពិត សូមព្រះអង្គប្រទានឲ្យខ្ញុំនាំគេរកសេចក្តីពិត
ពេលមនុស្សអស់សង្ឃឹម សូមព្រះអង្គប្រទានឲ្យខ្ញុំចេះនាំគេឲ្យមាន
ក្តីសង្ឃឹមឡើងវិញ ។

៤- ពេលមនុស្សកើតទុក្ខព្រួយ សូមព្រះអង្គប្រទានឲ្យខ្ញុំជួយសម្រាលទុក្ខគេ
ពេលមនុស្សខ្វាក់ងងឹត សូមព្រះអង្គប្រទានឲ្យខ្ញុំនាំពន្លឺឲ្យភ្លឺ
ស្វាងរុងរឿង ។

## ១១៥- នេះជាអាហារឧត្តម

១- នេះជាអាហារឧត្តម សម្រាប់ចិញ្ចឹមជីវិត
បើយើងយកមកទទួលទាន យើងមានជីវិតអនន្ត ។
២- ឱ ! ព្រះជាម្ចាស់យេស៊ូ ជាព្រះអម្ចាស់បវរ
សូមទ្រង់យាងមកគង់សណ្ឋិត ក្នុងដួងចិត្តនៃយើងខ្ញុំ ។
៣- យើងខ្ញុំច្រៀងអរសាទរ ថ្វាយព្រះជាម្ចាស់ជីវិត
នាំយើងទៅស្ថានបរមសុខ រស់នៅអស់កល្បជានិច្ច ។

## ១១៦- បពិត្រព្រះអម្ចាស់

បពិត្រព្រះអម្ចាស់ សូមមានព្រះបន្ទូលមកខ្ញុំ
ទូលបង្គំជាអ្នកបម្រើ រង់ចាំស្ដាប់ហើយៗ
ព្រះបន្ទូលរបស់ព្រះអង្គ ផ្ដល់ជីវិតអស់កល្បជានិច្ច ។



## ១១៧- ពេលណាយើងស្រឡាញ់គ្នា

បន្ទរ- ពេលណាយើងស្រឡាញ់គ្នា យ៉ាងពិតប្រាកដ
ពេលនោះព្រះជាអម្ចាស់ គង់ជាមួយយើង
ពេលណាយើងរួបរួមគ្នា ពេលនោះព្រះជាអម្ចាស់ប្រទានពរឲ្យយើង ។

១- ឱ ! ព្រះអង្គអើយ យើងខ្ញុំសូមគាល់បម្រើព្រះអង្គ
ដោយចិត្តសប្បាយ ព្រះអង្គបង្រួបបង្រួមយើងខ្ញុំជាធ្លុងតែមួយ
ព្រះអង្គបានជួយសង្គ្រោះយើងខ្ញុំ ដោយបានបូជាព្រះជន្មព្រះអង្គ ។

២-ឱ ! ព្រះអង្គអើយ សូមទ្រង់មេត្តាបំបាត់ទុក្ខភ័យ
របស់យើងខ្ញុំ សូមទ្រង់បំពេញដួងចិត្តយើងខ្ញុំដោយសន្តិភាព
ហើយសូមប្រទានឲ្យមនុស្សទាំងឡាយ នូវអំណោយទានតាមយើងខ្ញុំសូម ។

៣-សូមទ្រង់មេត្តា ធ្វើឲ្យរូបកាយពេញដោយទុក្ខព្រួយ
របស់យើងខ្ញុំ ឲ្យបានដូចជាព្រះកាយព្រះអង្គជារៀងរាល់ថ្ងៃ
យើងខ្ញុំប្រុងប្រៀបទទួលព្រះអង្គ នៅថ្ងៃដែលទ្រង់នឹងយាងមកវិញ ។

៤-នៅថ្ងៃចុងក្រោយ យើងខ្ញុំសប្បាយយ៉ាងពិតប្រាកដ
ដោយនឹងរស់នៅ ជាមួយសន្តបុគ្គលទាំងឡាយ
ក្នុងសិរីយសដ៏សែនរុងរឿងរបស់ព្រះអង្គ ហើយបានសុខសាន្តអស់កល្បជានិច្ច ។

## ១១៨- ព្រលឹងខ្ញុំស្រេកឃ្លានព្រះជាម្ចាស់

(ដកស្រង់ពីទំនុកតម្កើងលេខ ៦៣-៦២)

បន្ទរ- ឱ! ព្រះជាម្ចាស់អើយ ព្រះអង្គពិតជាព្រះខ្ញុំមែន
ខ្ញុំស្វែងរកព្រះអង្គ ដូចដីស្ងួតបែកក្រហែង
ស្រេកឃ្លានទឹកភ្លៀងនោះយ៉ាងណា ព្រលឹងខ្ញុំស្រេកឃ្លានព្រះអង្គ ។

១- រូបខ្ញុំស្រេកឃ្លាន ព្រះប្រាជ្ញាញាណ អាល័យនឹកភ្នក ដូចដីប្រេះបែក
គ្មានភ្លៀងធ្លាក់មក ខ្ញុំដើរកាត់ជ្រក គ្រប់ទីទិសា ។

២-សូមឲ្យរូបខ្ញុំ បានឃើញព្រះអង្គ ក្នុងទីសក្ការ ខ្ញុំចង់ឃើញណាស់
បារមីឫទ្ធា អំណាចបេស្ដា របស់ព្រះអង្គ ។

៣-ហឫទ័យមេត្តា សន្ដោសករុណា ប្រសើរឥតហ្មង ខ្ញុំនឹងពោលពាក្យ
សរសើរតម្កើង សិរីរុងរឿង ព្រះម្ចាស់មានឫទ្ធិ ។

៤- ខ្ញុំសូមថ្លាថ្លែង អំណរក្រៃលែង អស់មួយជីវិត ខ្ញុំសូមលើកដៃ
បង្គំថ្វាយថ្វាត់ ព្រះនាមវិសុទ្ធ ព្រះអង្គតែមួយ ។

៥- ខ្ញុំសែនសប្បាយ ឥតមានខ្វល់ខ្វាយ ព្រោះមានព្រះជួយ បានសុខរមនា
គ្មានភ័យគ្មានព្រួយ ព្រះម្ចាស់តែមួយ ខ្ញុំច្រៀងតម្កើង ។

៦- រៀងរាល់រាត្រី ខ្ញុំនឹកស្រមៃ ទៅដល់ព្រះអង្គ អស់ពេញមួយយប់
រាត្រីកន្លង នឹកដល់ព្រះអង្គ ឥតមានពេលភ្លេច ។

៧-ព្រោះតែព្រះអង្គ បានជួយតម្រង់ រូបខ្ញុំជានិច្ច ខ្ញុំច្រៀងខ្ញុំរាំ
សប្បាយពន់ពេក ឥតមានរារែក ក្រោមម្លប់បារមី ។

៨-ចិត្តខ្ញុំជំពាក់ ឥតមានស្រាន្តស្រាក នឹកគិតអាល័យ ទៅដល់ព្រះម្ចាស់
ទោះយប់ឬថ្ងៃ ទ្រង់គាំទ្រឲ្យ រីកមុខស្រស់ថ្លា ។

## ១១៩- ព្រះកាយព្រះគ្រីស្ត

១- យើងសូមក្រាបសំពះព្រះគ្រីស្ត សូមលើកតម្កើងព្រះគ្រីស្ត
សូមព្រះអង្គទ្រង់ព្រះមេត្តា គង់ជាមួយយើងរាល់គ្នា ។

**បន្ទរ- ឱព្រះកាយាព្រះគ្រីស្ត ដែលជាជីវិតរបស់យើង**
**យើងកោតសរសើរ សូមទ្រង់គង់ជាមួយយើង ។**

២- យើងជឿពិតក្នុងព្រះបន្ទូល អ្នកណាទទួលព្រះកាយ
នឹងមានជីវិតរស់អស់កល្ប សូមឲ្យយើងបានសុខសាន្ត ។

## ១២០- ព្រះគ្រីស្តព្រលឹងខ្ញុំស្រេកឃ្លាន

(គ្រហឹម) ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ

**បន្ទរ-ប. សូមព្រះគ្រីស្តយាងមកក្នុងព្រលឹងខ្ញុំ ចិត្តខ្ញុំរង់ចាំទន្ទឹងព្រះអង្គមួយ**
**សូមទ្រង់កុំបែរព្រះភក្ត្រចេញឡើយ តែឲ្យខ្ញុំជឿស្រឡាញ់សង្ឃឹមមែន ។**

១- **ស.** ឱ ! ព្រះគ្រីស្តព្រលឹងខ្ញុំស្រេកឃ្លាន **ប.**យើងខ្ញុំស្រេកឃ្លាន
ឲ្យបាននៅក្បែរព្រះអង្គ នៅក្បែរព្រះអង្គ
ដូចប្រើសស្រេកឃ្លានរត់រកទឹកជ្រោះ **រួម.**ខ្ញុំរត់មករកព្រះអង្គជាម្ចាស់ ។

២- **ស.** ឱ ! ព្រះគ្រីស្តព្រលឹងខ្ញុំភ័យខ្លាច **ប.**យើងខ្ញុំភ័យខ្លាច
ព្រោះខ្ញុំមិនសមទទួលព្រះអង្គ ទទួលព្រះអង្គ
ជាស្ដេចធំលើសខ្ពង់ខ្ពស់បំផុត **រួម.**ឲ្យមកសណ្ឋិតក្នុងព្រលឹងខ្ញុំ ។

## ១២១- ព្រះគ្រីស្ដព្រលឹងខ្ញុំស្រេកឃ្លាន

១- ឱ ! ព្រះគ្រីស្ដព្រលឹងខ្ញុំស្រេកឃ្លាន ស្រេកឃ្លានឲ្យបាននៅក្បែរព្រះអង្គ
ដូចប្រើសស្រេកឃ្លានរត់រកទឹកជ្រោះ ខ្ញុំរត់មករកព្រះអង្គជាម្ចាស់ ។

**បន្ទរ-សូមទ្រង់យាងមកក្នុងព្រលឹងខ្ញុំ ចិត្តខ្ញុំរង់ចាំទន្ទឹងព្រះអង្គមួយ**
**សូមទ្រង់កុំបែរព្រះភក្ត្រចេញឡើយ តែឲ្យខ្ញុំជឿស្រឡាញ់សង្ឃឹមមែន ។**

៣- ឱ ! ព្រះអង្គព្រលឹងខ្ញុំភ័យខ្លាច ព្រោះខ្ញុំមិនសមទទួលព្រះអង្គ
ជាស្ដេចធំលើសខ្ពង់ខ្ពស់បំផុត ឲ្យមកសណ្ឋិតក្នុងព្រលឹងខ្ញុំ ។

## ១២២- ព្រះគ្រីស្ដជាគង្វាល

បន្ទរ- ព្រះគ្រីស្ដជាគង្វាលការពារខ្ញុំ កាលព្រះអង្គដឹកនាំខ្ញុំ ខ្ញុំមិនខ្លាចស្លាប់ឡើយ ។

១- វាលស្មៅដ៏ខៀវស្រងាត់ ជាជំរុំដែលសម្រាកកាយ
រីទឹកជ្រោះវែងអន្លាយ ព្រះម្ចាស់ទុកឲ្យខ្ញុំបរិភោគ ។

២- នាកាលសត្រូវបៀតបៀន ខ្ញុំក្លាហានមិនខ្លាចក្ដីស្លាប់
ដោយគុណព្រះអានុភាព អំពើបាបលាចាកទៅឆ្ងាយ ។

៣- ព្រះគ្រីស្ដទ្រង់ប្រោសប្រណី ប្រក្រតីខ្ញុំសង្ឃឹមរឿយ
លុះត្រាខ្ញុំដល់គ្រាណត្រើយ ទីសុខសាន្តក្នុងស្ថានបរមសុខ ។

# ១២៣- ព្រះគ្រីស្ដជាផ្លូវ

**បន្ទរ-ឱ ! ព្រះគ្រីស្ដអើយ ទ្រង់ជាផ្លូវហើយ ជាសេចក្ដីពិត ទ្រង់ជាជីវិត**
**ជាក្ដីសង្ឃឹម អំណរសប្បាយ របស់យើងខ្ញុំ ។**

១- ព្រះគ្រីស្ដមានព្រះបន្ទូលថា៖ ខ្ញុំនេះហើយពិតជាពន្លឺ បំភ្លឺពិភពលោកងងឹត
អស់អ្នកដែលដើរតាមខ្ញុំពិត នឹងបានដើរពិតក្នុងពន្លឺ ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

២- ព្រះគ្រីស្ដមានព្រះបន្ទូលថា៖ ខ្ញុំជាដើមទំពាំងបាយជូរ រីឯអ្នករាល់គ្នាជាមែក
មែកណាដែលជ្រាភ្ជាប់នឹងខ្ញុំ មែកនោះបង្កើតផលផ្លែល្អ ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

៣- ព្រះគ្រីស្ដមានព្រះបន្ទូលថា៖ ខ្ញុំជាទឹកដែលផ្ដល់ជីវិត ប្រភពពិតអំណរសប្បាយ
អស់អ្នកស្រេកឃ្លានហើយនឿយណាយ ចូរមករកខ្ញុំនឹងលែងស្រេក ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

៤-ព្រះគ្រីស្ដមានព្រះបន្ទូលថា៖ ខ្ញុំជាផ្កាយព្រឹករបស់អ្នក ដែលថ្លៃងបញ្ចាក់ថ្ងៃគ្មានផុត
ថ្ងៃរុងរឿងគ្មានទីបំផុត លើភពងងឹតលោកីយ៍នេះ ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

៥- ព្រះគ្រីស្តមានព្រះបន្ទូលថា៖ ខ្ញុំជាគង្វាលដ៏សប្បុរសខ្ញុំស្វែងរកនិងដឹកនាំចៀម ។
ចូរត្រង់ត្រាប់ស្តាប់កុំធ្វើហី បើថ្ងៃនេះខ្ញុំត្រាស់ហៅអ្នក ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

៦-ព្រះគ្រីស្តមានព្រះបន្ទូលថា៖ ខ្ញុំជាជីវិតយ៉ាងរុងរឿង ដែលបើកផ្លូវនៃអ្នករាល់គ្នា
ហើយត្រាស់ហៅអ្នកឲ្យយាត្រា ដើម្បីចូលព្រះរាជ្យនៃខ្ញុំ ។
ខ្ញុំរស់ដោយមានជំនឿ លើព្រះបុត្រា របស់ព្រះជាអម្ចាស់
ព្រះអង្គទ្រង់ស្រឡាញ់ខ្ញុំ ហើយបានបូជា ព្រះជន្មដើម្បីរូបខ្ញុំ ។

## ១២៤- ព្រះគ្រីស្តជាព្រះមាគ៌ា

១-**ស.** ព្រះគ្រីស្តមានបន្ទូលថា **ប.** ខ្ញុំជាពន្លឺក្នុងទីងងឹត
អ្នកណាដើរតាមខ្ញុំ អ្នកនោះមិនដើរក្នុងទីងងឹតឡើយ ។

**បន្ទរ-ស. ព្រះជាអម្ចាស់ ជាព្រះមាគ៌ា និងជីវិតយើងខ្ញុំ**

**ប. ឱ ! ព្រះអង្គអើយ ស.ឱ ! ព្រះអង្គអើយ**

**ប. ទ្រង់ជាក្តីពិត ស.ទ្រង់ជាក្តីពិត**

**ប. សេចក្តីសង្ឃឹម ស.សេចក្តីសង្ឃឹម** (រួម) **សេចក្តីសប្បាយរបស់យើងខ្ញុំ ។**

២-**ស.** ព្រះគ្រីស្តមានបន្ទូលថា **ប.** ខ្ញុំជាជ្រោះទឹកដែលផ្តល់ជីវិត
អ្នកណាស្រេកទឹកខ្លាំង ចូរដើរមករកខ្ញុំនោះលែងស្រេកហើយ ។

៣-**ស.** ព្រះគ្រីស្តមានបន្ទូលថា **ប.** ខ្ញុំជាក្តីសប្បាយពិតប្រាកដ
កាលខ្ញុំនឹងមកវិញ អ្នករាល់គ្នានឹងផុតទុក្ខក្នុងលោកា ។

៤-**ស.** ព្រះគ្រីស្តមានបន្ទូលថា **ប.** ខ្ញុំជាជីវិតអស់កល្បជានិច្ច
កាលអ្នកបាកលោកីយ៍ ខ្ញុំនឹងនាំអ្នកចូលក្នុងព្រះរាជ្យខ្ញុំ ។

## ១២៥- ព្រះគ្រីស្តជាម្ចាស់នៃសត្វលោក

១- ចូរត្រេកសប្បាយ ញញឹមរីករាយ អរនឹងព្រះគុណ នៃព្រះបិតា
ដែលប្រោសពេកពន់ ឲ្យអស់បងប្អូន បានសម្បត្តិ នៅស្ថានបរមសុខ ។

២-បងប្អូនទទួល ជួបជុំខ្មៅខ្មួល រៀបរៀងតាមជួរ រួមប្រជាជន
ស្រុះស្រួលគាប់គួរ ចូលក្នុងពន្លឺ ព្រះរាជ្យភ្លឺ ថ្លាពន់ពេកក្រៃ ។

៣-ព្រះអង្គបានប្រោស ឲ្យយើងបានរស់ រួចផុតពីមារ ដែលមានអំណាច
កោងកាចឫស្យា ប្រព្រឹត្តទោសា នៅទីងងឹត ហួសនិស្ស័យ ។

៤- ព្រះអង្គចម្លង បានចូលតែម្តង ក្នុងព្រះរាជ្យពិត នៃព្រះបុត្រា
ជាទីរួមសិទ្ធ ស្រឡាញ់ជំនិត របស់ព្រះ អង្គជាបិតា ។

៥- ដោយយើងរួមជា មួយព្រះបុត្រា ទ្រង់បានលោះផង លើកលែងទាំងទោស
រំដោះបាបបង់ ឲ្យយើងជូរជង់ ជាបុត្រថ្លាថ្លៃ នៃព្រះជាម្ចាស់ ។

## ១២៦- ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ

**បន្ទរ-ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ តាំងពីខ្ញុំក្នុងផ្ទៃម្តាយ ទ្រង់បានតែងតាំងខ្ញុំឲ្យធ្វើ**
**ព្យាការីព្រះម្ចាស់ ទូលបង្គំគ្មានសិទ្ធិ នឹងថ្លែងព្រះបន្ទូលទេ**
**ដ្បិតទូលបង្គំនៅក្មេងពេក និយាយមិនបានល្អ ។**

១- កុំពោលថា ខ្ញុំនៅក្មេងពេកនោះឡើយ អ្នកត្រូវតែ
ជួបអស់អ្នកដែលត្រូវជួប ហើយនឹងប្រកាសសេចក្តី ទាំងប៉ុន្មានដែលយើងនឹង
បង្គាប់អ្នកឲ្យប្រកាស កុំភ័យខ្លាច ពួកគេឡើយ ។

២- យើងបានដាក់ ពាក្យយើងក្នុងមាត់អ្នកហើយ យើងតែងតាំង
ឲ្យអ្នកនឹងមានអំណាច ដើម្បីឲ្យអ្នករំលំ ឲ្យអ្នកកម្ទេចបំផ្លាញ
ហើយដើម្បីឲ្យអ្នកសង់ នឹងឲ្យអ្នកដាំឡើងវិញ ។

# ១២៧- ព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់

(ដកស្រង់ពីទំនុកតម្កើង ៣៤)

**បន្ទរ-ព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់ សម្ដីរាយរ៉ាប់ទូលអង្វរ**
**នៃអស់អ្នកកម្សត់ទុរគតក្រីក្រ ហឫទ័យទ្រង់ស្មោះសរជួយសង្គ្រោះ ។**

១- ខ្ញុំអរព្រះគុណ អម្ចាស់ពេកពន់ គ្រប់ពេលវេលា សូមលើកតម្កើង
ព្រះអង្គគ្រប់គ្នា ឥតមានរួញរា ឥតឈប់ឈរសោះឡើយណា ។

២- ខ្ញុំបានស្វែងរក ព្រះម្ចាស់តបមក ឥតមានបង្អង់ ទ្រង់បានរំដោះ
ខ្ញុំអស់ទុក្ខផង តក់ស្លុតមួយហ្វូង ខ្ញុំបានឆ្លងផុតទាំងអស់ ។

៣-អ្នកដែលសម្លឹង ឆ្ពោះទៅព្រះអង្គ បានសុខឥតមោះ ផុតអស់ទុក្ខសោក
វិយោគរងគ្រោះ ពួកគេទាំងនោះ មិនខកចិត្តសោះឡើយណា ។

៤-អស់អ្នកកម្សត់ និងមនុស្សទុរគត គេស្រែកដង្ហោយ ហៅរកព្រះម្ចាស់
ទ្រង់សណ្ដាប់ហើយ សង្គ្រោះគេឲ្យ រួចផុតពីគ្រោះកាចហើយ ។

៥- ទេវទូតរបស់ ព្រះម្ចាស់ទាំងអស់ ថែទាំអ្នកខ្លាច ឲ្យផុតគ្រោះកាច
ការពាររក្សា គេក្រោមអំណាច រំដោះឲ្យរួចទុក្ខភ័យ ។

៦- ចូរអ្នកពាក់ពឹង ពិសោធឲ្យដឹង ថាព្រះម្ចាស់ថ្លៃ ទ្រង់មានមេត្តា
សប្បុរសពេកក្រៃ អស់ជនប្រុសស្រី មានជ័យមង្គលគ្រប់គ្នា ។

៧- ព្រះម្ចាស់តែងតែ រំពៃមើលថែ អស់មនុស្សសុចរិត យកព្រះហឫទ័យ
ទុកដាក់ពិតៗ ថែទាំនៅជិត រាល់ទិនទិវាហើយណា ។

៨- ព្រះម្ចាស់គង់ជិត ក្បែរអ្នកគ្រាំចិត្ត មានទុក្ខខ្វល់ខ្វាយ ព្រះអង្គសង្គ្រោះ
អស់អ្នកទាំងឡាយ បានសុខសប្បាយ ឲ្យផុតអស់ទុក្ខរីងរៃ ។

៩- ព្រះជាអម្ចាស់ ទ្រង់សប្បុរសណាស់ តាមថែរក្សា ដល់មនុស្សសុចរិត
គ្រប់ៗអាត្មា គ្មានឆ្អឹងណាមួយ ដែលត្រូវបាក់បែកឡើយណា ។

១០-ព្រះម្ចាស់សង្គ្រោះ ជីវិតទាំងអស់ ដល់អ្នកដែលបាន បម្រើព្រះអង្គ
ពឹងផ្អែកផ្ញើប្រាណ តែងទទួលបាន សុខផុតទុក្ខទោសទាំងអស់ ។

## ១២៨- ព្រះជាម្ចាស់ប្រសើរថ្លៃថ្លា

បន្ទរ-ឱ ! ព្រះជាម្ចាស់ប្រសើរថ្លៃថ្លា ដែលគង់នៅស្ថានបរមសុខ
ខ្ញុំងើបភក្ត្រាសម្លឹងរំពៃ មើលព្រះអង្គថ្លៃរាល់ពេលវេលា ។

១- ប្រៀបបានដូចពួកខ្ញុំបម្រើ តែងសម្លឹងឆ្ពោះទៅហត្ថា
ម្ចាស់របស់ខ្លួនជាទីស្នេហា ឯខ្ញុំនេះណាក៏ដូច្នេះដែរ ។

២- ឱ ! ព្រះជាម្ចាស់ប្រសើរឧត្ដម គេប្រមាថខ្ញុំឥតមានល្ហែ
សូមទ្រង់សន្ដោសប្រោសប្រណីថៃ ឲ្យខ្ញុំបានល្ហែស្បើយពីទុក្ខា ។

៣- សូមលើកតម្កើងសិរីជោគជ័យ តេជះបារមីឆ្ពោះព្រះបិតា
សូមកោតសរសើរព្រះឯកបុត្រា និងក្រាបវន្ទាឆ្ពោះព្រះវិញ្ញាណ ។

## ១២៩- ព្រះជាម្ចាស់ប្រទានសុខសន្តិភាព

បន្ទរ- ព្រះអម្ចាស់មានបន្ទូលថា ខ្ញុំទុកសេចក្ដីសុខសាន្តឲ្យអ្នករាល់គ្នា
ខ្ញុំផ្ដល់សេចក្ដីសុខសាន្តឲ្យអ្នក សេចក្ដីសុខសាន្តដែលខ្ញុំផ្ដល់ឲ្យនោះ
មិនដូចសេចក្ដីសុខសាន្តដែលមនុស្សលោកឲ្យទេ
ចូរកុំតប់ប្រមល់កុំភ័យខ្លាចឲ្យសោះ ។

១- ឱ ! ព្រះជាម្ចាស់ថ្លាថ្លៃ សូមទ្រង់ប្រណី ប្រទានសន្តិភាពសិទ្ធី
សូមឲ្យយុត្តិធម៌ថ្មី នឹងក្ដីមេត្រី បញ្ចេញពីលើភ្នំមក ។

២- សូមទ្រង់លុះលង់វិះរក ឲ្យអ្នកទុរគត ទទួលយុត្តិធម៌ណា
សូមទ្រង់សង្គ្រោះរក្សា អ្នកក្រីក្រខ្វះ តោកយ៉ាកឲ្យគេមានបាន ។

## ១៣០- ព្រះជាម្ចាស់ជាពន្លឺ

**បន្ទរ- ព្រះជាម្ចាស់ទ្រង់ជាពន្លឺៗ ព្រះជាម្ចាស់ជាធម៌មេត្តាៗ ព្រះជាម្ចាស់គឺព្រះបិតាៗ ។**

១- ព្រះជាម្ចាស់ទ្រង់ជាពន្លឺ គ្មានភាពងងឹតក្នុងព្រះអង្គ
បើយើងដើរនៅក្នុងពន្លឺ ព្រះបន្ទូលស្ថិតនៅនឹងយើង ។

២- ព្រះជាម្ចាស់ជាធម៌មេត្តា អ្នកឯណាមានចិត្តករុណា
អ្នកនោះកើតពីព្រះជាម្ចាស់ ហើយគេស្គាល់ព្រះអង្គជងណា ។

៣- ព្រះជាម្ចាស់សម្ដែងមេត្តា ករុណានៅកណ្ដាលយើង
ព្រះអង្គចាត់ព្រះរាជបុត្រា ដើម្បីផ្ដល់ជីវិតឲ្យយើង ។

៤- យើងត្រូវមានចិត្តករុណា ព្រះជាម្ចាស់ជាធម៌មេត្តា
ទោះយើងមិនស្រឡាញ់ព្រះអង្គ ក៏ព្រះអង្គស្រឡាញ់យើងហើយ ។

# ១៣១- ព្រះជាម្ចាស់ស្គាល់ខ្ញុំច្បាស់

(ដកស្រង់ពីទំនុកតម្កើងលេខ ១៦៩-១៣៨)

**បន្ទរ- ឱ ! ព្រះជាម្ចាស់អើយ ! ទ្រង់នេះហើយស្គាល់ខ្ញុំពិត**
**ធម៌មេត្តាករុណា ព្រះជាម្ចាស់ដឹកនាំខ្ញុំ ។**

១- បពិត្រព្រះជាម្ចាស់ដ៏សប្បុរស ទ្រង់ឈ្វេងយល់អស់ជម្រៅចិត្ត
នៃទូលបង្គំដែលមានពិត ព្រះអង្គស្គាល់ឥតសល់ចន្លោះ ។

២- ទ្រង់ជ្រាបឥតបីមានសង្ស័យ ក្រោកឈរអង្គុយគ្រប់ទាំងអស់
ឈ្វេងយល់គំនិតខ្ញុំឥតខ្ចោះ ពីមុនទាំងអស់ស្រេចទៅហើយ ។

៣- ទោះបីដើរដេកធ្វើកិច្ចការ តិចច្រើនម្តេចម្តាមិនបាត់ឡើយ
ព្រះអង្គទ្រង់ជ្រាបអស់ទៅហើយ សម្រាកក៏ដោយមិនកំបាំង ។

៤- ទោះជាពាក្យពេចន៍ប្រុងនឹងស្តី ទ្រង់យល់អត្ថន័យអស់តែម្តង
សព្វទាំងសេចក្តីដែលបម្រុង ទុកក្នុងចិត្តផងក៏មិនសល់ ។

៥- ព្រះអង្គនៅពាំងទាំងមុខក្រោយ ការពារមិនឲ្យមានកង្វល់
មិនឲ្យខ្ញុំជួបគ្រោះអំពល់ ព្រោះតែទ្រង់ផ្តល់បារមីថ្លៃ ។

៦- នេះគឺព្រះអង្គទ្រង់ត្រាស់ញាណ ទើបទ្រង់ជ្រាបបានមិនសល់អ្វី
អស្ចារ្យពេកណាស់គួរស្ញែងក្រៃ ខ្ញុំមិនយល់ន័យដូចម្តេចសោះ ។

៧- តើទូលបង្គំអាចទៅណា ឆ្ងាយពីភក្ត្រាព្រះអង្គនោះ
គេចទៅទីណាមិនផុតសោះ ព្រះអង្គជ្រាបអស់សព្វទិសា ។

៨- បើខ្ញុំនឹងឡើងទៅលើមេឃ ក៏មិនផុតភ្នែកផុតនេត្រា
បើទៅស្ថានមនុស្សមរណា ក៏ជួបភក្ត្រាទ្រង់ជានិច្ច ។

៩- ទោះបីជាខ្ញុំពាក់ស្លាបហោះ ទៅកន្លែងរះព្រះអាទិត្យ
ឬទោះបីខ្ញុំចង់រត់គេច ទៅរស់ឯលិចនាយសមុទ្រ ។

១០- ក៏ព្រះអង្គគង់នៅទីនោះ ឥតមានចន្លោះឬគេចផុត
ជួយដឹកនាំខ្ញុំលែងតក់ស្លុត ដោយបារមីឫទ្ធិដ៏ឧត្តម ។
១១- ប្រសិនបើខ្ញុំពោលឡើងថា សូមឲ្យអន្ធិកាគ្របលើខ្ញុំ
ពន្លឺថ្ងៃដែលនៅជិតជុំ ប្រែក្លាយយប់ជ្ដុំឥតពន្លឺ ។
១២- ទោះបីងងឹតយ៉ាងណាក្ដី ព្រះអម្ចាស់ថ្លៃនៅតែភ្លឺ
ពេលយប់ដូចថ្ងៃជះរន្ទឺ ងងឹតប្រែភ្លឺមានរស្មី ។
១៣- ព្រះអង្គបង្កើតខ្ញុំបានសុខ ហើយទ្រង់បានទុកខ្ញុំក្នុងផ្ទៃ
អ្នកម្ដាយមានគុណយូរខែថ្ងៃ សន្ដោសប្រណីគ្រប់កាយា ។
១៤- ខ្ញុំសូមលើកតម្កើងព្រះអង្គ ស្នាព្រះហស្តទ្រង់ដ៏អស្ចារ្យ
ខ្ញុំដឹងថាអ្វីគ្រប់ប្រការ សុទ្ធតែអស្ចារ្យកើតពីទ្រង់ ។
១៥- ពេលទូលបង្គំចាប់កំណើត នៅក្នុងទីស្ងាត់លាក់កំបាំង
ក៏មិនអាចពួននឹងព្រះអង្គ អ្វីៗក៏ទ្រង់ជ្រាបទាំងអស់ ។
១៦- កាលទូលបង្គំមិនមានខ្លួន រូបកាយមាំមួនសាច់ឈាមស្រស់
ព្រះអង្គទតឃើញខ្ញុំទាំងអស់ ឥតមានចន្លោះត្រង់ណាឡើយ ។
១៧- ព្រះអង្គកំណត់ពេលជងណា អាយុសង្ខារខ្ញុំរួចហើយ
កត់ទុកជាស្រេចមិនកន្តើយ មុននឹងដល់ថ្ងៃនោះមកទៀត ។
១៨- ឱ! ព្រះជាម្ចាស់មានព្រះតម្រិះ ព្រះអង្គជ្រៅជ្រះជាងសមុទ្រ
ខ្ពស់ហួសអាកាសវេហាស៍ផុត មិនអាចកំណត់ដឹងប៉ុន្មាន ។
១៩- ប្រសិនបើចិត្តខ្ញុំចង់រាប់ ក៏មិនអាចគ្រប់ទាំងអស់បាន
ពីការអស្ចារ្យទាំងប៉ុន្មាន មានចំនួនច្រើនជាងគ្រាប់ខ្សាច់ ។
២០- ព្រះជាម្ចាស់អើយសូមពិនិត្យ ឲ្យបានស្គាល់ចិត្តជុតកង្វល់
ទាំងល្បងមើលខ្ញុំឲ្យអស់ខ្វល់ ដើម្បីឲ្យយល់អ្វីដែលខ្ញុំគិត ។
២១- សូមព្រះជាម្ចាស់ទតមើលតើ ខ្ញុំមិនបានដើរខុសពីក្រឹត្យ
ជួយដឹកនាំខ្ញុំឲ្យជួបជិត មាគ៌ាប្រណិតនៅអស់កល្ប ។

## ១៣២- ព្រះបន្ទូលព្រះគ្រីស្ដ

ព្រះបន្ទូលព្រះគ្រីស្ដជាផ្លូវ ជាពន្លឺ ព្រះបន្ទូលព្រះគ្រីស្ដជាជីវិតនឹងសេចក្ដីពិត
សូមគង់ស្ថិតក្នុងដួងចិត្តយើងខ្ញុំរៀងរាល់ថ្ងៃ !

## ១៣៣- ព្រះបន្ទូលព្រះអង្គ

**(ហប ៤, ១២)**

| | | |
|---|---|---|
| ព្រះបន្ទូលព្រះអង្គ | មានជីវិត មានជីវិត | **(២ដង)** |
| មហិទ្ធិឫទ្ធិ | មុតជាងដាវមុខពីរ | **(២ដង)** |
| ព្រះបន្ទូលព្រះអង្គ | ព្រះបន្ទូលព្រះអង្គ ។ | |
| ព្រះបន្ទូលនេះ | ចាក់ទម្លុះ ចាក់ទម្លុះ | |
| ចូលទៅកាត់ព្រលឹង | ចូលទៅកាត់ព្រលឹង | **(២ដង)** |
| វិញ្ញាណដាច់ចេញពីគ្នា | កាត់សន្លាក់ឆ្អឹង | **(២ដង)** |
| និងខួរឆ្អឹងចេញពីគ្នា | និងខួរឆ្អឹងចេញពីគ្នា | |
| ព្រះបន្ទូលព្រះអង្គ | មានជីវិត មានជីវិត | **(២ដង)** |
| មហិទ្ធិឫទ្ធិ | មុតជាងដាវមុខពីរ | **(២ ដង)** |
| ព្រះបន្ទូលព្រះអង្គ | ព្រះបន្ទូលព្រះអង្គ ។ | |

## ១៣៤- ព្រះបន្ទូលព្រះអង្គជាចង្កៀង

**(ទំនុកតម្កើង ១១៩,១០៥)**

ព្រះបន្ទូលព្រះអង្គព្រះអង្គ ជាចង្កៀង បំភ្លឺជំហានទូលបង្គំ
បំភ្លឺជំហានទូលបង្គំ ពន្លឺ បំភ្លឺ ផ្លូវទូលបង្គំ ពន្លឺ បំភ្លឺ ផ្លូវទូលបង្គំ
ព្រះបន្ទូលព្រះអង្គ ព្រះអង្គ ។

## ១៣៥- ព្រះម្ចាស់តែមួយ

**បន្ទរ- ព្រះម្ចាស់តែមួយ ជំនឿតែមួយ បុណ្យជ្រមុជទឹក ក៏តែមួយពិត**
**រីឯព្រះម្ចាស់ ព្រះអង្គទ្រង់ជា ព្រះបិតាយើង ។**

១-ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យទទួលជំនឿតែមួយ ក្នុងអង្គព្រះគ្រីស្ត
យើងច្រៀងកោតសរសើរព្រះអង្គ ហើយយើងប្រកាសថា ។

២-ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យចូលរួមក្នុងព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត
យើងច្រៀងកោតសរសើរព្រះអង្គ ហើយយើងប្រកាសថា ។

៣-ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យទទួលក្ដីសង្ឃឹមតែមួយ ក្នុងអង្គព្រះគ្រីស្ត
យើងច្រៀងកោតសរសើរព្រះអង្គ ហើយយើងប្រកាសថា ។

៤-ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យក្លាយជាបុត្រធីតាតែមួយ ក្នុងអង្គព្រះគ្រីស្ត
យើងច្រៀងកោតសរសើរព្រះអង្គ ហើយយើងប្រកាសថា ។

## ១៣៦- ព្រះម្ចាស់ទ្រង់បានជ្រើសរើសយើង

បន្ទរ- ព្រះជាម្ចាស់បានជ្រើសរើសយើង ទ្រង់លើកតម្កើងតម្កល់ទុក
តទៅមុខតាមរយៈព្រះគ្រីស្ត ឲ្យទៅជាប្រជាជនថ្លៃថ្លា ។

១- សូមនាំគ្នាលើកតម្កើងព្រះ ជាអម្ចាស់វរព្រះបិតា
នៃព្រះយេស៊ូគ្រីស្តសាស្តា ជាម្ចាស់នៃយើងទ្រង់ជាស្ពាន
ព្រះអង្គប្រោសពរគ្រប់បែបយ៉ាង ពរថ្មីស្រឡាងទ្រង់ប្រទាន
ចេញមកឲ្យយើងពីវិញ្ញាណ ព្រះយេស៊ូគ្រីស្តបរមសុខ ។

២- ព្រះជាម្ចាស់បានលើកលែងទោស អស់ទាំងកំហុសទ្រង់ជាត់ញែក
តាមព្រះហឫទ័យប្រោសពន់ពេក ប្រណីប្រទានដ៏លើសលប់
យើងចូលរួមជាមួយព្រះគ្រីស្ត មិនបាច់ត្រិះរិះពិចារណា
រួចផុតពីបាបកម្មទោសា លែងមាននរណាហូរទឹកភ្នែក ។

៣- មិនតែប៉ុណ្ណោះទ្រង់សទ្ធា ទ្រង់ប្រោសវិជ្ជាចំណេះគ្រប់
ប្រាជ្ញាវាងវៃមិនស្គាល់យប់ ភ្លឺច្បាស់ចេះសព្វយល់គ្មានសល់
សព្វគម្រោងការណ៍អាថ៌កំបាំង ព្រះអង្គបញ្ចាំងឲ្យយើងស្គាល់
បំណងសប្បុរសទ្រង់តម្កល់ បានសម្រេចតាមព្រះតម្រិះ ។

៤- សូមនាំគ្នាលើកសិរីជោគ ជ័យលើកត្រដែតលើកឲ្យខ្ពស់
តាមព្រះហឫទ័យប្រណីប្រោស ដល់យើងតាមរយៈព្រះបុត្រា
ទ្រង់មានព្រះហឫទ័យមេត្តា ឲ្យបុត្រធីតាចូលរួមស្ម័គ្រ
ជាមួយព្រះគ្រីស្តដោយរាក់ទាក់ នេះជាបំណងដ៏សប្បុរស ។

## ១៣៧- ព្រះយេស៊ូគឺជាពន្លឺ

១- ព្រះយេស៊ូគឺជាពន្លឺ ជាពន្លឺបំភ្លឺលោកា សូមយាងមកសង្គ្រោះមនុស្សលោក ដែលកំពុងរងទុក្ខ យើងជឿថាព្រះយេស៊ូគ្រីស្ត ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយជឿថា ព្រះអង្គគង់នៅជាមួយយើង គ្រប់ពេលវេលា ។

**បន្ទរ- ចូរយើងរួបរួមគ្នា ធ្វើដំណើរឆ្ពោះទៅព្រះបិតា ដែលមានធម៌មេត្តា និងក្ដីស្រឡាញ់ ។**

**- ព្រះយេស៊ូគ្រីស្តទ្រង់មានព្រះជន្មរស់ឡើងវិញហើយ យើងទាំងអស់គ្នាសូមកោតសរសើរ ។**

២- ព្រះយេស៊ូទ្រង់មានព្រះជន្ម រស់ឡើងវិញ គឺជាពន្លឺ មកបំភ្លឺលោកា មិនឲ្យងងឹតដូចមុន ទ្រង់មានព្រះជន្មរស់ឡើងវិញ នាំមកនូវសេចក្ដីសង្ឃឹម ដែលធ្វើឲ្យជីវិតយើង មានអំណរមិនសាបសូន្យឡើយ ។



# ១៣៨- ព្រះរាជ្យព្រះជាម្ចាស់

**បន្ទរ- ឱ ! ព្រះជាម្ចាស់អើយ សូមឲ្យព្រះរាជ្យ ព្រះអង្គបានមកដល់ ។**

១- អ្នកណាមិនទទួលព្រះរាជ្យព្រះ ដូចក្មេងតូចទេ
អ្នកនោះមិនអាចចូលក្នុងព្រះរាជ្យព្រះ ជាម្ចាស់បានឡើយ ។

២- អ្នកដែលចូលទៅក្នុងព្រះរាជ្យព្រះ ជាអម្ចាស់បាន
គឺអ្នកដែលធ្វើតាមព្រះហឫទ័យ នៃព្រះបិតា ។

៣- ប្រសិនបើមនុស្សមិនបានកើត សាជាថ្មីទេ
គេមិនអាចឃើញព្រះរាជ្យព្រះ ជាម្ចាស់បានឡើយ ។

៤- ប្រសិនបើមនុស្សមិនបានកើតពី ទឹក និងវិញ្ញាណ
គេពុំអាចចូលក្នុងព្រះរាជ្យព្រះ ជាម្ចាស់បានឡើយ ។

៥- ព្រះរាជ្យព្រះជាម្ចាស់ប្រៀបដូចគ្រាប់ ពូជតូចម៉្យាង
ព្រោះហើយគ្រាប់ពូជនោះក៏ដុះឡើង ធំជាងគេ ។

៦- ព្រះរាជ្យស្ថានបរមសុខប្រៀបបី ដូចមេនំប៉័ង
ស្រីម្នាក់យកមកលាយធ្វើឲ្យម្សៅ នោះដោរឡើង ។

៧- ព្រះរាជ្យព្រះជាម្ចាស់ជិតមកដល់ ចូរយើងនាំគ្នា
កែប្រែចិត្តគំនិតខិតខំប្រឹង ជឿជំណឹងល្អ ។

## ១៣៩- ព្រះហឫទ័យសប្បុរស

បន្ទរ- ឱព្រះជាម្ចាស់អើយ! ព្រះអង្គពិតជាមាន ព្រះហឫទ័យសប្បុរស
លើសលប់មែន ពេលខ្ញុំអស់កម្លាំង ព្រះអង្គយាងមករកខ្ញុំ

១- ឱព្រះគ្រីស្តជាព្រះអម្ចាស់ សូមប្រោសមេត្តាមនុស្សប្រុសស្រី
ដែលបានលាចាកពីលោកីយ៍ បានរស់ក្នុងនៃក្តីស្រឡាញ់ ។

២- ឱព្រះគ្រីស្តជាព្រះសង្គ្រោះ សូមជួយរំដោះអស់វិញ្ញាណ
កុំប្រកាន់ទោសថែមប្រទាន ជីវិតរស់រានក្បែរព្រះអង្គ ។

៣- ឱព្រះគ្រីស្តជាព្រះបុត្រា សូមអង្វរព្រះវរបិតា
ឲ្យវិញ្ញាណដែលបានលាចាក បានរស់សុខសាន្តស្ថានព្រះអង្គ ។

៤- ឱព្រះគ្រីស្តជាព្រះសង្គ្រោះ មេត្តាសន្តោសបងប្អូនស្លាប់
កុំបោទប្រកាន់កុំចាប់ផ្តាក់ ប្រទានពរក្រាស់តាមហឫទ័យ ។

៥- ឱព្រះគ្រីស្តព្រះធម៌មេត្តា អង្វរបិតាព្រះឧត្តម
ប្រទានជីវិតដ៏រឿងរុង ឲ្យបានរស់ក្នុងស្ថានបរមសុខ ។



# ១៤០- ព្រះអង្គថ្កុំថ្កើងរុងរឿង...

១- ព្រះអម្ចាស់ខ្ញុំ ពេលទូលបង្គំឃើញមេឃា ឃើញផែនដីជា
ស្នាព្រះហស្តថ្លៃថ្លា ឃើញដួងតារា ឃើញការអស្ចារ្យទ្រង់សម្ដែង
តេជានុភាព ព្រះអង្គលើភពផែនដី ។

**បន្ទរ- ខ្ញុំសូមបង្គំ សរសើរតម្កើងព្រះអង្គ ព្រះអង្គថ្កុំថ្កើង រុងរឿងអស្ចារ្យ**
**ខ្ញុំសូមបង្គំ សរសើរតម្កើងព្រះអង្គ ព្រះអង្គថ្កុំថ្កើង អស្ចារ្យក្រៃណាស់។**

២- ពេលឃើញព្រះអង្គ បាត់ព្រះបុត្រាឲ្យយាងមក រស់នៅជីវិត
មនុស្សពិតៗដូចយើង ឃើញព្រះបុត្រា សោយទិវង្គតលើឈើឆ្កាង
ប្រទានជីវិត អស់កល្បជានិច្ចឲ្យយើង ។

៣- ពេលអង្គព្រះគ្រីស្ត យាងមកក្នុងសិរីរុងរឿង ប្រមូលមនុស្សលោក
ឲ្យចូលស្ថានបរមសុខ ពេញដោយអំណរ ពេញដោយអំណរអរព្រះគុណ
យើងប្រកាសថា ព្រះអង្គអស្ចារ្យក្រៃណាស់ ។

## ១៤១- មានសុភមង្គលហើយ! អស់អ្នកដែលព្រះអង្គជ្រើសរើស

(ដកស្រង់ពីទំនុកតម្កើងលេខ ៦៥)

**បន្ទរ-មានសុភមង្គលហើយណា អស់អ្នកឯណាព្រះម្ចាស់ជ្រើសរើស**
**ហើយនាំចូលមកឲ្យនៅរស់ ក្នុងទីសក្ការៈរបស់ព្រះអង្គ ។**

១- ឱ ! ព្រះម្ចាស់អើយខ្ញុំតម្កើង លើកព្រះអង្គឡើងក្នុងស៊ីយ៉ូន
សរសើរហើយថ្វាយតង្វាយជូន ស្របតាមពាក្យខ្លួនបង់សន្យា ។

២- ព្រះអង្គតែងតែព្រះសណ្ដាប់ ពាក្យមនុស្សរ៉ាយរ៉ាប់គ្រប់វេលា
មនុស្សលោកក៏អាចចរយាត្រា រកព្រះនាមាបានគ្រប់វ័យ ។

៣- អស់អ្នកដែលទ្រង់បានជ្រើសរើស គេនឹងជួបតែសុខសិរី
រស់ក្នុងសក្ការៈដ៏ប្រពៃ វិសេសថ្លាថ្លៃលើលោកា ។

៤- យើងខ្ញុំនឹងបានស្កប់ស្កល់ចិត្ត ព្រោះបាននៅជិតក្នុងវិហារ
ទទួលព្រះពរក្នុងពន្លា ដំណាក់ថ្លៃថ្លាដ៏វិសុទ្ធ ។

៥- បពិត្រព្រះម្ចាស់ព្រះសង្គ្រោះ ព្រះអង្គជាព្រះដ៏សុចរិត
ប្រជាជិតឆ្ងាយសមុទ្រពិត គេផ្ញើជីវិតលើព្រះអង្គ ។

៦- ព្រះអង្គស្រោចស្រពស្រែចម្ការ ទាំងដីផងណារាបផូរផង់
ភ្លៀងធ្លាក់ទឹកដក់ថ្លាត្រចង់ ស្រែស្រូវរហង់ពូជជាដុះ ។

៧- ដល់ពេលច្រូតកាត់ព្រះអង្គបាន ផ្ដល់ស្រូវជាទានដ៏សប្បុរស
ដែលជាអំណោយដ៏ខ្ពង់ខ្ពស់ សម្បូរទាំងអស់ឥតមានខ្វះ ។

៨- រីឯនៅវាលរហោស្ថាន មានស្មៅដុះច្រើនកើនស្មេកស្គះ
ភ្នំតូចភ្នំធំជុំល្ហល្ហះ ញញឹមស្រស់ណាស់ដោយអំណរ ។

៩- ហ្វូងសត្វពាសពេញតាមវាលស្មៅ ជ្រលងពេញដោយស្រូវដ៏ល្អ
អ្វីសព្វសារពើសូរអ៊ូអរ ច្រៀងដោយអំណរដ៏លើសលប់ ។

# ១៤២- យើងខ្ញុំជឿ ហើយស្រឡាញ់ព្រះអង្គ

(ដកស្រង់ពី យហ ៦:៦៨)

បន្ទរ- ឱ! ព្រះអម្ចាស់ ទោះយើងខ្ញុំម្ចាស់ ពុំឃើញព្រះអង្គតែយើងជឿហើយ
ស្រឡាញ់ព្រះអង្គ ទាំងត្រេកអរណាស់ ដោយដឹងច្បាស់ថា
ទ្រង់សង្គ្រោះយើង យើងខ្ញុំជឿហើយ ឱ ! ព្រះអង្គអើយ ។

១- អ្នកស្តាប់ព្រះបន្ទូលព្រះអង្គ នឹងមិនស្គាល់សេចក្តីស្លាប់ឡើយណា
ដ្បិតគេមានជីវិតហើយណា ជីវិតអស់កល្បក្នុងកាយា ។
បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំទៅរកនរណា ?
ព្រះបន្ទូលព្រះអង្គ ផ្តល់នូវជីវិតអស់កល្បជានិច្ច ។

២- បើអ្នករាល់គ្នាស្ថិតនៅជាប់ ជាមួយពាក្យរបស់ខ្ញុំពិត
អ្នករាល់គ្នានឹងស្គាល់ក្តីពិត ហើយក្តីពិតនឹងផ្តល់សេរីភាព ។
បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំទៅរកនរណា ?
ព្រះបន្ទូលព្រះអង្គ ផ្តល់នូវជីវិតអស់កល្បជានិច្ច ។

៣- មិនមែនខ្ញុំទៀតទេដែលរស់ គឺព្រះគ្រីស្តមានព្រះជន្មក្នុងខ្ញុំ
ខ្ញុំរស់នៅដោយមានជំនឿ លើព្រះបុត្រាព្រះជាម្ចាស់ ។
បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំទៅរកនរណា ?
ព្រះបន្ទូលព្រះអង្គ ផ្តល់នូវជីវិតអស់កល្បជានិច្ច ។

៤- បពិត្រព្រះអម្ចាស់ខ្ញុំអើយ គឺព្រះអង្គហើយទ្រង់សង្គ្រោះ
ដោយព្រះហឫទ័យប្រណីសន្តោស ជាព្រះអំណោយទានព្រះអង្គ ។
បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំទៅរកនរណា ?
ព្រះបន្ទូលព្រះអង្គ ផ្តល់នូវជីវិតអស់កល្បជានិច្ច ។

| | | |
|---|---|---|
| ៥- ព្រះជាម្ចាស់ទ្រង់ចាក់បង្ហូរ | ព្រះហឫទ័យស្រឡាញ់ព្រះអង្គ | |
| ក្នុងដួងចិត្តយើងគ្រប់អាត្មា | ដោយប្រទានព្រះវិញ្ញាណជីវិសុទ្ធ | ។ |
| បពិត្រព្រះអម្ចាស់ | តើឲ្យយើងខ្ញុំទៅរកនរណា ? | |
| ព្រះបន្ទូលព្រះអង្គ | ផ្តល់នូវជីវិតអស់កល្បជានិច្ច | ។ |
| ៦- ដូចព្រះបិតាស្រឡាញ់ខ្ញុំ | ខ្ញុំស្រឡាញ់អ្នករាល់គ្នាដែរ | |
| ចូរទុកក្តីស្រឡាញ់នៃខ្ញុំ | ឲ្យស្ថិតនៅនិងអ្នករាល់គ្នា | ។ |

## ១៤៣- យើងខ្ញុំជឿជាប្រាកដ

| | | |
|---|---|---|
| ១- យើងខ្ញុំជឿជាប្រាកដ | មានព្រះអង្គគង់សណ្ឋិត | |
| នំបុ័ងក្លាយជាព្រះកាយា | និងស្រាជាព្រះលោហិត | ។ |
| ២- យើងខ្ញុំមានចិត្តស្រឡាញ់ | ព្រះអង្គតែមួយថ្លៃថ្លា | |
| សូមព្រះអង្គអាសូរយាងមក | សណ្ឋិតក្នុងចិត្តយើងខ្ញុំ | ។ |
| ៣- យើងខ្ញុំសូមអរព្រះគុណ | ដែលបានយាត្រាជួបជុំ | |
| ទទួលព្រះរាជ្យករុណា | ព្រះកាយាព្រះបុត្រា | ។ |

## ១៤៤- វិន័យថ្មី ម៉ាកុស : ១២

ស្រឡាញ់ព្រះអម្ចាស់ ដោយយើងស្រឡាញ់ អស់បងប្អូន
ចិត្តយើងស្វែងរក ព្រះហឫទ័យ ព្រះអម្ចាស់
យើងត្រូវស្រឡាញ់ ព្រះអម្ចាស់ អស់ពីចិត្តគំនិត អស់ពីស្មារតី
អស់ពីប្រាជ្ញា ហើយស្រឡាញ់បងប្អូន ឯទៀត ឲ្យដូចខ្លួនឯង ។

## ១៤៥- វិន័យព្រះយេស៊ូ

**បន្ទរ- វិន័យរបស់ខ្ញុំ គឺអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។**

១- បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជានឹងដឹង
ថាអ្នករាល់គ្នាជាសាវ័កខ្ញុំ ។

២- គ្មាននរណាមានសេចក្ដីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត
ដើម្បីមិត្តសម្លាញ់របស់ខ្លួន ។

៣- ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិត គ្មាននរណាទៅកាន់ព្រះបិតា
ប្រសិនបើគេមិនមកតាមខ្ញុំ ។

៤- ខ្ញុំបានធ្វើជាគំរូឲ្យ អ្នករាល់គ្នាប្រព្រឹត្តតាមដូចខ្ញុំ
បានប្រព្រឹត្តដល់អ្នករាល់គ្នាដែរ ។

# ១៤៦- សុភមង្គលដ៏ពិតប្រាកដ

**បន្ទរ-មានសុភមង្គលហើយ !មានសុភមង្គលហើយ ! មានសុភមង្គលហើយ !**

១- អស់អ្នកទាំងឡាយដែលដាក់ចិត្ត ស្គាល់ក្ដីក្រខ្សត់នៅក្នុងខ្លួន
ដ្បិតអ្នកទាំងអស់នោះនឹងបាន ចូលក្នុងព្រះរាជ្យព្រះជាម្ចាស់ ។

២- អស់អ្នកទាំងឡាយដែលសោកសៅ ពិតមានសុភមង្គលហើយ
ដ្បិតអ្នកទាំងនោះនឹងបានក្ដី អំណរសប្បាយផុតពីទុក្ខ ។

៣- អស់អ្នកដាក់ចិត្តតាមព្រះអង្គ មានចិត្តស្លូតត្រង់ក្រៃកន្លង
ពិតបានទទួលដែនដីគ្រង តាមព្រះបន្ទូលដែលសន្យា ។

៤- អស់អ្នកដែលស្គាល់ការស្រេកឃ្លាន ក្ដីសុចរិតទៀងក្នុងអាត្មា
ពិតមានសុភមង្គលថ្លា បានឆ្អែតកាយាដោយព្រះពរ ។

៥- អ្នកមានចិត្តមេត្តាករុណា តាមព្រះបេស្គាម្ចាស់បវរ
ព្រះអង្គសម្ដែងហឫទ័យា ចិត្តមេត្តាធម៌អ្នកប្រាកដ ។

៦- អ្នកដែលមានចិត្តបរិសុទ្ធ ពិតមានសុភមង្គលហើយ
ដ្បិតអ្នកនឹងបានឃើញប្រាកដ នូវព្រះវិសុទ្ធជាអម្ចាស់ ។

៧- អស់អ្នកកសាងសន្តិភាព ពិតមានសុភមង្គលហើយ
ដ្បិតអ្នកទាំងនោះនឹងមានឈ្មោះ ជាបុត្ររបស់ព្រះជាម្ចាស់ ។

៨- អស់អ្នកដែលត្រូវគេបៀតបៀន ដោយបានធ្វើតាមក្ដីសុចរិត
ដ្បិតអ្នកទាំងនោះនឹងបានចូល ព្រះរាជ្យនៃស្ថានបរមសុខ ។

# ១៤៧- សូមកោតសរសើរព្រះម្ចាស់

**បន្ទរ- យើងខ្ញុំសូមកោតសរសើរព្រះម្ចាស់ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ។**

១- សូមកោតសរសើរព្រះម្ចាស់ ដែលបានបង្កើតផែនដីទាំងមូល និងផ្ទៃមេឃដ៏ធំធេង ។

២- សូមកោតសរសើរព្រះម្ចាស់ ដែលបានបញ្ជាឲ្យព្រះបុត្រា យាងមកសង្គ្រោះយើងខ្ញុំ ។

៣-សូមកោតសរសើរព្រះម្ចាស់ ដែលប្រទានមកយើងនូវអាហារ ដែលផ្តល់ជីវិតអានន្ត ។

៤-សូមកោតសរសើរព្រះម្ចាស់ ដែលផ្តល់ឲ្យយើងខ្ញុំបានសប្បាយ ត្រេកអរនៅនាលោកនេះ ។

៥-សូមកោតសរសើរព្រះម្ចាស់ ដែលប្រទានឲ្យយើងខ្ញុំរួមគ្នា ក្នុងក្តីស្រឡាញ់តែមួយ ។

៦- សូមកោតសរសើរព្រះម្ចាស់ ដែលប្រទានឲ្យយើងខ្ញុំទាំងឡាយ ទៅជាបុត្រធីតាព្រះអង្គ ។

៧-សូមកោតសរសើរព្រះម្ចាស់ ដែលបានកសាងព្រះសហគមន៍ ដោយក្រុមគ្រីស្តទូតព្រះអង្គ ។

៨-សូមកោតសរសើរព្រះម្ចាស់ ដែលឲ្យសន្តបុគ្គលទាំងឡាយ ជួយថែរក្សាយើងខ្ញុំ ។

## ១៤៨- សូមព្រះជាម្ចាស់មេត្តាប្រោសភ្នែក

"សូមព្រះជាម្ចាស់ ! សូមព្រះជាម្ចាស់ !"

១- សូមព្រះជាអម្ចាស់ មេត្តាប្រោសភ្នែកកូនណា ឲ្យឃើញការអស្ចារ្យ
នៃធម៌មេត្តាព្រះអង្គ កូនជាមនុស្សខ្វាក់ ដើរតេះតះតាមមាគ៌ា
សូមប្រោសកូនឲ្យជា កូនចង់ឃើញព្រះអង្គណាស់ ។

២- សូមមេត្តាលាដៃ ដែលក្តាប់អ្វីៗខ្លួនមាន អ្នកក្រីក្រស្រេកឃ្លាន
ដើរសុំទានមុខផ្ទះកូន សូមឲ្យកូនបេះបែក បេះរំលែកនូវធនធាន
ដែលព្រះអង្គប្រទាន ដល់អ្នកមានក្តីត្រូវការ ។

៣- ឲ្យកូនបេះដើរទៅ ទោះជាផ្លូវសែនលំបាក កូនចង់តាមទ្រង់ណា
លុះមរណាលើឈើឆ្កាង សូមព្រះអង្គមេត្តា យាងយាត្រាដឹកដៃកូន
ដឹកកូនដើរតម្រង់ មាគ៌ាត្រង់នៃព្រះអង្គ ។

៤- សូមជួយឲ្យកូនឮ សូរទន្ទ្រីនៃបងប្អូន កំពុងស្រែកតម្អូញ
ក្តីចុកត្អូញទូលព្រះអង្គ ឲ្យកូនបេះត្រង់ត្រាប់ ឲ្យបេះស្តាប់កុំធ្វើហី
ចំពោះក្តីសោកា ក្តីទុក្ខាទាំងនេះណា ។

## ១៤៩- សូមមេត្តាសង្គ្រោះយើងខ្ញុំ

**បន្ទរ- ឱ ! ព្រះជាអម្ចាស់ សូមមេត្តាសង្គ្រោះយើងខ្ញុំ**
**ហើយសូមប្រមូលផ្ដុំ អស់យើងខ្ញុំក្នុងក្ដីស្រឡាញ់ ។**

១- តើនរណាអាចបំបែកយើង ចេញពីព្រះហឫទ័យស្រឡាញ់ របស់ព្រះគ្រីស្ដបាន?
តើទុក្ខវេទនា ការតប់ប្រមល់ ឬការបៀតបៀន ឬការស្រេកឃ្លាន
ឬគ្មានស្លៀកពាក់ ឬត្រូវគ្រោះថ្នាក់ ត្រូវគេសម្លាប់ ។

២- តើនរណាអាចបំបែកយើង ចេញពីព្រះហឫទ័យស្រឡាញ់ របស់ព្រះគ្រីស្ដបាន?
ខ្ញុំជឿជាក់ថា ទោះសេចក្ដីស្លាប់ ទោះជីវិតក្ដី ទោះទេវទូតក្ដី
វត្ថុស័ក្ដិសិទ្ធិ បច្ចុប្បន្នកាលក្ដី អនាគតក្ដី ។

៣-តើនរណាអាចបំបែកយើង ចេញពីព្រះហឫទ័យស្រឡាញ់ របស់ព្រះគ្រីស្ដបាន?
ខ្ញុំជឿជាក់ថា អំណាចនានា អ្វីនៅស្ថានលើ អ្វីនៅស្ថានក្រោម
អ្វីៗផ្សេងទៀត ដែលព្រះជាម្ចាស់ បានបង្កើតមក ។
ក៏ពុំអាច បំបែកយើងខ្ញុំ ពីក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់
ដែលបានសម្ដែង ឲ្យយើងបានឃើញ ក្នុងអង្គព្រះគ្រីស្ដ ។

## ១៥០- សេចក្តីស្រឡាញ់ដែលព្រះជាអម្ចាស់ប្រទានមក

១- សេចក្តីស្រឡាញ់ដែលព្រះជាអម្ចាស់ប្រទានមក ពីសន្តិភាព
ដែលមនុស្សលោកត្រូវការទាំងអស់គ្នា ។

២- សេចក្តីសង្ឃឹមថា ព្រះជាអម្ចាស់នៅក្បែរយើង ខិតខំស្វែងរក
ដើម្បីជួបសេចក្តីស្រឡាញ់ ។

**បន្ទរ-សូមព្រះអម្ចាស់ ប្រទានពរដល់យើងទាំងអស់គ្នា គ្រប់ពេលវេលា ដែលយើងនឹងធ្វើដំណើរតាមផ្លូវ ។**

ចូរអធិដ្ឋានទៅព្រះជាអម្ចាស់ យើងនឹងបានក្តីសុខ
ចូរកុំភិតភ័យនូវអ្វីៗ ដែលធ្វើឲ្យយើងនឹងខ្លាច ។ (**២ដង**)

- ចូរអធិដ្ឋានទៅព្រះជាអម្ចាស់ យើងនឹងបានក្តីសុខ
ចូរកុំភិតភ័យនូវអ្វីៗដែលធ្វើឲ្យ យើងនឹងថ្វាយរហូត ។

- ចូរអធិដ្ឋានទៅព្រះជាម្ចាស់ យើងនឹងបានក្តីសុខ
ចូរកុំភិតភ័យនូវអ្វីៗដែលធ្វើឲ្យ យើងនឹងខ្លាច ។

- ចូរអធិដ្ឋានទៅព្រះជាម្ចាស់ យើងនឹងបានក្តីសុខ
ចូរកុំភិតភ័យនូវអ្វីៗដែលធ្វើឲ្យ យើងនឹងខ្លាចរហូត ។

# ១៥១- សេចក្ដីស្រឡាញ់មិនសាបសូន្យឡើយ

(ដកស្រង់ពី រម ៥/៥ និង ១ករ ១៣/៤-៧)

បន្ទរ-ព្រះជាអម្ចាស់ បានចាក់បង្ហូរ ហឫទ័យស្រឡាញ់ របស់ព្រះអង្គ
ក្នុងដួងចិត្តយើង ដោយទ្រង់ប្រទាន ព្រះវិញ្ញាណដ៏វិសុទ្ធ មកយើងគ្រប់គ្នា។

១- សេចក្ដីស្រឡាញ់ តែងតែអត់ធ្មត់ ជួយធុរៈគេ មិនបេះឈ្នានីស
មិនវាយឫកខ្ពស់ មិនអួតបំប៉ោង ។

២- សេចក្ដីស្រឡាញ់ មិនដែលប្រព្រឹត្ត អំពើថោកទាប មិនរកប្រយោជន៍
មិនបេះគំនុំ ហើយមិនមួម៉ៅ ។

៣- សេចក្ដីស្រឡាញ់ មិនអបមិនអរ អំពើទុច្ចរិត ប៉ុន្តែសប្បាយ
រីករាយជានិច្ច និងសេចក្ដីពិត ។

៤- សេចក្ដីស្រឡាញ់ អត់ឱនទាំងអស់ លើកលែងទាំងអស់ សង្ឃឹមទាំងអស់
ស៊ូទ្រាំទាំងអស់ ព្រមជឿទាំងអស់ ។

៥- សេចក្ដីស្រឡាញ់ មិនសាបសូន្យឡើយ ឯការថ្លែងបន្ទូល និយាយភាសា
បំណោះដឹងណា នឹងត្រូវរលាយ ។

## ១៥២- សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏លើសលប់

**បន្ទរ- ព្រះជាអម្ចាស់ ពោរពេញដោយសេចក្តីស្រឡាញ់**
**ទ្រង់បានប្រទានព្រះអំណោយ ឥតឧបមាលើរូបខ្ញុំ**
**តើខ្ញុំមានអ្វីតបស្នងសងគុណព្រះអង្គ ?**

១- ពីក្នុងគភ៌មាតា ព្រះជាអម្ចាស់ បានបង្កើតខ្ញុំ
ជារូបជារាង ដឹកនាំខ្ញុំចូលក្នុងជីវិត ត្រាស់ហៅខ្ញុំជាបុត្រធីតា
ដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ។

២- តើខ្ញុំជាអ្វីទៅ បានជាព្រះអម្ចាស់ បានជ្រើសរើសខ្ញុំ
ធ្វើជាសាក្សី ឲ្យទៅប្រកាស ដំណឹងល្អដល់ជនទាំងឡាយ
ឲ្យគេស្គាល់ធម៌មេត្តាករុណារបស់ព្រះអង្គ ។

៣- នេះជាជីវិតខ្ញុំ សូមព្រះអម្ចាស់ ជម្រះចិត្តខ្ញុំ
ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យក្លាយទៅជាអំបិល ជាពន្លឺភ្លឺ
ដើម្បីគេបានស្គាល់ព្រះជាម្ចាស់ជាព្រះបិតា ។

# ១៥៣- អាលេលូយ៉ា ឱនកាយត្រៀបត្រា

បន្ទរ-អាលេលូយ៉ា ចូរឱនត្រៀបត្រា សរសើរព្រះម្ចាស់ ទ្រង់បានស្រោចស្រង់
ព្រមទាំងសង្គ្រោះ ទ្រង់មានជោគស្នោះ ជ័យឫទ្ធិបារមី ។

១-ព្រះអង្គវិនិច្ឆ័យ ត្រឹមត្រូវពេកក្រៃ យុត្តិធម៌ប្រិមប្រិយ សូមអ្នករាល់គ្នា
ទោះជិតឆ្ងាយក្តី សូមនឹកមមៃ កុំនៅស្ងៀមស្ងាត់ ។

២-សូមអ្នកបម្រើ គ្រប់គ្រាជំណើរ ទាំងអ្នកប្រណិប័តន៍ ទាំងតូចទាំងធំ
សូមស្មូតថ្វាយថ្វាត់ ចង្វាក់បែបបទ សរសើរព្រះអង្គ ។
អាលេលូយ៉ា ស្មូតគ្រប់ប្រការ ដ្បិតព្រះម្ចាស់យើង ទ្រង់មានតេជា
នុភាពទាំងឡើង សោយរាជ្យថ្កុំថ្កើង មើលយើងគ្រប់គ្នា ។

៣-ចូរយើងរីករាយ ត្រេកអរសប្បាយ បញ្ចេញវាចា ចូរលើកតម្កើង
សិរីជ័យា កុំនៅវេរា កុំបីប្រអូស ។
ដ្បិតនេះជាថ្ងៃ ទ្រង់រៀបមង្គលជ័យ នឹងអស់ប្រុសស្រី ប្រជាជនដ៏ឆោម
តែងខ្លួនស្រេចអស់ គ្មានអ្វីនៅខ្វះ ចន្លោះសោះទេ ។

៤-ព្រះអង្គប្រទាន បំពាក់បំប៉ន សម្លៀកសាច់ព្រៃ ស្អាតភ្លឺត្រចះ
បាំងផ្លេកឡើងទ្វេ នេះជាអំពើ សុចរិតបរិសុទ្ធ ។

# ១៥៤- អាលេលូយ៉ាសរសើរព្រះម្ចាស់

(ដកស្រង់ពីទំនុកតម្កើងលេខ ១៤៨)

បន្ទរ- អាលេលូយ៉ា សរសើរព្រះម្ចាស់ ប្រសើរថ្លៃថ្លា វិសេសវិសុទ្ធ
អស់អ្នកដែលរស់ ស្ថានខ្ពស់បំផុត ចូរច្រៀងសព្វបទ ថ្វាយព្រះនាមា។

១- ឱ! ពួកទេវទូតទាំងឡាយអើយ ! ចូរសរសើរហើយតម្កើងផង
ទាំងពួកទេវទូតកុំវេរវង់ សរសើរព្រះអង្គព្រះនៃអ្នក ។

២- ឯព្រះអាទិត្យនិងព្រះច័ន្ទ កុំនៅអែអង់ឬស្ទើរស្ទាក់
តម្កើងព្រះអង្គព្រះនៃអ្នក ដាក់ខ្ពស់ដល់ថ្នាក់សួគ៌វិមាន ។

៣- អស់ផ្កាយទាំងឡាយដែលផ្លេកភ្លឺ រស្មីរន្ទឺគ្រប់ទីស្ថាន
ចូរកោតសរសើរព្រះថ្កើងថ្កាន គោរពឲ្យបានដោយផ្ចិតផ្ចង់ ។

៤- ឱ ! មេឃដែលនៅខ្ពស់បំផុត សរសើរក្រាបលុតថ្កើងព្រះអង្គ
ទាំងទឹកដែលនៅលើមេឃផង សូមជួយថ្កើងអង្គព្រះជាម្ចាស់ ។

៥- ចូរឲ្យអ្វីៗសព្វសារពើ តម្កើងសរសើរព្រះខ្ពង់ខ្ពស់
ពេលព្រះអង្គមានបន្ទូលនោះ អ្វីៗទាំងអស់កើតព្រោងព្រាត ។

៦- មនុស្សគ្រប់ៗប្រជារាស្ត្រ ចូរនាំគ្នាតម្កើងសិរី
ព្រះម្ចាស់ខ្ពង់ខ្ពស់លើលោកីយ៍ មិនអាចរកអ្វីប្រៀបស្មើបាន ។

៧- ចូរកោតសរសើរនាមព្រះម្ចាស់ ជាព្រះខ្ពង់ខ្ពស់លើសអស់ស្ថាន
ព្រះនាមព្រះអង្គល្បីថ្កើងថ្កាន ពាសពេញទីស្ថានមេឃ និងដី ។

## ១៥៥- អ្នកជឿលើព្រះគ្រីស្ទ នឹងបានសង្គ្រោះ

បន្ទរ- ព្រះជាម្ចាស់ចាត់ព្រះបុត្រា	របស់ព្រះអង្គមកលោកា
ពុំមែនដាក់ទោសមនុស្សទេណា គឺសង្គ្រោះមនុស្សដោយព្រះបុត្រា ។

១- អ្នកណាជឿលើព្រះបុត្រា	អ្នកនោះនឹងបានសង្គ្រោះណា
ឯអ្នកមិនជឿនាមព្រះអង្គ	អ្នកមិនបានសង្គ្រោះជីវិត ។

២- អ្នកណាស្ដាប់សេចក្ដីខ្ញុំប្រាប់	ហើយជឿលើព្រះអង្គបានចាត់
អ្នកនោះមានជីវិតអស់កល្ប	គឺឆ្លងផុតពីសេចក្ដីស្លាប់ ។

៣- អ្នកណាជឿលើខ្ញុំមែនពិត	មិនត្រឹមតែជឿលើខ្ញុំទេ
គឺជឿលើព្រះអង្គបានចាត់	ឲ្យខ្ញុំមកជួប្រទះនោះដែរ ។

៤- ខ្ញុំជាពន្លឺបំភ្លឺពិត	ខ្ញុំមកស្ថិតពិភពលោកនេះ
ដើម្បីឲ្យអ្នកជឿលើខ្ញុំ	ពុំស្ថិតក្នុងសេចក្ដីងងឹត ។

៥- ពាក្យដែលខ្ញុំបាននិយាយនេះ	គឺព្រះបិតាចាត់ខ្ញុំមក
បង្គាប់ខ្ញុំថ្លែងនូវសេចក្ដី	សុទ្ធតែផ្ដល់ជីវិតអស់កល្ប ។

៦- អ្នកណាជឿលើព្រះបុត្រា	នឹងមានជីវិតអស់កល្បណា
អ្នកណាជឿលើព្រះបុត្រា	នឹងមានជីវិតអស់កល្បណា
ឯអ្នកមិនជឿព្រះបុត្រា	អ្នកមិនទទួលជីវិតឡើយ ។

# ១៥៦- អ្នកណាសុំ រមែងតែងទទួល

បន្ទរ- ព្រះបិតានៅស្ថានបរមសុខ ព្រះអង្គប្រទានព្រះវិញ្ញាណ
ដ៏វិសុទ្ធដល់អស់អ្នកដែល ទូលសុំអង្វរពីព្រះអង្គ
ដ្បិតអ្នកដែលសុំតែងទទួល អ្នកស្វះស្វែងរករមែងឃើញ
ហើយគេតែងតែបើកទ្វារឲ្យ អ្នកដែលមកគោះទ្វារនោះណា ។

១- ព្រះយេស៊ូគ្រីស្តទ្រង់ប្រាប់យើងថា ចូរអ្នករាល់គ្នា ទូលសូមអង្វរ
នោះអ្នករាល់គ្នា គង់តែនឹងបាន ទទួលប្រាកដ ។

២-ព្រះយេស៊ូគ្រីស្តទ្រង់ប្រាប់យើងថា ចូរអ្នករាល់គ្នា ស្វះស្វែងរិះរក
នោះអ្នកគង់តែ បានឃើញប្រត្យក្ស នូវសុភមង្គល ។

៣- ព្រះយេស៊ូគ្រីស្តទ្រង់ប្រាប់យើងថា ចូរអ្នករាល់គ្នា គោះទ្វារចុះណា
គង់តែព្រះជាម្ចាស់ បើកដោយករុណា ឲ្យអ្នកមិនខាន ។



# ១៥៧- អ្វីៗ ដែលអ្នកបានប្រព្រឹត្ត

**បន្ទរ-** គ្រប់ពេលដែលអ្នករាល់គ្នា បានប្រព្រឹត្តអំពើអ្វី
ចំពោះអ្នកតូចតាចនោះ គឺអ្នករាល់គ្នាបានប្រព្រឹត្តចំពោះខ្ញុំដែរ ។

១- **ប.** កាលខ្ញុំឃ្លាន អ្នករាល់គ្នាឲ្យអាហារខ្ញុំបរិភោគ
កាលខ្ញុំស្រេក អ្នករាល់គ្នាយកទឹកមកឲ្យខ្ញុំពិសា ។
**ស.** បពិត្រព្រះអម្ចាស់តើ យើងខ្ញុំដែលបានឃើញព្រះអង្គឃ្លាន
**ប.** ឃើញព្រះអង្គស្រេក
**រួម.** ហើយបានយកអាហារនិងទឹក មកថ្វាយព្រះអង្គកាលពីពេលណា ?

២- **ប.** កាលខ្ញុំជាជនបរទេស អ្នករាល់គ្នាបានទទួលខ្ញុំ
កាលខ្ញុំគ្មានសម្លៀកបំពាក់ អ្នកបានឲ្យខ្ញុំស្លៀកពាក់ ។
**ស.** បពិត្រព្រះអម្ចាស់តើ យើងខ្ញុំឃើញព្រះអង្គជាជនបរទេស
**ប.** ឃើញអាក្រាតអង្គប្រាណ
**រួម.** ហើយបានឲ្យស្នាក់នៅនិង ថ្វាយសម្លៀកបំពាក់កាលពីពេលណា?

៣- **ប.** នៅពេលខ្ញុំមានជំងឺ អ្នករាល់គ្នាសួរសុខទុក្ខខ្ញុំ
ហើយកាលខ្ញុំជាប់ឃុំឃាំង អ្នកក៏បានមកសួរខ្ញុំដែរ ។
**ស.** បពិត្រព្រះអម្ចាស់តើ យើងខ្ញុំបានឃើញព្រះអង្គមានជំងឺ
**ប.** ឃើញជាប់ឃុំឃាំង
**រួម.** ហើយបានខិតខំមកសួរ សុខទុក្ខព្រះអង្គកាលពីពេលណា ?

## ១៥៨- ចូរចេញទៅប្រកាស

ដកស្រង់ពីទំនុកតម្កើង ៩៦ (៩៥)

| | | | |
|---|---|---|---|
| បន្ទរ- | ចូរចេញទៅប្រកាស | គ្រប់ជាតិសាសន៍ឲ្យដឹងថា | |
| | ព្រះរាជ្យព្រះជាម្ចាស់ | គង់កណ្តាលអ្នករាល់គ្នាហើយ | |
| | អាលេលូយ៉ា ! | អាលេលូយ៉ា ! | |
| | ព្រះរាជ្យព្រះជាម្ចាស់ | គង់កណ្តាលអ្នករាល់គ្នាហើយ | ។ |
| ១- | ចូរច្រៀងបទថ្មីថ្វាយ | ព្រះម្ចាស់ថ្លៃមិនឈរឈប់ | |
| | មនុស្សនៅលើពិភព | ច្រៀង កុំឈប់ឈរថ្វាយព្រះអង្គ | ។ |
| ២- | ចូរច្រៀងថ្វាយព្រះម្ចាស់ | តម្កើងព្រះនាមត្រចង់ | |
| | ប្រកាសរាល់ថ្ងៃផង | ពីបំណងទ្រង់ដ៏ថ្លាថ្លៃ | ។ |
| ៣- | ចូរប្រកាសនៅម្តុំ | ចំណោមក្រុមជាតិទីទៃ | |
| | នូវរុងរឿងសិរី | ព្រះហស្តថ្លៃថ្លាដ៏អស្ចារ្យ | ។ |
| ៤- | ដ្បិតព្រះម្ចាស់ឧត្តម | យើងខ្ញុំខំសរសើរណា | |
| | អស់ពីដួងចិន្តា | ព្រះក្សត្រាដ៏ប្រសើរខ្ពស់ | ។ |



# ១៥៩- ចូរនាំគ្នាទៅចុះ

បន្ទរ- ចូរនាំគ្នាទៅចុះ ដ្បិតស្រូវដែលត្រូវច្រូតកាត់
មានច្រើនពន់ពេកណាស់ តែមានអ្នកច្រូតតិចពេក ។
ចូរអង្វរព្រះម្ចាស់ សូមទ្រង់ចាត់អ្នកច្រូតកាត់
មកក្នុងស្រែព្រះអង្គបានបរិបូណ៌ផងណា ។

១- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នករាល់គ្នាចរចេញទៅ
ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដូចកូនចៀមក្នុងហ្វូងចចក ។

២- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នករាល់គ្នាចរចេញទៅ
ផ្សាយដំណឹងល្អដល់បងប្អូនថា ព្រះរាជ្យព្រះម្ចាស់មកជិតហើយ ។

៣- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នករាល់គ្នាចរចេញទៅ
ដោយមិនយកថង់ប្រាក់ ថង់យាម ឬស្បែកជើងទៅជាមួយឡើយ ។

៤- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នករាល់គ្នាចរចេញទៅ
បើអ្នកសម្រាកក្នុងផ្ទះណា សូមព្រះម្ចាស់ផ្តល់សុខឲ្យផ្ទះនោះ ។



## ១៦០- អរគុណព្រះម្ចាស់

បន្ទរ- អរគុណព្រះម្ចាស់ អរព្រះគុណទាំងអស់គ្នា ព្រោះទ្រង់ការពារ
យើងរាល់គ្នា ឲ្យផុតទុក្ខ ឲ្យរស់ស្រណុក
នៅក្នុងសុខសន្តិភាព ហើយផ្តល់កម្លាំង ក្នុងជីវិតរស់នៅសព្វថ្ងៃ ។

១- ព្រះអង្គជាម្ចាស់ មានតែមួយមែនពិត ទ្រង់បានបង្កើត
ផ្ទៃមេឃ និងដី អស្ចារ្យពេកក្រៃ អស្ចារ្យពេកក្រៃ
ទុកឲ្យយើងខ្ញុំ សង់លំនៅរស់នៅអើយ ។

២- ព្រះអង្គជាម្ចាស់ ខ្ពង់ខ្ពស់សោភាពិត ទ្រង់បានបង្កើត
សត្វគោក និងទឹក អស្ចារ្យពេកក្រៃ អស្ចារ្យពេកក្រៃ
ទុកឲ្យយើងខ្ញុំ បរិភោគរស់នៅអើយ ។

៣- ព្រះអង្គជាម្ចាស់ ធំលើសពីការស្មាន ទ្រង់បានបង្កើត
ឈើព្រៃ និងទឹក អស្ចារ្យពេកក្រៃ អស្ចារ្យពេកក្រៃ
ទុកឲ្យយើងខ្ញុំ យកប្រើប្រាស់រស់នៅអើយ ។

## ១៦១- អរព្រះគុណព្រះអង្គនៅពេលនេះ

នៅពេលនេះៗ យើងរួបរួមគ្នា អរព្រះគុណព្រះជាម្ចាស់
ព្រះអង្គទ្រង់ឲ្យយើងរួមគ្នា ឲ្យស្រឡាញ់បងប្អូនទាំងឡាយ
យើងរួមគ្នាអរព្រះគុណព្រះអង្គ នៅពេលនេះ ។

## ១៦២- កោតសរសើរ

**បន្ទរ- កោតសរសើរ កោតសរសើរ កោតសរសើរ ម៉ារីយ៉ា ។**

១- យើងខ្ញុំក្រាបអង្វរ ប្រណម្យឱនកាយ ក្រាបថ្វាយបង្គំ
ពេញបុណ្យរុងរឿង ប្រសើរថ្លៃថ្លា នៃព្រះនាងម៉ារីយ៉ា ។

២- មាតាល្អប្រសើរ ខ្ពង់ខ្ពស់អស្ចារ្យ នៅនាឋានដី
សូមជួយអង្វរ បុត្រាសម្លាញ់ ឲ្យកូនជាអ្នកបាប ។

## ១៦៣- ក្សត្រីបវរលើលោកា

១- ក្សត្រីបវរលើលោកា មាតាថ្លៃថ្លាយើងរាល់គ្នា
ព្រះនាងទ្រង់ជួយការពារ អ្នកដែលរត់មករកព្រះនាង (**ពីរដង**) ។

២- មាតាបិត្តធម៌ល្អឥតខ្ចោះ តែងសន្តោសដល់កូនទាំងឡាយ
សូមឲ្យកូនបានសប្បាយ ឃ្លាតបាកឆ្ងាយពីក្តីទុក្ខទោស (**ពីរដង**) ។

៣- មាតាពុំដែលជំពាក់បាប ជាទីគាប់ព្រះហឫទ័យព្រះម្ចាស់
កូនសូមជ្រកក្រោមបាទា សូមការពារដោយក្តីអាសូរ (**ពីរដង**) ។

## ១៦៤- ក្សត្រីវរមាតា

១- សម្តេចក្សត្រីវរមាតាម៉ារីយ៉ា មាតាព្រះគ្រីស្ត មាតានៃយើងខ្ញុំផង សូមទ្រង់មេត្តា ឲ្យយើងកូនចៅនៃនាង រត់មកជួបជុំក្រាបបង្គំព្រះបាទនាង ឱ ! ម៉ារីយ៉ា ។

២- សម្តេចក្សត្រីព្រហ្មចារិនីដ៏ថ្លៃថ្លា ពេញធម៌មេត្តាពេញព្រះអំណោយទានផង សូមទ្រង់មេត្តា ឲ្យយើងកូនចៅនៃនាង ស្រឡាញ់មាតាហើយស្រឡាញ់ព្រះអង្គផង ឱ ! ម៉ារីយ៉ា ។

## ១៦៥- ក្សត្រីវិមានសុខ

១- សូមសម្ដេចក្សត្រី ទ្រង់អរសប្បាយឡើង អាលេលូយ៉ា ។
ដ្បិតព្រះយេស៊ូគ្រីស្ដ ជាបុត្រារបស់ព្រះនាង អាលេលូយ៉ា ។

២-ព្រះអម្ចាស់មានព្រះជន្មដ៏រុងរឿង តាមបន្ទូលសន្យា អាលេលូយ៉ា ។
សូមព្រះនាងជួយអង្វរព្រះអម្ចាស់ ឲ្យយើងខ្ញុំផង អាលេលូយ៉ា ។

៣- ឱ ! ព្រះនាងម៉ារី សូមសប្បាយរីករាយឡើង អាលេលូយ៉ា ។
ដ្បិតព្រះបុត្រាព្រះនាង មានព្រះជន្មដ៏រុងរឿង អាលេលូយ៉ា ។

## ១៦៦- ចម្រៀងកោតសរសើរព្រះនាងម៉ារី

ឱ ! ព្រះនាងម៉ារី ជាព្រះមាតាព្រះគ្រីស្ដជាអម្ចាស់ និងជាព្រះមាតាយើងខ្ញុំអើយ ! យើងខ្ញុំសូមគោរពលើកតម្កើង ព្រះនាងដ៏ឧត្ដមប្រសើរ លើសអស់ទេវទូត និងសន្ដបុគ្គលទាំងឡាយ ។
សូមព្រះនាងសព្វព្រះហឫទ័យទទួលយើងខ្ញុំ ជាកូនចៅនៃព្រះនាង ។
ហើយសូមដឹកនាំយើងខ្ញុំ ឆ្ពោះទៅព្រះយេស៊ូ ជាបុត្រាព្រះនាង
និងជាអម្ចាស់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបាន ទទួលអំណរសប្បាយ
ឯស្ថានបរមសុខជាមួយព្រះនាង និងព្រះយេស៊ូ អស់កល្បជាអង្វែងតរៀងទៅ
អាម៉ែន! អាម៉ែន! ។

## ១៦៧- ច្រៀងអាលេលូយ៉ា

**បន្ទរ-ច្រៀងអាលេលូយ៉ា! ច្រៀងអាលេ អាលេលូយ៉ា!**

១- ព្រះជាម្ចាស់បានប្រទានពរ ដល់នាងលើសស្ត្រីនានា
ព្រះអង្គក៏ប្រទានពរ ដល់បុត្រារបស់នាងដែរ!

២- ព្រះនាងមានសុភមង្គល ដ្បិតព្រះនាងជឿព្រះបន្ទូល
ព្រះជាម្ចាស់ប្រាប់ព្រះនាង ពិតជាបានសម្រេចមិនខាន ។

៣- ចូរព្រះនាងអរសប្បាយឡើង ព្រះជាម្ចាស់គាប់ព្រះហឫទ័យ
នឹងព្រះនាងពិតមែនណា! ព្រះអង្គគង់ជាមួយព្រះនាង ។

៤- ព្រះនាងដែលជាអ្នកបម្រើ របស់ព្រះជាម្ចាស់ខ្ពង់ខ្ពស់
ព្រះនាងសូមឲ្យសម្រេច តាមព្រះហឫទ័យរបស់ព្រះអង្គ ។

## ១៦៨- តារាសមុទ្រ

**បន្ទរ- ចូរអបអរ ចូរសរសើរ ចូរច្រៀងថ្វាយមាតាព្រះ**
**ចូរអបអរ ចូរសរសើរ ចូរច្រៀងថ្វាយម៉ារីយ៉ា ។**

១- សូមក្រាបសំពះព្រះនាង ជាមាតាថ្លៃនៃព្រះ
តារាសមុទ្ទលោកា ជាទ្វារនៃស្ថានបរមសុខ ។

២- សូមផ្តាច់ចំណងអ្នកបាប បំភ្លឺដល់អ្នកងងឹត
អាសូរកម្ចាត់គ្រោះថ្នាក់ ផ្តល់នូវសុភមង្គល ។

៣- សិរីរុងរឿងមានដល់ ព្រះបិតាព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជរាបទៅមុខ ។

## ១៦៩- ចំនុកតម្កើងរបស់នាងម៉ារី

(បទព្រហ្មគីតិ)

១- ខ្ញុំសូមលើកតម្កើង ព្រះនៃយើងជាអម្ចាស់
ចិត្តខ្ញុំសប្បាយណាស់ ព្រះអម្ចាស់សង្គ្រោះខ្ញុំ ។

២- ទ្រង់មានព្រះហឫទ័យ មេត្តាក្រៃអាសូរខ្ញុំ
ជាអ្នកបម្រើទន់- ទាបពេកពន់នៃព្រះអង្គ ។
អំណើះតទៅមុខ មនុស្សគ្រប់ស្រុកស្រែករំពង
ថាខ្ញុំមានសុភ- មង្គលរុងរឿងពេកក្រៃ ។

៣- ព្រះអង្គបានប្រព្រឹត្ត អស្ចារ្យពិតហួសវិស័យ
មិនឲ្យខ្ញុំក្សិណក្ស័យ ជាស្នាដៃព្រះវិសុទ្ធ ។

៤- ទ្រង់មានព្រះហឫទ័យ ប្រោសប្រណីខ្ពស់បំផុត
ដល់អស់អ្នកដែលស្លុត កោតខ្លាចជុតព្រះម្ចាស់ថ្លៃ ។

៥- ទ្រង់បានសម្ដែងឫទ្ធិ ដោយកម្ចាត់ជនអប្រិយ៍
ព្រមទាំងមនុស្សឆ្មើងឆ្មៃ ដោយស្នាដៃព្រះទ្រង់ឫទ្ធិ ។

៦- ទ្រង់បានទម្លាក់អ្នក អំណាចជាក់មិនឲ្យស្ថិត
នៅតំណែងពិសិដ្ឋ ហើយលើកពិតអ្នករាបសា ។

៧- ទ្រង់បានប្រោសប្រទាន ឲ្យអ្នកឃ្លានឆ្អែតហូរហៀរ
ឯអ្នកមានមហា ទ្រង់ដេញទៅដៃទទេ ។

៨- ទ្រង់មានព្រះហឫទ័យ ប្រោសប្រណីឥតមានរេ
ដល់ជនជាតិអ៊ីស្រាអែល ជាពួកដែលបម្រើព្រះអង្គ ។

៩- ពីលោកអប្រាហាំ រហូតទាំងអស់ពូជពង្ស
ទ្រង់ពិតជួយស្រោចស្រង់ ជួយតម្រង់ណែនាំផ្លូវ ។
ស្របតាមព្រះសន្យា នឹងដូនតាពីមុនកូវ
រហូតដល់ឥឡូវ នេះតទៅទ្រង់មិនភ្លេច ។

## ១៧០- ទំនុកតម្កើងរបស់ព្រះនាងម៉ារី ១

១- វិញ្ញាណខ្ញុំសូមលើកតម្កើង ព្រះដ៏រុងរឿងម្ចាស់លោកា
បិត្តខ្ញុំត្រេកអរឥតឧបមា នឹងការសង្គ្រោះនៃម្ចាស់ថ្លៃ ។

២- ព្រះជាអម្ចាស់ថ្លៃឧត្តម ទតមើលមកខ្ញុំរាល់យប់ថ្ងៃ
ជាអ្នកបម្រើដ៏ក្រក្រី ទ្រង់ប្រោសប្រណីជួយសង្គ្រោះ ។

៣- អំណឹះតទៅគ្រប់សម័យ មនុស្សក្នុងលោកីយ៍នេះទាំងអស់
តែងពោលសរសើរខ្ញុំដោយស្មោះ ជាមានកេរ្តិ៍ឈ្មោះភ័ព្វវាសនា ។

៤- ព្រះម្ចាស់មានឫទ្ធិលើសលែងស្តេច ទ្រង់បានសម្រេចការអស្ចារ្យ
សង្គ្រោះរូបខ្ញុំដោយមេត្តា ព្រះអង្គពិតជាព្រះវិសុទ្ធ ។

៥- មេត្តាករុណានៃព្រះអង្គ ល្អល្អះត្រចង់ប្រសើរផុត
ប្រោសប្រណីអស់អ្នកក្រខ្សត់ មានចិត្តអំណត់បេះកោតខ្លាច ។

៦- ព្រះម្ចាស់កម្ចាត់ជនឆ្មើងឆ្មៃ ដកសិទ្ធពីដៃអ្នកកោងកាច
លើកជនសុភាពដោយអង់អាច ឲ្យកាន់អំណាចមានសីលធម៌ ។

៧- ព្រះជាអម្ចាស់បានប្រទាន ដល់អ្នកស្រេកឃ្លានដែលទ័លក្រ
ទ្រង់ដេញអ្នកមានមិនកាន់ធម៌ ឲ្យបាកបេញចរដៃទទេ ។

៨- ព្រះម្ចាស់លើកស្ទួយជួយរំដោះ កូនចៅទាំងអស់ឥតទំនេរ
ព្រោះទ្រង់នឹងចាំឥតភ្លេចទេ ហឫទ័យរិះរេជួយសង្គ្រោះ ។

៩- តាមព្រះបន្ទូលដ៏ប្រពៃ ថានឹងប្រណីបុព្វបុរស
លោកអប្រាហាំព្រមទាំងអស់ ពូជពង្សរបស់លោករៀងទៅ ។

## ១៧១- ទំនុកតម្កើងរបស់ព្រះនាងម៉ារី ២

**បន្ទរ- ព្រះជាអម្ចាស់បានសម្រេចការអស្ចារ្យ ចំពោះរូបខ្ញុំ ព្រះនាមព្រះអង្គ ពិតជាព្រះដ៏វិសុទ្ធ ។**

១- វិញ្ញាណខ្ញុំសូមលើកតម្កើង ព្រះដ៏រុងរឿងម្ចាស់លោកា
ចិត្តខ្ញុំត្រេកអរឥតឧបមា នឹងការសង្គ្រោះនៃម្ចាស់ថ្លៃ
ព្រះជាអម្ចាស់ថ្លៃឧត្ដម ទតមើលមកខ្ញុំរាល់យប់ថ្ងៃ
ជាអ្នកបម្រើដ៏ក្រក្រី ទ្រង់ប្រោសប្រណីជួយសង្គ្រោះ ។

២- អំណើះតទៅគ្រប់សម័យ មនុស្សក្នុងលោកីយ៍នេះទាំងអស់
តែងពោលសរសើរខ្ញុំដោយស្មោះ ថាមានកេរ្ដិ៍ឈ្មោះភ័ព្វវាសនា
ព្រះម្ចាស់មានឫទ្ធិលើសលែងស្ដេច ទ្រង់បានសម្រេចការអស្ចារ្យ
សង្គ្រោះរូបខ្ញុំដោយមេត្ដា ព្រះអង្គពិតជាព្រះវិសុទ្ធ ។

៣- មេត្ដាករុណានៃព្រះអង្គ ល្អល្អះត្រចង់ប្រសើរជុត
ប្រោសប្រណីអស់អ្នកក្រខ្សត់ មានចិត្តអំណត់បេះកោតខ្លាច
ព្រះម្ចាស់កម្ចាត់ជនឆ្មើងឆ្មៃ ដកសិទ្ធពីដៃអ្នកកោងកាច
លើកជនសុភាពដោយអង់អាច ឲ្យកាន់អំណាចមានសីលធម៌ ។

៤- ព្រះជាអម្ចាស់បានប្រទាន ដល់អ្នកស្រេកឃ្លានដែលទ័លក្រ
ទ្រង់ដេញអ្នកមានមិនកាន់ធម៌ ឲ្យបាកចេញចរដៃទទេ
ព្រះម្ចាស់លើកស្ទួយជួយរំដោះ កូនចៅទាំងអស់ឥតទំនេរ
ព្រោះទ្រង់នឹងចាំឥតភ្លេចទេ ហប្ញទ័យរិះរេជួយសង្គ្រោះ ។

៥- តាមព្រះបន្ទូលដ៏ប្រពៃ ថានឹងប្រណីបុព្វបុរស
លោកអប្រាហាំព្រមទាំងអស់ ពូជពង្សរបស់លោករៀងទៅ
សូមកោតសរសើរព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ
ដែលគង់ស្ថិតស្ថេរឥតសៅហ្មង យូរលង់កន្លងតរៀងទៅ ។

## ១៧២- នាដែនលោកីយ៍

១- នាដែនលោកីយ៍ដ៏វេទនា ព្រោះអេវ៉ាចង់ស្មើព្រះម្ចាស់
បានមេត្តាករុណាជាទីពឹង អាសូរទ្រទ្រង់ជួយដោះសារ ។

**បន្ទរ- យើងខ្ញុំបង្គំស្ដេចក្សត្រី ប្រសើរថ្លៃថ្លាគ្មានប្រដូច**
**ឱនក្រាបពួកទេវទូត សូមជួយអង្វរឲ្យយើងខ្ញុំ ។**

២- នាកាលទឹកធំលិចកំពូលភ្នំ ព្រោះទុក្ខនាជនដែនលោកា
សំពៅមួយធំឥតគណនា រំដោះនាំឲ្យរួចទុក្ខភ័យ ។

៣- ក្សត្រីប្រសូតរាជបុត្រា ទ្រង់ព្រះឫទ្ធាពេញបារមី
យាងចុះប្រោសលោះលានាថានដី ឲ្យសម្នាយរស់រៀងទៅ ។

## ១៧៣- នេះជាថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមក

### "បុណ្យព្រះជាម្ចាស់លើកនាងម៉ារីឡើងស្ថានបរមសុខ"ទំនុកថ្មី

បន្ទរ- នេះជាថ្ងៃដែលព្រះ ជាម្ចាស់បានបង្កើតមក ថ្ងៃដ៏សែនសប្បាយរីករាយ
អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !

១- ចូរយើងកោតសរសើរព្រះជាម្ចាស់ ដ្បិតថ្ងៃនេះព្រះអង្គសព្វព្រះហឫទ័យ
លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ទាំងកាយទាំងវិញ្ញាណ
ចូរយើងច្រៀងបទថ្មីថ្វាយ ព្រះជាម្ចាស់អស់កល្បជានិច្ច ។

២- ចូរយើងអរព្រះគុណព្រះជាម្ចាស់ ចូរយើងច្រៀងបទថ្មីថ្វាយព្រះអម្ចាស់
ដ្បិតព្រះអង្គប្រោសព្រះនាងម៉ារី មានកិត្តិយសខ្ពង់ខ្ពស់
ជាមាតាព្រះបុត្រាព្រះអង្គ អាលេលូយ៉ា ។

៣- ចូរយើងលើកតម្កើងជោគជ័យ ចំពោះព្រះបិតាព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលទ្រង់គង់នៅ
តាំងពីដើមរៀងមកហើយជាដរាប តរៀងទៅ ។

## ១៧៤- បពិត្រព្រះនាងម៉ារី

១- បពិត្រព្រះនាងម៉ារី ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ ព្រះអង្គគង់នៅជាមួយនាង ។

២- ទ្រង់បានប្រទានពរ ដល់នាងលើសស្ត្រីទាំងឡាយ
ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ ។

៣- ឱ ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ សូមជួយអង្វរព្រះអង្គឲ្យយើងខ្ញុំ
ជាអ្នកបាបនៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង(**២ដង**) ។ **អាម៉ែន**

## ១៧៥- ព្រះនាងជាកិត្តិយសរបស់យើងខ្ញុំ

**បន្ទរ- ព្រះនាងជាកិត្តិយស និងជាសិរីរុងរឿង**
**របស់យើងខ្ញុំហើយ ឱ!ព្រះនាងម៉ារីអើយ!**

១- ព្រះនាងជាសិរីរុងរឿង របស់ក្រុងយេរូសាឡឹម ឱ!ព្រះនាងម៉ារីអើយ!

២- ព្រះនាងពិតជាកិត្តិយស របស់យើងខ្ញុំគ្រប់ៗគ្នា ឱ!ព្រះនាងម៉ារីអើយ!

៣- សូមព្រះម្ចាស់ទ្រង់ប្រទានពរ ដល់ព្រះនាងជារៀងរហូត ឱ!ព្រះនាងម៉ារីអើយ!

# ១៧៦- ព្រះនាងម៉ារីជាមាតា

**បន្ទរ- ច្រៀងលើកតម្កើង ច្រៀងកោតសរសើរ ថ្វាយព្រះជាម្ចាស់**
**ច្រៀងចម្រៀងថ្មី ថ្វាយព្រះជាម្ចាស់ ជាព្រះបិតា**
**អាលេលូយ៉ា អាលេលូយ៉ា ។**

១- ថ្ងៃនេះយើងអបអរ ព្រះអង្គប្រទានពរ ដល់ព្រះនាងម៉ារី
មាតានៃព្រះយេស៊ូ ថ្ងៃនេះយើងរួមគ្នា លើកតម្កើងព្រះនាមព្រះអង្គ ។

២- ថ្ងៃនេះយើងអបអរ ព្រះអង្គប្រទានពរ ដល់ព្រះនាងម៉ារី
ជាមាតាយើងខ្ញុំដែរ ថ្ងៃនេះយើងរួមគ្នា កោតសរសើរព្រះនាមព្រះអង្គ ។

៣- ថ្ងៃនេះយើងអបអរ ព្រះអង្គប្រទានពរ ដល់ព្រះនាងម៉ារី
មានសុភមង្គលមែន ថ្ងៃនេះយើងរួមគ្នា អរព្រះគុណព្រះជាម្ចាស់ ។

៤- ថ្ងៃនេះយើងអបអរ ព្រះអង្គប្រទានពរ ដល់ព្រះនាងម៉ារី
លើសអស់ស្ត្រីទាំងឡាយ ថ្ងៃនេះយើងរួមគ្នា អរព្រះគុណព្រះជាម្ចាស់ ។

## ១៧៧- ព្រះនាងមិនជំពាក់បាប
## (លំនាំបទ តារាសមុទ្រ)

បន្ទរ- ច្រៀងអបអរ ច្រៀងសរសើរ យើងច្រៀងថ្វាយ ព្រះជាម្ចាស់
ច្រៀងអបអរ ច្រៀងសរសើរ យើងច្រៀងថ្វាយ ព្រះមាតា ។

១- សូមលើកតម្កើងព្រះម្ចាស់ ព្រះអង្គសព្វព្រះហប្ញទ័យ
ប្រោសប្រទានពរព្រះនាង ឲ្យលើសស្រ្តីទាំងឡាយ ។

២- សូមលើកតម្កើងព្រះម្ចាស់ ព្រះអង្គសព្វព្រះហប្ញទ័យ
ប្រទានពរដល់ព្រះនាង និងដល់បុត្រព្រះនាងដែរ ។

៣- សូមកោតសរសើរព្រះម្ចាស់ ព្រះអង្គសព្វព្រះហប្ញទ័យ
ប្រោសឲ្យព្រះនាងម៉ារី ជាមាតាព្រះអម្ចាស់ ។

៤- សូមកោតសរសើរព្រះម្ចាស់ ព្រះអង្គសព្វព្រះហប្ញទ័យ
ប្រោសឲ្យព្រះនាងម៉ារី មិនឲ្យជំពាក់បាបឡើយ ។

៥- សូមអរព្រះគុណព្រះម្ចាស់ ដ្បិតព្រះអង្គសព្វហប្ញទ័យ
ប្រោសឲ្យព្រះនាងម៉ារី មានកិត្តិយសដ៏ខ្ពង់ខ្ពស់ ។

៦- សូមថ្វាយសិរីរុងរឿង ព្រះបិតាព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បអង្វែងរៀងទៅ ។

## ១៧៨- មាតាជាទីពំនឹង

១- បពិត្រព្រះនាងម៉ារី ស្អាតបរិសុទ្ធឧត្តម
រំដោះសង្គ្រោះបាប អស់អ្នកដែលមានទុក្ខព្រួយ
សូមជួយអង្វរព្រះអង្គ អាសូរកម្ចាត់គ្រោះថ្នាក់
សូមស្តាប់ពាក្យអង្វរកូន ថ្វាយនៅពេលនេះ ។

**បន្ទរ- សូមប្រទានពរ កម្លាំងកាយចិត្ត ឲ្យយើងខ្ញុំនៅលើផែនដីនេះ**
**ឆ្លងផុតទុក្ខសោក ព្យុះភ្លៀងបក់បោកពេលនេះ ។**
**ឱព្រះមាតា កូនទូលអង្វរ សូមជួយគាំពារផ្តល់ចិត្តជឿជាក់**
**ជាទីពំនឹង ស្វែងរកមាគ៌ារុងរឿង ។**

២- រួមគំនិតទាំងចិត្តកាយ បន្លឺចម្រៀងសរសើរ
ថ្វាយសម្តេចក្សត្រី នូវជំនឿពិតមុតមាំ
កូនប្រគល់ទាំងជីវិត ទាំងដួងចិត្តទាំងវិញ្ញាណ
រាល់គ្រប់គ្រាដំណើរ សូមថែរក្សាកូន ។

## ១៧៩- មាតាព្រះសង្គ្រោះ

១- ឱ ! មាតានៃព្រះសង្គ្រោះ ប្រៀបដូចជាទ្វារនៃស្ថានបរមសុខ
ជាតារានៃជលសា សូមជួយសង្គ្រោះរាស្ត្រដ៏ទន់ខ្សោយ ។
២- ដែលចង់ត្រឡប់មករកព្រះជាម្ចាស់វិញ មាតាបានប្រសូតព្រះបុត្រា
ដែលជាម្ចាស់ផែនដី សត្វលោកទាំងឡាយកោតសរសើរ ។
៣- មាតាដែលនៅព្រហ្មចារីជាដរាប សូមព្រះមាតាទទួលគារវកិច្ចពីយើងខ្ញុំ
ហើយអាណិតអាសូរយើងខ្ញុំជាអ្នកបាប ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ ។

## ១៨០- យើងខ្ញុំសូមជ្រកកោនក្រោមម្លប់ព្រះនាង

ឱព្រះនាងម៉ារីជាមាតាព្រះគ្រីស្តជាអម្ចាស់អើយ យើងខ្ញុំសូមជ្រកកោន
ក្រោមម្លប់បារមីព្រះនាង សូមព្រះនាងកុំលះបង់ពាក្យអង្វរ
ដែលយើងខ្ញុំទូលព្រះនាងក្នុងគ្រាមានអាសន្នឡើយ
តែសូមព្រះនាងជួយរំដោះយើងខ្ញុំ
ឲ្យរួចគ្រោះអន្តរាយគ្រប់បែបយ៉ាងផង ។ **អាម៉ែន**

## ១៨១- យើងខ្ញុំឱនក្រាបប្រណម្យមាតា

១- យើងខ្ញុំឱនក្រាបប្រណម្យមាតា រុងរឿងថ្លាដូចខែពេញបូរមី
សូមបំភ្លឺអស់យើងគ្រីស្តបរិស័ទ ឲ្យកាន់តាមក្រឹត្យវិន័យព្រះគ្រីស្ត ។

**បន្ទរ-ឱ ! សម្តេចព្រះវរមាតា សូមមេត្តាប្រោសអស់កូនអ្នកបាប**
**នាថានដីកំពុងត្រូវលំបាក សូមមេត្តាអង្វរជួយយើងខ្ញុំ ។**

២- ក្សត្រីគង់នៅស្ថានដ៏ខ្ពង់ខ្ពស់ រួបរួមនឹងអស់ទាំងទេវទូត
ជនទាំងឡាយកំពុងគាល់រកូត ទ្រង់ងារសម្តេចតាក់តែងវិមាន ។

## ១៨២- យើងសូមកោតសរសើរព្រះនាងម៉ារី

យើងសូមកោតសរសើរព្រះនាងម៉ារី ជាទីគាប់ព្រះទ័យព្រះជាម្ចាស់
ព្រះអង្គគង់នៅជាមួយនាង មាតាព្រះអម្ចាស់
សូមព្រះនាងជួយអង្វរព្រះជាម្ចាស់ឲ្យយើងខ្ញុំទាំងអស់ ដែលជាអ្នកបាប
សូមឲ្យយើងអធិដ្ឋានរាល់ថ្ងៃ ធម៌ព្រះផ្គាំនាំជីវ៉ា
ព្រះនាងម៉ារីយ៉ា ព្រះនាងម៉ារីយ៉ា ព្រះនាងម៉ារីយ៉ា ។

## ១៨៣- សូមក្រាបសំពះសម្តេចក្សត្រីម៉ារី

**ស.** សូមក្រាបសំពះសម្តេចក្សត្រីម៉ារី ជាព្រះមាតាដ៏មានធម៌មេត្តាជាពំនឹង
ហើយជាទីសង្ឃឹមរបស់យើង ។

**ប.** យើងខ្ញុំជាកូនចៅអេវ៉ានៅស្ថានដ៏លំបាកនេះ ស្រែកដង្ហោយហៅព្រះនាង ។

**ស.** កាលយើងខ្ញុំបានលាចាកលោកនេះហើយ សូមព្រះនាងនាំយើងខ្ញុំ
ឲ្យបានរួមជាមួយព្រះយេស៊ូ ជាព្រះបុត្រាដ៏ប្រសើររបស់ព្រះនាង ។

**ប.** ឱ ! ព្រះនាងព្រហ្មចារិនីម៉ារី ពោរពេញដោយព្រះហឫទ័យមេត្តា
ករុណានិងប្រោសប្រណី ហើយនិងសុភាពរាបសា ។

**រួម. សូមជួយអង្វរព្រះជាអម្ចាស់ឲ្យយើងខ្ញុំផង ។**

## ១៨៤- អរព្រះគុណព្រះយេស៊ូគ្រីស្ត

អរព្រះគុណព្រះយេស៊ូគ្រីស្ត ជាជីវិតនិងជាក្តីពិត
ឲ្យយើងបានស្គាល់ធម៌មេត្តា ព្រះបិតាដែលស្រឡាញ់យើង ។

## ១៨៥- អាវេ៉ម៉ារីយ៉ា

**បន្ទរ-អាវ៉េ អាវ៉េ អាវ៉េ ម៉ារីយ៉ា ! អាវ៉េ អាវ៉េ អាវ៉េ ម៉ារីយ៉ា !**

១- យើងខ្ញុំឱនក្រាបប្រណម្យ ឱនកាយក្រាបថ្វាយបង្គំ
ពេញបុណ្យរុងរឿងប្រសើរ ក្សត្រីនៃម៉ារីយ៉ា ។

២- សូមជួយអង្វរព្រះអង្គ ឲ្យគ្រីស្តបរិស័ទទាំងឡាយ
បានពរសង្ឃឹមថ្វាត់ថ្វាយ ដូចផ្កាយនាំផ្លូវសួគ៌ា ។

## ១៨៦- ឱ ! ព្រះនាងព្រហ្មចារិនីម៉ារី

១- ឱ ! ព្រះនាងព្រហ្មចារិនីម៉ារី ដ៏មានធម៌មេត្តាអើយ
តាំងពីដើមរៀងមកពុំដែលឮថា ព្រះនាងបានលះបង់បោលអ្នកណា
ដែលចូលមកសូមព្រះនាងជួយការពារ ។

២- ឱ ! ព្រះនាងម៉ារី ជាព្រះមាតាខ្ញុំអើយ
បើខ្ញុំមានបាបច្រើន ក៏ខ្ញុំមានចិត្តសង្ឃឹមយ៉ាងមាំ
ហើយចូលមកប្រណម្យទៀប ក្រោមព្រះបាទព្រះនាងដែរ ។

៣- ឱ ! ព្រះមាតាព្រះយេស៊ូអើយ សូមកុំលះបង់បោលខ្ញុំឡើយ
តែសូមទ្រង់ព្រះសណ្ដាប់ធម៌អង្វររបស់ខ្ញុំ ដោយព្រះហឫទ័យប្រោសប្រណី ។

## ១៨៧- ឱ ព្រះនាងម៉ារី

បន្ទរ- ឱ ! ព្រះនាងម៉ារី មាតាព្រះជាអម្ចាស់
យើងរួមគ្នាច្រៀងឡើង អស់ពីចិត្ត ជីវិតយើង ។
ឱ! ព្រះនាងម៉ារី មានមេត្តាចិត្តស្លូតបូត
សូមព្រះនាងជួយអង្វរ ព្រះជាម្ចាស់ឲ្យយើងខ្ញុំ ។

១- សូមថ្វាយព្រះនាងអស់ពីចិត្តគំនិតយើង អតីតកាល បច្ចុប្បន្ន អនាគត កោតសរសើរព្រះជាម្ចាស់អស់ពីចិត្ត ដោយមានព្រះនាងជាគំរូនៃយើងខ្ញុំ ។

២- ភាពក្រីក្រ ព្រហ្មចារិយ៍ ស្ដាប់បង្គាប់ យើងដើរតាមព្រះយេស៊ូទ្រង់បង្រៀន យើងស្រឡាញ់អ្នកដទៃដូចបងប្អូន យើងសូមលះបង់ជីវិតថ្វាយព្រះអង្គ ។

## ១៨៨- ឱ! ម៉ារីអើយ

ឱ ! ម៉ារីយ៉ាអើយ! សូមរក្សាចិត្តកូនឲ្យទៀងត្រង់
ដូចទឹកជ្រោះហូរធ្លាក់ថ្លាយង់ ។
ឱ ! ម៉ារីអើយ! សូមប្រោសប្រទានឲ្យកូនមានចិត្តជ្រះថ្លា
មិនប្រកាន់ទោសមិនភ្លេចគុណណា ។
ឱ ! ម៉ារីយ៉ា សូមផ្ដល់ឲ្យកូនអាចមានចិត្តរីករាយសាទរ
ផ្ដល់ក្ដីស្រឡាញ់ដោយដួងចិត្តស្មោះសរ ។
ឱ ! ម៉ារីយ៉ាអើយ! គឺព្រះនាងហើយ ជាមាតាដ៏ឧត្ដម
ប្រោសប្រណីដល់រូបខ្ញុំ សណ្ដោសដល់មនុស្សមានបាប ។
ឱ ! ម៉ារីយ៉ាអើយៗ! សូមដឹកនាំកូនឲ្យស្ដាប់បង្គាប់ដល់ព្រះ
នាំដួងចិត្តខ្ញុំ ថ្វាយបង្គំព្រះជាម្ចាស់ ។
ឱ! ម៉ារីយ៉ា! ឱ! ម៉ារីយ៉ាអើយ! សូមព្រះនាងសណ្ដាប់ពាក្យកូនអង្វរ
សូមព្រះនាងសណ្ដាប់ពាក្យកូនទូលអង្វរ ឱ! ម៉ារីយ៉ា ។

## ១៨៩- កោតសរសើរសន្តយ៉ូសែប

១- សន្តយ៉ូសែប ដែលជារាជវង្ស របស់ព្រះបាទដាវីឌ

**បន្ទរ- យើងខ្ញុំសូមកោតសរសើរ កោតសរសើរដោយចិត្តរីករាយ**

២- សន្តយ៉ូសែប ថែរក្សាព្រះ យេស៊ូជាព្រះបុត្រា

៣- សន្តយ៉ូសែប ថែរក្សាព្រះ មាតាព្រះយេស៊ូគ្រីស្ត

៤- សន្តយ៉ូសែប ជាស្វាមីព្រះ នាងព្រហ្មចារិនីម៉ារី

៥- សន្តយ៉ូសែប ជាគ្រួសារនៃ គំរូគ្រីស្តបរិស័ទ

៦- សន្តយ៉ូសែប ថែរក្សាព្រះ សហគមន៍របស់យើង

៧- សន្តយ៉ូសែប ដែលពោរពេញព្រះ អំណោយទានព្រះជាម្ចាស់

៨- សន្តយ៉ូសែប ដែលជាមនុស្ស ទៀងត្រង់សប្បុរសពេកក្រៃ

៩- សន្តយ៉ូសែប តែងតែការពារ រក្សាគ្រីស្តបរិស័ទ

១០- សន្តយ៉ូសែប ស្មោះត្រង់លះបង់ ថ្វាយព្រះអង្គមួយជីវិត ។

## ១៩០- សន្តយ៉ូសែបជាគំរូ

១- សន្តយ៉ូសែបជាគំរូ សុចរិតជាមិត្ត ដ៏បរិសុទ្ធ របស់ព្រះនាងម៉ារី ជាអ្នកបម្រើដោយចិត្តស្មោះ ពោរពេញដោយ អំណោយទាននឹងសង្ឃឹម ជឿជាក់លើព្រះជាម្ចាស់ ។

**បន្ទរ-យើងខ្ញុំសូមត្រាប់តាមដោយចិត្តត្រង់ស្មោះស្ម័គ្រតាមគំរូរបស់សន្តយ៉ូសែប សូមសន្តប្រទានពរឲ្យគ្រប់គ្រួសារ បានរស់នៅ ក្នុងក្ដីសុខសាន្ត។**

២- យើងខ្ញុំសូមថ្វាយពាក្យសរសើរ លើកតម្កើង កិត្តិនាមដ៏ថ្លៃថ្លា របស់សន្តយ៉ូសែប រួមជាមួយ សន្តយ៉ូសែប ក្នុងដំណើរជីវិត កសាងគ្រួសារ ក្នុងភាពសុភមង្គល ។

# ១៩១- យើងអបអរសន្តយ៉ូសែប

**បន្ទរ-យើងអបអរ សរសើរសន្តយ៉ូសែប ពោរពេញដោយ**
**ព្រះអំណោយទាន នៃព្រះជាម្ចាស់ ។**

១- សន្តយ៉ូសែប បានស្តាប់បង្គាប់ ព្រះជាម្ចាស់គ្រប់ពេល
និងថែរក្សា ព្រះយេស៊ូជាព្រះបុត្រា របស់ព្រះជាម្ចាស់ ។

២- សន្តយ៉ូសែប ស្ម័គ្រចិត្តលះបង់ ស្មោះត្រង់តាមការពារ
ព្រះនាងម៉ារី ជាមាតាព្រះគ្រីស្តយេស៊ូ ព្រះសង្គ្រោះនៃយើង ។

៣- សន្តយ៉ូសែប តែងតែការពារ គ្រួសារគ្រីស្តបរិស័ទ
និងថែរក្សា ព្រះសហគមន៍របស់យើង គ្រប់ពេលវេលារាល់ថ្ងៃ ។

៤- សូមអរព្រះគុណ ព្រះវរបិតា ព្រះបុត្រាព្រះវិញ្ញាណ
ព្រះអង្គប្រទាន សន្តយ៉ូសែបជួយការពារ បុត្រធីតាព្រះអង្គ ។

## ១៩២- ចូរយើងខំរៀបចំចិត្តគំនិត

**បន្ទរ- ចូរយើងខំរៀបចំចិត្តគំនិត ដើម្បីទទួលព្រះយេស៊ូទ្រង់យាងមក**

១-ចូរយើងខំរៀបចំចិត្តគំនិត រង់ចាំព្រះគ្រីស្ដយាងមកសង្គ្រោះ
មានទាំងទេវទូតតាមហែព្រះអង្គ ប្រៀបដូចជាក្បួនយ៉ាងឱឡារិក ។

២-ព្រះអង្គមានកំណើតជាមនុស្ស ដើម្បីសង្គ្រោះអស់មនុស្សលោក
ទោះមានជាតិសាសន៍ផ្សេងគ្នាក៏ដោយ ព្រះអង្គមិនរើសមុខអ្នកណាឡើយ ។

៣-ឱ ! ព្រះអម្ចាស់នៃយើងរាល់គ្នា ដែលពោរពេញដោយព្រះប្រាជ្ញាញាណ
យើងខ្ញុំសូមថ្វាយព្រះនាមព្រះអង្គ ជាព្រះបុត្រានៃព្រះបិតា ។

៤-សូមព្រះយេស៊ូគ្រីស្ដជួយរំដោះ អស់ទាំងជីវិតសត្វលោកទាំងឡាយ
ឲ្យបាកផុតពីទុក្ខវេទនាផង ដើម្បីរស់នៅជាមួយព្រះអង្គ ។

៥-សូមណែនាំអស់អ្នកដែលវង្វេង ប្រាសចាកមាគ៌ាព្រះជាអម្ចាស់
ដោយបាញ់ការល្បួងនៃអំណាចមារ ឲ្យបានស្គាល់ផ្លូវនៃព្រះអង្គវិញ ។

៦-ឱ ! ព្រះយេស៊ូជាម្ចាស់ទឹកដី សូមទ្រង់ជួយការពារនិងស្រោចស្រង់
អស់អ្នកដែលរងទុក្ខវេទនាផង ដោយការអត់ឃ្លាននិងដោយសង្គ្រាម ។

## ១៩៣- ចូរឲ្យយើងកាន់ដៃ

១- ចូរឲ្យយើងកាន់ដៃ ចូរឲ្យយើងកាន់ដៃ ចូរឲ្យយើងកាន់ដៃ ដើរទៅ ដល់ព្រះគ្រីស្ត ជាជីវិតរបស់គ្រីស្តបរិស័ទ ។

២- ចូរឲ្យយើងបង្ហាញ ចូរឲ្យយើងបង្ហាញ ចូរយើងបង្ហាញ មេត្តា ព្រះបិតា ដែលស្រឡាញ់យើង ។

**បន្ទរ-ភ្នំតូចភ្នំធំៗ ពង្រាបឲ្យរាបៗ ផ្លូវដែលវៀចវេរៗ តម្រង់ឲ្យត្រង់ៗ ទទួលជីវិតៗ ដែលព្រះគ្រីស្តឲ្យយើងៗ ក្លាយជាបុត្រធីតាព្រះបិតាដែលស្រឡាញ់យើង ។**

## ១៩៤- ម៉ារ៉ាណាថា

ម៉ារ៉ាណាថា ម៉ារ៉ាណាថា ម៉ារ៉ាណាថា ម៉ារ៉ាណាថា
សូមព្រះយេស៊ូ ជាអម្ចាស់ សូមទ្រង់យាងមក ក្នុងដួងចិត្តយើង ។
ម៉ារ៉ាណាថា ម៉ារ៉ាណាថា ម៉ារ៉ាណាថា ម៉ារ៉ាណាថា ។

## ១៩៥- រង់ចាំព្រះគ្រីស្ត

រង់ចាំព្រះគ្រីស្ត ដែលទ្រង់យាងមក ! រង់ចាំព្រះគ្រីស្ត ចូរកែប្រែចិត្ត !

## ១៩៦- ឱ ! ព្រះសង្គ្រោះយើងខ្ញុំ

**បន្ទរ- ប. ឱ ! ព្រះសង្គ្រោះយើងខ្ញុំ (បន្ទរ) សូមយាងមកប្រោសយើងខ្ញុំ(បន្ទរ)**
**សូមទ្រង់កុំចាំយូរឡើយ (បន្ទរ) ព្រោះទុក្ខយើងខ្ញុំធ្ងន់ធ្ងរ (បន្ទរ) ។**

១- **ស.** ទិវារាត្រីទ្រង់ទតឃើញ អស់ទុក្ខយើងខ្ញុំព័ទ្ធរុំជុំជិត
សឹងតែបាត់បង់អស់ស្មារតី ឱ! ព្រះសង្គ្រោះសូមទ្រង់កុំបង្អង់ឡើយ ។

២- **ប.** មើលចំនួនទុក្ខរាប់ម៉ឺនលាន យើងខ្ញុំអស់សង្ឃឹម
បើទ្រង់ចាប់ទោសនោះណា តើអ្នកណាជួយសង្គ្រោះយើងខ្ញុំ
មានតែព្រះអង្គសូមទ្រង់កុំបង្អង់ឡើយ ហ៊ឺ ហ៊ឺ ហ៊ឺ ហ៊ឺ ។

## ១៩៧- ឱ ! ព្រះសង្គ្រោះសូមយាងមក

**បន្ទរ-ប. ឱ ! ព្រះសង្គ្រោះសូមយាងមក ស. ឱ ! ព្រះសង្គ្រោះសូមយាងមក**
**ប. រំដោះថ្ងៃដ៏សែនអភ័ព្វនៃយើងខ្ញុំ ស. ព្រះអង្គផ្តល់ជីវិតយើងខ្ញុំ**
**រួម. យាងមក ! យាងមក ! យាងមក !**

១-**ស.** ឱ ! ព្រះជាម្ចាស់ សូមយាងមកជួយ ស្រោចស្រង់មនុស្ស កុំឲ្យត្រូវស្លាប់
សូមជួយយើង កុំឲ្យយឺតយូរ ព្រះអង្គទ្រង់ទតទុក្ខព្រួយយើង
**ប.** ព្រះអង្គអត់ទោសកំហុសយើង **ស.**ព្រះអង្គទ្រង់ទតមកយើងវិញ
**រួម.**យាងមក ! យាងមក ! យាងមក !

២-**ស.**ឱ ! ព្រះជាម្ចាស់ ស្ថិតក្នុងបិន្តា ធ្វើឲ្យយើងខ្ញុំ ស្រឡាញ់ព្រះអង្គ
កាន់តែច្រើនជាង ជារៀងរាល់ថ្ងៃ ដើម្បីឲ្យយើងខ្ញុំនាំគេ
**ប.** អ្នកមិនទទួលឲ្យវិលបែរ **ស.** ឲ្យវិលបែររកព្រះអង្គវិញ
**រួម.**យាងមក ! យាងមក ! យាងមក !

## ១៩៨- ចូរយើងច្រៀង

១- ចូរយើងរួមអរសប្បាយ នៅថ្ងៃ ព្រះគ្រីស្តប្រសូត
ទាំងច្រៀងសរសើរព្រះម្ចាស់ ព្រះអង្គស្រឡាញ់លោកា
ប្រទានព្រះបុត្រាមក ជាព្រះសង្គ្រោះនៃយើង
ដើម្បីឲ្យយើងស្គាល់ ធម៌មេត្តាករុណារបស់ព្រះអង្គ ។

**បន្ទរ- ចូរយើងច្រៀង! ចូរយើងច្រៀង! កោតសរសើរព្រះគ្រីស្ត**
**ព្រោះព្រះអង្គបានប្រសូតមកនៅក្នុងលោកនេះហើយ ! ។**

**ចូរយើងច្រៀង! ចូរយើងច្រៀង! កោតសរសើរព្រះគ្រីស្ត**
**ព្រោះព្រះអង្គ បានប្រសូត មកនៅក្នុងលោកនេះ! ។**

២- ចូរយើងអបអរសប្បាយ ថ្ងៃព្រះបុត្រាប្រសូត
ព្រះនាមថ្វាយថាយេស៊ូ ជាព្រះសង្គ្រោះនៃយើង
ចូរយើងច្រៀងលើកតម្កើង តម្កើងសិរីរុងរឿង
តម្កើងព្រះធម៌មេត្តា ព្រះអង្គពិតជាព្រះរបស់យើង ។

៣- ចូរយើងយកគ្រឿងតង្វាយ មកថ្វាយព្រះរាជបុត្រា
ព្រះនាមអេម៉ានូអែល ព្រះអម្ចាស់គង់ជាមួយយើង
ចូរយើងក្រាបថ្វាយបង្គំ បង្គំច្រៀងលើកតម្កើង
តម្កើងព្រះរាជបុត្រា ព្រះអង្គយាងមកព្រោះស្រឡាញ់យើង ។

## ១៩៩- ជូនជារាត្រី

១- ជូនជារាត្រី ព្រះឱរសថ្លៃប្រសូតហើយ ចាំងពន្លឺរស្មីថ្លាសែនអស្ចារ្យ
ស្ថានលោកា ។

**បន្ទរ- គង្វាលចៀមអើយ កុំបីភ័យខ្លាច ចរចេញថ្លែងប្រាប់ការណ៍ដ៏ចម្លែក
ប្លែកពេកពន់ក្រៃ ហៅគ្នាមកឆាប់ ចូរប្រញាប់រៃ បង្គំក្សត្រថ្លៃបុត្រស្ដេចបារមី
ទ្រង់ប្រសូតហើយ។**

២- មើលបុត្រល្អថ្កើង ផ្ទុំលើចំបើងក្រោលគោលា បង្គំស្ដេចតូចកុមារបុត្រស្ងួគ៌ា
ពេញបារមី ។

## ២០០- តង្វាយណូអែល

១- ឱព្រះជាម្ចាស់អស្ចារ្យពេកក្រៃ សូមទ្រង់ប្រោសប្រណីដល់ជីវិតកូន
ខិតខំឃ្មាតខ្មីធ្វើការរាល់ថ្ងៃ ដើម្បីចិញ្ចឹមជីវិតខ្លួន ។ **(ភ្លេង)**
កូនសូមថ្វាយចិត្តរួមនិងដង្វាយ ច្រៀងសរសើរតម្កើងព្រះនាមព្រះអង្គ
អំណរសប្បាយរួមនិងទុក្ខព្រួយ កូនសូមថ្វាយទៅក្នុងព្រះហស្តព្រះជាម្ចាស់ ។

**បន្ទរ-ក្នុងនាមព្រះឱរស នំស្រាដង្វាយ ដែលយើងលើកថ្វាយឆ្ពោះព្រះនាមា
និងក្លាយទៅជាយញ្ញ សក្ការៈបូជាជីវិតលោកា រួមនិងព្រះកុមារសូមទ្រង់ទទួល។**

២-កូនដឹងច្បាស់ថាចម្រៀងដែលកូនច្រៀង ទោះពីរោះនិងមានខ្លឹមសារយ៉ាងណា
ក៏មិនបន្ថែមសិរីរុងរឿង នៃព្រះអង្គបានឡើយ ។ **(ភ្លេង)**
ហើយកូនក៏ដឹងតង្វាយដែលកូនថ្វាយ ទោះជាមានតម្លៃក្រាស់ក្រៃប៉ុនណា
មិនអាចប្រៀបផ្ទឹមព្រះរាជបុត្រា ដែលជាសេចក្ដីសង្ឃឹមនៃមនុស្សលោក ។

## ២០១- បុណ្យណូអែល ៩៨

១-ព្រះយេស៊ូជាប្រភពនៃជីវិតយើងរាល់គ្នា ព្រះអង្គជួយយើងឲ្យចេះរួបរួមគ្នា
ដោយក្ដីស្រឡាញ់ គោរពហើយអត់ឱនគ្នា មិនត្រូវប្រឹងយកឈ្នះចាញ់
ជួយគ្នាដោយក្ដីស្រឡាញ់ ជុតទោម្ចេញរស់បានសុខសាន្ដ ។

**បន្ទរ- សូមអរព្រះគុណព្រះអង្គ គុណធ្ងន់គ្មានអ្វីស្មើបាន**
**យាងចាកស្ថានដ៏សុខសាន្ត នាំមនុស្សស្ថានដែលនាំសង្គ្រោះ ។**

២-ព្រះអង្គមានក្ដីមេត្តា ករុណាជនដែលលើសលោះ ឲ្យជៀសពីផ្លូវអាក្រក់
រួចទុក្ខទោសជួបស្ថានបរមសុខ យើងត្រូវចេះស្រឡាញ់គ្នា ជួយគ្នាតាមព្រះសង្គ្រោះ
គោរពគ្នាដោយចិត្តស្មោះ នោះមានឈ្មោះកូនចៅព្រះអង្គ ។

## ២០២- បុត្រម្នាក់បានប្រសូត

**បន្ទរ-បុត្រម្នាក់បានប្រសូតមកសម្រាប់យើង ព្រះជាម្ចាស់បានប្រទានមកឲ្យយើង**
**ឫទ្ធានុភាពបុត្រនោះនឹងស្ថិតនៅ អស់កល្បជានិច្ច។**

១-ប្រជាជនដែលដើរ ក្នុងទីងងឹតបានឃើញ ពន្លឺភ្លឺត្រចង់
បំភ្លឺមនុស្សក្នុងទីងងឹត ព្រះជាម្ចាស់ប្រោសគេ ឲ្យសប្បាយរីករាយ
ដូចអ្នកស្រុកធ្លាប់សប្បាយ ក្នុងរដូវចម្រូត ។

២-ប្រាកដមានបុត្រមួយ បានប្រសូតសម្រាប់យើង ព្រះជាម្ចាស់ប្រទាន
បុត្រមួយឲ្យយើងរាល់គ្នា គេថ្វាយនាមបុត្រនោះ ថាព្រះដ៏មានប្រាជ្ញា
ព្រះសង្គ្រោះនៃយើង ព្រះអម្ចាស់នៃសន្តិភាព ។

## ២០៣- ព្រះកុមារយេស៊ូជានរណា ?

១- តើព្រះកុមារយេស៊ូជានរណា យាងមកក្នុងលោកាដើម្បីអ្វី ?
ព្រះអង្គជាព្រះមានឫទ្ធិបារមី មកយករូបកាយជាមនុស្សធម្មតា
ជាមួយមាតាក្នុងខ្ទមកម្សត់ទុរគត ។

២- ព្រោះតែស្រឡាញ់ព្រះអង្គស្ដាប់បង្គាប់ ធ្វើតាមព្រះទ័យនៃព្រះជាអម្ចាស់
យាងមកក្នុងលោកាបង្ហាញក្ដីមេត្ដា និងសេចក្ដីសង្ឃឹមនៃពិភពលោក
យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ។

អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា
អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា
អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា
អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា
អាលេលូយ៉ា អាម៉ែន ។

## ២០៤- ព្រះគ្រីស្ដប្រសូត

១- ព្រះគ្រីស្ដប្រសូតចូរអរសប្បាយ ឲ្យយើងរួមគ្នាសរសើរ
ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ព្រះគ្រីស្ដរំដោះលោកា
ព្រះអង្គមានធម៌មេត្ដា ឲ្យយើងៗច្រៀងកោតសរសើរ

២- ព្រះគ្រីស្ដយាងមកសង្គ្រោះលោកា ឲ្យយើងកែប្រែដួងចិត្ត
ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់ ចូរច្រៀងសរសើរព្រះម្ចាស់ៗ
ចូរច្រៀងៗ សរសើរព្រះម្ចាស់ ។

## ២០៥- ព្រះអម្ចាស់យេស៊ូប្រសូតហើយ

**បន្ទរ-ព្រះអម្ចាស់យេស៊ូប្រសូតហើយ ដែលបានប្រោសលោះអស់យើងខ្ញុំទាំងឡាយ**
**ព្រះអម្ចាស់យេស៊ូប្រសូតហើយ អស់បងប្អូនអើយ ចូរមកថ្វាយបង្គំ ។**

១- តាំងតែពីជាងបួនពាន់ឆ្នាំហើយ អស់គ្រូអាចារ្យសឹងតែបានទស្សទាយ
អរអំណរប្រសើរថ្លៃឧត្តម ឥឡូវព្រះទ្រង់ស្ដេចប្រសូតហើយ ។

២- ក្រោលគោក្លាយទៅជាព្រះពន្លា ចំបើងវល្លិ ជាគ្រែក្រឡាផ្ទុំ
ក្រោលគោក្លាយទៅជាព្រះពន្លា កម្សត់ក្រៃចំពោះស្ដេចបរមសុខ ។

## ២០៦- យប់ដ៏សុខសាន្ត

១- យប់ដ៏សុខសាន្ត យប់បរិសុទ្ធ យប់ស្ងាត់ឈឹងស្រួលបំផុត នៅជុំវិញព្រះរាជបុត្រា
ជាបុត្រដ៏វិសុទ្ធទន់ភ្លន់អស្ចារ្យ សូមផ្ទំលក់ដោយសុខសាន្តៗ ។

២- យប់ដ៏សុខសាន្ត យប់បរិសុទ្ធ គង្វាលចៀមបានភ័យស្លុតដោយសិរីរុងរឿងភ្លឺអស្ចារ្យ
និងទេវទូតមកច្រៀងអាលេលូយ៉ា ព្រះសង្គ្រោះប្រសូតហើយៗ ។

៣- យប់ដ៏សុខសាន្ត យប់បរិសុទ្ធ ព្រះយេស៊ូជារាជបុត្រ មានរស្មីភ្លឺចេញពីព្រះភក្ត្រ
ឲ្យបានឃើញបារមីព្រះអង្គយ៉ាងជាក់ ក្នុងកាលទ្រង់ប្រសូតនោះៗ ។

## ២០៧- យេស៊ូជាកូនចៀម

**បន្ទរ-ប. យេស៊ូកូនចៀម សុភាពពេកក្រៃ ដែលជាតង្វាយបូជាបិតា**
**តាំងពីគង់ក្នុងគភ៌មាតាថ្លៃ លុះត្រាតែក្ស័យ ព្រះជន្មព្រះអង្គ ។**

១- **ស.** ពេលព្រះអង្គប្រសូតនៅលោកីយ៍ **ប.** នៅលោកីយ៍
ដាច់ចិត្តថ្លាថ្លៃលះបោលស្ថានសុខ លះបោលស្ថានសុខ
ចុះមកយកឋានៈជាមនុស្ស ជាមនុស្ស
ឲ្យបានរួបរួមនឹងអស់យើងខ្ញុំ ។

២-**ស.** ឱ ! អស់មនុស្សម្នាទាំងឡាយអើយ **ប.** ទាំងឡាយអើយ
ចូរឱនក្រាបថ្វាយស្ដេចតូចកុមារ ស្ដេចតូចកុមារ
មិនខ្ពើមមនុស្សបាបក្នុងលោកីយ៍ បាកស្វែងរកកូនដែលវង្វេងផ្លូវ(**ពីរដង**)

## ២០៨- យើងរីករាយទទួលព្រះកុមារយេស៊ូ

១- យើងខ្ញុំសប្បាយរីករាយទទួល ព្រះកុមារដោយអំណរ
យើងខ្ញុំព្រមទទួលថា ព្រះអង្គ ជាព្រះបុត្រា នៃព្រះជាម្ចាស់
យាងមកសង្គ្រោះមនុស្សលោក ។

**បន្ទរ- យើងខ្ញុំរីករាយ ទទួលព្រះសង្គ្រោះ ជាព្រះនៃយើង ដោយចិត្តស្មោះស្ម័គ្រ**
**អបអរអំណរ ប្រសើរឧត្តម ចូរឱនក្រាបថ្វាយ ស្ដេចតូចកុមារ ។**

២- សូមតម្កើងសិរីរុងរឿង ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់
ហើយសូមឲ្យមនុស្សលោក ដ៏ជាទីស្រឡាញ់របស់
ព្រះម្ចាស់បានក្ដីសុខសាន្តអំណរតរៀងទៅ ។

## ២០៩- រាត្រីរងា

**ស.** រាត្រីរងាព្រះអង្គប្រសូត ព្រះអង្គប្រសូត គង់ក្នុងរូងថ្មលើស្មូកស្មៅ ក្នុងភូមិបេថ្លេហិម ពន្លឺរស្មីរុងរឿង ។

**ប.** ឮលើអាកាស សម្លេងទេវទូតសរសើរ **ស.**ចម្រៀងលាន់ឮរងំសរសើរភិរម្យពិរោះ

**ប.** បុត្រាស្តេចស្ថានបរមសុខ យាងមកប្រោសលោះយើង ។

**ស.** បងប្អូនចូរឆាប់មកមើល ក្នុងភូមិបេថ្លេហិម ព្រះអង្គប្រសូត កម្សត់ទុរគត ។

**បន្ទរ.ថ្ងៃនេះព្រះអង្គ ប្រសូតប្រោសលោះលោកីយ៍ !**

**ស.** ទ្រង់ផ្តល់មគ្គផលចូលមកឲ្យរាស្ត្រទាំងឡាយ

**ប.** ក្នុងភូមិបេថ្លេហិម គោលាផ្តល់ចំហាយ ស្តេចស្ថានបរមសុខ យាងមកលោះយើង

**ស.** បងប្អូនចូរឆាប់ មកមើលក្នុងភូមិបេថ្លេហិម **រួម.**ព្រះអង្គប្រសូតកម្សត់ទុរគត

## ២១០- រីករាយថ្ងៃណូអែល

១- យើងសែនរីករាយ យើងសែនសប្បាយៗ ដ្បិតព្រះកុមារ ទ្រង់បានប្រសូត ទ្រង់បានយាងមក ប្រោសលោះជនលោកា ដែលទន្ទឹងចាំព្រះអង្គ រង់ចាំព្រះអង្គ ។

**បន្ទរ- យើងសែនសប្បាយ សែនសប្បាយ សែនសប្បាយ ទទួលព្រះអង្គ**
**យើងសូមទូលថ្លែង អំណរគុណ អំណរគុណ ឆ្ពោះព្រះជាម្ចាស់**
**ដែលទ្រង់យាងមក សង្គ្រោះសត្វលោក ។**

២- យើងច្រៀងរួមគ្នា និងអស់ទេវទូតៗ ច្រៀងកោតសរសើរ ថ្វាយព្រះបុត្រា ទ្រង់បានប្រសូត នៅក្នុងខ្ទមកម្សត់ យើងគ្រប់គ្នាក្រាបបង្គំ សូមក្រាបបង្គំ ។

## ២១១- ហោរាមកថ្វាយបង្គំ

**បន្ទរ-ស.នៅលើមេឃកណ្ដាលអាកាសរាត្រី មានពន្លឺភ្លឺចម្លែក ប្លែកអស្ចារ្យចម្លែក**
**ប. នៅលើមេឃកណ្ដាលអាកាសរាត្រី មានពន្លឺភ្លឺចម្លែក ប្លែកអស្ចារ្យចម្លែក**
**ស.មានអង្គក្សត្រថ្លៃប្រសូតនៅលោកីយ៍ ដោយសាររស្មីនាំយើងមកដល់ព្រះអង្គ**
**រួម. ដោយសាររស្មីនាំយើង មកដល់ព្រះអង្គ ។**

១-**ស.**ឱ! ទីភូមិដែលព្រះសង្គ្រោះប្រសូត គួរឲ្យសរសើរដល់វាសនាឯងក្នុងថ្ងៃនេះ
**ប.**ពួកហោរាមកពីទិសខាងកើត ដោយមានផ្កាយបំភ្លឺនាំផ្លូវមកដល់កន្លែង
**រួម.**ពួកហោរាមកពីទិសខាងកើត យាងមកស្វែងរកព្រះអង្គសង្គ្រោះប្រសូត ។

២-**ស.**ដល់កន្លែងដែលបុត្រគង់តែអង្គឯង ទទួលស្គាល់ក្មេងតូចជាព្រះរាជបុត្រា
**ប.**ទាំងថ្វាយតង្វាយដោយចិត្តស្រឡាញ់ ហើយមានចិត្តជឿទុកជាទីសម្គាល់ដរាប
**រួម.**ទាំងថ្វាយតង្វាយដោយចិត្តស្រឡាញ់ ប្រសើរជាងមាសកំញ៉ាននិងជ័រល្វីងទេស ។

## ២១២- អបអរថ្ងៃកំណើតព្រះយេស៊ូ

ចូរអបអរថ្ងៃកំណើតព្រះគ្រីស្ត ចូរអបអរថ្ងៃកំណើតព្រះគ្រីស្ត
ចូរអបអរថ្ងៃកំណើតព្រះ គ្រីស្ត និងថ្ងៃចូលឆ្នាំថ្មី
សូមព្រះម្ចាស់ប្រទានពរ ដល់បងប្អូនទាំងឡាយ
ឲ្យបានសេចក្ដីសុខសាន្ត នៅថ្ងៃបុណ្យណូអែល ។

## ២១៣- អេម៉ានូអែល ១

១- ព្រះយេស៊ូព្រះរាជបុត្រា បានចាប់កំណើតមកជាមនុស្ស
ដើម្បីនាំនូវក្តីស្រឡាញ់ សម្រាប់មនុស្សគ្រប់ជាតិគ្រប់សាសន៍ ។
២- ព្រះនាងព្រហ្មចារិនីម៉ារី បានប្រសូតបុត្រដ៏ឧត្តម
អេម៉ានូអែលព្រះសង្គ្រោះ បំភ្លឺពិភពលោកទាំងមូល ។

**បន្ទរ- បុត្រមនុស្ស... បានប្រសូតហើយ ចូរយើងមានអំណរសប្បាយ**
**អេម៉ានូអែល អេម៉ានូអែល អេម៉ានូអែល អេម៉ានូអែល**

២- អស់អ្នកដែលអស់សង្ឃឹមអើយ ចូររង់ចាំទទួលព្រះរាជ្យ
ដោយមានចិត្តអំណររីករាយ ដ្បិតព្រះអម្ចាស់គង់ជាមួយ ។
៤- ព្រះបុត្រានៃព្រះបិតា ពិតជាព្រះដ៏វិសុទ្ធ
ដែលប្រទានព្រះវិញ្ញាណ នៃក្តីស្រឡាញ់ ឲ្យយើង ។

**បន្ទរ- បុត្រមនុស្ស....... បានប្រសូតហើយ ចូរយើងមានអំណរសប្បាយ**
**អេម៉ានូអែល អេម៉ានូអែល អេម៉ានូអែល អេម៉ានូអែល......**

## ២១៤- ឱ ! ពួកគង្វាល

១- ឱ ! ពួកគង្វាលសត្វអើយ សូមស្តាប់ ដំណើរយើងប្រាប់ការណ៍ជាកុំខ្លាច
ដឹងការណ៍ចម្លែកប្លែកដែលទន្ទឹង នៅក្រោលគោនៅស្រុកបេថ្លេហិម ។

**បន្ទរ- យើងខ្ញុំក្រាបថ្វាយបង្គំព្រះគ្រីស្ត ជាស្តេចស្ថានបរមសុខ**
**យើងខ្ញុំក្រាបថ្វាយបង្គំព្រះគ្រីស្ត ជាស្តេចស្ថានបរមសុខ**

២- នឹកឃើញព្រះអម្ចាស់របស់យើង ចុះមកយោនយកកំណើតជាក្មេង
ដេកក្រោលចំបើងជណ្តប់កន្ទេល រងាក្រៃលែងព្រោះអាណិតយើង ។

## ២១៥- ឱ ! មេឃស្ងប់ស្ងន្យ

១- ឱ ! មេឃស្ងប់ស្ងន្យ ប្រាំបួនជាន់ក្រៃ ចម្លែកក្រៃពេក
ពិភពដែនដី បុត្រស្តេចបរមសុខ យាងមកប្រសូត
ដាក់អង្គកុមារ គួរប្រដូចតូចកម្សត់ លំបាកទុរគតឯកអង្គ
ថ្ងៃនេះយល់ទ្រង់ មកកើតជាមនុស្ស ទ្រង់ជាអម្ចាស់
នៃដែនលោកា នៃដែនលោកា ។

២- រាត្រីយប់ស្ងាត់ ស្តេចព្រះមាតា ប្រសូតបុត្រថ្កើង
រុងរឿងថ្លៃថ្លា នៅនានគរបន្ទាយបេថ្លេហឹម ដាក់បុត្រឲ្យផ្ទំ
ក្នុងក្រោលសត្វគោសត្វលា យកចំបើងធ្វើពូកខ្នើយ ស្នូកជាព្រះក្រឡាបន្ទំ
ទ្រង់ជាអម្ចាស់ នៃដែនលោកាៗ ។



## ២១៦- កោតសរសើរព្រះគ្រីស្ត

**បន្ទរ- យើងកោតសរសើរព្រះគ្រីស្ត អស់ពីដួងចិត្ត ដែលបានបូជាជីវិត ឲ្យយើងរាល់គ្នា ចូរកោតសរសើរ ចូរលើកតម្កើង ព្រះបិតាយើងដែលទ្រង់មានធម៌មេត្តា។**

១-ឱ! ប្រជាជាតិទាំងឡាយអើយ ចូរសរសើរ ធម៌មេត្តាដែលព្រះបុត្រាបង្ហាញ
២-ព្រះបុត្រាដែលគង់ខាងស្តាំព្រះបិតា សូមព្រះអង្គប្រោសជួយអង្វរឲ្យយើង!
៣-ព្រះយេស៊ូជាព្រះគ្រីស្ត បូជាជីវិត ទ្រង់លះបង់ ដើម្បីសង្គ្រោះលោកា
៤-សូមឲ្យយើងផ្ញើជីវិតទៅអង្គព្រះគ្រីស្ត ហើយធ្វើតាមព្រះបន្ទូលព្រះអង្គផង
៥- ព្រះបិតាព្រះបុត្រានិងព្រះវិញ្ញាណ សូមព្រះអង្គទ្រង់ព្រះមេត្តាយើងខ្ញុំ ។

## ២១៧- ចូររៀបចំផ្លូវ

| | | | | |
|---|---|---|---|---|
| ១- | ចូររៀបចំផ្លូវៗ | រៀបផ្លូវ | ថ្វាយព្រះជាម្ចាស់ | |
| | រៀបចំចិត្តគំនិត | ដើម្បីទទួល | ព្រះរាជ្យព្រះម្ចាស់ | ។ |
| ២- | ចូរតម្រង់ផ្លូវៗ | តម្រង់ផ្លូវ | ថ្វាយព្រះជាម្ចាស់ | |
| | តម្រង់ចិត្តគំនិត | ដើម្បីទទួល | ព្រះជាអម្ចាស់ | ។ |
| ៣- | ចូរកែប្រែចិត្តៗ | កែប្រែចិត្ត | រកព្រះជាម្ចាស់ | |
| | កែប្រែចិត្តគំនិត | នោះព្រះជាម្ចាស់ | យាងមកសង្គ្រោះ | ។ |
| ៤- | ចូរកែគំនិតៗ | កែគំនិត | សារភាពកំហុស | |
| | ចូរកែប្រែគំនិត | ដើម្បីព្រះម្ចាស់ | លើកលែងទោសឲ្យ | ។ |

## ២១៨- ឈើឆ្កាងនៃទុក្ខលំបាក

១- ព្រះយេស៊ូទ្រង់បានបូជាព្រះជន្ម ដោយអំពើបាបរបស់យើង
ធ្វើឲ្យព្រះអង្គបានសោយក្ដីលំបាក ស៊ូទ្រាំរងទុក្ខនៅលើឈើឆ្កាង ។

**បន្ទរ- ដោយឈើឆ្កាងនៃទុក្ខលំបាក របស់ទ្រង់បានមកសង្គ្រោះយើង**
**ក្នុងទីងងឹតឲ្យមានជីវិតថ្មីឡើង ចូរយើងកែប្រែចិត្តគំនិតថ្មី**
**ទទួលព្រះយេស៊ូគ្រីស្ត ព្រះអង្គទ្រង់គង់នៅជាមួយយើង**
**ឲ្យយើងមានក្ដីសង្ឃឹមឡើងវិញ ។**

២- កូនសូមអរព្រះគុណទៅដល់ព្រះជាម្ចាស់ ដែលផ្ដល់ក្ដីស្រឡាញ់ឲ្យយើង
ដោយបូជាជីវិត គឺដើម្បីកូន ចូរយើងរឹងមាំដើរតាមព្រះអង្គ ។



# ២១៩- តើព្រះជាម្ចាស់ជានរណា ?
(ចម្រៀងទី ១)

១- តើព្រះជាម្ចាស់ជានរណា?　　ទុកឲ្យមនុស្សបានយកឈ្នះ
ចាប់យកធ្វើបាបយ៉ាងដូច្នេះ　　ដោយទ្រង់មិនចេះចាប់កំហុសឡើយ ។

**បន្ទរ-តើព្រះជាម្ចាស់ជានរណា?　　ដែលស្រឡាញ់មនុស្សលោកយ៉ាងនេះ?(២ដង)**

២- តើព្រះជាម្ចាស់ជានរណា?　　ដែលបានសោយព្រះទិវង្គត
ប្រទានជីវិតមិនរលត់　　ឲ្យមនុស្សរួមរស់ជាមួយព្រះអង្គ ។

៣- តើព្រះជាម្ចាស់ជានរណា?　　ដែលយំសោកាលើទុក្ខា
នៃមនុស្សលោកាដូចមាតា　　សោកសៅសោកាទុក្ខកូនភ្ញាណា ។

៤- តើព្រះជាម្ចាស់ជានរណា?　　ដែលប្រទានព្រះរាជបុត្រា
និងមាតាឲ្យគ្រប់អាត្មា　　រួមសុខទុក្ខានឹងអស់យើងណា ។

៥- តើព្រះជាម្ចាស់ជានរណា?　　ដែលទ្រង់ត្រាស់ហៅរូបកាយយើង
ឲ្យទទួលសិរីរុងរឿង　　ឯស្ថានបរមសុខរួមនឹងព្រះអង្គ ។

៦- តើព្រះជាម្ចាស់ជានរណា?　　មានធម៌មេត្តាករុណា
តើក្តីស្រឡាញ់ជានាមឬ?　　ត្រាស់ហៅមនុស្សគឺជាបុត្រធីតា ។

## ២២០- ទំនុកតម្កើងលេខ ៧២ (៧១)

**បន្ទរ- ព្រះគ្រីស្តជួយសង្គ្រោះជនក្រីក្រ និងផ្តល់សន្តិភាពឲ្យមនុស្សលោក ជាអង្វែងតរៀងទៅ ។**

១- ព្រះគ្រីស្តជាម្ចាស់ទ្រង់សោយរាជ្យ ពេញដោយអំណាចនិងយុត្តិធម៌
ទ្រង់វិនិច្ឆ័យដោយសុចរិត ទាំងចេះគូរគិតដោយប្រាជ្ញា ។

២- ព្រះអង្គសង្គ្រោះជនក្រីក្រ ទ្រង់ប្រោសប្រណីជនខ្សត់ខ្សោយ
ទ្រង់គង់ក្នុងលោកដោយស្ថិតស្ថេរ ទ្រង់មិនផ្លាស់រេប្រែប្រួលឡើយ ។

៣- ទ្រង់គង់សណ្ឋិតក្នុងលោកីយ៍ ផ្តល់ព្រះបារមីដ៏អស្ចារ្យ
ព្រះរាជ្យពេញដោយសន្តិភាព ពុំសាបរលាបរលាយសូន្យ ។

៤- ទ្រង់មានអំណាចពេញលោកីយ៍ ទូទាំងដែនដី និងសមុទ្រ
ពួកបច្ចាមិត្តក្រាបភិតភ័យ ជនពាលទីទៃក៏កោតស្ញែង ។

៥- ស្តេចគ្រប់ប្រទេសទាំងជិតឆ្ងាយ នឹងលំទោនកាយថ្វាយបង្គំ
ព្រះអង្គជាម្ចាស់លើពិភព ខ្ពង់ខ្ពស់លើសលប់ស្តេចនានា ។

៦- ទ្រង់ជួយឧបត្ថម្ភជនក្រីក្រ ដែលសូមអង្វរព្រះជាម្ចាស់
ទ្រង់ប្រោសមេត្តាជនទុរគត ជនកម្សត់ដែលគ្មានទីពឹង ។

៧- ទ្រង់ប្រោសជីវិតគេឲ្យផុត ពីការសម្លុតបិត្តឃោរឃៅ
ព្រះគ្រីស្តជាម្ចាស់ទ្រង់ទាមទារ ពីសត្រូវមារបង្ហូរឈាម ។

៨- សូមកោតសរសើរឆ្លោះព្រះគ្រីស្ត ពីឥឡូវនេះតរៀងទៅ
ព្រះរាជ្យព្រះអង្គតែងគង់នៅ ស្ថិតស្ថេរតទៅមិនសាបសូន្យ ។

៩- សូមកោតសរសើរព្រះត្រៃឯក ដែលទ្រង់នឹងគង់តរៀងទៅ
ព្រះជន្មព្រះអង្គនៅគង់វង្ស ជរាបយូរលង់ពុំសាបសូន្យ ។

## ២២១- នេះគឺជាសេចក្ដីស្រឡាញ់

១- នៅលើឈើឆ្កាង យើងឃើញព្រះគ្រីស្ដ សោយទិវង្គតបូជា
យើងមានបាបច្រើនឥតគណនា សូមព្រះអង្គលើកលែង ។

**បន្ទរ-នេះគឺជាសេចក្ដីស្រឡាញ់ ដែលបានបូជាព្រះជន្ម**
**ឲ្យយើងបានរួចពីក្ដីស្លាប់ រស់នៅជាមួយព្រះម្ចាស់ ។**

២- ព្រះលោហិតបង្ហូរ ពេញខ្លួនឈឺចុកចាប់ពេកក្រៃ បន្លាជាមកុដ
ព្រះអង្គស៊ូទ្រាំដល់កន្លែងឈើឆ្កាង ។

## ២២២- នេះជាឈើឆ្កាង

**ប-** នេះជាឈើ ដែលគេឆ្កាងព្រះយេស៊ូគ្រីស្ដ
គេបានធ្វើគុតព្រះសង្គ្រោះមនុស្សលោក នៅលើឈើនេះ !

**គ្រ-** យើងខ្ញុំសូមក្រាបបង្គំព្រះឈើឆ្កាង ។

## ២២៣- បុត្រព្រះអម្ចាស់

១- បុត្រព្រះអម្ចាស់ បានឆ្កាងព្រះហស្ដ ជាយញ្ញបូជា ដោយទ្រង់ជ្រាបច្បាស់
កិច្ចការនានា រងទុក្ខវេទនា នៃមនុស្សលោកីយ៍ ។

២- ក្ដីស្រឡាញ់ត្រង់ របស់ព្រះអង្គ ទាញយកផែនដី ទាំងមូលចូលមក
ហើយទ្រង់ឃ្មាតខ្មី នាំមនុស្សប្រុសស្រី ឆ្ពោះព្រះបិតា ។

៣- ដោយអង្គព្រះគ្រីស្ដ ទ្រង់ព្រះតម្រិះ កែប្រែលោកា ទ្រង់ជាដើមចុង
សារពើនានា ក៏ក្លាយទៅជា អំណោយព្រះអង្គ ។

## ២២៤- ព្រះយេស៊ូគ្រីស្តបានបូជាជីវិត

១- ព្រះយេស៊ូគ្រីស្តបានបូជាជីវិត  ដើម្បីឲ្យលោករួចពីសេចក្តីស្លាប់
ដោយចិត្តស្រឡាញ់ ទ្រង់បានលះបង់ជីវិត ដោយព្រះបន្ទូលឲ្យយើងរួបរួមគ្នា
យើងសូមដើរតាមព្រះគ្រីស្តរហូតតទៅ ធ្វើតាមព្រះបន្ទូលព្រះអម្ចាស់ ។

**បន្ទរ-ខ្ញុំសូមដើរតាមព្រះយេស៊ូ ព្រះគ្រីស្តជាសេចក្តីពិត ព្រះគ្រីស្តជាជីវិត**
**គឺជាសេចក្តីស្រឡាញ់ ធ្វើតាមព្រះបន្ទូលព្រះគ្រីស្ត**
**គឺស្រឡាញ់អ្នកដទៃទៅវិញទៅមក ឲ្យដូចបងប្អូន ត្រូវរួបរួមគ្នា**
**ដើរទៅកាន់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។**

២- ក្នុងដំណើរជីវិតយើង ព្រះគ្រីស្តតែងតែស្រឡាញ់ ទ្រង់ឲ្យយើងចេះរួបរួម
និងស្រឡាញ់គ្នាដូចបងប្អូនយើង សូមដើរតាមព្រះគ្រីស្តរហូតតទៅ
ធ្វើតាមព្រះបន្ទូលព្រះអម្ចាស់ ។(**បន្ទរ**)

## ២២៥- ព្រះគ្រីស្តព្រះសង្គ្រោះ

យើងជឿពិត ព្រះគ្រីស្ត គង់ជាមួយយើង យើងសូមកោតសរសើរ
លើឈើឆ្កាង ព្រះអង្គ ទ្រង់បានសង្គ្រោះយើង យើងសូមកោតសរសើរ
ឱ ! ព្រះគ្រីស្ត ជីវិតបូជាលើឈើឆ្កាង យើងសូមកោតសរសើរ ទ្រង់រំដោះ
បាបយើងមនុស្សលោកីយ៍ យើងសូមកោតសរសើរ ។

# ២២៦- ព្រះគ្រីស្ទព្រះសង្គ្រោះ

**បន្ទរ-ឱ! ព្រះគ្រីស្ដអើយ! ឱ! ព្រះគ្រីស្ដអើយ! មេត្តាប្រណី**

១- ឱ! ព្រះគ្រីស្ដអើយ ព្រះអង្គពិតជា ព្រះរាជបុត្រា
នៃព្រះបិតា ដោយព្រះហឫទ័យ ស្រឡាញ់មនុស្ស
ព្រះអង្គបូជាជីវិតដើម្បី សង្គ្រោះយើងខ្ញុំ ។

២- ឱ! ព្រះគ្រីស្ដអើយ ដោយស្ដាប់បង្គាប់ តាមព្រះហឫទ័យ
នៃព្រះបិតា ព្រះអង្គបូជា ព្រះជន្មថ្លៃថ្លា
ប្រទានជីវិតរុងរឿងអស់កល្ប ផ្ដល់ឲ្យមនុស្សលោក ។

៣- ឱ! ព្រះគ្រីស្ដអើយ ព្រះអង្គពិតជា ព្រះរាជបុត្រា
នៃព្រះបិតា ជាព្រះវិសុទ្ធ ឧត្ដមថ្លៃថ្លា
ពេលព្រះអង្គឡើងគ្រងរាជ្យ សូមទ្រង់ កុំភ្លេចយើងខ្ញុំ ។

៤- ឱ! ព្រះគ្រីស្ដអើយ ព្រះដ៏វិសុទ្ធ ឧត្ដមថ្លៃថ្លា
ជាព្រះបុត្រា ដោយសង្គ្រោះខ្ញុំ ជាមនុស្សមានបាប
ព្រះអង្គបូជាជីវិតសុគត នៅលើឈើឆ្កាង ។

៥- ឱ! ព្រះគ្រីស្ដអើយ ព្រោះបាបយើងខ្ញុំ ធ្វើឲ្យព្រះអង្គ
រងទុក្ខលំបាក បូជាព្រះជន្ម នៅលើឈើឆ្កាង
សូមទ្រង់មេត្តាអាណិត លើកលែងទោសឲ្យខ្ញុំផង ។

## ២២៧- ព្រះយេស៊ូជួយសង្គ្រោះ

១- ព្រះគ្រីស្ដជាព្រះពិតប្រាកដ ទ្រង់បានសោយទិវង្គតទាំងវេទនា
ព្រោះតែធ្វើតាមព្រះបញ្ជា នៃព្រះបិតាដែលថ្វាយនាម ។

២- ព្រះកេសពោរពេញដោយលោហិត ព្រះកាយជុំជិតសុទ្ធតែស្នាម
គេទុកព្រះអង្គដូចសំរាម ព្រះកាយនិងឈាមសែនវេទនា ។

៣- ដោយស្នាមរបួសនៃព្រះអង្គ អាចជួយស្រោចស្រង់យើងគ្រប់គ្នា
ឲ្យផុតបាបទុក្ខផងនានា ស្គាល់ក្ដីសុខជាបានសះស្បើយ ។

៤- ព្រះអង្គបម្រើព្រះបិតា អាសូរមេត្តាមិនកន្ដើយ
បំភ្លឺមនុស្សលោកឲ្យស្គាល់ត្រើយ មិនឲ្យល្ងេងល្ងើយគ្រប់ទិសទី ។

៥- ព្រះនាមព្រះអង្គល្បីសុសសាយ រន្ទឺខ្ទរខ្ទារពេញលោកា
សត្វលោកទាំងឡាយកោតបេស្ដា ហើយប្រកាសថាទ្រង់ជាព្រះអម្ចាស់ ។

## ២២៨- ព្រះយេស៊ូបានសុគត

១- ព្រះយេស៊ូបានសុគត ទ្រង់បានបូជាព្រះជន្មឰដ៏ឈើឆ្កាង
អំពើអាក្រក់មនុស្សច្រើនពន់ប្រមាណ ធ្វើឲ្យព្រះអង្គសោយក្ដីលំបាក
ដោយស៊ូទ្រាំរងទុក្ខក្នុងអង្គប្រាណ ។

២- មាតារបស់ព្រះអង្គ រងទុក្ខឈឺចាប់ខ្លោចផ្សានៅក្បែរឈើឆ្កាង
ពេញទាំងឱរាមេត្តាអាណិតបុត្រថ្លៃ ដែលរងទណ្ឌកម្មដោយមិនបេញស្ដី
ដើម្បីសង្គ្រោះមនុស្សលោកីយ៍ ។

៣- យើងខ្ញុំថ្លែងអំណរគុណ ចំពោះហឫទ័យមេត្តាសន្ដោសយើងខ្ញុំ
យើងខ្ញុំសូមសន្យាថាវៀរបាកអាក្រក់ សូមជួយយើងខ្ញុំកាន់ផ្លូវទៀងត្រង់
និងបានជ្រកកោនក្រោមម្លប់ព្រះអង្គ ។

## ២២៩- ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

បន្ទរ- រួម. ជយោ ! ព្រះរាជវង្សព្រះបាទដាវីឌ
ស. សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះគ្រីស្ត
ប. ដែលយាងមកក្នុងព្រះនាមព្រះអង្គ
រួម. ជយោ ! ព្រះអម្ចាស់ដែលគង់ឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

១- ឱ ! ទ្វារទាំងឡាយរចនាល្អ ចូរបើកចំហត្រឹមត្រូវត្រង់
ចូរបើកចំហថ្វាយមហាក្សត្រ ព្រះអង្គយាងកាត់មានសិរី
រុងរឿងបវរទាំងបារមី ព្រះនាមល្បាញល្បីព្ញខ្ទរខ្ទារ ។

២- តើមហាក្សត្រនោះជានរណា មនុស្សធម្មតានៅរៀងអាយ
ឬអ្នកមានបុណ្យមកពីឆ្ងាយ អម្ចាស់នេះហើយដែលយើងថ្វាយ
បង្គំឱនកាយអធិដ្ឋាន ព្រះអង្គជាមហាក្សត្រថ្កើងថ្កាន ។

៣- ឱ ! ទ្វារទាំងឡាយរចនាល្អ ចូរបើកចំហត្រឹមត្រូវត្រង់
ចូរបើកចំហថ្វាយមហាក្សត្រ ព្រះអង្គយាងកាត់មានសិរី
រុងរឿងបវរទាំងបារមី ព្រះនាមល្បាញល្បីព្ញខ្ទរខ្ទារ ។

៤- តើមហាក្សត្រនោះជានរណា ពូជពង្សក្សត្រាឬក្លែងក្លាយ
គឺព្រះអម្ចាស់ជាមហាក្សត្រ រុងរឿងប្រោសសត្វលោកគ្រប់ប្រាណ
មានសិរីជោគជ័យថ្មីមពុំបាន កម្លាំងប៉ុន្មានទ្រង់ជាអម្ចាស់ ។

## ២៣០- យើងខ្ញុំសូមក្រាបបង្គំ

បន្ទរ- យើងខ្ញុំសូមក្រាបបង្គំ គោរពដល់ព្រះឧត្តម
ដែលបានប្រោសលោះលោកា ដោយបានបូជាព្រះជន្ម ។

១- គ្រាប់ស្រូវធ្លាក់នៅលើដី ឧបមេយ្យបើមិនងាប់ទៅ
គ្រាប់នៅតែមួយដដែល មិនអាចបង្កើតផលឡើយ ។

២- អ្នកណាស្រឡាញ់ជីវិត អ្នកនោះពិតជាបាត់វា
អ្នកដែលស្ម័គ្រចិត្តលះបង់ នឹងរក្សាជីវិតគង់ ។

៣- អ្នកណាចង់បម្រើខ្ញុំ អ្នកនោះនឹងខំមកតាម
រីអ្នកដែលបានបម្រើ ព្រះបិតាតម្កើងគេ ។

## ២៣១- រួមគ្នាកោតសរសើរព្រះគ្រីស្ត

រួមគ្នាកោតសរសើរព្រះគ្រីស្ត បូជាជីវិតឲ្យយើង យើងខ្ញុំសូមលើកតម្កើង
សរសើរអស់កល្បជានិច្ច រួមគ្នាសរសើរ តម្កើងនឹងធម៌មេត្តា
ឲ្យយើងជាបុត្រធីតា ព្រះបិតាដែលស្រឡាញ់យើង ។

## ២៣២- សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តា

**បន្ទរ-សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តា អាសូរករុណា និងប្រោសប្រណី**
**សូមទ្រង់ប្រទានព្រះពរជោគជ័យ ដោយព្រះហឫទ័យដ៏សប្បុរស ។**

១- មនុស្សក្នុងពិភពលោកសាកល មុខជានឹងស្គាល់នូវការសង្គ្រោះ
ព្រមទាំងបានយល់នូវក្តីសន្តោស ជាបំណងខ្ពស់របស់ព្រះអង្គ ។

២- សូមឲ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍ រួមគ្នាប្រកាសនូវចិត្តស្មោះត្រង់
ថ្លែងអំណរគុណចំពោះព្រះអង្គ ដែលទ្រង់ស្រោចស្រង់មនុស្សលោកា ។

៣- សូមឲ្យប្រជារាស្ត្រជងទាំងឡាយ ច្រៀងអរសប្បាយអស់ពីចិន្តា
ដ្បិតព្រះអង្គតែងគ្រប់គ្រងរក្សា មនុស្សក្នុងលោកាដោយយុត្តិធម៌ ។

៤- ព្រះអង្គណែនាំមនុស្សលោកីយ៍ គ្រប់ជាតិប្រុសស្រីឲ្យឡើងត្រង់ល្អ
គ្រប់គ្រងដែនដីនិងប្រជាករ ត្រឹមត្រូវបវរត្រចះត្រចង់ ។

៥- សូមឲ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍ រួមគ្នាប្រកាសនូវចិត្តស្មោះត្រង់
ថ្លែងអំណរគុណចំពោះព្រះអង្គ ដែលទ្រង់ស្រោចស្រង់មនុស្សលោកា ។

៦- ព្រះជាអម្ចាស់បានប្រោសប្រទាន ឲ្យដែនដីមានភោគផលថ្លៃថ្លា
ព្រមទាំងប្រទានព្រះពរជ័យា ឲ្យយើងគ្រប់គ្នាបានក្តីសុខុម ។

៧- សូមព្រះជាម្ចាស់មេត្តាប្រណី ប្រទានពរជ័យមកដល់យើងខ្ញុំ
សូមឲ្យមនុស្សលោកក្រាបថ្វាយបង្គំ កោតខ្លាចប្រណម្យព្រះអង្គគ្រប់ប្រាណ ។

៨- សូមកោតសរសើរឆ្លោះព្រះបិតា ទាំងព្រះបុត្រា និងព្រះវិញ្ញាណ
ដែលគង់ស្ថិតស្ថេរប្រសើរថ្កើងថ្កាន នៅគ្រប់ទីស្ថានជរាបរៀងទៅ ។

## ២៣៣- សូមព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់

១-សូមព្រះជាម្ចាស់អាសូរស្ដាប់សំឡេងកូន ឯទីជម្រៅជ្រៅខំស្រែកហៅព្រះអង្គ
កុំទុកបោលកូននៅក្នុងក្ដីអាម៉ាស សូមស្ដាប់សម្រែកកូនជាអ្នកបាប ។

២-កាលណាកូនភាវនាយ៉ាងខ្លាំងក្លា កូនសង្ឃឹមថាព្រះម្ចាស់អាសូរប្រណី
ផ្ដល់សេចក្ដីសុខពោរពាសមកដែនដី លោះលាលោកីយ៍ឲ្យរួចពីទុក្ខ ។

៣-ព្រលឹងកូនសង្ឃឹមលើព្រះអង្គទំនុក សូមទ្រង់កុំភ្លេចមេត្ដាប្រណីផង
ឥតនរណាមួយអាចឈរនឹងឡើយហោង បើព្រះអង្គពុំមេត្ដាអត់ទោសឲ្យ ។

៤-ព្រលឹងកូនសង្វាតទន្ទឹងរង់ចាំ សូមទ្រង់អាណិតនឹកភ្នកមករកកូន
បីដូចអ្នកចាំយាមរមែងរង់ចាំ មើលពន្លឺរស្មីផ្កាយព្រឹករះ ។

## ២៣៤- សូមមេត្តាប្រោសយើងខ្ញុំ

**បន្ទរ-សូមមេត្តាប្រោសយើងខ្ញុំ ឱ !ព្រះជាអម្ចាស់ ដែលបានរងទុក្ខ និងសង្គ្រោះលោកា**

១-សូមប្រោសយើងខ្ញុំ ឱ! ព្រះជាអម្ចាស់ ព្រោះយើងខ្ញុំបានធ្វើអាក្រក់ ។

២-សូមប្រោសយើងខ្ញុំ ឱ!ព្រះជាអម្ចាស់ ដែលបានសន្ដោសប្រោសលោកា ។

៣-សូមប្រោសយើងខ្ញុំ ឱ!ព្រះជាអម្ចាស់ ដែលបានបូជាព្រះជន្មសម្រាប់លោកា ។

៤-សូមប្រោសយើងខ្ញុំ ឱ!ព្រះជាអម្ចាស់ ដែលបានរំដោះលោកាដោយលោហិតព្រះអង្គ ។

៥-សូមប្រោសយើងខ្ញុំ ឱ! ព្រះជាអម្ចាស់ ដែលបានប្រទានជីវិតឲ្យលោកាវិញ ។

## ២៣៥- អំពើអាក្រក់របស់ខ្ញុំ

១- អំពើអាក្រក់ខ្ញុំច្រើនឥតគណនា ធ្វើឲ្យព្រះម្ចាស់ព្រួយហឫទ័យ
ម្តេចឡើយក៏ខ្ញុំនៅរឹងទទឹង មិនចាប់ភ្លឹកលន់តួព្រះអង្គ ។

**បន្ទរ- ព្រះអម្ចាស់ខ្ញុំដឹងច្បាស់ហើយថា ព្រោះយើងខ្ញុំទើបព្រះអង្គក្ស័យ**
**ដោយរងទុក្ខលំបាកឥតចេញស្តី ខ្ញុំសូមទោសសូមទ្រង់មេត្តា ។**

២- នៅសួនច្បារកេតសេម៉ានីនោះ ព្រះអង្គជួលព្រោះទតបាបច្រើន
សូមបិតាវៀរពែងទុក្ខនេះចេញ តែសូមតាមព្រះហឫទ័យចុះ ។

៣- ពេលយូដាអ្នកក្បត់មកដល់ភ្លាម លក់ព្រះអង្គថ្លៃសាមសិបរៀល
ពួកឯងមកចាប់ខ្ញុំដូចចាប់ចោរ តែទ្រង់ធ្វើតាមព្រះបិតា ។

៤- ស៊ីម៉ូនសិលាក៏មានចិត្តក្បត់ មិនហ៊ានប្រកាសថាជាគ្រូឯង
តែមានចិត្តកំសាកនិយាយក្លែង ខ្ញុំមិនដែលស្គាល់អ្នកនោះទេ ។

៥- មហាបូជាចារ្យពួកជំនុំ ត្មះដៀលព្រះអង្គគ្រប់ប្រការ
មើលព្រះអង្គពុំដឹងជានរណា ព្រះអង្គដែលជាព្រះអម្ចាស់ ។

៦- ពួកយូដាប្រមាថថាលីលា ថែមទាហានវាយនូវព្រះហស្ត
ខ្លះព្រួសស្តោះខ្លះទះសព្វអន្លើ ព្រះអង្គដែលជាព្រះអម្ចាស់ ។

៧- គេដោះលែងបារ៉ាបាសចោរកំណាច គេកាត់ក្តីធ្វើគុតព្រះអង្គ
មើលព្រះអង្គពុំដឹងជានរណា ព្រះអង្គដែលជាព្រះអម្ចាស់ ។

## ២៣៦- អ្នកបម្រើដ៏ប្រសើរ

១- អ្នកបម្រើដ៏ប្រសើរ អ្នកមានចិត្តស្មោះត្រង់អើយ
អ្នកស្មោះត្រង់នឹងកិច្ចការមួយដ៏តូច យើងនឹងតែងតាំងឲ្យអ្នក
ត្រួតត្រាកិច្ចការដ៏ធំវិញៗ ។

២- អ្នកបម្រើដ៏ប្រសើរ អ្នកមានចិត្តស្មោះត្រង់អើយ
អ្នកស្មោះត្រង់នឹងកិច្ចការមួយដ៏តូច យើងនឹងតែងតាំងឲ្យអ្នក
ត្រួតត្រាកិច្ចការដ៏ធំវិញៗ ។

## ២៣៧- ឱ ! ជនកម្សត់

១- ឱ ! ជនកម្សត់ ម្ដេចក៏ប្រាសព្រាត់ ពីព្រះយេស៊ូ ចូរមកយ៉ាងឆាប់
មកយ៉ាងប្រញាប់ សូមទ្រង់លើកលែងទោស ។

**បន្ទរ-ឱ ! ព្រះយេស៊ូសូមមេត្តា លើកលែងទោស ឲ្យយើងខ្ញុំទាំងឡាយ ។**

២-ខ្ញុំបាត់ស្មារតី បាត់ទាំងសិរី ធ្លាក់ខ្លួនក្រៀមក្រំយ ព្រោះតែបាបកម្ម
ខុសព្រះបណ្ដាំ នៃព្រះអម្ចាស់ ។

៣- រាល់ទិនទិវា ខ្មាំងមកយាយី គ្រប់ទាំងទិសទី ពីទីជម្រៅ
យើងខ្ញុំស្រែកហៅ សូមឲ្យព្រះអង្គជួយ ។

## ២៣៨- ក្រោមម្លប់បារមីព្រះគ្រីស្ទ

**បន្ទរ-ក្រោមម្លប់បារមីព្រះយេស៊ូ យើងសែនត្រេកអរថ្លែងអំណរគុណ**
**ក្រោមម្លប់បារមីព្រះយេស៊ូគ្រីស្ទ យើងសែនត្រេកអរថ្លែងអំណរគុណ ។**

១- សូមអរព្រះគុណព្រះអម្ចាស់ ដែលបានផ្តល់ព្រះបន្ទូលបំភ្លឺជីវិតយើងខ្ញុំ ។
២- សូមអរព្រះគុណព្រះអម្ចាស់ ដែលប្រទានឲ្យយើងខ្ញុំរួបរួមគ្នាថ្វាយតង្វាយ ។
៣- សូមអរព្រះគុណព្រះអម្ចាស់ ដែលប្រទានឲ្យយើងខ្ញុំរួមគ្នាសរសើរព្រះអង្គ ។
៤- សូមអរព្រះគុណព្រះអម្ចាស់ ដែលប្រទានឲ្យយើងខ្ញុំនូវជីវិតដ៏រុងរឿង ។
៥- សូមព្រះអង្គទ្រង់មេត្តា រក្សាយើងខ្ញុំថ្ងៃនេះក្នុងក្តីស្រឡាញ់ព្រះអង្គ ។
៦- សូមព្រះអង្គទ្រង់មេត្តា គង់ជិតយើងខ្ញុំថ្ងៃនេះ នោះយើងខ្ញុំអរសប្បាយ ។
៧- សូមព្រះអង្គជួយយើងខ្ញុំ ឲ្យចេះស្រឡាញ់បងប្អូនដូចទ្រង់ស្រឡាញ់យើងខ្ញុំ ។

## ២៣៩- ខ្ញុំច្រៀងកោតសរសើរ

១- ខ្ញុំច្រៀងកោតសរសើរ (**ស្ងួន**) កោតសរសើរដល់ព្រះជាម្ចាស់(**ស្ងួន**)
ដ្បិតព្រះអង្គទ្រង់មានជោគជ័យច្បាស់ ទ្រង់បានជម្រះទ័ពសេះក្នុងសមុទ្រ ។

២- ខ្ញុំច្រៀងកោតសរសើរ (**ស្ងួន**) សរសើរព្រះនាមជីវិសុទ្ធ (**ស្ងួន**)
ព្រោះបានប្រានកម្លាំងរថទ័ពដ៏ខ្លាំងបំផុត ដែលលង់ខ្លួនក្នុងសមុទ្រក្របាម(**ស្ងួន**)

**បន្ទរ-(ស)ខ្ញុំច្រៀង (ប)ខ្ញុំច្រៀង (ស)កោតសរសើរ (ប)កោតសរសើរ**
**(ស)កោតសរសើរ បារមីព្រះអង្គ (ប)បារមីព្រះអង្គ**
**(ស)ទ្រង់បានបំផ្លាញ (ប)ទ្រង់បានបំផ្លាញ (ស)សត្រូវខ្ទេចបង់**
**(ប)សត្រូវខ្ទេចបង់ (ស)ជួយផ្គត់ផ្គង់រូបខ្ញុំ (ប)ពេលសឹកសង្គ្រាមជ័យ**
**(រួម) ពេលសឹកសង្គ្រាមជ័យ ។**

៣- ខ្ញុំច្រៀងលើកតម្កើង (**ស្ងួន**) តម្កើងព្រះម្ចាស់លើលោកីយ៍ (**ស្ងួន**)
ជាព្រះខ្ញុំទាំងប្រុសស្រីហើយដែលមានហឫទ័យ ព្រះអង្គសន្តោសប្រណីកន្លង(**ស្ងួន**)

៤- ខ្ញុំច្រៀងលើកតម្កើង (**ស្ងួន**) ព្រះរបស់ឪពុកខ្ញុំផង (**ស្ងួន**)
ខ្ញុំច្រៀងនិងតម្កើងសូមឲ្យព្រះអង្គ គង់សោយរាជ្យអស់កល្បតរៀងទៅ(**ស្ងួន**) ។

## ២៤០- ចូរសប្បាយរីករាយឡើង

**បន្ទរ- អាលេលូយ៉ា ព្រះគ្រីស្តមានព្រះជន្ម រស់ឡើងវិញពិតមែនហើយ**
**ប្រជាជនទាំងឡាយអើយ ចូរសប្បាយរីករាយឡើង អាលេលូយ៉ាៗ**

១- នេះហើយជាថ្ងៃ ដែលព្រះម្ចាស់ថ្លៃ ទ្រង់បានបង្កើត ថ្ងៃសែនសប្បាយ
ចូរយើងច្រៀងថ្វាយ ព្រះគ្រីស្តអម្ចាស់ ទ្រង់មានព្រះជន្ម ពេញដោយសិរី ។

២- ព្រះយេស៊ូគ្រីស្ត ទ្រង់ឈ្នះក្តីស្លាប់ គង់ជាមួយយើង ជារៀងរហូត
ចូរយើងតម្កើង ព្រះអម្ចាស់យើង ទ្រង់មានព្រះជន្ម ពេញដោយសិរី ។

៣- ដោយស្រឡាញ់យើង ទ្រង់សព្វព្រះហឫទ័យ បូជាព្រះជន្ម បើកផ្លូវសង្គ្រោះ
ឲ្យយើងបានរស់ ដោយជីវិតថ្មី នៃព្រះម្ចាស់ថ្លៃ អស់កល្បជានិច្ច ។

៤- យើងសែនសប្បាយ ក្រាបបង្គំថ្វាយ អំណរព្រះគុណ ព្រះគ្រីស្តអម្ចាស់
ទ្រង់ជាជីវិត យើងខ្ញុំជឿពិត ថានឹងបានរស់ រួមនឹងព្រះអង្គ ។

៥- សូមថ្វាយពរជ័យ សិរីសួស្តី ឆ្ពោះព្រះបិតា ព្រះរាជបុត្រា
ព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះតែឯក ថ្កើងថ្កានឥតហ្មង ដែលគង់ជានិច្ច ។

## ២៤១- ជ័យជម្នះ

**បន្ទរ- ជ័យជម្នះ ព្រះអម្ចាស់គ្រងរាជ្យ ព្រះគ្រីស្តព្រះអង្គស្រោចស្រង់ខ្ញុំ ។**

១- សូមបញ្ចេញពន្លឺរស្មី លើស្ថានដីស្វែងរកសច្ចៈ
ព្រះគ្រីស្តជាចង្កូរហូរបាក់ ធម៌ស្រឡាញ់ស៊ូគ្រសេរីភាព ។

២- សូមផ្តល់ក្តីអង់អាចក្លៀវក្លា ដល់ជនក្រីក្រអកុសល
សូមប្រមូលបងប្អូនយើងខ្ញុំ ទៅមូលផ្តុំក្រោមម្លប់បារមី ។

៣- សូមទ្រង់យាងមកបំភ្លឺដល់ អស់យើងខ្ញុំជាអ្នកមានទុក្ខ
ព្រះគ្រីស្តទ្រង់បានសម្តែង មេត្តាប្រោសទទួលយើងខ្ញុំ ។

# ២៤២- ថ្ងៃដែលព្រះជាម្ចាស់បានបង្កើត

**បន្ទរ-នេះជាថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមក**
**ថ្ងៃដ៏សែនសប្បាយរីករាយ អាលេលូយ៉ាៗ**

១- ចូរយើងអរព្រះគុណព្រះជាម្ចាស់ ចូរយើងច្រៀងបទថ្មីថ្វាយព្រះអង្គ
ដ្បិតព្រះអង្គទ្រង់មានព្រះហឫទ័យ មេត្តាករុណា
ព្រះអង្គទ្រង់ស្រឡាញ់មនុស្សលោក អស់កល្បជានិច្ច ។

២- តេជានុភាពនៃព្រះអង្គ បានសម្រេចការអស្ចារ្យ
ព្រះអង្គធ្វើឲ្យខ្ញុំងើបឡើងវិញ ខ្ញុំមិនត្រូវស្លាប់ឡើយ
ខ្ញុំនៅរស់ហើយខ្ញុំប្រកាស ពីស្នាព្រះហស្តព្រះអង្គ ។

៣- សូមថ្វាយព្រះពរជោគជ័យ ចំពោះព្រះបិតាព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះអង្គគង់នៅ
តាំងពីដើមរៀងមកហើយជាដរាប តរៀងទៅ ។

## ២៤៣- ព្រះយេស៊ូគ្រីស្តរស់ឡើងវិញមែន

**បន្ទរ-ព្រះយេស៊ូគ្រីស្តរស់ឡើងវិញមែន ដូចព្រះអង្គមានព្រះបន្ទូល**
**អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា ។**

១- ព្រះជាម្ចាស់បានលើកព្រះអង្គឡើង ឲ្យគង់នៅជាមួយហើយ
ព្រះយេស៊ូពោរពេញដោយជីវិតថ្មី និងដោយសិរីរបស់ព្រះម្ចាស់ ។

២- ទេវទូតទាំងឡាយ សប្បាយក្រៃ មហាក្សត្រដែនដីមានជ័យជម្នះ
ពន្លឺចែងចាំងរបស់ព្រះគ្រីស្ត ដែលទ្រង់បានឈ្នះលើសេចក្តីស្លាប់ ។

៣- ទ្រង់បានកម្ចាយសេចក្តីងងឹត ដែលបានរួមរឹតលើដែនដី
ព្រះគ្រីស្តមានព្រះជន្មរុងរឿងសិរី ពិភពលោកីយ៍ស្គាល់ព្រះចេស្តា ។

៤- ទ្រង់សោយទិវង្គតបានបីថ្ងៃ ស្របតាមសេចក្តីបានចែងថា
ព្រះគ្រីស្តបានបូជាព្រះកាយា រំដោះមនុស្សាពីបាបកម្ម ។

៥- ជយោព្រះមហាក្សត្រដ៏ថ្កុំថ្កើង រក្សាពួកយើងក្នុងក្តីស្រឡាញ់
សូមឲ្យយើងបេះអរព្រះគុណព្រះអង្គ ដែលជួយស្រោចស្រង់ទ្រទ្រង់ជីវិត ។

៦- យើងហ៊ានស្រែកច្រៀងអាលេលូយ៉ា អស់ពីកាយាដោយអំណរពិត
ដោយអគ្គសញ្ញាបុណ្យជ្រមុជទឹក យើងបានជិតស្និទ្ធជាមួយព្រះអង្គ ។

## ២៤៤- ព្រះគ្រីស្តគង់ជាមួយយើង

១- ព្រះគ្រីស្តគង់ជាមួយយើង ព្រះគ្រីស្តគង់ជាមួយយើង ព្រះអង្គស្រឡាញ់យើង
ព្រះអង្គប្រទានជីវិត ព្រះគ្រីស្តគង់ជាមួយយើង ។

**បន្ទរ-ដោយសារឈើឆ្កាង ទុក្ខលំបាករបស់ព្រះអង្គ ដែលបានសង្គ្រោះយើង**
**ពីទីងងឹត ឲ្យមានជីវិតថ្មី ។**

២-សូមព្រះគ្រីស្តសណ្ឋិតនៅ សូមព្រះអង្គមកជួយជីវិត កែប្រែចិត្តយើងរាល់គ្នា
ឲ្យយើងដើរតាមព្រះអង្គ ព្រះគ្រីស្តគង់ជាមួយយើង ។

## ២៤៥- ព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញហើយ

បន្ទរ- (ស)ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញហើយ អាលេលូយ៉ា
(ប)ពន្លឺរស្មីជីវិត ឈ្នះភាពងងឹត អាលេលូយ៉ា
(រួម)ចូរយើងត្រេកអរសប្បាយ តាំងចិត្តរីករាយ អាលេលូយ៉ា
អាលេ អាលេលូយ៉ា អាលេលូយ៉ា អាលេលូយ៉ា ។

១- ព្រះគ្រីស្ទមានព្រះជន្ម រស់ឡើងវិញពិតមែនហើយ
ទ្រង់ឈ្នះសេចក្ដីស្លាប់ ហើយប្រទានជីវិតថ្មី
ចូរយើងកោតសរសើរ ព្រះបិតាជាអម្ចាស់
ទ្រង់ប្រោសព្រះបុត្រា ឲ្យមានព្រះជន្មរស់ឡើងវិញ ។

២- ព្រះគ្រីស្ទមានព្រះជន្ម រស់ឡើងវិញពិតមែនហើយ
ទ្រង់ជាក្ដីសង្ឃឹម នៃអស់អ្នកដែលបានស្លាប់
ចូរយើងលើកតម្កើង ព្រះបិតាជាអម្ចាស់
ទ្រង់ប្រោសព្រះបុត្រា ឲ្យមានព្រះជន្មរស់ឡើងវិញ ។

៣- ព្រះគ្រីស្ទមានព្រះជន្ម រស់ឡើងវិញពិតមែនហើយ
ព្រះអង្គជាពន្លឺ ជាជីវិតសេចក្ដីពិត
ចូរយើងអរព្រះគុណ ព្រះបិតាជាអម្ចាស់
ទ្រង់ប្រោសព្រះបុត្រា ឲ្យមានព្រះជន្មរស់ឡើងវិញ ។

## ២៤៦- ព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញមែន

បន្ទរ-ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញមែន អាលេលូយ៉ា! អាលេលូយ៉ា!

១-ទ្រង់បានបង្ហាញឲ្យសិលាឃើញ អាលេលូយ៉ា អាលេលូយ៉ា ។

២-ពេលគាត់បានឃើញព្រះអង្គរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ា ។

៣-ទើបគាត់មានក្ដីអំណរសប្បាយ អាលេលូយ៉ា អាលេលូយ៉ា ។

៤-កោតសរសើរព្រះបិតា ព្រះរាជបុត្រ ព្រះវិញ្ញាណ អាលេលូយ៉ា អាលេលូយ៉ា ។

## ២៤៧- ព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញមែន

**បន្ទរ-ព្រះយេស៊ូគ្រីស្ទមានព្រះជន្មរស់ឡើងវិញមែន អាលេលូយ៉ា អាលេលូយ៉ា**
**ដូចព្រះអង្គទ្រង់មានបន្ទូលមែន អាលេលូយ៉ា អាលេលូយ៉ា**

១- ព្រះគ្រីស្ទទ្រង់បានបង្ហាញព្រះអង្គ ឲ្យអស់ពួកមនុស្សមើលឃើញផង
ជាមនុស្សសាមញ្ញធម្មតាឡើង គឺព្រះអង្គព្រះគ្រីស្ទជាព្រះសង្គ្រោះ ។

២- ព្រះគ្រីស្ទមានព្រះជន្មដោយព្រះវិញ្ញាណ ដ៏វិសុទ្ធស្អាងស្អាតព្រះជាម្ចាស់
ព្រះអង្គបង្ហាញទៀតយ៉ាងច្បាស់ ឲ្យដល់អស់ពួកទេវទូតផង ។

៣- ពេលនេះគេបានប្រកាសឡើង សិរីរុងរឿងរបស់ព្រះអង្គ
ឲ្យមនុស្សក្នុងលោកមានជំនឿ ព្រមជឿលើព្រះអង្គ ជាព្រះវិសុទ្ធ ។

៤- គឺព្រះអម្ចាស់បានលើកព្រះអង្គ មានសិរីផងជោគជ័យពិត
ឲ្យមនុស្សទាំងឡាយបានមូលមិត្ត នៅជិតព្រះអង្គ តរៀងទៅ ។

# ២៤៨- ព្រះអម្ចាស់ទ្រង់សោយរាជ្យ

បន្ទរ-ព្រះអម្ចាស់ទ្រង់សោយរាជ្យ មានឫទ្ធិអំណាចគ្រប់ទិសទី
ចូរយើងម្ទីម្នាត្រេកអរសប្បាយ តាំងចិត្តតាំងកាយ រីករាយទទួលព្រះជាម្ចាស់ ។

១- តេជានុភាពខ្លាំងក្លាណាស់ ពពកខ្មៅដាស់ជុំវិញបល្ល័ង្ក
អំពើយុត្តិធម៌ជាទីតាំង អាចជួយសម្រាំងក្តីសុចរិត ។

២- ព្រះអង្គជាសេចក្តីពិត ព្រះអង្គមានឫទ្ធិលើមនុស្សគ្រប់ប្រាណ
គ្មានអ្នកណាមួយឈ្នះបាន ទោះគ្រប់ទីស្ថានពុំអាចប្រៀបផ្ទឹម ។

៣- វាស្រ្តផងមានចិត្តសង្ឃឹម រីករាយញញឹមទាំងចិត្តសោមនស្ស
ព្រោះបានយល់សិរីយស នៃព្រះសង្គ្រោះមានឫទ្ធិអស្ចារ្យ ។

៤- អ្នកដែលក្បត់ព្រះបិន្ថា កុហកមុសាប្រព្រឹត្តអាក្រក់
សេពគប់អំពើលាមក ស្មោគគ្រោកកខ្វក់វិនាសឥតស្បើយ ។

៥- អស់កូនចៅទាំងឡាយអើយ កុំនៅកន្តើយចូរមកប្រណម្យ
លើកហត្ថក្រាបថ្វាយបង្គំ ដល់ព្រះឧត្តមជាព្រះសង្គ្រោះ ។

៦- ដ្បិតព្រះអម្ចាស់ខ្ពង់ខ្ពស់ មកជួយរំដោះមនុស្សលើដែនដី
ព្រោះទ្រង់មានឫទ្ធិបារមី អស្ចារ្យពេកក្រៃលើសជនលោកា ។

៧- ទ្រង់មានហឫទ័យមេត្តា ទ្រង់ថែរក្សាអ្នកជឿសង្ឃឹម
ទ្រង់ជួយទាំងក្តីញញឹម ឲ្យរួចពីនឹមនៃជនឃោរឃៅ ។

៨- ព្រះអង្គគឺពិតជាផ្លូវ ដែលនាំយើងទៅស្វែងរកក្តីសុខ
ព្រះអង្គជួយឲ្យជុតទុក្ខ ស្គាល់ស្ថានបរមសុខបាកក្តីស្រេកឃ្លាន ។

៩- សូមអរព្រះគុណព្រះបិតា ទាំងព្រះបុត្រា និងព្រះវិញ្ញាណ
ព្រះអង្គបានជួយប្រទាន ក្តីសុខក្សេមក្សាន្តឲ្យជនលោកា ។

## ២៤៩- ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ

**បន្ទរ- ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

១- ព្រះអម្ចាស់យាងឡើង ប្រជាជនស្រែកជ័យឃោស អាលេលូយ៉ា! អាលេលូយ៉ា!
ព្រះអង្គយាងឡើងទៅ ទីដ៏ខ្ពង់ខ្ពស់បំផុត អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

២- ចូរយើងនាំគ្នា ទះដៃសម្តែងសាទរថ្វាយ អាលេលូយ៉ា! អាលេលូយ៉ា!
ដ្បិតព្រះអម្ចាស់ ខ្ពង់ខ្ពស់បវរថ្លៃថ្លា អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

៣- ចូរយើងជួបជុំ ប្រគុំថ្វាយភ្លេងជាតង្វាយ អាលេលូយ៉ា! អាលេលូយ៉ា!
ចូរនាំគ្នាច្រៀងស្រែក ថ្វាយអំណរថ្វាយជ័យឃោស អាលេលូយ៉ា! អាលេលូយ៉ា!ៗ

## ២៥០- រ៉ូម ៦

យើងទាំងអស់ ដែលបានទទួល ទទួលពិធី ពិធីជ្រមុជទឹក
យើងបានរួមស្លាប់ យើងបានរួមរស់ ជាមួយព្រះ ព្រះយេស៊ូ
ព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មី ដ៏រុងរឿង
ធ្វើឲ្យយើង រស់នៅតាម របៀបថ្មី ដែលមកពី ព្រះជាម្ចាស់ ។

## ២៥១- សូមទៅប្រាប់បងប្អូនខ្ញុំឲ្យទៅស្រុកកាលីឡេ

សូមទៅប្រាប់បងប្អូន ខ្ញុំឲ្យទៅស្រុកកាលីឡេ ទៅស្រុកាលីឡេ
ទៅស្រុកាលីឡេ ទៅស្រុកាលីឡេ ទៅស្រុកាលីឡេ គេនឹងឃើញខ្ញុំ
គេនឹងឃើញខ្ញុំ គេនឹងឃើញខ្ញុំនៅជាមួយ ។

## ២៥២- ឱ ! អ្នកស្រុកកាលីឡេអើយ !

១- អុំះឱ ! អ្នកស្រុកកាលីឡេអើយ ហេតុអ្វីឡើយ នៅឈរសម្លឹងមើលមេឃ
ដ្បិតព្រះយេស៊ូ ព្រះជាម្ចាស់បានលើក ពីកណ្ដាលអ្នករាល់គ្នា ឡើងស្ថានបរមសុខ ។

២- ព្រះអង្គ នឹងយាងត្រឡប់មកវិញ តាមរបៀប ដែលអ្នករាល់គ្នាបានឃើញ
ព្រះអង្គយាង ឡើងស្ថានបរមសុខដែរ ទៅគង់ខាងស្ដាំ ព្រះបិតាហើយ ។

៣- ចូរចេញ ទៅផ្សព្វផ្សាយដំណឹងល្អ ដល់មនុស្ស គ្រប់រូបនូវការស្រឡាញ់
របស់ព្រះ ជាម្ចាស់នឹងការសង្គ្រោះ របស់ព្រះអង្គ តាមរយៈព្រះយេស៊ូ ។

៤- ចូរចេញ ទៅធ្វើសាក្សីឲ្យមនុស្ស ជឿទុកចិត្តនិង សង្ឃឹមលើព្រះអង្គ
ចូរមានចិត្ត ក្លាហានកុំខ្លាចអ្វីឡើយ ទ្រង់គង់ជាមួយ អ្នករាល់គ្នាហើយ ។

# ២៥៣- ទំនុកតម្កើងអង្វរព្រះវិញ្ញាណ
## ដកស្រង់ទំនុកតម្កើងអង្វរព្រះវិញ្ញាណ

(បទពាក្យ ៧)

១- ឱ ! ព្រះវិញ្ញាណព្រះបវរ សូមយាងកុះករក្នុងដួងចិត្ត
សូមបាត់ពន្លឺរស្មីពិត ឲ្យមកតាំងស្ថិតលើអស់យើង ។

២- ព្រះអង្គជាបិតាអ្នកកម្សត់ ក្រីក្រទុរគតបិតាថ្កើង
យាងមកប្រទានកុំបីផ្អើង អំណោយក្រាស់ស្តើងកូនទទួល ។

៣- សូមយាងមកបំភ្លឺគំនិត បំភ្លឺដួងចិត្តកុំឲ្យជ្រួល
ទប់ឲ្យនឹងនមិនរំជួល រស់នៅសុខស្រួលក្នុងអំណោយ ។

៤- ព្រះអង្គលួងលោមដួងចិត្តខ្ញុំ ទ្រង់គង់សម្ងំមិនមែនខ្សោយ
ព្រះអង្គជាម្លប់ពីមុខក្រោយ ត្រជាក់ត្រជុំពេលខ្ញុំហត់ ។

៥- ព្រះអង្គប្រទានឲ្យសម្រាក កុំឲ្យលំបាកហួសកំណត់
ក្តៅហួតក្តៅហែងហេវកម្សត់ ព្រះអង្គជាផ្លិតបក់ត្រជាក់ ។

៦- កាលណាយើងខ្ញុំកើតទុក្ខព្រួយ ព្រះអង្គលើកស្ទួយមិនស្ទើរស្ទាក់
ទឹកចិត្តខ្ញុំឡើងខ្ពស់ប្រត្យក្ស ឥតបីមានញាក់ស្លុតរន្ធត់ ។

៧- ឱ ! ពន្លឺភ្លឺថ្លៃងត្រចះ ត្រចង់ឥតខ្វះមិនរលត់
យាងមកបំភ្លឺ និងបំពត់ អ្នកជឿសង្ឃឹមលើព្រះអង្គ ។

៨- កុំតែព្រះអង្គយាងមកប្រោស យាងមកសន្តោសគ្មានបង្អង់
កុំអីមនុស្សលោកគ្មានផ្លូវត្រង់ គ្មានចិត្តគ្មានចង់ធ្វើអ្វីឡើយ ។

៩- កិច្ចការទាំងអស់ដែលគេធ្វើ ជំពាក់បាបស្មើរពុំដែលស្បើយ
សូមទ្រង់យាងមកលាងឲ្យហើយ អ្វីៗកខ្វក់ចេញឲ្យអស់ ។

១០- សូមទ្រង់ស្រោចលើចិត្តហែងហួត កុំឲ្យក្រៀមស្ងួតសោះកក្រោះ
និងចិត្តដែលមានស្នាមរបួស ឲ្យមានសម្រស់ស្រស់បំព្រង ។

១១- សូមបន្ទន់ចិត្តកាយវាចា កុំឲ្យប្ញស្យាមានសៅហ្មង
សូមប្រទានតាមព្រះបំណង ហឫទ័យថ្វាយង់កុំខានណា ។

១២- សូមតម្រង់ចិត្តកោងវេរវៀច ចិត្តខូចកាចកៀបដោយហឹង្សា
ខន្តីអំណត់តាមមាគ៌ា តាមក្តីប្រាថ្នាហឫទ័យត្រង់ ។

១៣- សូមទ្រង់ប្រទានអំណោយសព្វ ឲ្យមានភពភ័ព្វបែបទំនង
ដល់អ្នកជឿផងតាមបំណង ចិត្តជឿលើទ្រង់ជាអម្ចាស់ ។

១៤- សូមទ្រង់ប្រទានព្រះពរជ័យ ឲ្យមានសិរីក្រៃលក្រៃក្រាស់
អំណរសប្បាយមានដេរដាស របូតដល់អស់កល្បទៅហោង ។

## ២៥៤- ភ្លើង ! នៃក្តីស្រឡាញ់

ភ្លើង! ភ្លើង! ភ្លើង! នៃក្តីស្រឡាញ់ មកសណ្ឋិតលើពួកយើង
ឲ្យពួកយើង ពោរពេញទៅដោយ ព្រះវិញ្ញាណជីវិសុទ្ធ ។

**បន្ទរ- ឱ ! ព្រះយេស៊ូគ្រីស្តអើយ ! ប្រទានភ្លើងឲ្យយើង**
**ឱ! ព្រះយេស៊ូគ្រីស្តអើយ ! ប្រទានភ្លើងក្នុងចិត្តយើង ។**

## ២៥៥- លូកា ៤,១៨-១៩

"ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ សណ្ឋិតលើខ្ញុំ ព្រះអង្គចាក់ប្រេងអភិសេកខ្ញុំ
ឲ្យនាំដំណឹងល្អ ទៅប្រាប់ជនក្រីក្រ ព្រះអង្គចាត់ខ្ញុំឲ្យមកប្រកាស
ប្រាប់ជនជាប់ជាឈ្លើយ ថាគេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថា
គេនឹងមើលឃើញវិញ គេនឹងមើលឃើញវិញ ព្រះអង្គចាត់ខ្ញុំឲ្យមករំដោះ
អស់អ្នកដែល ត្រូវគេសង្កត់សង្កិន ព្រមទាំងប្រកាសអំពីឆ្នាំ
ដែលព្រះអម្ចាស់ សម្តែងព្រះហឫទ័យ មេត្តាករុណា" ។

## ២៥៦- សូមព្រះវិញ្ញាណយាងមក

(សម្រាប់បុណ្យព្រះវិញ្ញាណយាងមក)

ស- សូមយាងមក ឱ! ព្រះវិញ្ញាណនៃព្រះជាម្ចាស់
ប- យាត្រាមក គង់សណ្ឋិតក្នុងដួងចិត្តយើងខ្ញុំរាល់គ្នា
ស- ហើយសូមទ្រង់ប្រទានបំពេញអំណោយទានឧត្តម
ក្នុងចិត្តអស់អ្នកដែលព្រះអង្គទ្រង់បានបង្កើតមក ។

១- **ប**-គេហៅទ្រង់ជាអ្នកជូនយោបល់ **ស**-ប្រាជ្ញាថ្លៃថ្លា
ទ្រង់បានប្រទានអំណោយទាន នៃស្ថានបរមសុខ
ជាជ្រោះឲ្យរស់ ដែលហូរពុំស្ងួតហែង
ហើយជាភ្លើងនាំឲ្យយើងបេះ **រួម**៖ឈើឆ្កាលស្រឡាញ់គេផង ។

**បន្ទរ-ស-ព្រះអង្គជាវិញ្ញាណផ្តល់អំណោយទាន ប- ទាំងប្រាំពីរ**
**ជាសេចក្តីសន្យាស្នេហា ចំពោះជនទាំងឡាយ**
**រួម៖ ព្រះអង្គអាចនឹងបណ្តាលមាត់យើងខ្ញុំនូវវាចា**
**ឲ្យបានប្រកបដោយអំណោយទានដ៏បរិបូណ៌ ។**

២- **ប-**ព្រះអង្គជាបិតាអ្នកកម្សត់ **ស-** ក្រីក្រទុរគត
យាងមកប្រទានកុំបីឆ្មើង ឲ្យមាំមួនឡើងមានកម្លាំង
សូមយាងមកបំភ្លឺ បិត្តគំនិតកុំឲ្យជ្រួល
ទប់ឲ្យនឹងនរមិនរំជួល **រួម:**រស់សុខស្រួលក្នុងអំណោយ ។

៣- **ប-**គេហៅទ្រង់ពន្លឺភ្លឺត្រចះ **ស-** ត្រចង់ឥតខ្ចះ
យាងមកបំភ្លឺនឹងបំពត់ អ្នកជឿសង្ឃឹមលើព្រះអង្គ
កុំតែព្រះអង្គយាងមកប្រោស យាងមកប្រោសគ្មានបង្អង់
កុំអីមនុស្សលោកគ្មានផ្លូវត្រង់ **រួម:** គ្មានចិត្តចង់ធ្វើអ្វីឡើយ ។

## ២៥៧- សូមព្រះវិញ្ញាណយាងមក

**បន្ទរ-សូមព្រះវិញ្ញាណយាងមក យាងមកក្នុងដួងចិត្ត**
**ហើយគង់សណ្ឋិត លើដួងចិត្តរបស់យើងខ្ញុំ**

១-សូមយាងមកបំភ្លឺ ពន្លឺក្នុងជីវិត ឲ្យយើងកែប្រែចិត្ត ជិតស្និទ្ធជាមួយព្រះអង្គ ។

២-កិច្ចការដែលយើងធ្វើ បំភ្លឺនឹងធម៌មេត្តា ដែលមកពីព្រះបិតា និងព្រះបុត្រា ទាំងព្រះវិញ្ញាណ ។

## ២៥៨- ឱ! ព្រះបិតាប្រកបដោយឫទ្ធានុភាព

ឱ! ព្រះបិតាប្រកបដោយឫទ្ធានុភាព
សូមទ្រង់ព្រះមេត្តាចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធលើយើងខ្ញុំ ដ៏វិសុទ្ធលើយើងខ្ញុំ
គឺព្រះវិញ្ញាណដែលផ្ដល់ឲ្យ ចេះរិះគិតពិចារណា និងដឹងខុសត្រូវ
ឲ្យមានប្រាជ្ញាឈ្លាសវៃៗ ឲ្យយោបល់ល្អ និងចិត្តអង់អាចឲ្យស្គាល់សេចក្ដីពិត និង
ស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើង ខ្លាំងឡើង កាន់តែខ្លាំងឡើង ខ្លាំងឡើង ។

## ២៥៩- កោតសរសើរព្រះអម្ចាស់

កោតសរសើរព្រះអម្ចាស់ កោតសរសើរព្រះនាមព្រះអង្គ
កោតសរសើរព្រះអម្ចាស់ ព្រះអង្គគឺជាជីវិត ។

## ២៦០- កោតសរសើរព្រះអម្ចាស់

**បន្ទរ- កោតសរសើរព្រះអម្ចាស់ កោតសរសើរព្រះអម្ចាស់**
**ប្រជាជាតិទាំងឡាយ អាលេលូយ៉ា ។(២ដង)**

១- អស់ប្រជាជាតិ សរសើរព្រះម្ចាស់ តម្កើងសិរីរុងរឿងព្រះអង្គ អាលេលូយ៉ា
ទ្រង់មានក្តីស្រឡាញ់មេត្តា ព្រះម្ចាស់គ្មានចិត្តវៀចវេរឡើយ អាលេលូយ៉ា ។

២-អាលេលូយ៉ា អាលេលូយ៉ា សូមឲ្យគ្រប់ជីវិតក្នុងលោកសរសើរព្រះម្ចាស់ ។(**២ដង**)
អាលេលូយ៉ា អាលេលូយ៉ា សូមឲ្យគ្រប់ជីវិតក្នុងលោក សរសើរព្រះម្ចាស់ ។

៣- មនុស្សលោកច្រៀងថ្វាយព្រះអង្គដោយអំណរ អាលេលូយ៉ា អាលេលូយ៉ា
ចូរមនុស្សជាតិក្រាបថ្វាយទ្រង់ដោយសប្បាយរីករាយ អាលេលូយ៉ា អាលេលូយ៉ា ។

៤- ទ្រង់មានព្រះហឫទ័យមេត្តាករុណាជានិច្ច អាលេលូយ៉ា អាលេលូយ៉ា
ទ្រង់ស្មោះស្ម័គ្រអស់កល្បជាអង្វែងតរៀងទៅ អាលេលូយ៉ា អាលេលូយ៉ា ។

## ២៦១- កុំឲ្យរន្ធត់ចិត្ត

កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច ព្រោះយើងមានព្រះអម្ចាស់
គង់នៅជាមួយយើង កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច
មានព្រះអម្ចាស់បានហើយ ។

## ២៦២- ក្នុងព្រះគ្រីស្ទ

១- ព្រះអម្ចាស់ជាកម្លាំងរបស់ខ្ញុំ ក្នុងព្រះគ្រីស្ទ ខ្ញុំនឹងរីករាយ
មានព្រះអង្គ ខ្ញុំមិនខ្លាចអ្វីទេ ចូរផ្ញើជីវិត ព្រះអម្ចាស់នៅជិត (**២ដង**) ។

២- ក្នុងព្រះគ្រីស្ទយើងខ្ញុំសូមអរព្រះគុណ ក្នុងព្រះគ្រីស្ទ យើងនឹងរីករាយ
មានព្រះអង្គ យើងមិនខ្លាចអ្វីទេ បន្លឺសម្លេងឡើង ព្រះអង្គនៅជិត (**២ដង**) ។

## ២៦៣- ខ្ញុំសូមប្រគល់វិញ្ញាណរបស់ខ្ញុំ

ខ្ញុំសូមប្រគល់វិញ្ញាណ ខ្ញុំទៅក្នុងព្រះហស្ត ព្រះបិតាវិញ
ខ្ញុំសូមប្រគល់វិញ្ញាណ ខ្ញុំទៅក្នុងព្រះហស្តព្រះបិតាវិញ ។(**២ដង**)

## ២៦៤- ចូរយើងច្រៀងថ្វាយព្រះជាម្ចាស់

អូ អូ អូ អូ ចូរយើងច្រៀងថ្វាយព្រះម្ចាស់ អូ អូ អូ អូ ចូរយើងច្រៀងថ្វាយព្រះម្ចាស់
អូ អូ អូ អូ ចូរយើងច្រៀងថ្វាយព្រះម្ចាស់ ចូរយើងច្រៀងថ្វាយព្រះម្ចាស់ ។

## ២៦៥- ទីណាមានមេត្តា

ទីណាមានមេត្តា និងក្តីស្រឡាញ់ ! ទីណាមានមេត្តា ព្រះអម្ចាស់គង់ជាមួយយើង ។

## ២៦៦- ព្រះយេស៊ូគ្រីស្ត

ព្រះយេស៊ូគ្រីស្ត ពន្លឺរបស់ព្រះម្ចាស់ គង់ជាមួយយើង កុំឲ្យចិត្តយើងងងឹតឡើយ!
ព្រះយេស៊ូគ្រីស្ត ពន្លឺរបស់ព្រះម្ចាស់ គង់ជាមួយយើង សូមឲ្យយើងចេះស្រឡាញ់ ។

## ២៦៧- ព្រះគ្រីស្តរស់ឡើងវិញ

អូ...ព្រះគ្រីស្តរស់ឡើងវិញ អាលេលូយ៉ា
អូ...កោតសរសើរព្រះអម្ចាស់ អាលេលូយ៉ា ។

## ២៦៨- ព្រះយេស៊ូសូមកុំភ្លេចខ្ញុំ

ព្រះយេស៊ូ ! សូមកុំភ្លេចខ្ញុំ ! ពេលព្រះអង្គយាងមកគ្រងរាជ្យ (**២ដង**) ។

## ២៦៩- មកតាមខ្ញុំហើយនៅជាមួយខ្ញុំ (១)

មកតាមខ្ញុំ ហើយនៅជាមួយខ្ញុំ ចូរប្រុងស្មារតី ហើយអធិដ្ឋាន ។

## ២៧០- មកតាមខ្ញុំហើយស្នាក់នៅជាមួយខ្ញុំ (២)

មកតាមខ្ញុំ ហើយស្នាក់នៅជាមួយខ្ញុំ
ចូរប្រុងស្មារតី ហើយអធិដ្ឋាន(**២ដង**) ។

## ២៧១- យើងទុកចិត្តលើព្រះជាអម្ចាស់

យើងទុកចិត្តលើព្រះជាអម្ចាស់ ព្រោះព្រះអង្គល្អណាស់
យើងទុកចិត្តលើព្រះជាអម្ចាស់ អាលេលូយ៉ា ! ។

## ២៧២- យើងសូមអរព្រះគុណ

យើងសូមអរព្រះគុណ ព្រះបិតាដែលស្រឡាញ់យើង
ប្រទានព្រះបុត្រាមកឲ្យយើង ស្គាល់នូវធម៌មេត្តា
យើងត្រូវចេះស្រឡាញ់គ្នា ព្រោះយើងជាបងប្អូន
យើងមានអង្គព្រះបិតាតែមួយ របស់មនុស្សទាំងឡាយ ។

## ២៧៣- ល្អណាស់ពេលយើងទុកចិត្ត

ល្អណាស់ពេលយើងទុកចិត្តទៅលើព្រះអម្ចាស់
ល្អណាស់ពេលយើងសង្ឃឹមទៅលើព្រះអង្គ ។

## ២៧៤- សូមព្រះអង្គគង់នៅជាមួយយើង

សូមព្រះអង្គគង់នៅជាមួយយើង ព្រះយេស៊ូគ្រីស្ទ ដ្បិតថ្ងៃកាន់តែទាប
ហើយជិតយប់ជង សូមគង់ជាមួយយើង ។

## ២៧៥- សូមព្រះអង្គគង់នៅជាមួយយើង

សូមព្រះអង្គគង់នៅជាមួយយើង ព្រះយេស៊ូគ្រីស្ទ សូមគង់នៅជាមួយ
ដ្បិតថ្ងៃកាន់តែទាប ហើយជិតយប់ជង សូមស្នាក់នៅជាមួយយើង
សូមស្នាក់នៅជាមួយយើង ។

## ២៧៦- អស់ពីដួងចិត្ត

អស់ពីដួងចិត្ត! អស់ពីដួងចិត្ត! អស់ពីដួងចិត្ត កោតសរសើរព្រះជាអម្ចាស់ !
អស់ពីដួងចិត្ត! អស់ពីដួងចិត្ត! អស់ពីដួងចិត្ត កោតសរសើរព្រះម្ចាស់ ។

## ២៧៧- ឱ ! ព្រះវិញ្ញាណសូមយាងមក

ឱ ! ព្រះវិញ្ញាណសូមយាងមក ឲ្យយើងពោរពេញ ដោយភ្លើងនៃក្តីស្រឡាញ់!
ឱ ! ព្រះវិញ្ញាណសូមយាងមក ឱ ! ព្រះវិញ្ញាណសូមយាងមក ។

## ២៧៨- ច្រៀងថ្វាយព្រះជាម្ចាស់ ថ្ងៃចូលឆ្នាំថ្មី

**បន្ទរ-អបអរសាទរ ថ្ងៃចូលឆ្នាំថ្មី យើងខ្ញុំប្រុសស្រី បង្គំព្រះអម្ចាស់ ។**

១-សូមកោតសរសើរ ព្រះម្ចាស់ថ្លាថ្លៃ ពេញដោយហឫទ័យ សន្ដោសមេត្តា(**២ដង**)
ព្រះម្ចាស់បានថែ រក្សាថ្នមថ្នាក់ ទឹកចិត្តល្អល្អះ សប្បាយកន្លង ។
២-យើងទាំងអស់គ្នា សូមអរព្រះគុណ ដល់ព្រះម្ចាស់ថ្លៃ មួយឆ្នាំកន្លង
សូមព្រះបិតា ប្រទានព្រះពរ អំណរសប្បាយ នៅក្នុងឆ្នាំថ្មី ។
៣-ឲ្យមានប្រាជ្ញា កម្លាំងមាំមួន ចិត្តមេត្តាធម៌ ដូចព្រះជាម្ចាស់
កសាងព្រះសហគមន៍ ឲ្យបានលូតលាស់ រីកចម្រើនឡើង ក្ដីសុខសាន្តអើយ ។

## ២៧៩- ត្រេកអរថ្ងៃចូលឆ្នាំថ្មី

១-ត្រេកអរត្រេកអរ ត្រេកអរថ្ងៃចូលឆ្នាំថ្មី កូនទាំងប្រុសស្រី រួបរួមទាំងអស់គ្នា
សូមព្រះជាម្ចាស់ ប្រទានពរថ្លៃថ្លា ដល់លោកអភិបាល និងលោកឪពុកសម្លាញ់ ។
២-ព្រះពរអាយុ វណ្ណៈសុខៈពលៈ កូនជឿសង្ឃឹមជាក់ ថាបានដូចបំណង
សូមព្រះជាម្ចាស់ ជាព្រះត្រៃឯក សូមជួយទ្រទ្រង់ រក្សាឪពុកសម្លាញ់ ។

## ២៨០- ព្រះជាម្ចាស់ប្រទានពរឆ្នាំថ្មី

**បន្ទរ-សូមព្រះជាម្ចាស់ប្រទានពរឆ្នាំថ្មី សូមព្រះអង្គប្រទានកម្លាំងឲ្យយើងខ្ញុំ**
**កសាងព្រះសហគមន៍ ជារៀងរាល់ថ្ងៃ ។**

១-សូមអរព្រះគុណព្រះអង្គដែលបាន ប្រទានអាយុឲ្យយើងខ្ញុំពេញមួយឆ្នាំ ។
២-សូមទ្រង់ប្រទានពរឲ្យបងប្អូន ជិតឆ្ងាយដែលស្វះស្វែងរកព្រះជាម្ចាស់ ។

## ២៨១- ជូនពរគូស្វាមីភរិយា

១- ព្រះជាម្ចាស់ស្រឡាញ់យើង ព្រោះយើងជាបុត្រធីតាព្រះជាម្ចាស់
ទ្រង់ស្រឡាញ់ និងថែរក្សាឲ្យយើង ឲ្យយើងមានសេចក្ដីសុខសាន្ត ។

២- សូមព្រះអម្ចាស់ទ្រង់ប្រទានពរដល់គូស្វាមីភរិយា ស្រឡាញ់គ្នាស្មោះត្រង់
អស់មួយជីវិត បេះរិះគិត បង្ហាញក្ដីស្រឡាញ់ ។
ដោយមានព្រះអម្ចាស់គង់ជាមួយ ព្រះអង្គជួយបង្ហាញក្ដីស្រឡាញ់
សូមព្រះជាអម្ចាស់ទ្រង់ប្រទានពរ ឲ្យសម្បូរសប្បាយមានសុភមង្គល ។

**(ច្រៀងវគ្គ២ម្ដងទៀត)**

## ២៨២- ព្រះជាម្ចាស់ប្រទានពរជ័យមង្គល

**បន្ទរ- ថ្ងៃនេះ ជាថ្ងៃដែលព្រះម្ចាស់ ប្រទានពរជ័យឲ្យមានដល់**
**គូស្វាមី ភរិយាថ្មី រួមរស់និងគ្នា អនាគត ជីវិតមានគូ**
**រួមសុខទុក្ខ ក្នុងក្ដីស្រឡាញ់ និងជ្រកក្រោម ម្លប់បារមីព្រះជាម្ចាស់ ។**

១- ស្នេហ៍ស្មោះស្ម័គ្រដោយចិត្តថ្លើមតែមួយ ស្រឡាញ់អស់សង្ខារមិនកែប្រែ
បងពិតជាស្មោះ អូនពិតជាស្ម័គ្រ ថ្វាយព្រះបិតា
សូមក្ដីស្រឡាញ់នៃព្រះជាម្ចាស់ ផ្ដល់អំណោយទានដល់គូរៀបការ
ចម្រើនជល្លា ពរជ័យសិរី មង្គលថ្លៃថ្លា ។

២-ទោះថ្ងៃក្រោយមានទុក្ខលំបាកអ្វី ចិត្តភក្ដីមិនភ្លេចពាក្យសន្យា
រួមចិត្តគំនិតចែករំលែកទុក្ខ ស្មោះត្រង់នឹងគ្នា មានចិត្តធម៌មេត្តាករុណា
រីតបំណងមេត្រីក្នុងព្រះគុណ សុភមង្គលអស់មួយជីវិត ក្នុងព្រះបិតា ។

## ២៨៣- សច្ចាអាពាហ៍ពិពាហ៍

**បន្ទរ-យើងខ្ញុំសច្ចា យើងខ្ញុំសន្មត់ ជាប្រាកដស្ម័គ្ររួមរស់ ស្មោះនឹងគ្នា**
**សូមសច្ចា ស្ម័គ្ររួមរស់ ស្មោះរួមគ្នា ។**

១- យើងខ្ញុំបាន ព្រមទទួលអគ្គសញ្ញា មានឈ្មោះថា ជាបុណ្យអាពាហ៍ពិពាហ៍
ជាចំណង ចងយើងខ្ញុំពីរអង្គា ស្ម័គ្ររួមគ្នាលើកដៃទ្រាប ចុះសន្យា ។

២- សូមព្រះម្ចាស់ ប្រទានពរជ័យបវរ កើតមានដល់ គូស្វាមីភរិយា
បេះរួបរួម អប់រំកូនតាមព្រះបន្ទូល ព្រះអង្គគ្រប់ទីស្ថានដែល យើងរស់នៅ ។

## ២៨៤- ស្វាមីត្រូវស្រឡាញ់ភរិយា

ស្វាមីត្រូវស្រឡាញ់ភរិយា
ដូចព្រះគ្រីស្តបានស្រឡាញ់ ព្រះសហគមន៍ដែរ(**២ដង**) ។

## ២៨៥- កាលពីមុនខ្ញុំខ្វាក់

កាលពីមុនខ្ញុំខ្វាក់ ឥឡូវនេះខ្ញុំមើលឃើញហើយ
ឥឡូវនេះខ្ញុំមើលឃើញហើយ ។

## ២៨៦- កោតសរសើរ អរព្រះគុណព្រះអង្គ

**បន្ទរ- ច្រៀងសរសើរព្រះជាអម្ចាស់ សូមលើកដៃសូមក្រាបសំពះ**
**ដល់ព្រះបិតាមានធម៌មេត្តា អាលេលូយ៉ា អាលេលូយ៉ា ។**

១- ទ្រង់បង្កើតពួកយើង ហើយទ្រង់ថែថ្នាក់ថ្នមគ្រប់ពេល
យើងមករួបរួមគ្នា កោតសរសើរអរព្រះគុណព្រះអង្គ ។

២- ព្រះអង្គប្រោសប្រទាន ក្ដីសុខសាន្តឲ្យមនុស្សទាំងអស់
យើងសូមលើកតម្កើង កោតសរសើរអរព្រះគុណព្រះអង្គ ។

៣- ព្រះអង្គបានលើកលែងទោស ឲ្យពួកយើងដែលជាមនុស្សបាប
ព្រះអង្គទ្រង់មេត្តា កោតសរសើរអរព្រះគុណព្រះអង្គ ។

## ២៨៧- ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ

ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន ខ្ញុំទៅរៀបចំ
ខ្ញុំទៅរៀបចំកន្លែងឲ្យអ្នករាល់គ្នា ខ្ញុំនឹងត្រឡប់មកវិញ យកអ្នករាល់គ្នា
ដើម្បីឲ្យអ្នកបាននៅកន្លែងខ្ញុំនៅ ។

## ២៨៨- កុំបរាជ័យនៃជីវិត

១- ពេលដែលយើងមានចិត្តអស់សង្ឃឹម មិនដឹងនិងត្រូវធ្វើយ៉ាងណាទេ?
ឈឺចុកចាប់ ឈឺផ្សានៅក្នុងឱរ៉ា គ្មាននរណាអាចមកជួយរំលែកទុក្ខបាន ។

២- ពេលដែលទុក្ខព្រួយ ចូលក្នុងជីវិត ធ្វើឲ្យខ្លួនគិតថាគ្មានតម្លៃ
តែព្រះម្ចាស់ឲ្យយើងខិតខំជម្នះ ទោះមានឧបសគ្គ ត្រូវឈ្នះឆ្ពោះទៅព្រះអង្គ ។

**បន្ទរ-ចូរកុំអស់សង្ឃឹម ជីវិតយើងមានតម្លៃ មានព្រះជាអម្ចាស់
គឺជាសេចក្តីស្រឡាញ់ ព្រះអង្គស្រឡាញ់ និងសង្គ្រោះមនុស្សលោក
គ្រប់ជាតិគ្រប់សាសន៍ ហើយទ្រង់ក៏បាន គង់នៅជាមួយយើងដែរ ។**

**- កុំអស់សង្ឃឹម ជីវិតយើងមានតម្លៃ កុំបរាជ័យនៅក្នុងជីវិត
យើងជឿលើព្រះម្ចាស់ ព្រះអង្គគង់នៅជាមួយ ។**

## ២៨៩- ខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី

ខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ខ្ញុំឃើញក្រុងយេរូសាឡឹមថ្មី
ចុះពីស្ថានបរមសុខ តែងខ្លួនដូចភរិយាថ្មោងថ្មី តុបតែងខ្លួន ទទួលស្វាមីៗ ។

## ២៩០- ខ្ញុំស្រឡាញ់ព្រះយេស៊ូ

១- ខ្ញុំស្រឡាញ់ព្រះយេស៊ូ(**៤ដង**) ខ្ញុំស្រឡាញ់ព្រះអង្គ ។
២- កោតសរសើរព្រះយេស៊ូ(**៤ដង**) ខ្ញុំស្រឡាញ់ព្រះអង្គ ។
៣- អរព្រះគុណព្រះយេស៊ូ(**៤ដង**) អរព្រះគុណព្រះអង្គ ។

## ២៩១- ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិត

ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិតៗ ។
ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិតៗ ។

## ២៩២- ខ្ញុំនឹងក្រោកឡើង

ខ្ញុំនឹងក្រោកឡើង វិលត្រឡប់ទៅ រកឪពុកខ្ញុំវិញ
វិលត្រឡប់ទៅ រកឪពុកខ្ញុំវិញ ។

## ២៩៣- ខ្ញុំសូមយកព្រះម្ចាស់ជាទីពឹង

ខ្ញុំសូមយកព្រះគ្រីស្ដជាទីពឹង
ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង
ខ្ញុំសូមយកព្រះបន្ទូល
ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង
ខ្ញុំសូមយកព្រះគ្រីស្ដ
ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង ។

## ២៩៤- ខ្ញុំអត់ទោសឲ្យអ្នក

"កូនអើយ! ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាបហើយ"

## ២៩៥- គុណពុកនាំកូនឲ្យស្គាល់ព្រះអម្ចាស់

១- លោកពុកស៊ូទ្រាំពិបាក ខិតខំធ្វើការរាល់ថ្ងៃ មិនដែលត្អូញត្អែរថា
លំបាកយ៉ាងណា ទោះនឿយហត់ក៏ពុក ចង់ឲ្យកូនបានក្តីសុខ
មានអនាគត មានជីវិតថ្លៃថ្លាជានិច្ច ។

**បន្ទរ-ពុកអ្នកមានគុណ បានផ្តល់ជីវិតឲ្យកូន ណែនាំកូនឲ្យដើរតាមមាគ៌ា**
**ព្រះម្ចាស់ ពេលគ្រាលំបាក ពុកតែងលួងលោមចិត្តកូន ឲ្យកូនព្យាយាម**
**តស៊ូអត់ធ្មត់រាល់ពេល កុំឲ្យរារេចិត្ត ជឿជាក់លើព្រះម្ចាស់**
**ឧបសគ្គទាំងឡាយ កូនពិតជាឈ្នះមិនខាន ។**

២- លោកពុកណែនាំផ្លូវកូន ឲ្យទៅស្គាល់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ
សូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានលោកពុក
ដែលនាំកូនយល់ពីក្តីស្រឡាញ់ព្រះគ្រីស្ត ។



## ២៩៦- គោលការណ៍អប់រំទាំងបី

១- ស្វាគមន៍អ្នកស្វែងរក អញ្ជើញមកចូលក្នុងក្រុម
ទទួលការអប់រំគ្រីស្ទសាសនា ឲ្យបានជឿលើព្រះយេស៊ូ
មាគ៌ានេះសែនអស្ចារ្យ ព្រះបិតាមេត្តាមនុស្សលោក ។

២- គោលការណ៍អប់រំបី គឺជាត្រីវិស័យតមក
ទីមួយគឺយើងយកព្រះបន្ទូល ទីពីរគឺយើងធ្វើពិធី
និងទីបីហ្វឹកហ្វឺនចូល ក្នុងជីវិតទាំងមូលគឺស្រឡាញ់ ។

៣- អរគុណហើយណាបងប្អូនដែល ត្រងត្រាប់ស្ដាប់ព្រះបន្ទូល
ហើយសុខចិត្តចូល ទាំងក្នុងគ្រប់ពិធី
ខំរស់នៅរបៀបថ្មី តាមនាទីជីវិតរបស់អ្នកជឿ ។

៤- សូមអរគុណព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ
ដែលទ្រង់ប្រទានជីវិត ពេញអស់កល្បទ្រង់អត់ទោស
ប្រោសប្រណី មិនបោះបង់ យើងដែលជាអ្នកមានបាប ។

## ២៩៧- គ្មានអ្នកណា

គ្មានអ្នកណា អាចបម្រើម្ចាស់ ពីរនាក់បានទេ
អ្នករាល់គ្នាពុំអាច គោរពបម្រើព្រះជាម្ចាស់ផង គោរពបម្រើ
ទ្រព្យសម្បត្តិលោកីយ៍ផងបានឡើយ ។

## ២៩៨- គ្រប់សាសនាបង្ហាញរស្មីនៃសេចក្ដីពិត

សាសនា នានា តែងតែអប់រំ មនុស្ស
ឲ្យស្គាល់រស្មី នៃសេចក្ដីពិត ដែលបំភ្លឺមនុស្ស មនុស្សគ្រប់ៗរូប ។

## ២៩៩- គ្រីស្តទូត ១២រូប

គ្រីស្តទូត១២រូប ដែលព្រះយេស៊ូត្រាស់ហៅ ស៊ីម៉ូនសិលា អន់ដ្រេ យ៉ាកុប យ៉ូហាន ភីលីព ម៉ាថាយ ថូម៉ាស យ៉ាកុបជាកូនអាល់ផាយ ថាដេ នឹង ស៊ីម៉ូន យ៉ូដាស បារថូឡូមេ ។ ទ្រង់បានត្រាស់ហៅយើង ទ្រង់បានត្រាស់ហៅយើង ជាសាវ័កព្រះយេស៊ូ គឺខ្ញុំនឹងអ្នក ទ្រង់បានត្រាស់ហៅយើង ទ្រង់បានត្រាស់ហៅយើង ជាសាវ័កព្រះយេស៊ូ ប្រកាសដំណឹងល្អ ។

## ៣០០- គ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ

**បន្ទរ- សូមព្រះជាអម្ចាស់ សូមព្រះអង្គបង្រួបបង្រួមយើង**
**ជាគ្រីស្តបរិស័ទ ឲ្យរួបរួមគ្នាជាធ្លុងតែមួយ ។**

១- យើងសូមព្រះវិញ្ញាណ ជួយយើងឲ្យមានចិត្តសង្ឃឹម
ទោះបីយើងទន់ខ្សោយ ឲ្យចេះរួបរួមគ្នា ជាព្រះអំណោយទាន ។

២- សូមរួមជាមួយព្រះយេស៊ូ ឲ្យយើងចេះស្រឡាញ់គ្នា
ចេះរួបរួមគ្នា យល់ប្រកាន់គ្នា យើងជាបងប្អូន ។

## ៣០១- គ្រួសារសុខសាន្ត

គ្រួសារសុខសាន្ត ព្រះជាម្ចាស់ប្រទានពរ
ដោយយើងចេះស្រឡាញ់ ចេះអត់ឱនឲ្យគ្នា
ចេះពុះពារឧបសគ្គ បំបាត់អំពើហិង្សា
គ្រួសារយើងនឹងបាន នូវសុភមង្គល ។

## ៣០២- ចិតសិបដង ប្រាំពីរដង

"ចិតសិបដង ប្រាំពីរដង ចិតសិបដង ប្រាំពីរដង ចិតសិបដង ប្រាំពីរដង"
អ្នកត្រូវ អត់ទោសឲ្យគេ មិនត្រឹមតែប្រាំពីរដង
គឺត្រូវ អត់ទោសឲ្យគេ ចិតសិបដង ប្រាំពីរដង ។

## ៣០៣- ចូរយើងប្រារព្ធពិធី

- ចូរយើងខ្នះខ្នែងប្រារព្ធ ពិធីផ្សេងៗ តាមដំណាក់កាលនៃការ អប់រំជំនឿ
- ពិធីទាំងនោះសំខាន់ (**៣ដង**)
- ពិធីអប់រំជំនឿ ពិធីឲ្យមានជំនឿ ពិធីបង្កើតជំនឿ (**២ដង**) ។

## ៣០៤- ចូរចាកចេញ

ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីបងប្អូនញាតិសន្តាន
និងចាកចេញពីក្រុមគ្រួសារ ឪពុកម្ដាយបងប្អូនរបស់អ្នក
តម្រង់ឆ្ពោះទៅស្រុកដែលយើង នឹងបង្ហាញឲ្យអ្នកតម្រង់ទៅ
យើងនឹងឲ្យប្រជាជាតិមួយ ដ៏ធំធេងកើតចេញពីអ្នក
យើងនឹងឲ្យព្រះពរដល់អ្នក យើងនឹងធ្វើឲ្យអ្នកមានឈ្មោះល្បី
មនុស្សទាំងអស់នៅលើផែនដី នឹងទទួលព្រះពរដោយសារអ្នក ។

## ៣០៥- ចូរនាំគ្នាទៅគ្រប់ទីកន្លែង

ចូរនាំគ្នាទៅ គ្រប់ទីកន្លែង ក្នុងពិភពលោកទាំងមូល
ហើយប្រកាសដំណឹងល្អ ដល់មនុស្សលោកទាំងអស់ ។

## ៣០៦- ចូរនាំមនុស្សគ្រប់ជាតិគ្រប់សាសន៍

ចូរនាំមនុស្សគ្រប់ជាតិគ្រប់សាសន៍ៗ ឲ្យធ្វើជាសាវ័កៗ
ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ
ត្រូវបង្រៀនគេ ឲ្យប្រតិបត្តិតាម សេចក្ដីដែលខ្ញុំបានបង្គាប់ៗ
ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នា ជារៀងរាល់ថ្ងៃ
រហូតដល់អវសានកាលនៃពិភពលោក ។

## ៣០៧- ចូរប្រុងស្មារតី

ចូរប្រុងស្មារតី ហើយអធិដ្ឋាន កុំឲ្យបាញ់ការល្បួងឡើយ ។

## ៣០៨- ចូរផ្ញើជីវិតលើព្រះអម្ចាស់

**បន្ទរ-ព្រះជាម្ចាស់ស្រឡាញ់ មនុស្សលោកខ្លាំងណាស់**
**ហេតុនេះហើយបានជាព្រះអង្គប្រទាន**
**ព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នក**
**ដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច ។**

១- ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គនឹងការពារ ឲ្យអ្នករាល់គ្នា
ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គនឹងការពារ អ្នកផុតក្ដីស្លាប់ ។
២- ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គប្រទានអ្នក ជីវិតដូរជង់
ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គប្រទានអ្នក ជីវិតរុងរឿង ។
៣- ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គប្រទានអ្នក ប្រាជ្ញាថ្លាថ្លៃ
ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គប្រទានអ្នក ឲ្យបានចិត្តស្ងប់ ។
៤- ចូរផ្ញើជីវិតលើព្រះអម្ចាស់ ព្រះអង្គជាបិតា សប្បុរសករុណា
ចូរផ្ញើជីវិតលើព្រះអម្ចាស់ ប្រសើរជាងអ្នកផ្ញើលើ មនុស្សលោកា ។

## ៣០៩- ឆ្នាំមហាករុណាធិគុណ

**បន្ទរ១-ចូរមានចិត្តមេត្តាដូចព្រះបិតា ចូរមានចិត្តមេត្តាដូចព្រះបិតា (៣ដង)**

១- សូមអរព្រះគុណព្រះបិតា
ទ្រង់ល្អធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច ។

**បន្ទរ២-ធម៌មេត្តាករុណារបស់ព្រះអង្គអស់កល្បជានិច្ច ។**

ទ្រង់បានបង្កើតពិភពលោកដោយព្រះប្រាជ្ញា **(ធម៌មេត្តា...)**
ទ្រង់ដឹកនាំប្រជារាស្ត្រព្រះអង្គ ទូទាំងប្រវត្តិសាស្ត្រ
ទ្រង់លើកលែងទោស និងទទួលកូនទាំងអស់ ។

២- សូមអរព្រះគុណព្រះបុត្រាពន្លឺ នៃប្រជាជាតិ
ទ្រង់ស្រឡាញ់យើងដោយហឫទ័យមេត្តា
យើងបានទទួលពីព្រះជាម្ចាស់ សូមឲ្យយើងផ្តល់ដល់ព្រះជាម្ចាស់
បើកចិត្តឲ្យអស់អ្នកដែលអត់ឃ្លាន និងស្រេក

៣- ឲ្យយើងសុំព្រះអំណោយទាំងប្រាំពីរពីព្រះវិញ្ញាណ
ប្រភពនៃអំពើល្អ និងការផ្តល់ជំនួយសង្គ្រោះ
សម្រាលទុក្ខមកពីព្រះម្ចាស់ ឲ្យយើងជួយសម្រាលទុក្ខគេ
ធ្វើអ្វីគ្រប់យ៉ាង ដោយសង្ឃឹម និងស្រឡាញ់

៤- យើងសូមសន្តិភាពពីព្រះម្ចាស់ នៃក្តីសុខសន្តិភាព
ផែនដីរង់ចាំដំណឹងល្អអំពីព្រះរាជ្យ
អំណរនិងលើកលែងនៅក្នុងចិត្តអ្នកតូចតាច
ផ្ទៃមេឃ និងផែនដីត្រូវកើតថ្មីឡើងវិញ ។

## ៣១០- ៤៥០ ឆ្នាំ នៃព្រះសហគមន៍កម្ពុជា

បន្ទរ- ចូរអរព្រះគុណ ព្រះជាម្ចាស់ បួនរយហាសិបឆ្នាំកន្លងមក
ព្រះអង្គទ្រង់ប្រទានពរ ដល់ប្រទេសកម្ពុជា ។

១- ព្រះអង្គបាត់អ្នកប្រកាស ព្រះបន្ទូល ព្រះជាម្ចាស់
មកដល់ប្រទេសយើង ឲ្យយើងដឹងធម៌មេត្តា (**បន្ទរ**)

២- សូមឲ្យយើង បេះសម្តែង ធម៌មេត្តា ព្រះជាម្ចាស់
ដែលប្រទាន មកដល់យើង ដោយព្រះបន្ទូលព្រះអង្គ (**បន្ទរ**)

## ៣១១- យើងជាធ្លុងតែមួយ

យើងជាធ្លុងតែមួយៗ ចូរយើងបែកអំណរ ធ្វើឲ្យយើងរួមគ្នាតែមួយ
យើងជាធ្លុងតែមួយៗ ចូរយើងបែកសេចក្តីស្រឡាញ់
ធ្វើឲ្យយើងរួមគ្នាតែមួយៗៗៗ ។

## ៣១២- ជាមួយព្រះគ្រីស្ត

១- ជាមួយព្រះគ្រីស្ត ជីវិតថ្វាយព្រះអង្គ មានចិត្តថ្លាយង់ ដើរតាមព្រះបន្ទូល
យើងអរសប្បាយ ពេលយើងរួមគ្នា ជាមួយព្រះសហគមន៍ បេះស្រឡាញ់គ្នា
ពុះពារឧបសគ្គទាំងឡាយ ។

២- ពេលយើងមានទុក្ខ ចុកឈឺក្នុងចិត្តយើង មានមិត្តសម្លាញ់ ជួយយើងឲ្យធូរស្បើយ
មានព្រះបន្ទូល ឲ្យយើងដើរត្រង់ ដែលទ្រង់បង្ហាញផ្លូវឲ្យយើង ដើម្បីធ្វើតាម
យើងបានជាព្រះសហគមន៍ ។

## ៣១៣- ជួយព្រះសហគមន៍

១- ជាខ្ញុំ ជាខ្ញុំ ជាខ្ញុំ ត្រូវជួយព្រះសហគមន៍ (**៣ដង**)
ជាខ្ញុំត្រូវជួយព្រះសហគមន៍ ។

**បន្ទរ- ចេញទៅប្រាប់អស់បងប្អូន ឲ្យយើងចេះរួមគ្នា**
**ហើយជួយគ្នាដើម្បីកសាងព្រះសហគមន៍ (២ដង)**

២- ជាអ្នក ជាអ្នក ជាអ្នក ត្រូវជួយព្រះសហគមន៍ (**៣ដង**)
ជាអ្នកត្រូវជួយព្រះសហគមន៍ ។

៣- ជាយើង ជាយើង ជាយើង ត្រូវជួយព្រះសហគមន៍ (**៣ដង**)
ជាយើងត្រូវជួយព្រះសហគមន៍ ។

៤- ជាខ្ញុំ ជាអ្នក ជាយើង ត្រូវជួយព្រះសហគមន៍ (**៣ដង**)
ជាខ្ញុំ ជាអ្នក ជាយើង ត្រូវជួយព្រះសហគមន៍ ។

## ៣១៤- ដងគិរីវែងសែនឆ្ងាយ

ស)- ដងគីរីវែងសែនឆ្ងាយ ផ្ទៃសមុទ្រធំល្វឹងល្វើយ
ព្រះវិញ្ញាណគង់សណ្ឋិត ក្នុងដួងចិត្តយើង ។
ប)- យើងរីករាយ យើងសប្បាយ យើងកសាងសន្តិភាព
នេះជាពេលយើងរួមគ្នា ក្នុងក្តីស្រឡាញ់ ។
(ប+ស) មានកម្លាំងមាំមួន ទៅមុខ យើងរួមគ្នាជាផ្លុងតែមួយ
សាសន៍ខុសគ្នា តែជំនឿយើងមានតែមួយ ។

ប- យើងនូវយើងកែប្រែ យើងបង្ហាញក្តីស្រឡាញ់ ក្តីស្រឡាញ់ ក្តីសង្ឃឹម
យើងកុំចាញ់ ជញ្ជាំងបែងចែក

**បន្ទរ- ទាំងអស់គ្នាច្រៀងហើយ (ប+ស)កាន់ដៃគ្នាដោយចិត្តស្មោះ ។**

**ស)- ចូរយើងដើរតាមផ្លូវ ព្រះយេស៊ូ (ប+ស)ក្តីស្រឡាញ់ព្រះបន្ទូល**
**(ប)- ឆ្ពោះទៅកាន់សហស្សវត្សថ្មី នេះជាពេលដែលយើងបង្ហាញក្តីមេត្តា**
**ចូរប្រាប់ទៅទៅពិភពលោក ព្រះម្ចាស់គង់ជាមួយយើង ។**

**(លេងភ្លេង...)**

(ប+ស)-ព្រះអម្ចាស់ត្រាស់ហៅ (ប)ឲ្យយើងរួមជាមួយមនុស្ស
គ្រប់ជាតិសាសន៍ (ស)ព្រះអង្គបង្ហាញផ្លូវ
ដោយចិត្តព្រះបុត្រាយេស៊ូប៉ង (ប)រួមជាមួយយើង
នៃមហាគ្រួសារនៃអង្គព្រះគ្រីស្ត យើងច្រៀងសរសើរ
ស)- យើងលើកតម្កើង (រួម)អស់ពីដួងចិត្ត ។ (បន្ទរ)

## ៣១៥- ដីនៃក្តីសង្ឃឹម

ឱ! ព្រះបិតាដ៏វិសុទ្ធ ទ្រង់បានអាណិតថែរក្សា
ដោយព្រះអំណាច និងក្តីករុណានៃព្រះនាមព្រះអង្គ
ព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យឲ្យអ្នកថ្លាថ្លៃខ្លាំងគ្មានពីរ
ចិត្តអង់អាចក្លាហាន ឈ្នះអស់ការយាយី មិនសង្ស័យនឹងជំនឿ
ទោះក្នុងពេលមានអាសន្ន ជួបគ្រោះភ័យ អ្នកនៅតែស្ម័គ្រចិត្តបម្រើ
តើអ្នកទាំងនោះ គឺជានរណា
គឺអស់អ្នកដែលជឿសង្ឃឹមលើធម៌មេត្តា
ករុណារបស់ព្រះជាម្ចាស់ និងបានផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ
តើពួកគាត់បានបូជាអ្វីខ្លះ ដើម្បីការពារជំនឿរបស់ខ្លួន?
រងទារុណកម្ម និងការបៀតបៀនគ្រប់បែបយ៉ាង
ដើម្បីការពារដំណឹងល្អ និងព្រះសហគមន៍ ឱដីនៃក្តីសង្ឃឹម
អ្នកនេះហើយ ដែលធ្វើឲ្យគ្រាប់ពូជនៃជំនឿបានដុះឡើង
ក្នុងគ្រាដែលដីស្រែកំពុងមានទុក្ខគ្រោះរាំងស្ងួត
យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់វត្តមានដ៏ថ្លៃថ្លារបស់អ្នក
អ្នកបានរក្សាព្រះសហគមន៍ប្រទេសកម្ពុជា ។

## ៣១៦- ដើមដំបូង

**(កក ២, ៤២)**

ដើមដំបូងសាវ័ក **(២ដង)** ស្តាប់ៗ ស្តាប់គ្រីស្តទូតបង្រៀន
រស់ៗ រួមរស់ជាបងប្អូន ចូលរួមពិធីកាច់នំបុ័ង...និងអធិដ្ឋាន
ដើមដំបូង **(២ដង)** ។

## ៣១៧- ដើរតាមព្រះយេស៊ូ

ដើរតាមព្រះយេស៊ូ ដើរតាមព្រះយេស៊ូ ដើរតាមព្រះយេស៊ូ ជាពន្លឺបំភ្លឺជីវិត
ពីរបីនាក់យើង បើចេះរួមគ្នា មានព្រះអម្ចាស់គង់ជាមួយយើង ។

## ៣១៨- តើយើងនឹងចាត់នរណាឲ្យទៅ ?

តើយើងនឹងចាត់នរណាឲ្យទៅ? តើនរណានឹងនាំពាក្យរបស់យើង?
ទូលបង្គំនៅទីនេះស្រាប់ហើយ សូមព្រះអង្គចាត់ទូលបង្គំឲ្យទៅចុះ ។

## ៣១៩- ត្រូវស្រឡាញ់គ្នា

**"ម៉ាថាយ ២២: ៣៩"**

ត្រូវស្រឡាញ់គ្នា ព្រះគ្រីស្តទ្រង់ មានព្រះបន្ទូលថា
ត្រូវស្រឡាញ់បងប្អូនឯទៀត ឲ្យដូចស្រឡាញ់ខ្លួនឯង ។

## ៣២០- ត្រូវអធិដ្ឋាន

ត្រូវតែអធិដ្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ !
ត្រូវតែអធិដ្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ !

## ៣២១- ថ្ងៃនេះយើងមានសេចក្ដីសុខ !

១- ថ្ងៃនេះយើងមានក្ដីសុខ ម្សិលមិញយើងមានក្ដីសុខ
យើងបានមកពីព្រះជាម្ចាស់ (**២ដង**) ។

**បន្ទរ- ចូរឲ្យយើងរាំតាមភ្លេង លើកដៃឡើងលើចូររាំ**
**ហើយបង្វិលខ្លួនមួយជុំ ហើយញាក់បន្តិច(២ដង) ។**

២- ខ្លួនខ្ញុំក៏មានសុខ និងអ្នកក៏មានក្ដីសុខ
យើងបានមកពីព្រះជាម្ចាស់(**២ដង**) ។

## ៣២២- ទារកទើបកើត

**(១ សល ២,២)**

ទារកទើបកើត ប្រាថ្នាចង់បានទឹកដោះសុទ្ធ(២ដង)
យើងខ្ញុំប្រាថ្នាចង់បានព្រះបន្ទូល ។
តាមរយៈព្រះបន្ទូលនេះ បងប្អូនចម្រើនឡើង តាមរយៈព្រះបន្ទូលនេះ
យើងទទួលការសង្គ្រោះ ។

## ៣២៣- និទានជីវិតព្រះយេស៊ូ

និទានជីវិតព្រះយេស៊ូ(**៣ដង**) ក្នុងជីវិតរបស់យើង ។

## ៣២៤- និទានជីវិតព្រះយេស៊ូ

**បន្ទរ- និទានជីវិតព្រះយេស៊ូ នៅក្នុងជីវិតផ្ទាល់របស់យើង(២ដង)**

១- ព្រះគ្រីស្ទបង្រៀនយើងឲ្យស្គាល់...

**(ព្រះបិតា ព្រះបន្ទូល ជីវិតពិត សេចក្ដីពិត)**

២- ព្រះគ្រីស្ទបង្រៀនយើងឲ្យស្គាល់...

**(ព្រះបុត្រា ក្ដីប្រណី ក្ដីមេត្តា ក្ដីស្រឡាញ់)**

៣- ព្រះគ្រីស្ទបង្រៀនយើងឲ្យស្គាល់...

**(ព្រះវិញ្ញាណ ជីវិសុទ្ធ សន្តិភាព សុចរិត)**

៤- ព្រះគ្រីស្ទបង្រៀនយើងឲ្យ...

**(ចេះលើកតម្កើង ចេះទូលអង្វរ ចេះអរព្រះគុណ) ។**

## ៣២៥- នេះជាលោហិតរបស់ខ្ញុំ

នេះជាលោហិតរបស់ខ្ញុំ គឺឈាមនៃសម្ពន្ធមេត្រី ដែលត្រូវបង្ហូរ
សម្រាប់មនុស្សទាំងអស់ សម្រាប់មនុស្សទាំងអស់ ។

## ៣២៦- នៅជំនាន់ដើម

នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើង ជាច្រើនលើក
ច្រើនសា ដោយប្រើរបៀបផ្សេងៗជាច្រើន តាមរយៈព្យាការី

**បន្ទរ- គ្រានេះជាគ្រាៗ ចុងក្រោយបំផុតៗ**
**ព្រះអង្គមានព្រះបន្ទូលមកយើង តាមរយៈព្រះបុត្រា (២ដង)**

## ៣២៧- បន្ទូលព្រះអង្គ គឺជាចង្កៀង

**ទំនុកតម្កើង ១១៩: ១០៥-១០៦**

បន្ទូលព្រះអង្គ គឺជាចង្កៀង ខ្ញុំបានឃើញច្បាស់ ពិតជាពន្លឺ
ត្រចង់ត្រចះ ឃើញផ្លូវស្រឡះ ឲ្យខ្ញុំសុខសាន្ត ឲ្យខ្ញុំសុខសាន្ត
ខ្ញុំសូមសន្យា ឥតងាករេថា ធ្វើតាមមិនខាន ខ្ញុំនឹងប្រតិបត្តិ
សេចក្តីបង្គាប់ សុចរិតថ្កើងថ្កាន របស់ព្រះអង្គ របស់ព្រះអង្គ
បន្ទូលព្រះអង្គ គឺជាចង្កៀង ខ្ញុំបានឃើញច្បាស់ ពិតជាពន្លឺ ។

## ៣២៨- ប្រជាជនទាំងឡាយអើយ

**(យរ ៣១, ១០-១៤)**

១- ប្រជាជនទាំងឡាយអើយ កុំនៅកន្តើយ ស្តាប់ព្រះបន្ទូលព្រះអង្គ
ហើយនឹងផ្សព្វផ្សាយតាមប៉ង កោះឆ្ងាយៗផង ចូលរួមប្រកាសថា
ព្រះអម្ចាស់ថែរក្សា(**២ដង**) មេត្តាករុណាដូចគង្វាលថែចៀមខ្លួន(**២ដង**)

២- ពេលនោះស្ត្រីក្រមុំរាំរាំ រាំសប្បាយចិត្តនួន យុវជននិងចាស់ទុំ
និងសប្បាយជួបជុំរាំរាំរាំ រាំពីព្រោះតែខ្ញុំ ធ្វើឲ្យទុក្ខព្រួយពួកគេ
ប្រែជាអំណរបំពេរ(**២ដង**)
និងសម្រាលទុក្ខគេ មានអំណរសប្បាយវិញ(**២ដង**)

## ៣២៩- ប្រសិនបើ

**(សៀវភៅអប់រំជំនឿទី៣ ខ្ញុំជាជីវិត មេរៀនទី៤)**

ប្រសិនបើ ប្រសិនបើ មនុស្សមិនកើតមកពីទឹកនឹងពីព្រះវិញ្ញាណ គេពុំអាចចូល
ក្នុងព្រះរាជ្យព្រះជាម្ចាស់បានឡើយ ខ្យល់បក់ទៅទិសណាក៏បាន
យើងឮស្នូរវា តែពុំដឹងថា ខ្យល់បក់មកពីទីណាឡើយ
រីឯអ្នកដែលកើតមកពីព្រះវិញ្ញាណក៏ដូច្នេះដែរ ។

## ៣៣០- ប្រែចិត្តគំនិត

**១-ប្រែចិត្តគំនិត ដើម្បីទទួលជីវិតៗ**

ព្រះជាម្ចាស់បានប្រោសប្រទាន ឲ្យយើងប្រែចិត្តគំនិត ។

**២-ប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះៗ**

ព្រះយេស៊ូមានបន្ទូលថា៖ ចូរអ្នកប្រែចិត្តគំនិត ។

## ៣៣១- បំបាត់អំពើហិង្សា

គ្រួសារយើង មានក្ដីសុខ គ្រួសារយើង ត្រូវបេះស្រឡាញ់
បេះអត់ឱន មានធម៌មេត្តា ត្រូវបំបាត់អំពើហិង្សា ។

**បន្ទរ- គ្រួសារសុខសាន្ត គ្រួសារសុខសាន្ត ដោយបំបាត់អំពើហិង្សា (២ដង)**

## ៣៣២- ផ្សាយដំណឹងល្អ

**បន្ទរ-មានមនុស្សច្រើន ឥតគណនាៗ ដែលមិនស្គាល់ព្រះគ្រីស្តៗ**
**នរណាចង់ទៅ ផ្សាយឲ្យគេៗ យល់សេចក្តីស្រឡាញ់ៗ ។**

១- នរណាចង់ទៅ ផ្សាយដំណឹងល្អថា ព្រះគ្រីស្តស្រឡាញ់គេ
នរណាចង់ទៅ ផ្សាយដំណឹងល្អថា ព្រះគ្រីស្តស្រឡាញ់យើង ។
២- យើងខ្ញុំចង់ទៅ ផ្សាយដំណឹងល្អថា ព្រះគ្រីស្តស្រឡាញ់គេ
យើងខ្ញុំចង់ទៅ ផ្សាយដំណឹងល្អថា ព្រះគ្រីស្តស្រឡាញ់យើង ។

## ៣៣៣- ពាក្យអធិដ្ឋានទៅព្រះរាជវង្ស

**បន្ទរ- បពិត្រព្រះរាជវង្សៗ នៅភូមិណាសារ៉ែតអើយៗ (២ដង)**

១- សូមប្រោសឲ្យក្រុមគ្រួសារ យើងខ្ញុំៗ ជាកន្លែងរួបរួមគ្នានិងអធិដ្ឋាន (**២ដង**)
ក្រុមគ្រួសារយើង ជាសាលារៀន ពិតប្រាកដៗ(**២ដង**) ។
២-សូមកុំឲ្យមានហិង្សា ក្នុងគ្រួសារយើងខ្ញុំ សូមកុំឲ្យមាននរណា
ដាច់ឡែកពីគេ (**២ដង**)
ក្រុមគ្រួសារនេះ ជូនដំណឹងល្អឲ្យយើង ជាព្រះសហគមន៍ ជាសះស្បើយ (**២ដង**)
៣-ក្រុមគ្រួសារមានលក្ខណៈដ៏សក្ការដែលរំលោភមិនបានៗ(២ដង)
សូមឲ្យយើងខ្ញុំចាប់អារម្មណ៍ និងសោភណភាពនៃក្រុមគ្រួសារ (២ដង) ។

## ៣៣៤- ពិធីផ្តល់ជំនឿ

ជំនឿអ្នកស្វែងរកវីកចម្រើនឡើង   តាមពិធីផ្សេងៗរបស់ព្រះសហគមន៍
ជំនឿអ្នកស្វែងរកវីកចម្រើនឡើង   តាមពិធីផ្សេងៗរបស់ព្រះសហគមន៍ ។

## ៣៣៥- ពេលយើងរួមគ្នា

១-ពេលយើងរួមគ្នា ! ពេលយើងរួមគ្នា   យើងអរសប្បាយ (**៣ដង**)
២-ពេលពីរបីនាក់ ! ពេលពីរបីនាក់ !   ចេះរួបរួមគ្នា (**៣ដង**)
មានព្រះអម្ចាស់គង់ជាមួយយើង ។

## ៣៣៦- ពេលនេះឲ្យយើងច្រៀង

ពេលនេះឲ្យយើងច្រៀង   ពេលនេះឲ្យយើងរាំ
ពេលនេះឲ្យយើងច្រៀង   កោតសរសើរព្រះជាអម្ចាស់
យើងកោតសរសើរព្រះជាអម្ចាស់   យើងលើកតម្កើងព្រះនាមព្រះអង្គ
សូមឲ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍   លើកតម្កើងព្រះជាម្ចាស់ ។

## ៣៣៧- ព្យាការីអាម៉ូស

កាលពីដើម   ខ្ញុំពុំមែនជាព្យាការី   ឬជាសមាជិកនៃក្រុមព្យាការីទេ
គឺខ្ញុំជាអ្នកឃ្វាលគោ   និងជាអ្នកចម្ការ
ប៉ុន្តែ ព្រះម្ចាស់ត្រាស់ហៅខ្ញុំពីក្រោយហ្វូងគោ ហើយព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា
ទៅចុះ ! ទៅថ្លែងពាក្យក្នុងនាមយើងប្រាប់អ៊ីស្រាអែល ជាប្រជាជនរបស់យើង ។

## ៣៣៨- ព្យាការីអេសេគីអែល

## (សៀវភៅអប់រំជំនឿទី ២ ខ្ញុំជាសេចក្ដីពិត មេរៀនទី១៨)

១- យើងនឹងប្រោះទឹកដ៏បរិសុទ្ធលើអ្នក នោះអ្នករាល់គ្នានឹងបានបរិសុទ្ធ
យើងនឹងប្រគល់ចិត្តថ្មីឲ្យអ្នក ហើយដាក់វិញ្ញាណរបស់យើងក្នុងអ្នក ។

២- យើងនឹងដកចិត្តរឹងដូចថ្ម ចេញពីអ្នក ហើយឲ្យអ្នកមានចិត្តអាណិតអាសូរ
យើងដាក់វិញ្ញាណរបស់យើងក្នុងអ្នក ដើម្បីឲ្យអ្នកកាន់តាមវិន័យរបស់យើង ។

## ៣៣៩- ព្រះគម្ពីរ

ឲ្យយើងស្គាល់ព្រះគម្ពីរ ដែលយើងប្រាប់នេះ
គឺសម្ពន្ធមេត្រីថ្មី គ្រីស្ដបរិស័ទខំចាប់អារម្មណ៍ (**ណាយៗ**)
គ្រីស្ដបរិស័ទខំចាប់អារម្មណ៍ ហើយចងចាំថា តើមានប៉ុន្មានកណ្ឌ?
ម៉ាថាយ ម៉ាកុស លូកា កណ្ឌទីបួននោះ
ហៅថាយ៉ូហាន កណ្ឌទីប្រាំដល់ទីប្រាំបី (**ណាយៗ**)
កណ្ឌទីប្រាំដល់ទីប្រាំបី គឺកិច្ចការ រ៉ូម កូរិនថូស ។
កាឡាទី អេភេសូ ភីលីព កូឡូស ថេស្សាឡូនិក
(មួយជំពូកចែកណ្ឌពីរក៏មាន)ៗ ចូរចាំឲ្យជាក់ ទាំងទីតុស ភីលេម៉ូន ។
ហេព្រើ យ៉ាកុប សិលា សិលា យ៉ូហាន យ៉ូហានៗ
គម្ពីរយូដា ក៏មានដូចគ្នា (**ណាយៗ**)
គម្ពីរយូដាក៏មានដូចគ្នា កណ្ឌចុងក្រោយគឺ គម្ពីរវិវរណៈ ។

## ៣៤០- ព្រះគ្រីស្ទជាពន្លឺបំភ្លឺដំណើរជីវិតយើង

ព្រះគ្រីស្ទជាពន្លឺ ដែលបំភ្លឺ ដំណើរជីវិត មនុស្សគ្រប់ប្រាណ
ឲ្យមានសង្ឃឹម យល់ថាជីវិតមានតម្លៃ ។
ទោះជាមានឧបសគ្គ យើងត្រូវតែ សម្លឹងទៅមុខ ដោយចិត្តក្លាហាន
និងក្ដីស្រឡាញ់ ព្រះជាម្ចាស់គង់ជាមួយយើង ព្រះជាម្ចាស់បង្ហាញផ្លូវយើង ។

## ៣៤១- ព្រះជាម្ចាស់ត្រាស់ហៅយើង

ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យមានសេរីភាព
ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យទទួលការសង្គ្រោះ ។
សូមកុំយកសេរីភាព មកធ្វើជាលេស ដើម្បីរស់នៅតាមរបៀបលោកីយ៍ឲ្យសោះ
តែផ្ទុយទៅវិញ ត្រូវបម្រើគ្នាដោយចិត្តស្រឡាញ់ ។

## ៣៤២- ព្រះជាម្ចាស់ស្រឡាញ់យើង

ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គគង់នៅជាមួយយើង នៅទីណាក៏មិនខ្លាច
ទៅឆ្ងាយក៏មិនភ័យ ព្រោះព្រះជាម្ចាស់ស្រឡាញ់យើង ។

## ៣៤៣- ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក

ព្រះជាម្ចាស់ស្រឡាញ់លោកា ព្រះអង្គចាត់ព្រះរាជបុត្រា
ព្រះយេស៊ូមកសង្គ្រោះ មនុស្សគ្រប់ជាតិគ្រប់សាសន៍ ។

**បន្ទរ- ព្រះអង្គប្រទាននូវសេចក្ដីស្រឡាញ់ ដល់យើងគ្រប់ៗប្រាណ**
**ឲ្យនាំដំណឹងល្អ ដល់មនុស្សគ្រប់ជាតិ**
**ដោយសំឡេងខ្លាំងនិងច្បាស់ ចូរពួកយើងប្រាប់ទៅ**
**ពិភពលោក នូវក្ដីស្រឡាញ់របស់ព្រះម្ចាស់**
**ដល់អស់អ្នកដែលរងទុក្ខលំបាក បាត់ស្មារតីឲ្យមានសង្ឃឹម ។**

ចូរបំភ្លឺពិភពដែលងងឹត ដោយសារពន្លឺមកពីព្រះម្ចាស់
ចូរពួកយើងទៅ គ្រប់ទិសទីសព្វទិសា
ហើយប្រាប់លោកា ថាព្រះជាម្ចាស់ស្រឡាញ់យើង ។

## ៣៤៤- ព្រះជាម្ចាស់គង់ជាមួយយើង

ព្រះជាម្ចាស់ទ្រង់គង់ជាមួយយើង (**៤ដង**)
ជារៀងរាល់ថ្ងៃ ជារៀងរាល់ថ្ងៃ រហូតដល់អវសានកាល នៃពិភពលោក ។

## ៣៤៥- ព្រះជាម្ចាស់បង្កើតពិភពលោក

ព្រះជាម្ចាស់ទតឃើញថា សត្វលោកទាំងនោះ ល្អប្រសើរណាស់
ព្រះអង្គបង្កើតមនុស្ស ជារូបតំណាង របស់ព្រះអង្គ
ទ្រង់បង្កើតគេ ឲ្យមានលក្ខណៈ ដ៏ប្រសើរដូចព្រះអង្គ ព្រះអង្គបង្កើតគេជាបុរស ជាស្ត្រី ។

## ៣៤៦- ព្រះជាម្ចាស់មាន ព្រះបន្ទូលថា

(សៀវភៅអប់រំជំនឿ)

ព្រះជាម្ចាស់មានព្រះបន្ទូលថា យើងជាព្រះជាម្ចាស់
ប្រកបដោយព្រះហប្ញទ័យអាណិតអាសូរ និងប្រណីសន្ដោស
មានព្រះហប្ញទ័យអត់ធ្មត់ ហើយពោរពេញដោយព្រះហប្ញទ័យមេត្តាករុណា
និងស្មោះស្ម័គ្រជានិច្ច ។

## ៣៤៧- ព្រះជាអម្ចាស់ទ្រង់ជាសេចក្ដីស្រឡាញ់

**បន្ទរ- ព្រះជាអម្ចាស់... ព្រះជាអម្ចាស់ ទ្រង់ជាក្ដីស្រឡាញ់ (២ដង) ។**

នៅពេលយើងភ័យខ្លាច ព្រះអង្គជាពន្លឺ បំភ្លឺជីវិតរបស់យើង យើងដឹងពិតមែនថា
ព្រះអង្គគង់នៅជាមួយ ព្រះអង្គជួយឲ្យយើងលែងភ័យខ្លាច ។

## ៣៤៨- ព្រះបន្ទូលព្រះយេស៊ូ

១- បពិត្រព្រះយេស៊ូ ព្រះអង្គបាត់តាំងសាវ័ក១២នាក់ ឲ្យគេនៅជាមួយព្រះអង្គ
និងដើម្បីទ្រង់ចាត់តាំងគេ ឲ្យទៅប្រកាសដំណឹងល្អ ទាំងឲ្យគេមានអំណាច
កម្ចាត់ព្រាយខ្មោចថែមទៀតជង ។

**បន្ទរ-យើងខ្ញុំសូមលើកតម្កើង សិរីរុងរឿងព្រះអម្ចាស់**
**សូមកោតសរសើរព្រះនាម ព្រះអង្គតរៀងទៅ ។**

២- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ បើអ្នកណាចង់មកតាមខ្ញុំ
ត្រូវលះបង់ខ្លួនឯងនោះចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ជារៀងរាល់ថ្ងៃទៀតជង
ហើយដើរតាមមកក្រោយខ្ញុំចុះ ។

៣- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ បើអ្នកណាចង់រួចជីវិត
អ្នកនោះត្រូវបាត់បង់ជីវិត ឯអ្នកណាបាត់បង់ជីវិត ព្រោះតែខ្ញុំនិងដំណឹងល្អ
អ្នកនោះនឹងបានជីវិតវិញ ។

៤- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅសាវ័ក! ប្រសិនបើជាអ្នករាល់គ្នា
មិនអត់ទោសឲ្យគេនោះទេ ព្រះបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ
មិនអត់ទោសឲ្យអ្នករាល់គ្នា ។

៥- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ អ្វីរបស់ព្រះចៅអធិរាជ
ចូរថ្វាយទៅព្រះចៅអធិរាជ ហើយអ្វីៗដែលជា របស់ព្រះជាអម្ចាស់នោះ
ចូរថ្វាយទៅព្រះជាម្ចាស់វិញ ។

៦- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់
គឺជាព្រះរបស់នៃអ្នក ឲ្យអស់ស្មារតីទាំងប្រាជ្ញា និងស្រឡាញ់បងប្អូនឯទៀត
ឲ្យដូចស្រឡាញ់ខ្លួនឯងដែរ ។

៧- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖
ព្រះបន្ទូលដែលបានសន្យា របស់ព្រះជាអម្ចាស់
កើតជារូបរាងពេលនេះហើយ ចូរនាំគ្នាប្រែបចិត្តគំនិត
ហើយជឿលើដំណឹងល្អចុះ ។

៨- បពិត្រព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖
មនុស្សជាមិនត្រូវការពេទ្យទេ មានតែអ្នកដែលមានជំងឺ
គេត្រូវការគ្រូពេទ្យប៉ុណ្ណោះ ខ្ញុំមិនមែនរកមនុស្សសុចរិត
គឺខ្ញុំមករកមនុស្សបាបវិញ ។

## ៣៤៩- ព្រះបិតាស្រឡាញ់យើង

**បន្ទរ- ព្រះបិតាមានធម៌មេត្តា មានធម៌មេត្តា ហើយស្រឡាញ់យើង**
ព្រះបិតាមានធម៌មេត្តា ព្រះបិតាស្រឡាញ់លោកា
ព្រះបិតាប្រទានព្រះបុត្រា ព្រះបិតាស្រឡាញ់យើង ។

## ៣៥០- ព្រះពរតែងតាំង

**(លំនាំបទ យើងរីករាយទទួលព្រះកុមារយេស៊ូ)**

១- អបអរសប្បាយ ថ្ងៃព្រះជាម្ចាស់ សព្វហឫទ័យ ប្រោសប្រទាន
លោកអភិបាល ក្លាយជាគង្វាល ដឹកនាំយើងខ្ញុំ ដើរក្នុងមាគ៌ា
របស់ព្រះគ្រីស្ដជាអម្ចាស់ ។

**បន្ទរ-សូមលើកតម្កើង ព្រះជាម្ចាស់នៃយើង ជាព្រះបិតា ព្រះធម៌មេត្តា**
**សូមអរព្រះគុណ ព្រះគ្រីស្ដដ៏ឧត្ដម ប្រទានយើងខ្ញុំ គង្វាលស្មោះស្ម័គ្រ ។**

២- អបអរសប្បាយ ថ្ងៃព្រះជាម្ចាស់ ប្រោសប្រទាន លោកអភិបាល
ប្រកាសបន្ទូល ដឹកនាំគ្រប់គ្នា រួមថ្វាយបូជា ថ្វាយព្រះជាម្ចាស់
ជាព្រះបិតារបស់យើង ។

**បន្ទរ-ចូរយើងអបអរ ទះដៃយើងអបអរ ព្រះពរថ្លាថ្លៃ នៃព្រះបិតា**
**ព្រះអង្គប្រទាន ឲ្យលោកថ្វាយបូជា ប្រកាសបន្ទូល គ្រប់គ្នាហែតាម ។**



## ៣៥១- ព្រះមហាករុណាទិគុណ

១- ជាពេលអំណរ ពេលសន្តិភាព ពោរពេញដោយសេរីភាពប្រាកដ
ជាពេលដែល ត្រូវបញ្ចប់ គ្រប់ភាពរើសអើង ។
ជាពេលកែប្រែ ជាពេលសង្ឃឹម ជាពេលដែល
យើងរួមគ្នាតែមួយ ជាពេលកសាងពិភពលោកទាំងមូល ។

**បន្ទរ- នេះជាពេលអរព្រះគុណ ព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណ ជាមួយម៉ារី ជាមាតា យើងច្រៀងសរសើរ ។ ចូរបើកដួងចិត្តថ្វាយព្រះម្ចាស់ ហើយចាប់ផ្តើមយល់ពីសេចក្តីមេត្តា ថាមនុស្សគ្រប់ជាតិ គ្រប់សាសន៍ គឺជាបងប្អូននឹងគ្នា គ្មានកំពែង គ្មានខ្មោះឃ្មាង គ្មានការគិតថាខ្លួនឯងជាធំ ពេលនេះយើងរួមគ្នា ក្នុងព្រះរាជ្យព្រះម្ចាស់ គឺជាឆ្នាំព្រះមហាករុណាទិគុណ ។**

២-ជាពេលអធិដ្ឋាន ជាពេលសរសើរ ជាពេលទទួលព្រះរាជ្យព្រះម្ចាស់ ជាពេលកែប្រែចិត្ត ឲ្យបរិសុទ្ធ ។ ជាពេលទុកចិត្ត ជាពេលបង្វែរ បេះដូងទាំងឡាយដែលឃ្លាតបាកឆ្ងាយ ឲ្យវិលមកក្នុង រង្វង់ហត្ថាព្រះម្ចាស់ ។

## ៣៥២- ព្រះយេស៊ូ ជាប្រភពទឹក

ព្រះយេស៊ូជាប្រភពទឹក ដែលផ្តល់ជីវិត
សូមមេត្តាផ្តល់ទឹកនោះ ឲ្យខ្ញុំផង ។

## ៣៥៣- ព្រះយេស៊ូគង់នៅជាមួយ

ព្រះយេស៊ូគង់ជាមួយ យើងនឹងមិនភ័យខ្លាច មិនភ័យខ្លាច ៗ
ព្រះយេស៊ូគង់ជាមួយ យើងនឹងមិនភ័យខ្លាច យើងមានចិត្តក្លាហានៗៗ
ព្រះយេស៊ូគង់ជាមួយ យើងនឹងមិនភ័យខ្លាច យើងមានចិត្តក្លាហាន ។

## ៣៥៤- ព្រះយេស៊ូគ្រីស្ទជាកម្លាំង

យើងមានព្រះយេស៊ូគ្រីស្ទ ជាកម្លាំងរបស់យើង (**៣ដង**)
យើងមានព្រះយេស៊ូគ្រីស្ទ ជាកម្លាំង ។

**បន្ទរ- អាំ.... អាំ.... អាំ.... អាំ.... អាំ.... អាំ.... អាំ.... អាលេលូយ៉ា** (៣ដង)

យើងមានព្រះគ្រីស្ទ គង់ជាមួយយើង ។

## ៣៥៥- ព្រះយេស៊ូអើយ !

ព្រះយេស៊ូអើយ! ព្រះយេស៊ូអើយ ! សូមប្រោសភ្នែកទូលបង្គំឲ្យបានភ្លឺផង ។

## ៣៥៦- ព្រះវិញ្ញាណគង់សណ្ឋិត

ព្រះវិញ្ញាណ គង់សណ្ឋិត លើដួងចិត្តយើងខ្ញុំ យើងនឹង.....ដូចដាវីឌ.....(**២ដង**)
យើងនឹង..... យើងនឹង..... យើងនឹង..... ដូចដាវីឌ..... (**២ដង**)
(ច្រៀង..... រាំ..... ដើរ..... ញញឹម)

## ៣៥៧- ព្រះហឫទ័យសប្បុរស

ឱ! ព្រះជាម្ចាស់អើយ ព្រះអង្គពិតជាមាន ព្រះហឫទ័យសប្បុរស
លើសលប់មែនពេលខ្ញុំអស់កម្លាំង ព្រះអង្គយាងមករកខ្ញុំ ។

ឱ! ព្រះគ្រីស្តជាព្រះអម្ចាស់ សូមប្រោសមេត្តា មនុស្សប្រុសស្រីដែលបាន
លាចាកពីលោកីយ៍ បានរស់ក្នុងនៃក្តីស្រឡាញ់ ។

## ៣៥៨- ព្រះអង្គត្រាស់ហៅ

**បន្ទរ- ដោយព្រះអំណោយទាន ពីព្រះជាអម្ចាស់ ដឹកនាំកូន**
**ចូលក្នុងជីវិតត្រាស់ហៅ ជាបុត្រធីតាដ៏ជាទីស្រឡាញ់**
**ជាសាក្សីឲ្យទៅផ្សាយ ដំណឹងល្អ នេះជាជីវិត**
**កូនសូមថ្វាយព្រះអម្ចាស់ សូមក្រាបវន្ទាស្មោះបម្រើព្រះអង្គ**
**សទ្ធាជ្រះថ្លាក្នុងជំនឿតែមួយ សូមព្រះអង្គទ្រង់គង់នៅជាមួយយើង ។**

១- កូនពិតជាអ្នកក្រខ្សត់ កូនពិតជាអ្នកបម្រើ ដើម្បីឲ្យមនុស្សលោក
ស្គាល់ព្រះនាមព្រះជាម្ចាស់ ព្រះអម្ចាស់អស់ពីដួងចិត្ត កូនស្មោះពិត
ព្រះអង្គតែមួយ ។

២- កូនពិតគ្រប់គ្រាដំណើរ ប្រកាសផ្សាយដំណឹងល្អ ដ្បិតព្រះអង្គជាជីវិត
សេចក្តីពិត ព្រះសង្គ្រោះ ព្រះម្ចាស់កូនសុខចិត្ត រួមស្លាប់រស់ជាមួយព្រះអង្គ ។

៣- កូនពិតថ្វាយទាំងចិត្តកាយ សច្ចាបូជាជីវិត ដោយត្រូវរងទុក្ខរងភ័យ
និងបង្អាប់កិត្តិយស ព្រះអម្ចាស់ នេះជាបំណងចង់រួមរស់ជាមួយព្រះអង្គ ។

៤- ព្រះអម្ចាស់កូនសូមអង្វរ ឲ្យកូនមានចិត្តសង្ឃឹម ទោះបីយ៉ាប់យ៉ឺនទន់ខ្សោយ
មិនកែប្រែចិត្តគំនិត ព្រះអម្ចាស់អស់មួយជីវិត កូនស្មោះស្ម័គ្រដើរតាមព្រះអង្គ ។

## ៣៥៩- ព្រះអម្ចាស់មានតែមួយ

**បន្ទរ- ព្រះអម្ចាស់មានតែមួយៗ ជំនឿមានតែមួយៗ ពិធីជ្រមុជទឹកមានតែមួយៗ**

១- ព្រះជាម្ចាស់មានតែមួយ ព្រះអង្គជាព្រះបិតា របស់មនុស្សទាំងអស់
ព្រះអង្គធ្វើការតាមរយៈមនុស្សទាំងអស់ និងសណ្ឋិតនៅក្នុងមនុស្សទាំងអស់ ។

២- ព្រះកាយមានតែមួយ ព្រះវិញ្ញាណក៏មានតែមួយ ដូចព្រះជាម្ចាស់
បានត្រាស់ហៅបងប្អូន ឲ្យមានសេចក្ដីសង្ឃឹមតែមួយ ។

## ៣៦០- ព្រះអម្ចាស់មានព្រះបន្ទូល

**អាលេលូយ៉ា ! អាលេលូយ៉ា ! អាលេលូយ៉ា !**

១-ព្រះអម្ចាស់មានព្រះបន្ទូលថា អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់
ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាសម្រាក ។

២-ព្រះយេស៊ូមានព្រះបន្ទូលថា គ្មាននរណាមានសេចក្ដីស្រឡាញ់ ខ្លាំងជាងអ្នក
ស៊ូប្ដូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួន ។

៣-ព្រះយេស៊ូមានព្រះបន្ទូលថា ស៊ីម៉ូន អន់ទ្រេ សូមអញ្ជើញ មកតាមខ្ញុំ
ខ្ញុំតែងតាំងអ្នក ឲ្យអ្នកទៅជានេសាទមនុស្សវិញ ។

៤- ព្រះយេស៊ូមានព្រះបន្ទូលថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់ អ្នករាល់គ្នា
ព្រមទាំងអង្វរ ព្រះអង្គប្រទានពរឲ្យគេផង ។

៥- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកណាស្ដាប់ព្រះបន្ទូលរបស់ ព្រះជាម្ចាស់
ហើយអនុវត្តតាម គឺអ្នកនោះមានសុភមង្គល ។

៦- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកណាតម្កើងខ្លួននឹងត្រូវ បន្ទាបចុះ
ឯអ្នកបន្ទាបខ្លួន នឹងត្រូវគេលើកតម្កើងឡើងវិញ ។

## ៣៦១- មហាសន្និបាតលើកទី ១៥

បងប្អូនធ្វើអ្វីក៏ដោយ ចូរធ្វើទាំងអស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ។

## ៣៦២- ម៉ាថាយ ៥:១៧

ខ្ញុំមិនមែនមក លុបបំបាត់ ធម្មវិន័យទេ គឺខ្ញុំមក ធ្វើឲ្យធម្មវិន័យ បានពេញលក្ខណៈ ។

## ៣៦៣- មានព្រះយេស៊ូគ្រីស្តជីវិតយើងចេះស្រឡាញ់

យើងជាយុវជន សូមឲ្យយើងចេះស្រឡាញ់ មានព្រះយេស៊ូគ្រីស្ត
ជីវិតយើងចេះស្រឡាញ់ ស្រឡាញ់ ស្រឡាញ់ ស្រឡាញ់ ស្រឡាញ់ ។

## ៣៦៤- មានសុភមង្គលមែន

**បន្ទរ- មានសុភមង្គលមែន (២ដង)**

១- ស្ត្រីដែលបង្កើតលោក មានសុភមង្គលមែន
ព្រមទាំងបំបៅលោក មានសុភមង្គលមែន **(បន្ទរ)** ។

២- អ្នកណាស្តាប់ព្រះបន្ទូល មានសុភមង្គលមែន
ហើយអនុវត្តតាម មានសុភមង្គលមែន **(បន្ទរ)** ។

## ៣៦៥- យុវជនគឺជាទំពាំងស្នងឫស្សី

យុវជនគឺជាទំពាំងស្នងឫស្សី គឺជាសេចក្ដីសង្ឃឹម សូមឲ្យយើងបេះជួយអ្នកដទៃ
ធ្វើអ្វីឲ្យបេះស្រឡាញ់ យើងរួបរួមគ្នាជាធ្លុងតែមួយ លើកស្ទួយ
ជួយអ្នកទន់ខ្សោយ សូមឲ្យយើងបេះផ្ញើជីវិតទៅព្រះគ្រីស្ដ
គឺជាកម្លាំងរបស់យើង ។

## ៣៦៦- យុវជនជាពន្លឺផែនដី

១- តើអ្នកមានឃើញទេ? តើអ្នកមានដឹងទេថាពិភពលោកងងឹត?
ចូរបើកភ្នែកឡើង ចូរបើកចិត្តយើងមើលជុំវិញខ្លួន
ដែលមានភាពស្អប់ តែព្រះវិញ្ញាណបំភ្លឺយើងគ្រប់គ្នា ។

២- យុវជនជាពន្លឺផែនដី ចូរឲ្យពួកយើងនាំក្ដីសង្ឃឹម
យុវជនជាអំបិលនៃមនុស្ស ចូរឲ្យពួកយើងនាំក្ដីស្រឡាញ់ ។ **(២ដង)**

## ៣៦៧- យើងដើរតាមព្រះអង្គ

១- យើងរួមគ្នាជាធ្លុងតែមួយ ធ្វើដំណើរទៅកាន់ព្រះបិតា
ស្រឡាញ់គ្នាតាមព្រះបន្ទូល ពួកយើងជាបងប្អូន ។

**បន្ទរ-យើងជួបជុំគ្នាក្នុងសេចក្ដីស្រឡាញ់ ព្រះជាម្ចាស់គង់ជាមួយយើង**
**ព្រះយេស៊ូគ្រីស្ដនាំផ្លូវជីវិតយើង យើងដើរតាមព្រះអង្គ ។**

២- ពេលទុក្ខព្រួយ ឬមានក្ដីសុខ យើងខ្ញុំសូមដើរតាមព្រះគ្រីស្ដ
ផ្ញើជីវិតឲ្យព្រះគ្រីស្ដដឹកនាំ យើងដើរតាមព្រះអង្គ ។

៣- ព្រះយេស៊ូគឺជាពន្លឺ ជួយបំភ្លឺជីវិតឲ្យយើង
ព្រះយេស៊ូជាក្ដីសង្ឃឹម យើងដើរតាមព្រះអង្គ ។

## ៣៦៨- យើងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់

យើងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់ (យើងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់)
យើងខ្ញុំសូមអរព្រះគុណព្រះអង្គ (យើងខ្ញុំសូមអរព្រះគុណព្រះអង្គ)

**អា...ម៉ែន អាលេលូយ៉ា ។**

## ៣៦៩- យើងគិតដល់ជីវិត

យើងគិតដល់ជីវិត យើងរស់នៅឲ្យមានតម្លៃ អត្ថន័យនៃជីវិតវាសំខាន់
ចូររកផ្លូវមួយ ដើម្បីដើរទៅរកសុភមង្គល ។

## ៣៧០- យើងបានស្រឡាញ់អ្នក

យើងបានស្រឡាញ់អ្នក តាំងពីមុនអ្នកកើតមក យើងបានតែងតាំងអ្នក
ឲ្យនាំព្រះបន្ទូល ដល់មនុស្សគ្រប់ជាតិគ្រប់សាសន៍ ។

## ៣៧១- យើងមានព្រះគ្រីស្តធ្វើជាគំរូ

១- យើងមានព្រះគ្រីស្តធ្វើជាគំរូ យុវជនខិតខំតស៊ូដើរតាម
ទ្រង់មានចិត្តអាណិតមនុស្សគ្រប់ប្រាណ ជួយយើងឲ្យបានសុភមង្គល ។

២- ចូរយើងដាក់ចិត្តជាអ្នកក្រខ្សត់ មានចិត្តអំណត់ ធ្វើជាគំរូ
បើស្រឡាញ់យើងត្រូវហ៊ានស៊ូប្តូរជីវិត ដើម្បីជួយមិត្តសម្លាញ់ ។

## ៣៧២- យើងសូមដើរ

យើងខ្ញុំសូមដើរតាមព្រះយេស៊ូ យើងសូមដើរតាមផ្លូវព្រះយេស៊ូគ្រីស្ទ
ពេលយើងមានបញ្ហាព្រះអង្គមេត្តា ជាកម្លាំងឲ្យយើងបានសេចក្ដីសុខ(**២ដង**)
យើងនឹងប្រៀបដូចសត្វឥន្ទ្រីមាំមួន ពេលមានខ្យល់ព្យុះខ្លាំងមិនដែលភ័យខ្លាច
មានកម្លាំងមាំមួន មានកម្លាំងតស៊ូ យើងសូមដើរតាមផ្លូវព្រះយេស៊ូគ្រីស្ទ ។

## ៣៧៣- យើងសូមជូនផ្កា

\- យើងសូមជូនផ្កាមួយនេះ ជាសេចក្ដីស្រឡាញ់
សូមព្រះជាម្ចាស់ទ្រង់ប្រទានពរ ឲ្យយើងអរសប្បាយ ។

**បន្ទរ-** **សូមឲ្យជីវិតបានជិតស្និទ្ធ ព្រះយេស៊ូគ្រីស្ទ**
**សូមព្រះគ្រីស្ទប្រទានពរ សូមព្រះអង្គគង់ជាមួយ**
**សូមទ្រង់ជួយការពារ ។**
**ឲ្យអាយុយឺនយូរ សុខភាពមាំមួន ។**
**សូមព្រះគ្រីស្ទប្រទានពរ សូមព្រះអង្គគង់ជាមួយ**
**សូមទ្រង់ជួយការពារ ។**

## ៣៧៤- យើងខ្ញុំសូមអរព្រះគុណ

យើងខ្ញុំសូមអរព្រះគុណព្រះអម្ចាស់ ! យើងខ្ញុំសូមកោតសរសើរព្រះអង្គ ។

## ៣៧៥- រីករាយសាទរ

១- រីករាយស្វាគមន៍ ស្វាគមន៍យើងសូមជូនផ្កា
ជូនលោកអភិបាល ក្នុងសេចក្ដីស្រឡាញ់ព្រះគ្រីស្ត
រីករាយសាទរសាទរ ចូរយើងទះដៃសប្បាយចិត្តក្រៃ
ប្រុសស្រីលើកដៃជូនពរ ។

បន្ទរ១- សូមព្រះជាម្ចាស់ តាមថែរក្សា ប្រទានប្រាជ្ញាសុខភាពមាំមួន
សូមព្រះបិតា និងព្រះបុត្រា ទាំងព្រះវិញ្ញាណប្រទានពរសុខសាន្ត។

២- រីករាយសាទរ សាទរយើងសូមជូនផ្កា
ជូនលោកឪពុកថ្លៃថ្លា ក្នុងសេចក្ដីស្រឡាញ់ព្រះគ្រីស្ត
រីករាយសាទរសាទរ ចូរយើងទះដៃសប្បាយចិត្តក្រៃ
ប្រុសស្រីលើកដៃជូនពរ ។

បន្ទរ២- សូមព្រះជាម្ចាស់ ការពារថែរក្សា ព្រះសហគមន៍លូតលាស់ចម្រើន
សូមព្រះបិតា និងព្រះបុត្រា ទាំងព្រះវិញ្ញាណប្រទានពរសុខសាន្ត។

៣- រីករាយជួបជុំ ជួបជុំយើងព្រះសហគមន៍
យើងជាបងប្អូនរស់ ក្នុងសេចក្ដីស្រឡាញ់ព្រះគ្រីស្ត
រីករាយសាទរ ជយោព្រះសហគមន៍
ថ្កុំថ្កើងរុងរឿង យើងជាគ្រួសារតែមួយ ។

បន្ទរ៣- សូមព្រះជាម្ចាស់ ព្រះធម៌មេត្តា រក្សាការពារ បងប្អូនគ្រប់គ្នា
សូមព្រះបិតា និងព្រះបុត្រា ទាំងព្រះវិញ្ញាណ ប្រទានពរសុខសាន្ត។

## ៣៧៦- រួមគ្នាកសាងព្រះសហគមន៍

រួមគ្នាកសាងព្រះសហគមន៍ៗ រួមគ្នាកសាងព្រះសហគមន៍ៗ
យើងជាបុត្រធីតា របស់ព្រះជាអម្ចាស់ យើងជាបងប្អូនគ្នា យើងជាព្រះសហគមន៍ ។
**ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា**

## ៣៧៧- រួមជាមួយព្រះគ្រីស្ត

១- សូមជួយយើងខ្ញុំឲ្យចេះគិតគូរ ខំតស៊ូដើរតាមព្រះអង្គ
ទោះបីយ៉ាប់យ៉ឺនលំបាកប្រាណ លុះដល់ឈើឆ្កាងបានរុងរឿង ។

២- ពេលថ្ងៃខ្ញុំធ្វើការហត់នឿយ យប់មកដល់ហើយចិត្តខ្ញុំប៉ង
ចង់រួមជាមួយព្រះអង្គផង នេះជាបំណងដ៏ថ្លៃថ្លា ។

**បន្ទរ- រួមជាមួយព្រះយេស៊ូ ជាគំរូឲ្យយើងដើរតាម**
**រួមថ្វាយទៅកាន់ព្រះបិតា សូមទ្រង់មេត្តា មេត្តាយើងខ្ញុំ ។**

៣- សូមជួយយើងខ្ញុំឲ្យមានចិត្តត្រង់ ជឿតែព្រះអង្គគ្រប់ពេលវេលា
សូមឲ្យយើងខ្ញុំ ចេះស្រឡាញ់គ្នា ដូចជាព្រះបិតាស្រឡាញ់យើង ។

## ៣៧៨- រួមដំណើរ

១- នៅសម័យកាលនោះ គឺមានលោកប៉ូល ក្លាហានមិនខ្លាចផ្សាយដំណឹងល្អ
ដល់ជនក្រីក្រ ទោះលំបាកកាយ ដើម្បីព្រះយេស៊ូ មិនស្តាយ ។

២- បន្ទាប់ពីលោកប៉ូល គឺអ្នកនឹងខ្ញុំ យើងជាព្រះសហគមន៍កាតូលិក
រួមគ្នាតែមួយ យើងជាកម្លាំង កសាងព្រះសហគមន៍ ។

**បន្ទរ- រួមដំណើរជាមួយសន្តប៉ូល នាំឲ្យគេស្គាល់ព្រះយេស៊ូ ។**
**រួមដំណើរជាមួយសន្តប៉ូល នាំមកនូវសន្តិភាព ។**

## ៣៧៩- រួមដំណើរជាមួយសន្តប៉ូល

១- ព្រះសហគមន៍កាតូលិក មកពីទិសទីគ្រប់កន្លែង ភាពអង់អាចមានជាក់ស្តែង
ហ៊ានស្រែកជាថ្លែងដំណឹងល្អ ។
តាមរយៈសន្តប៉ូល ព្រះជាម្ចាស់ពោលប្រែគំនិត យើងទាំងអស់ គិតល្អល្អិត
រួមនឹងសន្តប៉ូលនៅពេលនេះ ។

**បន្ទរ- ចូរយើងរួមដំណើរជាមួយសន្តប៉ូល ដើម្បីនិទានជីវិតព្រះយេស៊ូ
ឲ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍ បានស្គាល់នូវសេចក្តីស្រឡាញ់
របស់ព្រះអង្គ ។**

**- ចូរយើងរួមដំណើរជាមួយសន្តសិលា ដើម្បីនិទានជីវិតព្រះយេស៊ូ
ឲ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍ បានស្គាល់ធម៌មេត្តាករុណា
របស់ព្រះអង្គ ។**

២- ចូរបាកចេញទៅប្រកាសផ្សាយ ដល់មនុស្សទាំងឡាយ នូវអំណរសិរីរុងរឿង
ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ សូមអរព្រះគុណព្រះអង្គ
ដែលទ្រង់ប្រទានសន្តប៉ូល ឲ្យសហគមន៍កាតូលិកក្លាយទៅជាសាក្សីព្រះអង្គ ។

## ៣៨០- រាំនិងច្រៀងសរសើរព្រះជាម្ចាស់

១- លើកដៃស្តាំចេញទៅ យកដៃស្តាំចូលមក
លើកដៃស្តាំចេញទៅ ចូលទៅបង្វិលខ្លួនមួយជុំ
ហើយចេញមករាំបន្តិច ដើម្បីឲ្យយើងខ្ញុំញញឹម
ច្រៀងសរសើរព្រះជាម្ចាស់ ។

២- លើកដៃឆ្វេងចេញទៅ យកដៃឆ្វេងចូលមក
លើកដៃឆ្វេងចេញទៅ ចូលទៅបង្វិលខ្លួនមួយជុំ
ហើយចេញមករាំបន្តិច ដើម្បីឲ្យយើងខ្ញុំញញឹម
ច្រៀងសរសើរព្រះជាម្ចាស់ ។

៣- លើកជើងឆ្វេងចេញទៅ យកជើងឆ្វេងចូលមក
លើកជើងឆ្វេងចេញទៅ ចូលទៅបង្វិលខ្លួនមួយជុំ
ហើយចេញមករាំបន្តិច ដើម្បីឲ្យយើងខ្ញុំញញឹម
ច្រៀងសរសើរព្រះជាម្ចាស់ ។

៤- លើកជើងស្តាំចេញទៅ យកជើងស្តាំចូលមក
លើកជើងស្តាំចេញទៅ ចូលទៅបង្វិលខ្លួនមួយជុំ
ហើយចេញមករាំបន្តិច ដើម្បីឲ្យយើងខ្ញុំញញឹម
ច្រៀងសរសើរព្រះជាម្ចាស់ ។

## ៣៨១- លាហើយមិត្តសម្លាញ់

លាហើយ លាហើយ លាហើយមិត្តសម្លាញ់
លាហើយមិត្តសម្លាញ់ លាហើយ លាហើយ យើងនឹងជួបគ្នាទៀត
យើងនឹងជួបគ្នាទៀត។ **(២ដង)**

## ៣៨២- លោកយេស៊ូនេះ ដែលបងប្អូនបានឆ្លង

លោកយេស៊ូនេះដែលបងប្អូនបានឆ្លង
ព្រះជាម្ចាស់ បានតែងតាំងលោកឡើង ជាព្រះអម្ចាស់និងជាព្រះគ្រីស្ត
ជាព្រះអម្ចាស់និងជាព្រះគ្រីស្ត ។

## ៣៨៣- លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង

លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង
**ចូរស្ដាប់ព្រះអង្គ(៣ដង)** ចូរស្ដាប់ព្រះអង្គចុះ ។

## ៣៨៤- លោកតាអាប្រាហាំ

បន្ទរ- លោកតាអាប្រាហាំមានចៅច្រើននាក់ មានចៅច្រើននាក់
មានលោកតាអាប្រាហាំ យើងខ្ញុំជាចៅ និងអ្នកជាចៅ
សូមឲ្យយើងចេះស្រឡាញ់ ។

១- ដៃស្ដាំ ដៃឆ្វេង ។

២- ដៃស្ដាំ ដៃឆ្វេង ជើងស្ដាំ ជើងឆ្វេង ។

៣- ដៃស្ដាំ ដៃឆ្វេង ជើងស្ដាំ ជើងឆ្វេង កាច់ចង្កេះ រក្បាល ។

## ៣៨៥- វិន័យ ១- ១០

| | | | |
|---|---|---|---|
| វិន័យទី១ | ត្រូវគោរពកោតខ្លាច | ព្រះជាម្ចាស់ | តែមួយព្រះអង្គគត់ |
| វិន័យទី២ | កុំឆ្លាក់រូបអ្វី | មកថ្វាយបង្គំ | មកថ្វាយបង្គំ |
| វិន័យទី៣ | កុំយកព្រះនាម | ព្រះជាម្ចាស់ | ទៅស្បថឬទៅ |
| | បោកបញ្ឆោតគេឡើយ | | |
| វិន័យទី៤ | ត្រូវញែកថ្ងៃសៅរ៍ | ថ្វាយបង្គំ | ព្រះជាម្ចាស់ |
| វិន័យទី៥ | ត្រូវគោរពកោតខ្លាច | មាតាបិតា | មាតាបិតា |
| វិន័យទី៦ | កុំសម្លាប់មនុស្ស | | |
| វិន័យទី៧ | កុំប្រព្រឹត្ត | អំពើ | ផិតក្បត់ |
| វិន័យទី៨ | កុំលួចប្លន់គេ | | |
| វិន័យទី៩ | កុំពោលពាក្យកុហក | | |
| វិន័យទី១០ | កុំមានចិត្ត | លោភលន់ឡើយ | លោភលន់ឡើយ ។ |

## ៣៨៦- វិន័យថ្មី ម៉ាកុសជំពូក ១២

(មក ១២,៣០)

| | | | |
|---|---|---|---|
| យើងរួបរួមគ្នា | ជាធ្លុងតែមួយ | ដោយយើងមាន | ព្រះយេស៊ូគ្រីស្ត |
| យើងចេះអត់ឱន | យើងចេះជួយគ្នា | ពុះពារឧបសគ្គ | ទាំងឡាយ |
| យើងត្រូវស្រឡាញ់ | ព្រះជាម្ចាស់ | ដោយស្រឡាញ់ | បងប្អូន |
| ជួយអ្នកក្រីក្រ | អ្នកអស់សង្ឃឹម | ធ្វើតាមព្រះបន្ទូល | ព្រះជាម្ចាស់ ។ |

## ៣៨៧- សទ្ធហៈ

យើងរួមជាមួយគ្នា យើងជាកម្លាំងចិត្ត យើងជួយជីវិត លើកទឹកចិត្តអ្នកជំងឺ ត្រូវស្រឡាញ់គេដូចបងប្អូនយើងបង្កើត មានមេត្តាធម៌ដល់អ្នកឈឺគ្រប់ៗគ្នា យើងរាល់គ្នាជាបងប្អូន ។

## ៣៨៨- សង់ផ្ទះ

១- មនុស្សឈ្លាសវៃ សង់ផ្ទះនៅលើថ្មាំងថ្ម (**៣ដង**)
នៅពេលភ្លៀងបង្អុរចុះមក ។
២- ហើយមានទឹកជន់ មានខ្យល់បក់បោកប៉ះ (**៣ដង**)
ផ្ទះនោះក៏មិនរលំដែរ ។
៣- មនុស្សឆោតល្ងង់ សង់ផ្ទះនៅលើដីខ្សាច់ (**៣ដង**)
នៅពេលភ្លៀងបង្អុរចុះមក ។
៤-ហើយមានទឹកជន់ មានខ្យល់បក់បោកប៉ះ(**៣ដង**)
ផ្ទះនោះក៏រលំបាក់បែក ។

## ៣៨៩- សន្និបាតព្រះសហគមន៍

សន្និបាតៗ សន្និបាតព្រះសហគមន៍ យើងខ្ញុំមកសន្និបាត
ជាឱកាសដ៏ល្អ រួមគ្នាយើងជាកម្លាំង
**កសាងព្រះសហគមន៍(៤ដង) ហូ..........**
**កសាងព្រះសហគមន៍(៣ដង) ។**

## ៣៩០- សូមផ្ញើជីវិត

ព្រះជាម្ចាស់ យើងខ្ញុំសូមផ្ញើជីវិត សូមថ្វាយទាំងកាយទាំងចិត្ត
ជាមួយព្រះយេស៊ូ ព្រះយេស៊ូ ។

## ៣៩១- សូមឲ្យចិត្តយើងបានសុខសន្តិភាព

សូមឲ្យចិត្តយើងបានសុខសន្តិភាព (**៤ដង**)

## ៣៩២- សូមលើកតម្កើងព្រះជាម្ចាស់

សូមលើកតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត
ជាអម្ចាស់នៃយើង ព្រះបិតាប្រទានពរគ្រប់យ៉ាង
ផ្នែកខាងវិញ្ញាណមកយើង ក្នុងអង្គព្រះគ្រីស្ត ព្រះអង្គបានជ្រើសរើសយើង
ក្នុងអង្គព្រះយេស៊ូគ្រីស្ត តាំងពីមុនកំណើតពិភពលោកនេះមកម្ល៉េះ
ដើម្បីឲ្យយើងបានវិសុទ្ធ ។(**២ដង**)

## ៣៩៣- សូមជួយយកពែងទុក្ខលំបាក

| | | | | |
|---|---|---|---|---|
| ឱព្រះបិតា | ព្រះអង្គអាច | សម្រេច | គ្រប់កិច្ច | ការទាំង |
| អស់បាន | សូម | ដកយកពែង | ទុក្ខលំបាក | នេះចេញ |
| ឲ្យឆ្ងាយ | ពីកូនទៅ | ប៉ុន្តែ | សូមកុំតាម | បំណងចិត្ត |
| កូនឡើយ | គឺសូមឲ្យ | បានសម្រេច | តាមព្រះហឫទ័យ | ព្រះអង្គវិញ |

## ៣៩៤- សួស្តីថ្ងៃកំណើត

១- សួស្តីថ្ងៃកំណើត  សួស្តីថ្ងៃកំណើត  ថ្ងៃជួបជុំមិត្តភក្តិ ឪពុកម្តាយបងប្អូន ។
២- សួស្តីថ្ងៃកំណើត  សួស្តីថ្ងៃកំណើត  រំឭកដល់ថ្ងៃកំណើត ថ្ងៃសិរីសួស្តី ។
៣- កុំគិតថាខ្លួនចាស់  ត្រូវផ្លាស់គំនិតថ្មី  ខ្ញុំសូមជូនពរជ័យ ឲ្យជួបតែក្តីសុខ ។
៤- សូមប្រាជ្ញាឆ្លាតវៃ  សុខភាពល្អប្រពៃ  អាយុវែងថ្លាថ្លៃ ប្រាថ្នាអ្វីបានសម្រេច ។
៥- មានកម្លាំងមាំមួន ជួបជូនតែសប្បាយ ទាំងផ្លូវចិត្តនិងកាយ ឥតខ្វល់ខ្វាយចិន្តា ។
៦- ពេលគេងសុបិនល្អ ពេលធ្វើចរាចរណ៍ ជួបតែសុខបវរ ជានិច្ចនិរន្តរ៍ទៅ ។

## ៣៩៥- សេរីភាពពិតប្រាកដ

ព្រះគ្រីស្ត!  ព្រះគ្រីស្ត!  ព្រះគ្រីស្ត!  ព្រះគ្រីស្តបានរំដោះយើង  **(២ដង)**
ឲ្យមានសេរីភាពពិតប្រាកដ ។

## ៣៩៦- អូ អូ អូ យុវជនយុវនារី

អូ អូ អូ អូ អូ  អូ អូ អូ អូ អូ  អូ អូ អូ អូ អូ អូ អូ អូ  អូ អូ អូ អូ អូ អូ
យុវជន យុវនារីជីវិតយើងមានតម្លៃ ព្រះបិតាទ្រង់សព្វព្រះទ័យឲ្យយើងជាបុត្រធីតា
សូមឲ្យយើងរួបរួមគ្នា យើងសុទ្ធតែជាបងប្អូន ដោយមានព្រះយេស៊ូគ្រីស្ត
ព្រះអង្គទ្រង់ជាគំរូ ព្រះអង្គទ្រង់គង់ជាមួយ ទ្រង់ជួយឲ្យយើងស្រឡាញ់
អូ អូ អូ អូ អូ  អូ អូ អូ អូ  អូ អូ អូ អូ អូ ។

## ៣៩៧- អបអរសាទរឆ្នាំព្រះមហាករុណាធិគុណ

**អបអរសាទរចូលឆ្នាំមហាករុណាទិគុណឆ្នាំដ៏វិសុទ្ធ**
**ឆ្នាំសែនរីករាយដែលព្រះជាម្ចាស់ក្នុងក្ដីករុណាដ៏សែនលើសលប់ប្រទានឲ្យយើង**
**អបអរសាទរខួបពីរពាន់ឆ្នាំដែលព្រះបិតាចាត់ព្រះបុត្រាឲ្យ មករួមរស់ប្រោសលោះមនុស្ស**
**លោក ថែមទាំងប្រទានព្រះវិញ្ញាណវិសុទ្ធឲ្យគ្រប់គ្នា ។**

១- ចូរកោតសរសើរចូរលើកតម្កើង ចូរអរព្រះគុណព្រះធម៌មេត្តានៃព្រះជាម្ចាស់
ឆ្នាំសែនសប្បាយ ឆ្នាំដ៏វិសុទ្ធ ចូរយើងបើកចិត្ត ទទួលធម៌មហាមេត្តាករុណា
ពីព្រះជាម្ចាស់ ហើយចូរសម្ដែងចិត្តមេត្តាធម៌ចំពោះបងប្អូន
គ្រប់ជាតិគ្រប់សាសន៍ ។

២- ចូរកោតសរសើរចូរលើកតម្កើង ចូរអរព្រះគុណព្រះធម៌មេត្តានៃព្រះជាម្ចាស់
ឆ្នាំមហាករុណា ចូរយើងប្ដេជ្ញា ផ្សាយធម៌មេត្តា ផ្ដល់ក្ដីសង្ឃឹមដល់អ្នកមានទុក្ខ
អ្នកគេជិះជាន់ អ្នកជាប់ឃុំឃាំង អ្នកគ្មានទីពឹងជ្រះជ្រាសត្រូវ ឲ្យជានាគ្នា ។

៣- ចូរកោតសរសើរចូរលើកតម្កើង ចូរអរព្រះគុណព្រះធម៌មេត្តានៃព្រះជាម្ចាស់
ចូរកោតសរសើរ ចូរអរព្រះគុណ ព្រះម្ចាស់ត្រៃអង្គ ព្រះវរបិតាព្រះរាជបុត្រា
ព្រះវិញ្ញាណវិសុទ្ធ ដ្បិតធម៌មេត្តា ករុណាព្រះអង្គស្ថិតស្ថេរ
អស់កល្បរៀងរហូតអើយ ។

## ៣៩៨- "អប្បា!"

"អប្បា!" "អប្បា!" "អប្បា!"
បងប្អូន បានទទួល ព្រះវិញ្ញាណ
ដែលធ្វើ ឲ្យបងប្អូន ទៅជា បុត្រធីតា របស់ ព្រះជាម្ចាស់
ដោយសារ ព្រះវិញ្ញាណនេះ យើង បន្លឺសំឡេង ឡើងថា
"អប្បា!" "អប្បា!" "អប្បា!"

## ៣៩៩- អរគុណព្រះជាម្ចាស់ចំពោះលោកអភិបាលរបស់យើង

យើងទាំងអស់អញ្ជើញមក អរព្រះគុណព្រះជាម្ចាស់ ដល់លោកអភិបាល
យើងថែរក្សាកូនចៀមព្រះអម្ចាស់ ឲ្យយើងដើរតាមព្រះយេស៊ូគ្រីស្ត
យើងរួមចិត្តជាមួយលោកអភិបាល ដោយយើងស្រឡាញ់អស់បងប្អូន
ធ្វើតាមបន្ទូលរបស់ព្រះជាម្ចាស់ ។

## ៤០០- អាលេលូយ៉ា! ព្រះបន្ទូលជាពន្លឺ

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា**

១- ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលច្បាស់ថា៖ ខ្ញុំនេះហើយជាអាហារផ្តល់ជីវិត
អ្នកមករកខ្ញុំលែងឃ្លានទៀតឯអ្នកណាដែលជឿលើខ្ញុំ លែងស្រេកទៀតដែរ ។

២- ព្រះយេស៊ូគ្រីស្តជាគង្វាលដ៏ប្រសើរ! ព្រះអង្គស្គាល់ចៀមរបស់ព្រះអង្គ
ចៀមនោះក៏ស្គាល់ព្រះអង្គដែរ ព្រះអង្គបានស៊ូប្តូរព្រះជន្ម ដើម្បីចៀមព្រះអង្គ ។

៣- ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលច្បាស់ថា៖ ខ្ញុំទុកសេចក្តីសុខសាន្តឲ្យអ្នក
សេចក្តីសុខសាន្តខ្ញុំផ្តល់ឲ្យ មិនដូចសេចក្តីសុខសាន្តមនុស្ស កុំភ័យខ្លាចឡើយ ។

៤- ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលថា៖ វិន័យរបស់ខ្ញុំមានដូចតទៅ
គឺអ្នករាល់គ្នាស្រឡាញ់គ្នា ទៅវិញទៅមក ដូចខ្ញុំស្រឡាញ់អ្នករាល់គ្នា ។

៥- ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលថា៖ ខ្ញុំជាពន្លឺបំភ្លឺមនុស្សលោក
អ្នកណាតាមខ្ញុំនោះអ្នកមិន ដើរក្នុងសេចក្តីដែលងងឹត គឺពន្លឺនាំជីវិត ។

៦- ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលច្បាស់ថា ៖ ខ្ញុំហ្នឹងហើយប្រោសមនុស្សឲ្យ
រស់ឡើងវិញ អ្នកជឿលើខ្ញុំទោះបីស្លាប់ ក៏នឹងបានរស់ជាមិនខាន
ដ្បិតអ្នកបានជឿ ។

## ៤០១- អ្នកជឿដោយឥតបានឃើញខ្ញុំ

អ្នកជឿមកពីអ្នកបានឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ
អ្នកនោះមានសុភមង្គលហើយ អ្នកនោះមានសុភមង្គលហើយ ។

## ៤០២- អ្នកណាកាន់តាមព្រះបន្ទូលព្រះអង្គ

អ្នកណាដែលកាន់តាមព្រះបន្ទូលព្រះអង្គ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់
ពិតជាស្ថិតនៅនោះ អ្នកនោះគ្រប់លក្ខណៈ ។

## ៤០៣- អ្នកណាស្តាប់

អ្នកណាស្តាប់ អ្នកណាស្តាប់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់
អនុវត្តតាម អនុវត្តតាម អ្នកនោះហើយមានសុភមង្គលមែន ។

## ៤០៤- អ្នកណាអង្វររកព្រះនាម

១- អ្នកណាអង្វររកព្រះនាម រកព្រះនាមព្រះអម្ចាស់
អ្នកនោះនឹងបានទទួល ការសង្គ្រោះរបស់ព្រះអង្គ ។

២- ឲ្យគេអង្វររកព្រះអង្គ រកព្រះអង្គដូចម្តេចកើត
ព្រោះគេមិនទាន់បានជឿៗ ព្រោះគេមិនដែលឮពីព្រះបន្ទូល ។

៣- ឲ្យគេឮព្រះបន្ទូល ឮព្រះបន្ទូលយ៉ាងដូចម្តេចកើត
បើគ្មាននរណាប្រកាសៗ ឲ្យគេឮពីព្រះបន្ទូល ។

៤- ឲ្យមានអ្នកប្រកាស អ្នកប្រកាសយ៉ាងដូចម្តេចកើត
ព្រោះគ្មានអ្នកចាត់ឲ្យទៅ ប្រកាសបន្ទូលរបស់ព្រះអង្គ ។

៥- សូមព្រះអង្គចាត់យើងខ្ញុំ ចាត់យើងខ្ញុំឲ្យទៅប្រកាស
ឲ្យគេស្គាល់ព្រះនាមៗ ព្រះអម្ចាស់ជាព្រះសង្គ្រោះ ។

## ៤០៥- អំណរគុណក្នុងការត្រាស់ហៅ

១- សូមអរព្រះគុណព្រះជាម្ចាស់កូនប្រកាសស្ម័គ្រមួយជីវិត
ការត្រាស់ហៅក្នុងសេចក្ដីពិតដែលទ្រង់អាណិតប្រោសប្រទាន ។
ទាំងចិត្តកាយថ្វាយព្រះអង្គប្រាជ្ញាជូរជង់និងគំនិត
ស្មារតីស្ម័គ្រស្មោះអស់ពីចិត្តនេះជាជីវិតកូនប្រាថ្នា ។

**បន្ទរ-ព្រះអង្គស្រឡាញ់កូនខ្លាំងណាស់ ឱព្រះជាម្ចាស់កូនត្រេកអរ**
**ស្ម័គ្រប្រកាសផ្សាយដំណឹងល្អ សូមទ្រង់គង់នៅជាមួយកូន ។**

២- សូមទ្រង់បណ្ដុះភាពក្រខ្សត់ទាំងទ្រព្យសម្បត្តិទាំងស្មារតី
ភាពក្រនាំចិត្តកូនភក្ដីបម្រើម្ចាស់ថ្លៃដោយអំណរ ។
សូមទ្រង់ប្រទានភាពសាមញ្ញមិនឈ្នះមិនចាញ់មិនវៀចវេរ
សាមញ្ញនាំកូនឥតងាករេឆ្ពោះត្រង់ទៅរកព្រះជាម្ចាស់ ។

៣- សូមទ្រង់បង្ហូរភាពសប្បុរសធ្វើអ្វីទាំងអស់មិនគិតថ្លៃ
មិនវាស់មិនរាប់មិនកេងគែបម្រើបងប្អូនគ្រប់ទិសទី ។
កូនសូមទូលអង្វរព្រះអង្គកូនសូមយកទ្រង់ជាទីពឹង
មានព្រះរូបកូនមានលំនឹងជីវិតទាំងស្រុងថ្វាយព្រះអង្គ ។

## ៤០៦- អំបិល និងពន្លឺ

**អំបិល ពន្លឺ (២ដង)**

អ្នករាល់គ្នាជាអំបិលសម្រាប់មនុស្សលោក អ្នករាល់គ្នាជាពន្លឺ
សម្រាប់បំភ្លឺមនុស្សលោក ។ (**២ដង**)

## ៤០៧- អុះឱប្រជាជនទាំងឡាយ

| | | |
|---|---|---|
| ១- អុះឱប្រជាជនទាំងឡាយ | ព្រះជាម្ចាស់បានត្រាស់ហៅយើង | |
| ឲ្យសម្តែងធម៌មេត្តា | ករុណាចំពោះមនុស្សទាំងឡាយ | |
| ចូរទៅគ្រប់ទីកន្លែង | ក្នុងពិភពលោកទាំងមូល | |
| ហើយប្រព្រឹត្តអំពើនោះ | ដោយសច្ចៈយុត្តិធម៌ | ។ |
| **បន្ទរ- ទោះជាមានឧបសគ្គ** | **កុំអួលអាក់កុំភ័យព្រួយ** | |
| **មានព្រះម្ចាស់គង់ជាមួយ** | **ព្រះអង្គជួយថែរក្សា** | **។** |

## ៤០៨- “ឱព្រះបិតាអើយ!”

“ឱព្រះបិតាអើយ! សូមអាណិតអាសូរ កូនដែលជាអ្នកបាប សូមអាណិតកូនផង”

## ៤០៩- ឱ ! ព្រលឹងខ្ញុំ ចូរក្រាបបង្គំ

បន្ទរ-ឱ! វិញ្ញាណខ្ញុំ ចូរក្រាបបង្គំសរសើរព្រះជាម្ចាស់ ឱ! ខ្លួនប្រាណខ្ញុំចូរនឹកព្រះជាម្ចាស់
គោរពសំពះសរសើរព្រះអង្គ គោរពសំពះសរសើរព្រះអង្គ ។

១- ព្រះជាម្ចាស់រំដោះ ឲ្យខ្ញុំរួចអស់ ពីក្ដីសៅហ្មង ឲ្យរួចពីស្លាប់
អំពើឆ្គាំឆ្គង ខុសព្រះបំណង ទ្រង់តែងមេត្តា ។
ទ្រង់តែងសម្រេច បំណងដូចម្ដេច ដែលខ្ញុំប្រាថ្នា ទ្រង់ឲ្យខ្ញុំមាន
កម្លាំងខ្លាំងក្លា ព្រមទាំងកាយា មាំមួនបវរ ។

២-ព្រះជាម្ចាស់លោកីយ៍ ទ្រង់មានហប្ញទ័យ សប្បុរសអស្ចារ្យ ទ្រង់តែងសន្ដោស
ប្រណីករុណា ដល់ជនលោកា ពុំដែលក្រោធឡើយ ។
ព្រះម្ចាស់ពុំធ្វើ តបនឹងអំពើ ដែលយើងធ្វើហើយ មិនផ្ដន្ទាទោស
តាមកំហុសឡើយ យើងមិនកន្តើយ សូមក្រាបវន្ទា ។

៣-ផ្ទៃមេឃទូលាយ ធំធេងខ្ពស់ឆ្ងាយ ពីផែនពសុធា រីឯហប្ញទ័យ
ដែលទ្រង់មេត្តា ធំឥតឧបមា ដូចមេឃនិងដី ។
ឪពុកម្ដាយមានចិត្ត អាសូរអាណិត កូនចៅយ៉ាងណា ព្រះម្ចាស់ស្រឡាញ់
អស់ជនលោកា ដែលកោតបេស្ដា ក៏យ៉ាងដូច្នោះ ។

## ៤១០- ឱ ! មនុស្សអើយ

(មីកា ៦,៨)

១- ឱ ! មនុស្សអើយ (**២ដង**) គេបានប្រៀនប្រដៅ
ប្រៀនប្រដៅអ្នកឲ្យស្គាល់ការល្អ ។

២- ព្រះអម្ចាស់ (**២ដង**) សព្វព្រះហប្ញទ័យ (**២ដង**) ឲ្យអ្នកតាមយុត្តិធម៌

៣- សេចក្ដីស្រឡាញ់ភាពស្មោះត្រង់ (**២ដង**)
យកចិត្តទុកដាក់តាមមាគ៌ានៃព្រះរបស់អ្នក ។

# ៤១១- ទំនុកតម្កើងរបស់នាងយូឌីត

(បទពាក្យ ៨)

១- ឱ ! ព្រះជាម្ចាស់យើងខ្ញុំគោរព រាល់ពេលថ្ងៃយប់យើងសូមបង្គំ
ព្រោះទ្រង់ពិតជាមានឫទ្ធិឧត្តម រុងរឿងសុខុមល្បីល្បាយខ្ពង់ខ្ពស់ ។

២- យើងសូមច្រៀងថ្វាយបទចម្រៀងថ្មី សូមទ្រង់ប្រណីហើយជួយរំដោះ
នេះពិតចម្រៀងសូរសៀងពិរោះ យើងច្រៀងដោយស្មោះអស់ពីដួងចិត្ត ។

៣- តេជានុភាពខ្ពង់ខ្ពស់ពេកក្រៃ សិរីជោគជ័យរុងរឿងពេកពិត
ឈ្នះសត្រូវផងទាំងឆ្ងាយទាំងជិត ពុំអាចស្មេរស្និតជិតព្រះដំណើរ ។

៤- ព្រះម្ចាស់បង្កើតសត្វលោកទាំងឡាយ ចូរមកក្រាបថ្វាយបង្គំបម្រើ
ចូរគាល់ព្រះអង្គទាំងកោតសរសើរ ដល់រាជដំណើរដ៏សុខក្សេមក្សាន្ត ។

៥-ទ្រង់មានបន្ទូលតែមួយព្រះឱស្ឋ នោះសត្វលោកផុសកើតឡើងភ្លាមបាន
អ្នកដែលកោតខ្លាចទ្រង់តែងប្រោសប្រាណ រក្សាឲ្យបានជីវិតគង់វង្ស ។

៦- សក្ការបូជាពុំអាចមកផ្ទឹម ស្មើក្តីសង្ឃឹមអ្នកខ្លាចព្រះអង្គ
អ្នកដែលកោតខ្លាចទ្រង់មិនបោះបង់ ទុកបោលឲ្យលង់នៅលើលោកា ។

៧-សូមជួយយើងឲ្យរួចពីសត្រូវ ដែលរារាំងផ្លូវនៃយើងរាល់គ្នា
ព្រះម្ចាស់នាំយើងឲ្យស្គាល់មាគ៌ា ទៅកាន់វិមាននៃស្ថានបរមសុខ ។

៨- ឱ ! ព្រះបិតាយើងសូមថ្វាយពរ និងថ្វាយអំណរដល់ព្រះឯកបុត្រ
និងព្រះវិញ្ញាណមានឫទ្ធិបំផុត ល្បីល្បាញវិសុទ្ធអស់កាលជានិច្ច ។

# ៤១២- ទំនុកតម្កើងរបស់លោកម៉ូសេ

(បទពាក្យ ៧)

១- ឱ ! ផ្ទៃមេឃអើយសូមស្ដាប់ខ្ញុំ ថ្លាថ្លែងពោលជម្រាបដំណឹង
ទាំងផែនដីផងសូមប្រៀបប្រុង ត្រចៀកត្រាប់ត្រង់ស្ដាប់ខ្ញុំពោល ។

២- ពាក្យប្រៀនប្រដៅខ្ញុំប្រៀបបាន នឹងភ្លៀងឥតស្រាន្តឈើដុះថ្កោល
បណ្ដាំខ្ញុំដូចទឹកសន្សើម ដូចភ្លៀងរលឹមស្មៅលាស់លា ។

៣- ចូរយើងតម្កើងឡើងឲ្យខ្ពស់ នាមព្រះអម្ចាស់អ្នករាល់គ្នា
អ៊ីស្រាអែលអើយតោងស្គាល់ថា ព្រះអង្គមហាខ្ពង់ខ្ពស់ក្រៃ ។

៤- ព្រះអម្ចាស់ប្រៀបបាននឹងថ្ម សិលាបវរមាំប្រពៃ
ទ្រង់ពិចារណារិះគិតថ្លៃ កិច្ចការអ្វីៗទ្រង់ប្រព្រឹត្ត ។
បានល្អប្រសិទ្ធពេញលក្ខណៈ ថ្លៃប្រសើរជាក់គ្មានរខិត
ព្រះអង្គសម្រេចសុទ្ធវិចិត្រ ត្រឹមត្រូវល្អពិតឥតថ្កោលបាន ។

៥- តែអ្នករាល់គ្នាជាមនុស្សខិល ខូចទាស់របិលចិត្តសាមាន្យ
បង្អាប់ព្រះនាមថ្លៃកល្យាណ លែងបានជាបុត្រធីតាហោង ។

៦- ជនលីលាឥតប្រាជ្ញាអើយ ម្ដេចធ្វើរំភើយមិនគិតសង
គុណព្រះអង្គថ្លៃពេកកន្លង តោងគិតជួរជ្លងនឹកគយគន់ ។

៧- ចូរនឹកចាំពីសម័យចាស់ បុរាណប្ដូរផ្លាស់កុំនឹកស្មាន
ចូរសួរម៉ែឪពុកមើលតាមដាន ឲ្យគាត់និទានប្រាប់សព្វគ្រប់ ។

៨- និទានអំពីព្រះខ្ពង់ខ្ពស់ ព្រះនាមពិរោះទាំងថ្ងៃយប់
ទ្រង់ចែកដែនដីឲ្យគេទប់ លើកភ្លឺទំនប់ស្រែចម្ការ ។

និទានអំពីព្រះអង្គញែក មនុស្សខ័ណ្ឌចែកដាច់ពីគ្នា
អំពីព្រះអង្គគូសសីមា ព្រំដែនខ័ណ្ឌខាមិនឡូកឡំ ។
ព្រះអង្គប្រទានតាមចំនួន ឲ្យសមបានសួនមិនបង្ខំ
គ្នាតិចឲ្យតិចមិនបន្លំ គ្នាច្រើនឧត្តមឲ្យល្ហឹងល្ហើយ ។

៩- តែព្រះអម្ចាស់ជ្រើសត្រកូល យ៉ាកុបបណ្ដូលមិនព្រងើយ
ធ្វើជាប្រជាជនផ្ទាល់ហើយ ទ្រង់ការពារគេឲ្យសុខសាន្ត ។

១០-ព្រះអម្ចាស់ទ្រង់បោលព្រះនេត្រ ឃើញពាសរកេតរហោស្ថាន
រកួតពាសវាលដូចគិរិប្ពាន វេទនាឥតបានសុខជួបជុំ ។
តែព្រះអង្គថែរក្សាគេ ចំនួនឡើងទ្វេទ្រង់អប់រំ
ការពារក្រសោបឱបគ្រលំ បីដូចដួងកែវព្រះនេត្រា ។

១១- ព្រះអង្គការពារ និងណែនាំ ឲ្យដើរត្រង់ចំផ្លូវសាស្ដា
ដូចសត្វឥន្ទ្រីជាបក្សា ត្រដាងស្លាបបាំងកូនកល្យាណ ។

១២-មានតែព្រះម្ចាស់មួយព្រះអង្គ ព្រះហស្តខែងខ្លាំងណែនាំបាន
គ្មានព្រះឯណាមកប្រទាន ឲ្យគេសុខសាន្តដូចព្រះម្ចាស់ ។

១៣- ឱ ! ជនជាតិអ៊ីស្រាអែលអើយ អ្នកធ្វើព្រងើយឆាប់ភ្លេចណាស់
បំភ្លេចសិលាគួរអាម៉ាស់ មិនគួរច្នេះសោះអ្នកកម្សត់ ។
១៤- ព្រះអម្ចាស់ទតឃើញដូច្នេះ ទ្រង់ព្រះតម្រិះខំទប់អត់
ទ្រាំមិនបានខ្ញាល់ឡើងញ័រមាត់ ដេញកម្ចាយអត់ឥតមានសល់ ។

១៥- ព្រះអង្គមានព្រះបន្ទូលថា យើងលែងការពារទាំងលែងខ្វល់
យើងចាំមើលគេនឹងរបល់ កើតទុក្ខអំពល់ឬយ៉ាងណា ។
ពួកនេះមានចិត្តមិនស្មោះត្រង់ វៀចវេរខ្វេខ្វង់ឥតឧបមា
ទុកចិត្តមិនបានគ្មានខ្លឹមសារ កូនឥតបានការសែនចង្រៃ ។

១៦- គេមើលងាយយើងទៅគោរព　　បម្រើសព្វគ្រប់ព្រះក្លែងក្លាយ
ឆ្លាក់រូបធ្វើព្រះមកកៀកកាយ　　ទុកបង្គំថ្វាយលុតឱនក្រាប ៕
ដូច្នេះយើងនឹងមើលងាយគេ　　ឥតមានរារេវាយស្រប៉ាប
ឲ្យគេដួលដេករេស្រប៉ាប　　ដោយប្រើពួកទាបទៅវាយជួស ៕
ប្រើអ្នកលល្ងង់ខ្លៅវាយកម្ទេច　　ចាប់វាយចាប់ញេចស្លាប់របួស
ដាក់ទោសឲ្យធ្ងន់ឥតស្រណោះ　　ធ្វើបាបទាំងអស់ឥតប្រណី ៕

១៧- យើងនឹងបំផ្លាញឲ្យម៉ដ្ឋខៃ　　វិនាសក្សិណក្ស័យពីដែនដី
កុំឲ្យសល់ម្នាក់ទោះប្រុសស្រី　　កុំឲ្យអ្នកណានឹកឃើញឡើយ ៕

១៨- តែម៉្យាងនឹកខ្លាចខ្មាំងសត្រូវ　　យល់ឃើញខុសផ្លូវមិនកន្តើយ
បែរមើលងាយយើងធ្វើព្រងើយ　　ហើយវាពោលថាពួកវាខ្លាំង ៕
វាថាវាប្រើពលវាផ្ទាល់　　វាយឈ្នះបានផលក្នុងចម្បាំង
គ្មានព្រះឯណាជួយតតាំង　　ប្រគល់ពួកនេះឲ្យវាទេ ៕

១៩- ជនជាតិអ៊ីស្រាអែលវង្វេង　　ស្មារតីភ្លាត់ភ្លាំងពីបុព្វេ
មោហ៍បាំងបិទជិតដើររារេ　　មិនអាចយល់ទេប្រទ្បំភ័ន្ត ៕

២០- បើខ្មាំងតែម្នាក់ដេញកម្ចាត់　　អ៊ីស្រាអែលរត់បោលវាល់ពាន់
បើខ្មាំងពីរនាក់មកជិះជាន់　　អ៊ីស្រាអែលម៉ឺននាក់ជាស់ក្រញាំ ៕
នេះមកពីដុំសិលាការ-　　ពារពួកគេថាលក់ប្រចាំ
សិលាបញ្ជូនឈប់ថែទាំ　　ឲ្យខ្មាំងចិញ្ចាំតាមចិត្តគេ ៕

២១- តែព្រះអង្គមានការសម្ងាត់　　ទ្រង់នឹងកម្ចាត់ខ្មាំងរិះរេ
ខ្មាំងត្រូវអន្តរាយស្លាប់ជាសដេរ　　មានទុក្ខត្រូវវេទនាក្រៃ ៕

២២- ដ្បិតព្រះអម្ចាស់ទ្រង់អាសូរ　　ប្រជាជនថ្ងូរទ្រង់វិនិច្ឆ័យ
អាណិតបម្រើមិនឲ្យក្ស័យ　　ទោះមានទោសពៃរ៍ទ្រង់សន្តោស ៕

២៣- ចូរអ្នករាល់គ្នាទទួលស្គាល់ កុំនឹកពិភាល់ត្រូវជាខុស
គឺយើងនេះហើយប្រណីប្រោស ជាព្រះអម្ចាស់តែមួយគត់ ។
គ្មានព្រះឯណាក្រៅពីយើង បំផ្លាញរំលើងតែអត់ធ្មត់
ប្រទានជីវិតមិនឲ្យខ្សត់ របួសប្រាកដថែឲ្យជា ។

២៤- យើងសំលៀងដាវបម្រុងជាប់ វិនិច្ឆ័យកាប់កប់មនុស្សម្នា
ដែលហ៊ានប្រឆាំងចិត្តពាលា យើងមិនរុញរាធ្វើបាបធ្ងន់ ។

## ៤១៣- ទំនុកតម្កើងលេខ ២៣ (២២)

(បទកាកគតិ)

១- ព្រះអង្គទ្រង់ប្រោស មេត្តាសន្ដោស គ្មានលោះមួយគ្រា ទ្រង់បានប្រទាន
នូវភោជន៍អាហារ ឲ្យខ្ញុំសុខា នៅក្បែរព្រះអង្គ ។

២- ព្រះអង្គទ្រង់ជួយ ណែនាំលើកស្ទួយ និងជួយតម្រង់ តាមគន្លងធម៌
ដ៏ល្អត្រចង់ ព្រះនាមព្រះអង្គ បានល្បីថ្កើងថ្កាន ។

៣- ទោះបីរូបខ្ញុំ ជួបអន្តរាយធំ ទាំងអម្បាលម៉ាន ក៏មិនខ្លាចដែរ
ដ្បិតរូបខ្ញុំមាន ព្រះជួយឲ្យបាន សុខសាន្តនិរន្តរ៍ ។

៤- ខ្ញុំសែនរីករាយ ក្រាបបង្គំថ្វាយ ថ្លែងអំណរគុណ ដ្បិតទ្រង់ប្រទាន
ឲ្យឈ្នះទុរជន ជានិច្ចនិរន្តរ៍ គ្រប់កាលទាំងអស់ ។

៥- ព្រះអង្គតែផ្ដល់ សុភមង្គល ដោយក្ដីសប្បុរស ខ្ញុំសូមគោរព
បម្រើដោយស្មោះ រហូតដល់អស់ អាយុសង្ខារ ។

៦- រាល់ពេលថ្ងៃយប់ ខ្ញុំជ្រកក្រោមម្លប់ នៃព្រះបេស្ដា ក្រោមព្រះបារមី
ប្រណីមេត្តា វិសេសថ្លៃថ្លា របស់ព្រះអង្គ ។

៧- សិរីជោគជ័យ បវរសួស្ដី រុងរឿងត្រចង់ សូមថ្វាយបង្គំ
ឆ្ពោះព្រះត្រៃអង្គ ទ្រង់គង់យូរលង់ អស់កល្បជានិច្ច ។

## ៤១៤- ទំនុកតម្កើងលេខ ៣៤ (៣៣)

(បទពាក្យ ៨)

១- ខ្ញុំសូមលើកតម្កើងតម្កល់ កោតសរសើរដល់ព្រះម្ចាស់លោកា
ហើយមាត់ខ្ញុំពោលសរសើរចេស្ដា រាល់ពេលវេលាជារៀងដរាប ។

២- ចិត្តខ្ញុំតម្កើងព្រះជាម្ចាស់ សូមឲ្យឮច្បាស់ដល់អ្នកសុភាព
និងបានសប្បាយរីករាយដរាប បានជ្រួតជ្រាបពីព្រះប្ញទ្ធា ។

៣- សូមអរសាទរថ្វាយព្រះអម្ចាស់ ប្រសើរក្រៃណាស់នៅលើលោកា
ចូរអរសាទរនឹងយើងរាល់គ្នា តម្កើងនាមារបស់ព្រះអង្គ ។

៤- ខ្ញុំខំស្វែងរកព្រះម្ចាស់លោកា ហើយទ្រង់មេត្តាបំពេញបំណង
ទ្រង់រំដោះខ្ញុំពីក្ដីសៅហ្មង និងអន្តរាយសព្វគ្រប់ប្រការ ។

៥- អស់អ្នកជឿជាក់លើព្រះអង្គ សង្ឃឹមលើទ្រង់រាល់ពេលវេលា
និងត្រេកអរសប្បាយក្នុងដួងចិន្តា គ្មានអ្វីដែលថាគួរខ្មាសអៀនឡើយ ។

៦- ទ្រង់ព្រះសណ្ដាប់អ្នកទុរគត ជនដែលកម្សត់រស់គ្មានកោះត្រើយ
ទ្រង់ជួយរំដោះឲ្យបានល្ហែល្ហើយ ឲ្យជាសះស្បើយពីទុក្ខទាំងឡាយ ។

៧- ព្រះជាម្ចាស់ទ្រង់ជួយការពារ និងជួយរក្សាឲ្យបានសប្បាយ
ចំពោះអស់អ្នកទាំងពួងទាំងឡាយ ដែលកោតថ្វាត់ថ្វាយគោរពព្រះអង្គ ។

៨- ចូរពិចារណាថាព្រះជាម្ចាស់ សប្បុរសពេកណាស់បរិសុទ្ធឥតហ្មង
អស់អ្នកដែលពឹងផ្អែកលើព្រះអង្គ បានសុខកន្លងឥតក្ដីទុក្ខា ។

៩- ឱ ! ប្រជារាស្ត្រនៃព្រះជាម្ចាស់ ចូរក្រាបសំពះដោយស្មោះចិន្តា
ដ្បិតអ្នកគោរពកោតព្រះចេស្ដា ពុំដែលទុក្ខាខ្វះខាតអ្វីឡើយ ។

១០- អ្នកមានយសស័ក្តិសម្បត្តិហូរហៀរ គង់ស្គាល់វេទនាបារម្ភឥតស្បើយ
តែអ្នកស្វែងរកព្រះអង្គជាត្រើយ ឥតខ្វះអ្វីឡើយហើយតែងក្សេមក្សាន្ត ។

១១- កូនចៅទាំងឡាយចូរប្រុងសោតា ចាំស្តាប់វាចាជាដំបូន្មាន
ចូរកោតគោរពព្រះប្រាជ្ញាញាណ បើសិនចង់បានសុភមង្គល ។

១២- ចូរកុំពោលពាក្យកុហកមុសា អំពើពាលាធម៌អកុសល
ចូរធ្វើអំពើប្រសើរនិមល ស្វែងរកមង្គលគឺសុខក្សេមក្សាន្ត ។

១៣- ព្រះជាអម្ចាស់ពុំសព្វហឫទ័យ នឹងជនអប្រិយ៍ទុយ៌សសាមាន្យ
ដ្បិតក្តីអាក្រក់នឹងនាំឲ្យបាន វិនាសចាកស្ថានសាបសូន្យអសារ ។

១៤- ព្រះជាអម្ចាស់ទ្រង់សព្វហឫទ័យ នឹងជនប្រុសស្រីដែលមានចិន្តា
ភក្តីស្មោះត្រង់សុភាពរាបសា ហើយទ្រង់មេត្តាសណ្តាប់អ្នកនោះ ។

១៥- ទ្រង់ព្រះសណ្តាប់ពាក្យជនស្មោះសរ ដែលតែងអង្វរសូមក្តីសន្តោស
ហើយព្រះជាម្ចាស់ទ្រង់ជួយរំដោះ ឲ្យរួចបាបគ្រោះចាកផុតទុក្ខា ។

១៦- ព្រះអង្គគង់ជិតអ្នកដែលលំបាក ក្រីក្រតោកយ៉ាកហើយទ្រង់តែងជួយ
ជនអស់សង្ឃឹមឲ្យបាត់ភ័យព្រួយ ដោយទ្រង់លើកស្ទួយឲ្យបានក្សេមក្សាន្ត ។

១៧- មនុស្សទៀងត្រង់មានទុក្ខលំបាក ដែលបានរួចចាកដោយទ្រង់ប្រទាន
រំដោះការពាររូបកាយអង្គប្រាណ ដោយមិនឲ្យមានគ្រោះថ្នាក់ឡើយណា ។

១៨- អំពើអាក្រក់តែងនាំមក នូវភាពជយជោកឥតឧបមា
អ្នកដែលស្អប់ជនសុភាពរាបសា ត្រូវមានទោសវិនាសបាត់បង់ ។

១៩- ព្រះជាម្ចាស់សង្គ្រោះជនណា ដែលក្រាបវន្ទាបម្រើព្រះអង្គ
អ្នកដែលពឹងផ្អែកដោយក្តីស្មោះត្រង់ ពុំវិនាសបង់គ្មានទុក្ខទោសា ។

២០- សូមលើកតម្កើងសិរីរុងរឿង តេជះបារមីឆ្ពោះព្រះបិតា
ឫទ្ធិរុងរឿងឆ្ពោះព្រះបិតា ព្រមទាំងបេស្តាឆ្ពោះព្រះវិញ្ញាណ ។

# ៤១៥- ទំនុកតម្កើងលេខ ៥១ (៥០)

(បទ កាកគតិ)

១- ឱ ! ព្រះជាម្ចាស់ ប្រសើរពេកណាស់ ដោយធម៌មេត្តា សូមទ្រង់អាណិត
លើកលែងទោសា ឲ្យខ្ញុំជងណា ដោយអនុគ្រោះ ។
សូមទ្រង់ឧបត្ថម្ភ ចិត្តគំនិតខ្ញុំ ឲ្យបានខ្ពង់ខ្ពស់ ឲ្យបានបរិសុទ្ធ
ផុតបាកបាបគ្រោះ រួចពីទុក្ខទោស សព្វគ្រប់ប្រការ ។

២- ខ្ញុំសូមសារភាព នូវអំពើបាប តូចធំយ៉ាណា ហើយតែងនឹកចាំ
រាល់ទិនទិវា បាបគ្រប់ប្រការ ដែលខ្ញុំប្រព្រឹត្ត ។
ទាំងការអាក្រក់ អំពើលាមក ឬក្តីទុច្ចរិត ដែលខ្ញុំបានធ្វើ
នឹងបានប្រព្រឹត្ត ជាកំហុសពិត ចំពោះព្រះភក្ត្រ ។

៣- ទ្រង់វិនិច្ឆ័យ ព្រមទាំងកាត់ក្តី ដោយធម៌សច្ចៈ ចំពោះបាបកម្ម
ដែលខ្ញុំជំពាក់ ពីអតីតៈ ដោយយុត្តិធម៌ ។
ទ្រង់សព្វហឫទ័យ នឹងជនប្រុសស្រី មានចិត្តស្មោះសរ សូមទ្រង់ទូន្មាន
នូវសច្ចធម៌ ឲ្យស្គាល់ផ្លូវល្អ នៅក្នុងលោកីយ៍ ។

៤- សូមទ្រង់កម្ចាត់ ព្រមទាំងបំបាត់ អំពើអប្រិយ៍ សូមឲ្យរូបខ្ញុំ
ប្រាសបាកទុក្ខភ័យ អស់គ្រោះចង្រៃ ស្គាល់ក្តីភិរម្យ ។
សូមទ្រង់មេត្តា លើកលែងទោសា របស់រូបខ្ញុំ សូមទ្រង់រំដោះ
ឲ្យបានសុខុម ហើយសូមទ្រង់កុំ បោះបង់ចោលខ្ញុំ ។

៥- ឱ ! ព្រះជាម្ចាស់ សូមទ្រង់ជម្រះ ចិត្តគំនិតខ្ញុំ ឲ្យស្អាតបរិសុទ្ធ
ហ្មត់ចត់សុខុម អង់អាចឧត្តម មាំមួនជរាប ។

សូមព្រះអង្គកុំ បោះបង់រូបខ្ញុំ ជាជនទន់ទាប ឲ្យឃ្លាតចេញឆ្ងាយ
ដូចអ្នកមានបាប សូមរស់ជរាប ក្បែរព្រះឧត្តម ។

៦- ឱ ! ព្រះវិញ្ញាណ វិសុទ្ធថ្កើងថ្កាន ថ្លៃថ្លាឧត្តម សូមទ្រង់មេត្តា
កុំបាកបោលខ្ញុំ ឲ្យនៅក្រៀមក្រំ តែឯងឯកា ។
សូមទ្រង់ប្រទាន ឲ្យរូបខ្ញុំមាន សទ្ធាជ្រះថា ឲ្យបានសប្បាយ
រីករាយចិន្តា ដោយទ្រង់មេត្តា សង្គ្រោះគាំទ្រ ។

៧- ខ្ញុំនឹងណែនាំ អ្នកមានបាបកម្ម ឲ្យស្គាល់ផ្លូវល្អ ជួយអ្នកវង្វេង
ឲ្យវិលមករក នូវគន្លងធម៌ របស់ព្រះអង្គ ។
ឱ ! ព្រះសង្គ្រោះ សូមជួយរំដោះ កុំបីលះបង់ ខ្ញុំនឹងប្រកាស
ហឫទ័យព្រះអង្គ ដែលជួយស្រោចស្រង់ ដោយចិត្តសប្បុរស ។

៨- ឱ ! ព្រះជាម្ចាស់ ព្រះអង្គជាព្រះ ដែលតែងសង្គ្រោះ សូមឲ្យរូបខ្ញុំ
និងមនុស្សទាំងអស់ បេះកោតដោយស្មោះ ឆ្ពោះព្រះនាមា ។
ព្រះម្ចាស់លោកីយ៍ ពុំសព្វហឫទ័យ នឹងយញ្ញបូជា តែទ្រង់តែងសព្វ
ព្រះហឫទ័យា នូវក្ដីសោកា របស់ខ្ញុំវិញ ។

៩- ព្រោះដ្បិតព្រះអង្គ ពុំដែលបោះបង់ ជនដែលពោរពេញ ដោយក្ដីសោកា
ឱរាទោម្នេញ ដោយចិត្តពោរពេញ ដោយបាបតូចធំ ។
សូមប្រោសប្រទាន ឲ្យកូនចៅបាន សុខសាន្តភិរម្យ ម្យ៉ាងទៀតសូមឲ្យ
ព្រះសហគមន៍ លូតលាស់ថ្កើងថ្កុំ មានជោគជ័យា ។

១០-សូមថ្លែងជោគជ័យ ដ៏អស្ចារ្យក្រៃ នៃព្រះបិតា សូមកោតបារមី
នៃព្រះបុត្រា សូមកោតចេស្ដា នៃព្រះវិញ្ញាណ ។

## ៤១៦- ទំនុកតម្កើងលេខ ៥១ (៥០)

(លំនាំបទថ្មី)

១- ឱ ! ព្រះអម្ចាស់សូមព្រះអង្គ បង្គំទូលត្រង់សូមមេត្តា
អាណិតអាសូរករុណា កុំខ្ញាល់សម្បាសូមលើកលែង
កុំបោទប្រកាន់ចាប់ថ្នាក់ខឹង ហឫទ័យតានតឹងនាំចម្បែង
ទោសបង្គំមានសូមទ្រង់បែង ចាប់បោលគ្រវែងកុំឲ្យសល់ ។

២- សូមព្រះអង្គទ្រង់ជម្រះចិត្ត ឫកពាគំនិតខ្ញុំឲ្យដល់
ទីល្អបានស្អាតផុតប្រឡប់ ផុតពីបាបគ្រោះគ្រប់បែបយ៉ាង
ខ្ញុំសូមទទួលស្គាល់បាបកម្ម ថែមទាំងនឹកចាំដែលខ្ញុំសាង
កំហុសទោសនោះថ្មីស្រឡាង នឹកឃើញជានិច្ចឥតភ្លេចទេ ។

៣- ខ្ញុំបានធ្វើអំពើបាបខុស ឆ្គំឆ្គងទើសទាស់ឥតមានល្ហែ
ទាស់ព្រះហឫទ័យឥតងាករេ អំពើខ្ញុំនោះទ្រង់សែនខ្ញាល់
បើព្រះអង្គទ្រង់វិនិច្ឆ័យ ដាក់ទោសដល់ក្ស័យអស់កប្បកល្ប
ឬផ្ដន្ទាធ្ងន់កុំភ័យប្រាល គឺទ្រង់ធ្វើតាមយុត្តិធម៌ ។

៤- ទ្រង់សព្វហឫទ័យនឹងមនុស្សទៀង ត្រង់ស្មើឥតល្អៀងអស់ពីចិត្ត
សូមប្រៀនឲ្យខ្ញុំកែគំនិត ប្រដៅឲ្យមានប្រាជ្ញាឆ្លាត
សូមទ្រង់នាំខ្ញុំលាងជម្រះ ឲ្យភ្លឺត្រចះបរិសុទ្ធស្អាត
កំហុសទាំងឡាយសូមបំបាត់ ឲ្យខ្ញុំស្អាតជាងសំឡី ។

៥- សូមព្រះអង្គកុំបោះបង់បោល ឲ្យខ្ញុំតែងតោលរស់ឥតន័យ
ឆ្ងាយពីព្រះអង្គទៅទីទៃ រងទុក្ខរងភ័យគ្មានទីពឹង

សូមព្រះវិញ្ញាណដ៏វិសុទ្ធ ថ្លៃថ្លាបំផុតសភ្លឺភ្លឹង
សូមកុំបាកចេញបោលព្រលឹង រូបកាយខ្ញុំម្ចាស់នោះសោះឡើយ ។

៦- ឱ ! ព្រះអម្ចាស់ខ្ញុំអើយ គឺព្រះអង្គហើយនាមវន្ទី
ប្រទានឲ្យខ្ញុំមានពន្លឺ ដូចរួចពីឈឺមានចិត្តថ្លា
សូមព្រះអង្គជាប់ដំពង្រឹង ចិត្តខ្ញុំឲ្យនឹងដូចថ្មដា
រឹងប៉ឹងមាំមួនអស់ក្រឡា ហាំហែងអស្ចារ្យថ្លាប្រពៃ ។

៧- សូមទ្រង់ប្រទានឲ្យខ្ញុំបាន អំណរក្សេមក្សាន្តពេញសប្បាយ
សង្គ្រោះប្រណីកុំឲ្យឆ្ងាយ ឲ្យខ្ញុំនៅអោយជាប់អែបអង្គ
សូមគាំទ្រខ្ញុំឲ្យមានចិត្ត សទ្ធាអាណិតជ្រះថ្លាយង់
ឲ្យមានចិត្តច្រើនចេះតែចង់ សន្តោសធ្វើល្អកុំបីឃ្លាត ។

៨- ឱ ! ព្រះជាអម្ចាស់អើយហោង សូមទ្រង់ឃើតយោងឲ្យស័ក្តិសម
ឲ្យខ្ញុំចេះពោលពាក្យថ្នាក់ថ្នម ចេះកោតសរសើរព្រះអម្ចាស់
ព្រះអង្គពុំសព្វព្រះហឫទ័យ នឹងឲ្យខ្ញុំធ្វើយញ្ញសក្ការៈ
បូជាតិចតួចឬច្រើនក្រាស់ ព្រះអង្គពុំត្រាស់ទទួលយក ។

៩- សក្ការបូជាដែលពេញគាប់ ហឫទ័យនឹកជាប់គឺចិត្តជោក
ជាំចេះខ្លោចផ្សា និងចេះសោក ស្តាយបាបកម្មដែលខ្លួនបានធ្វើ
ព្រះអង្គពុំលះបង់បោលទេ អ្នកដែលរិះរេគិតអំពើ
អកុសលជងសព្វអន្លើ ផតវាទីទើទុកជិតកាយ ។

១០- ពេលនោះព្រះអង្គនឹងសព្វព្រះ ហឫទ័យស្ម័គ្រស្មោះនិងពោរពេញ
អំណរទទួលសក្ការៈវិញ សព្វគ្រឿងបូជាតាមវិន័យ
ទ្រង់ព្រមទទួលទាំងតង្វាយ សត្វដុតទាំងឡាយបានបញ្ចេញ
ក្លិនឈ្ងុយឈ្ងប់ផុំក្លិនឈ្ងុយឆ្ងាញ់ ពីតុសក្ការៈព្រះអង្គ ។

## ៤១៧- ទំនុកតម្កើងលេខ ៦៧ (៦៦)

(បទពាក្យ ៧)

១- សូមព្រះជាម្ចាស់ទ្រង់អាណិត អាសូរស្នោះពិតបង្ហាញធម៌
មេត្តាករុណាប្រទានពរ យកពាក្យអង្វររបស់យើង ។

២- ដូច្នេះមនុស្សលោកលើផែនដី ទាំងមូលឃ្លាតខ្ចីឥតបីឆ្មើង
នឹងបានយល់កាន់តែច្បាស់ឡើង របៀបព្រះអង្គប្រណីប្រោស ។

៣- សូមប្រជាជនទាំងឡាយអរ ព្រះគុណទ្រង់មានធម៌សន្ដោស
សូមកោតសរសើរព្រះនាមសុស សាយព្រួនទ្វីគ្រប់នគរ ។

៤- សូមគ្រប់ប្រជាជាតិទាំងឡាយ ទទួលក្អាកក្អាយមានអំណរ
ដ្បិតព្រះអង្គមានយុត្តិធម៌ គ្រប់គ្រងប្រជាជនឥតល្មៀង ។

៥- ព្រះអង្គមានព្រះហឫទ័យ ស្មោះត្រង់ប្រពៃឥតបីឃ្លាង
យុត្តិធម៌ណាស់គ្រប់គ្រងទៀង ត្រង់ស្មើឥតផ្អៀងឥតធ្ងន់ស្រាល ។

៦- សូមប្រជាជនទាំងឡាយអរ- ព្រះគុណទ្រង់មានធម៌សន្ដោស
សូមកោតសរសើរព្រះនាមសុស សាយព្រួនទ្វីគ្រប់តំបន់ ។

៧- ផែនដីបានបង្កើតភោគផល មិនឲ្យយើងខ្វល់ពីអត់ឃ្លាន
សូមព្រះជាម្ចាស់ទ្រង់ប្រទាន ពរជ័យមកយើងខ្ញុំគ្រប់គ្នា ។

៨- សូមទ្រង់ប្រទានពរឲ្យយើង សូមឲ្យអស់ទាំងមនុស្សា
ចុងកាត់មាត់ញកជើងបុព្វតា ទទួលស្គាល់បារមីព្រះអង្គ ។

## ៤១៨- ទំនុកតម្កើងលេខ ៨៦ (៨៥)

១-ឱ ! ព្រះជាម្ចាស់ សូមព្រះសណ្ដាប់ សូមទ្រង់អាណិត ឆ្លើយតបមកកូន
ខ្លួនកូនអភ័ព្វ ទាំងទុក្ខវេទនា សូមទ្រង់ការពារ ដោយក្ដីអាសូរ ។

២-កូនតែងរំពឹង និងសង្ឃឹមពិត ថាទ្រង់មិនភ្លេច កូនចៅព្រះអង្គ
រាល់ទិនទិវា កូនតែងអង្វរ សូមព្រះបវរ ផ្ដល់ក្ដីមេត្តា ។

៣-កូនបានលើកចិត្ត ឆ្ពោះរកព្រះអង្គ សូមព្រះម្ចាស់ផ្ដល់ ចិត្តរីកសប្បាយ
ឱ ! ព្រះម្ចាស់អើយ ទ្រង់ជាប្រភព នៃក្ដីសប្បុរស និងធម៌មេត្តា ។

៤- ទ្រង់នឹងប្រទាន ក្ដីករុណា ដល់អស់ជនណា រត់រកព្រះអង្គ
ពាក្យកូនអង្វរ អស់ពីដួងចិត្ត សូមទ្រង់អាណិត នឹកភ្នកមកកូន ។

៥- ពេលកូនរងទុក្ខ កូនរកព្រះអង្គ ទ្រង់មិនបោះបង់ ឲ្យកូនឯកា
គ្មានព្រះអង្គណា បានដូចព្រះអង្គ គ្មានអ្វីប្រៀបដូច ស្នាដៃទ្រង់ឡើយ ។

៦- មនុស្សគ្រប់ជាតិ និងមកក្រាបថ្វាយ ដល់ព្រះម្ចាស់ថ្លៃ ទាំងកោតសរសើរ
ព្រះអង្គថ្កុំថ្កើង អស្ចារ្យក្រៃពេក ខ្ពង់ខ្ពស់អនេក គ្មានអ្វីប្រៀបផ្ទឹម ។

៧-សូមឲ្យកូនយល់ មាគ៌ាព្រះអង្គ ដើម្បីកាន់តាម ដោយចិត្តស្មោះសរ
កូនសូមលើកថ្លែង អំណរព្រះគុណ ដល់ព្រះមានបុណ្យ អស់កល្បជានិច្ច ។

៨-ហឫទ័យព្រះអង្គ ជាជ្រោះមេត្រី ពោរពេញដោយក្ដី មេត្តាករុណា
ទ្រង់មិនឆាប់ខ្ញាល់ តែប្រោសប្រណី ទ្រង់តែងអភ័យ ដោយក្ដីស្រឡាញ់ ។

៩- ឱ ! ព្រះអម្ចាស់ មានតែទ្រង់មួយ សូមអាសូរជួយ កូនចៅព្រះអង្គ
សូមផ្ដល់កម្លាំង និងជួយសង្គ្រោះ សូមទ្រង់រំដោះ និងជួយឧបត្ថម្ភ ។

១០-អស់ពួកសត្រូវ មុខនឹងអៀនខ្មាស ព្រោះព្រះអម្ចាស់ ជួយការពារកូន
សូមកោតសរសើរ ឆ្ពោះព្រះត្រៃអង្គ ដែលគង់ជានិច្ច ដរាបទៅមុខ ។

## ៤១៩- ទំនុកតម្កើងលេខ ៩៧ (៩៦)

(បទ កាកគតិ)

១- ព្រះអម្ចាស់ទ្រង់ សោយរាជ្យយូរលង់ តវែងអន្លាយ សូមឲ្យផែនដី
ត្រេកអរសប្បាយ ជនជាតិជិតឆ្ងាយ សូមរីករាយឡើង ។

២-មានពពកនៅ ជុំជិតក្នុងក្រៅ ព័ទ្ធជុំបល្ល័ង្ក ឯព្រះអង្គគ្រប់
គ្រងប្រជាទាំង ឡាយឲ្យជុំជ្រើង ដោយយុត្តិធម៌ ។

៣-មានភ្លើងនៅមុខ ព្រះអង្គគគុក បំផ្លាញអ្នកប្រ- ឆាំងនឹងព្រះអង្គ
ចូលមកតបត និងត្រូវញាប់ញ័រ គ្មានរួចខ្លួនម្នាក់ ។

៤- មានផ្លេកបន្ទោរ បំភ្លឺឡើងឆ្លោ មនុស្សឃើញឥតអាក់ ផែនដីបានឃើញ
តាំងភ័យកន្ទ្រាក់ សស្លើតញ័រញាក់ រញ្ជួយកក្រើក ។

៥- ភ្នំក៏រលាយ ដូចក្រមួនខ្វាយ ប៉ើងជាត់របើក មុខព្រះអម្ចាស់
ជាម្ចាស់លើលោក ក្នុងទឹកលើគោក ផែនដីទាំងមូល ។

៦- ផ្ទៃមេឃប្រកាស សុចរិតថ្មីចាស់ ប្រជាជនចូល ឃើញសិរីជោគ
រុងរឿងឡើងថ្កោល ប្រសើរកំពូល ខ្ពង់ខ្ពស់ថ្លាថ្លៃ ។

៧-សូមឲ្យអស់អ្នក គោរពស្មោះស្ម័គ្រ នឹងព្រះក្លែងក្លាយ ត្រូវខ្មាសអៀនវិញ
ក្រហល់ក្រហាយ អួតខ្លួនលើកកាយ រឿងឥតបានការ ។
ឱ ! ទេវទូតអើយ កុំបីតោះតើយ បង្គំទូលថា កុំនៅអឹមអៀន
ពួនស្ងាត់វាចា សាសងស័ព្ទសារ ជាមួយព្រះអង្គ ។

៨- អ្នកក្រុងស៊ីយ៉ូន ចូរស្ដាប់ទាំងកូន ទាំងចៅរញ្ជង់ ហើយបានសប្បាយ
រីករាយត្រចង់ ព្រមទាំងអ្នកក្រុង ស្រុកយូដាទៀត ។

ទាំងអស់គ្នាត្រេក អរសប្បាយស្រែក គ្មានអ្វីនឹងប្រៀប ដ្បិតព្រះអម្ចាស់
គ្រប់គ្រងគ្រប់ជាតិ ហឫទ័យសុចរិត ស្មោះស្ម័គ្រស្មោះត្រង់ ។

៩- ឱ ! ព្រះអម្ចាស់ ខ្ពង់ខ្ពស់ក្រៃណាស់ មានតែព្រះអង្គ ប្រសើរបំផុត
លើផែនដីទាំង- មូលហើយខ្ពស់ជាង ព្រះផងទាំងឡាយ ។

១០- អស់អ្នកស្រឡាញ់ មានចិត្តក្ដួចកាញ់ ឥតដែលជិនណាយ នឹកព្រះអម្ចាស់
ចូរក្ដៅក្រហាយ ស្អប់ចង់កម្ចាយ អំពើអាក្រក់ ។

១១- ព្រះអង្គការពារ ឈរបាំងរាំងរា ជីវិតអ្នកស្ម័គ្រ ស្មោះលើព្រះអង្គ
ទ្រង់រំដោះឆក់ ឲ្យរួចពីក្ដុង កណ្ដាប់ដៃពាល ។

១២- ពន្លឺរះបំាង បំភ្លឺយ៉ាងខ្លាំង រស្មីរន្ទាល មកមនុស្សសុចរិត
និងមនុស្សបានស្គាល់ ទៀងត្រង់រៀងរាល់ បានអរសប្បាយ ។

១៣- ឱ ! មនុស្សសុចរិត អើយចូរនឹកគិត តែពីរីករាយ ដោយសារព្រះម្ចាស់
ចូរកោតលើកថ្វាយ សរសើរក្អាកក្អាយ អម្ចាស់វិសុទ្ធ ។

## ៤២០- ទំនុកតម្កើង ៩៧ ( ៩៦ )

១- ព្រះអម្ចាស់ទ្រង់ សោយរាជ្យយូរលង់ តវែងអន្លាយ សូមឲ្យផែនដី
ត្រេកអរសប្បាយ ជនជាតិជិតឆ្ងាយ សូមរីករាយឡើង ។
៦- ផ្ទៃមេឃប្រកាស សុចរិតថ្មីចាស់ ប្រជាជនចូល ឃើញសិរីជោគ
រុងរឿងឡើងថ្កោល ប្រសើរកំពូល ខ្ពង់ខ្ពស់ថ្លាថ្លៃ ។
១២-ពន្លឺរះចាំង បំភ្លឺយ៉ាងខ្លាំង រស្មីរន្ទាល មកមនុស្សសុចរិត
និងមនុស្សបានស្គាល់ ទៀងត្រង់រៀងរាល់ បានអរសប្បាយ ។
១៣-ឱ! មនុស្សសុចរិត អើយចូរនឹកគិត តែពីរីករាយ ដោយសារព្រះម្ចាស់
ចូរកោតលើកថ្វាយ សរសើរក្អាកក្អាយ អម្ចាស់វិសុទ្ធ ។

## ៤២១- ទំនុកតម្កើង ១១៧

### អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

១- ចូរតម្កើងដ្បិតព្រះអម្ចាស់សប្បុរស ស្ថិតស្ថេរគង់វង្សតរៀងទៅ
អ៊ីស្រាអែលចូរអរសប្បាយច្រៀងឡើង ស្ថិតស្ថេរគង់វង្សតរៀងទៅ ។
២- ពេលមានអាសន្នខ្ញុំបានអង្វរព្រះអង្គ ព្រះអង្គបានឆ្លើយតបមកខ្ញុំ
មានព្រះអង្គនៅក្បែរខ្ញុំមិនខ្លាចអី ខ្ញុំនិងឈ្នះអស់ពួកសត្រូវ ។
៣- ព្រះម្ចាស់ពិតជាកម្លាំងរបស់ខ្ញុំ សូមតម្កើងទ្រង់បានសង្គ្រោះ
ខ្ញុំមិនស្លាប់ប៉ុន្តែខ្ញុំត្រូវតែរស់ ដើម្បីផ្សព្វផ្សាយដំណឹងល្អ ។
៤- សូមបើកទ្វារសុចរិតឲ្យខ្ញុំឈានចូល ដើម្បីខ្ញុំអរគុណព្រះអង្គ
នេះនែ៎ទ្វារដែលនាំចូលព្រះអម្ចាស់ មានតែអ្នកសុចរិតដើរចូល ។
៥- ឱ! ព្រះម្ចាស់ខ្ញុំអរព្រះគុណព្រះអង្គ ដ្បិតទ្រង់ស្រឡាញ់និងឆ្លើយតប
ចូរតម្កើងដ្បិតព្រះអម្ចាស់សប្បុរស ស្ថិតស្ថេរគង់វង្សតរៀងទៅ ។

## ៤២២- ទំនុកតម្កើងលេខ ១២១ (១២០)

(បទកាកគតិ)

១- ខ្ញុំបែរភក្ត្រា រកព្រះបេស្តា ព្រះអម្ចាស់ថ្លៃ តើក្តីសង្គ្រោះ
ឧត្តមពេកក្រៃ ឲ្យខ្ញុំរាល់ថ្ងៃ មកពីទីណា ។
គឺព្រះសង្គ្រោះ ទ្រង់បានរំដោះ យើងខ្ញុំគ្រប់គ្នា ព្រោះទ្រង់ឧត្តម
បង្កើតមេឃា និងពសុធា ដោយហឫទ័យស្ម័គ្រ ។

២- សូមព្រះជាម្ចាស់ ជួយយើងគ្រប់គ្នា ឲ្យរួចគ្រោះថ្នាក់ កុំឲ្យយើងដួល
ចូលក្នុងអន្ទាក់ របស់អារក្ស ដែលប៉ងរាល់ថ្ងៃ ។
សូមព្រះអម្ចាស់ រក្សាការពារ រាល់ពេលរាត្រី ឲ្យយើងសម្រាក
បានសុខសួស្តី កុំឲ្យទុក្ខភ័យ មកបៀតបៀនបាន ។

៣- គឺពិតជាទ្រង់ ដែលជួយស្រោចស្រង់ យើងខ្ញុំគ្រប់ប្រាណ ព្រះអង្គសង្គ្រោះ
ផ្តល់ក្តីសុខសាន្ត ពុំដែលអាក់ខាន ទាំងផ្តល់ជោគជ័យ ។
ឯសុរិយា រស្មីភ្លឺថ្លា ជារៀងរាល់ថ្ងៃ គង់មិនផ្តល់ឲ្យ
យើងមានទុក្ខភ័យ ទោះពេលរាត្រី ដួងច័ន្ទក៏រះ ។

៤- ព្រះម្ចាស់ការពារ ពេលមានទុក្ខា ដោយក្តីស្មោះសរ ទ្រង់តែងណែនាំ
ទៅរកផ្លូវល្អ ទាំងផ្តល់ព្រះពរ បវរក្សេមក្សាន្ត ។
សូមព្រះបិតា និងព្រះបុត្រា ទាំងព្រះវិញ្ញាណ ប្រកបជោគជ័យ
ជួយប្រោសប្រទាន ផ្តល់ក្តីរាប់អាន ដល់អស់កូនចៅ ។

## ៤២៣- ទំនុកតម្កើងលេខ ១៣០ (១២៩)

(បទកាកគតិ)

១- ខ្ញុំដង្ហោយហៅ ពីទីជម្រៅ រកព្រះបវរ សូមព្រះសណ្ដាប់
ពាក្យខ្ញុំអង្វរ នឹងថ្វាយព្រះពរ ឆ្ពោះព្រះជាម្ចាស់ ។

២- ឱ ! ព្រះសង្គ្រោះ សូមជួយសន្ដោស មនុស្សលោកា កុំចាប់កំហុស
តើមាននរណា រួចពីទោសា ស្ថិតស្ថេរនៅបាន ។

៣- បំណែកព្រះអង្គ តែងជួយស្រោចស្រង់ លើកលែងទោសបាន យើងគួរកោតខ្លាច
ព្រះម្ចាស់ថ្កើងថ្កាន ដោយចិត្តក្លាហាន បង្គំបូជា ។

៤- ខ្ញុំជឿសង្ឃឹម ត្រេកអរញញឹម អស់ពីឱរា គោរពព្រះអង្គ
កោតខ្លាចបេស្ដា ពឹងព្រះអង្គា ខ្ពង់ខ្ពស់ថ្លាថ្លៃ ។

៥- ឱ ! ព្រលឹងខ្ញុំ ចាំព្រះឧត្ដម ទាំងយប់ទាំងថ្ងៃ ជាងអ្នកឃ្លាំចាំ
មើលបច្ចុសសម័យ ចាំពន្លឺថ្ងៃ ពេលព្រឹកព្រលឹម ។

៦- ឱ ! ព្រះជាម្ចាស់ ខ្ពង់ខ្ពស់ពេកណាស់ គ្មានអ្វីប្រៀបផ្ទឹម កូនចៅព្រះអង្គ
ត្រេកអរញញឹម មានចិត្តសង្ឃឹម លើព្រះសន្ដោស ។

៧- ដោយសារព្រះអង្គ មកជួយស្រោចស្រង់ ដោយអនុគ្រោះ កូនចៅព្រះអង្គ
ឲ្យផុតបាបគ្រោះ ទ្រង់ជួយរំដោះ បាកផុតទោសា ។

៨- សូមថ្លែងជោគជ័យ ប្រសើរថ្លាថ្លៃ អស់ពីចិន្ដា ថ្លែងអំណរគុណ
ឆ្ពោះព្រះបិតា ទាំងព្រះបុត្រា នឹងព្រះវិញ្ញាណ ។

## ៤២៤- ទំនុកតម្កើងលេខ ១៤២ (១៤១)

១-កូនសូមស្រែកទូល អស់ពីដួងចិត្ត សូមព្រះជាម្ចាស់ ស្ដាប់សម្លេងកូន
ទំនួញអង្វរ ចំពោះព្រះភក្ត្រ កូនសូមក្រាបទូល អស់ទុក្ខវេទនា ។

២- ទាំងក្ដីសោកា និងបារម្ភព្រួយ សូមព្រះម្ចាស់ជួយ រំលែកទុក្ខកូន
គ្រាព្រលឹងកូន ហៀបនឹងរលត់ ភាពខ្មៅងងឹត ស្រោបជិតឱរា ។

៣- នេះគឺអន្ទាក់ សត្រូវប៉ុនប៉ង ប្រាថ្នាសាកល្បង ស្ទាក់គ្រប់ជំហាន
តែព្រះអម្ចាស់ ទ្រង់ឈ្វេងយល់សព្វ អស់ប្រកងងឹត ដែលកូនវង្វេង ។

៤- គ្មាននរជនណា ជាអ្នកស្ដាប់ជាក់ គ្មានជនណាម្នាក់ រវល់នឹងកូន
កូនអស់សង្ឃឹម អស់ក្ដីរំពឹង តែព្រះអម្ចាស់ នៅទតមកកូន ។

៥- ឱ ! ព្រះអង្គអើយ កូនសូមចូលជ្រក ពឹងទីជម្រក នៃម្លប់បេស្កា
សូមទ្រង់សណ្ដាប់ នូវពាក្យទំនួញ ដ្បិតកូនធ្លាក់ខ្លួន លំបាកពេកក្រៃ ។

៦- សូមព្រះអម្ចាស់ ជួយរំដោះកូន ដ្បិតមារសត្រូវ ខ្លាំងពេកកន្លង
សូមជួយចម្លង ព្រលឹងកូនផុត ពីក្ដីងងឹត ឲ្យឃើញពន្លឺ ។

៧- ដោយព្រះគុណនេះ កូនសូមសច្ចា ថាមិនបំភ្លេច បារមីបេស្កា
ដោយព្រះអំណោយ ស្រោចស្រង់ព្រលឹង កូនសូមរំពឹង លើព្រះអង្គហើយ
សូមកោតសរសើរ ឆ្ពោះព្រះត្រៃឯក ដែលគង់ជានិច្ច ដរាបរៀងទៅ ។

# ៤២៥- ទំនុកតម្កើងលេខ ១៤៣ (១៤២)

១- ឱ ! ព្រះជាម្ចាស់ កូនសូមអង្វរ សូមផ្ទៀងព្រះកាណ៌
ស្ដាប់ពាក្យកូនផង ដោយអនុគ្រោះ សូមប្រោសប្រណី ។

២- សូមកុំចាប់ទោស អ្នកបម្រើទ្រង់ ដ្បិតនៅចំពោះ
ព្រះភក្ត្រព្រះអង្គ គ្មានជនណាម្នាក់ ត្រឹមត្រូវល្អឡើយ ។

៣- ពួកមារសត្រូវ តែងបៀតបៀនកូន គេប្រឹងប្រានកូន
ឲ្យធ្លាក់ដល់ដី ហើយបង្ខាំងកូន នៅទីងងឹត ។

៤- កូនដូចអ្នកស្លាប់ អង្វែងយូរលង់ សតិវិញ្ញាណ
ហាក់ដូចរលត់ ចិន្ដាឯកអង្គ ក្រៀមក្រំរងា ។

៥- កូននឹកចាំថ្ងៃ កាលពីអតីត ក៏នឹករឭក
នូវអស់កិច្ចការ និងស្នាព្រះហស្ដ របស់ព្រះអង្គ ។

៦- ឱ ! ព្រះម្ចាស់អើយ អាណិតកូនផង ព្រោះដួងចិត្តកូន
ដូចដីហួតហែង សូមទ្រង់ថ្វាថ្លែង មានបន្ទូលប្រោស ។

៧- ដ្បិតជង្រើមកូន នៅខ្លីពេកណាស់ សូមទ្រង់កុំលាក់
ព្រះភក្ត្រព្រះអង្គ ក្រែងរូបកាយកូន ស្លាប់អសារបង់ ។

៨- ពេលព្រឹកព្រលឹម សូមទ្រង់សម្ដែង នូវធម៌មេត្តា
របស់ព្រះអង្គ និងណែនាំកូន តាមគន្លងធម៌ ។

៩- ដោយព្រះនាមទ្រង់ ឱ ! ព្រះម្ចាស់អើយ សូមឲ្យកូនរស់
ក្នុងក្ដីយុត្តិធម៌ និងបានរួចផុត ពីទុក្ខព្រួយផង ។

១០- សូមថ្លែងជ័យា នៃព្រះបិតា និងព្រះបុត្រា
ទាំងព្រះវិញ្ញាណ ជាព្រះត្រៃឯក ដែលគង់ជានិច្ច ។

# សេចក្ដីអធិស្ឋានប្រចាំថ្ងៃ



ក្នុងព្រះនាម ព្រះបិតា និងព្រះបុត្រា ✝ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ អាម៉ែន ។

## ខ្ញុំសូមថ្វាយខ្លួន

ខ្ញុំសូមថ្វាយកាយ វាចា ចិត្ត ចំពោះព្រះជាអម្ចាស់ សូមព្រះអង្គគង់ជាមួយនឹងខ្ញុំ ជួយការពារខ្ញុំ គ្រប់ពេលវេលា ឲ្យខ្ញុំប្រព្រឹត្តតែកិច្ចការដែលគាប់ព្រះហឫទ័យព្រះអង្គ ។

## សូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមក

ឱ ! ព្រះវិញ្ញាណដ៏វិសុទ្ធ សូមព្រះអង្គយាងមកបំភ្លឺចិត្តគំនិតយើងខ្ញុំ
ដែលជឿសង្ឃឹមលើព្រះអង្គ ហើយសូមប្រោសឲ្យយើងខ្ញុំ
មានចិត្តស្រឡាញ់អាណិតដូចព្រះអង្គ ។

សូមព្រះវិញ្ញាណយាងមក និងតម្រង់ចិត្តយើងខ្ញុំ ។

ឱ! ព្រះបិតាអើយ កាលពីដើម ព្រះអង្គបានប្រទានព្រះវិញ្ញាណមកបំភ្លឺអស់សាវ័កព្រះអង្គ ។ ឥឡូវនេះ យើងខ្ញុំក៏សូមអង្វរព្រះអង្គ សូមទ្រង់ប្រទានព្រះវិញ្ញាណមកបំភ្លឺយើងខ្ញុំឲ្យប្រព្រឹត្តតែកិច្ចការ ដែលគាប់ព្រះហឫទ័យព្រះអង្គ និងឲ្យមានអំណរតរៀងទៅ ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

## ខ្ញុំជឿព្រះត្រៃឯក

ឱ ! ព្រះជាម្ចាស់អើយ ខ្ញុំជឿព្រះបិតា ដែលទ្រង់ស្រឡាញ់អស់មនុស្សទាំងឡាយ
ខ្ញុំជឿព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ ដែលទ្រង់សង្គ្រោះមនុស្សលោក
ខ្ញុំជឿព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់ជាមួយយើងខ្ញុំ
ហើយណែនាំយើងខ្ញុំក្នុងព្រះសហគមន៍ព្រះអង្គ ។

## ខ្ញុំសង្ឃឹមយ៉ាងមាំលើព្រះជាម្ចាស់

ឱ! ព្រះជាម្ចាស់អើយ ខ្ញុំសង្ឃឹមយ៉ាងមាំលើព្រះអង្គ
ដែលទ្រង់ជួយដឹកនាំការពារខ្ញុំគ្រប់ពេលវេលា
ហើយនឹងប្រទានឲ្យខ្ញុំបានចូលរួមជាមួយព្រះយេស៊ូគ្រីស្ត
នាថ្ងៃព្រះអង្គយាងមកវិញ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

## ខ្ញុំស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត

ឱ ! ព្រះអម្ចាស់អើយ ខ្ញុំស្រឡាញ់ព្រះអង្គអស់ពីដួងចិត្ត
និងលើសអ្វីៗទាំងអស់ ដ្បិតព្រះអង្គមានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង
ខ្ញុំស្រឡាញ់បងប្អូនឯទៀតដូចស្រឡាញ់ខ្លួនឯង តាមព្រះបន្ទូលរបស់ព្រះអង្គ ។

## សូមព្រះជាម្ចាស់លើកលែងទោស

ឱ! ព្រះជាម្ចាស់អើយ ខ្ញុំសោកស្តាយណាស់
ដោយបានធ្វើបាបខុសនឹងព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គទ្រង់មេត្តាលើកលែងទោសឲ្យខ្ញុំ
ហើយប្រទានឲ្យខ្ញុំមានកម្លាំង ជៀសវាងអំពើបាបតរៀងទៅ ។ អាម៉ែន ។

## ឱ ! ព្រះបិតាយើងខ្ញុំ

ឱ ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !
សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ
សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់
សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី
ដូចនៅស្ថានបរមសុខដែរ ។
សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។
សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក
ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។
សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ ។
តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច ។

## សូមអង្វរព្រះនាងម៉ារី

បពិត្រព្រះនាងម៉ារី ! ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ ព្រះអង្គគង់ជាមួយនាង
ព្រះអង្គបានប្រទានពរដល់នាងលើសស្ត្រីទាំងឡាយ
ហើយទ្រង់ក៏ប្រទានពរដល់បុត្រព្រះនាងដែរ ។
ឱ ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !
សូមជួយអង្វរព្រះអង្គ ឲ្យយើងខ្ញុំជាអ្នកបាប
នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង ។ អាម៉ែន ។

## សូមកោតសរសើរ

សូមកោតសរសើរ ព្រះបិតា និងព្រះបុត្រា ✝ និងព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលព្រះអង្គគង់នៅតាំងពីដើមរៀងមក ហើយជាដរាបតរៀងទៅ ។ អាម៉ែន ។

# លើកតម្កើងព្រះបរមនាមព្រះយេស៊ូ

- ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ

**ឆ្លើយ ៖ ឱ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ**

- ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ

**ឆ្លើយ ៖ ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ**

- ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ

**ឆ្លើយ ៖ ឱ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ**

- សូមព្រះយេស៊ូទ្រង់ព្រះសណ្ដាប់យើងខ្ញុំ

**ឆ្លើយ ៖ សូមព្រះអង្គទទួលពាក្យអង្វរយើងខ្ញុំ**

- ព្រះបិតាដែលគង់នៅស្ថានបរមសុខ ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ

**ឆ្លើយ ៖ សូមអាណិតអាសូរយើងខ្ញុំ (ឃ្លាខាងក្រោមឆ្លើយដូចគ្នា)**

- ព្រះបុត្រា ដែលបានសង្គ្រោះមនុស្សលោក ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ
- ព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះជាម្ចាស់ដ៏ពិតប្រាកដ
- ព្រះអង្គត្រៃឯក ជាព្រះជាម្ចាស់តែមួយ
- ព្រះយេស៊ូ ជាព្រះបុត្រានៃព្រះជាម្ចាស់ ដែលគង់នៅជាដរាប
- ព្រះយេស៊ូ ជាសិរីរុងរឿងនៃព្រះបិតា
- ព្រះយេស៊ូ ជាព្រះមហាក្សត្រមានសិរីរុងរឿងមហាប្រសើរ
- ព្រះយេស៊ូ ជារស្មីដែលបំភ្លឺផ្លូវយើង
- ព្រះយេស៊ូ ជាបុត្ររបស់ព្រះនាងព្រហ្មចារិនីម៉ារី
- ព្រះយេស៊ូ ជាទីស្រឡាញ់របស់គ្រីស្តបរិស័ទទាំងឡាយ
- ព្រះយេស៊ូ ជាគំរូឲ្យអស់អ្នកជងទាំងពួងកោតសរសើរ
- ព្រះយេស៊ូ មានឫទ្ធានុភាពដ៏ខ្លាំងមហិមា

- ព្រះយេស៊ូ មានព្រះហឫទ័យអត់ធ្មត់ក្រៃលែង
- ព្រះយេស៊ូ គោរពតាមព្រះបញ្ជានៃព្រះបិតាជាដរាប
- ព្រះយេស៊ូ មានព្រះហឫទ័យស្លូតសុភាព
- ព្រះយេស៊ូ ស្រឡាញ់អ្នកកាន់ព្រហ្មចរិយធម៌
- ព្រះយេស៊ូ ស្រឡាញ់យើងខ្ញុំ
- ព្រះយេស៊ូ ប្រទានសុខសន្តិភាព
- ព្រះយេស៊ូ ជាអម្ចាស់នៃអាយុជីវិត
- ព្រះយេស៊ូ ជាគំរូនៃអំពើល្អទាំងឡាយ
- ព្រះយេស៊ូ ស្រឡាញ់មនុស្សទាំងអស់
- ព្រះយេស៊ូ ជាអម្ចាស់យើងខ្ញុំ
- ព្រះយេស៊ូ ជាទីពំនឹងពំនាក់របស់យើងខ្ញុំ
- ព្រះយេស៊ូ ប្រោសប្រណីអស់អ្នកកម្សត់ទុរគតទាំងឡាយ
- ព្រះយេស៊ូ ដឹកនាំមនុស្សលោកដោយព្រះហឫទ័យសប្បុរស
- ព្រះយេស៊ូ ជាពន្លឺដ៏ពិតប្រាកដ
- ព្រះយេស៊ូ មានព្រះប្រាជ្ញាញាណអស់កល្បជានិច្ច
- ព្រះយេស៊ូ មានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង
- ព្រះយេស៊ូ ជាមាគ៌ា និងជាអាយុជីវិតយើងខ្ញុំ
- ព្រះយេស៊ូ ជាប្រភពនៃអំណរសប្បាយរបស់ទេវទូតទាំងឡាយ
- ព្រះយេស៊ូ ជាព្រះអម្ចាស់នៃបុព្វបុរសទាំងឡាយ
- ព្រះយេស៊ូ ប្រទានឲ្យចិត្តមនុស្សបានស្អាតបរិសុទ្ធ
- ព្រះយេស៊ូ ជាកម្លាំងនៃសន្តបុគ្គល និងមរណសាក្សី
- ព្រះយេស៊ូ ជាពន្លឺនៃអ្នកប្រកាសផ្សាយដំណឹងល្អ
- ព្រះយេស៊ូ ជារង្វាន់ដ៏ឧត្តមនៃសន្តបុគ្គលទាំងឡាយ
- សូមព្រះយេស៊ូ ទ្រង់ព្រះមេត្តាអាណិតអាសូរយើងខ្ញុំ

**ឆ្លើយ ៖ សូមព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំ**

- សូមព្រះយេស៊ូទ្រង់ព្រះមេត្តាអាណិតអាសូរយើងខ្ញុំ

**ឆ្លើយ ៖ សូមព្រះអង្គទ្រង់សណ្ដាប់ពាក្យអង្វរយើងខ្ញុំ**

- ឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង

**ឆ្លើយ ៖ សូមព្រះអង្គរំដោះយើងខ្ញុំ (ឃ្លាខាងក្រោមឆ្លើយដូចគ្នា)**

- ឲ្យបាកផុតពីអំពើបាបគ្រប់បែបយ៉ាង
- ឲ្យបាកផុតពីការល្បួងនៃមារកំណាច
- ឲ្យបាកផុតពីចិត្តលោភលន់ នឹងអំពើសៅហ្មង
- ឲ្យបាកផុតពីសេចក្ដីស្លាប់អស់កល្បជានិច្ច
- ដោយព្រះគុណ ព្រះបុត្រាមានកំណើតជាមនុស្ស
- ដោយព្រះគុណ ព្រះយេស៊ូទ្រង់បានប្រសូត
- ដោយព្រះគុណ នៃកុមារភាពព្រះយេស៊ូ
- ដោយព្រះគុណ នៃកិច្ចការទាំងឡាយដែលព្រះយេស៊ូបានបំពេញ
- ដោយព្រះគុណ នៃទារុណកម្មគ្រប់បែបយ៉ាងដែលព្រះយេស៊ូបានទទួល
- ដោយព្រះគុណ នៃព្រះឈើឆ្កាងព្រះយេស៊ូ
- ដោយព្រះគុណ ព្រះយេស៊ូទ្រង់សោយទិវង្គត
- ដោយព្រះគុណ ព្រះយេស៊ូទ្រង់មានព្រះជន្មដ៏រុងរឿង
- ដោយព្រះគុណ ព្រះយេស៊ូទ្រង់យាងឡើងស្ថានបរមសុខ
- ដោយព្រះគុណ ព្រះយេស៊ូបានតាំងអគ្គសញ្ញាព្រះកាយ និងព្រះលោហិត
- ដោយព្រះគុណ ព្រះយេស៊ូទ្រង់មានសិរីរុងរឿងមហាប្រសើរ
- ឱ ! កូនចៀមនៃព្រះជាម្ចាស់ដែលរំដោះបាបមនុស្សលោកីយ៍

ឆ្លើយ ៖ សូមទ្រង់លើកលែងទោសឲ្យយើងខ្ញុំ

- ឱ ! កូនចៀមនៃព្រះជាម្ចាស់ដែលរំដោះបាបមនុស្សលោកីយ៍

**ឆ្លើយ ៖ សូមទ្រង់ព្រះសណ្ដាប់ពាក្យអង្វរយើងខ្ញុំ ។**

- ឱ ! កូនចៀមនៃព្រះជាម្ចាស់ដែលរំដោះបាបមនុស្សលោកិយ៍

**ឆ្លើយ ៖ សូមអាណិតអាសូរយើងខ្ញុំ**

- សូមព្រះយេស៊ូទ្រង់ព្រះសណ្ដាប់យើងខ្ញុំ

ឱ! ព្រះជាម្ចាស់យើងខ្ញុំអើយ ព្រះអង្គមានកំណើតជាមនុស្ស ទ្រង់បានសោយទុក្ខលំបាក និងសោយទិវង្គត ដោយទ្រង់មានព្រះហឫទ័យស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង ហើយមានព្រះជន្មដ៏រុងរឿង ។ យើងខ្ញុំសូមគោរពលើកតម្កើងព្រះបរមនាមដ៏ឧត្ដុង្គឧត្ដម របស់ព្រះអង្គ នៅនាលោកនេះ ដើម្បីឲ្យយើងខ្ញុំថ្វាយបង្គំកោតសរសើរព្រះអង្គ រួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ នៅស្ថានបរមសុខអស់កល្បជាអង្វែងតរៀង ទៅ ។ អាម៉ែន ។

# ពាក្យអង្វរសន្តបុគ្គលទាំងឡាយ

ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !

**ឆ្លើយ ៖ ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !**

ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ !

**ឆ្លើយ ៖ ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ !**

ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !

**ឆ្លើយ ៖ ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !**

- ព្រះនាងម៉ារី ជាព្រះមាតាព្រះគ្រីស្តជាអម្ចាស់ !

**ឆ្លើយ ៖ សូមជួយអង្វរព្រះអម្ចាស់ឲ្យយើងខ្ញុំ (ឃ្លាខាងក្រោមឆ្លើយដូចគ្នា)**

- សន្តទេវទូតមីកាអែល
- សន្តយ៉ូហាន-បាទីស្ត
- សន្តសិលា និង សន្តៈ ប៉ូល
- សន្តយ៉ូហាន
- សន្តស្ទេផាន
- សន្តឡូរ៉ង់
- សន្តីអាញ៉េស
- សន្តអូគុស្តាំង
- សន្តបាស៊ីល
- សន្តបេណេឌីតូ
- សន្តហ្វ្រង់ស័រ សាវីយេ
- សន្តីកាថារីណា នៅក្រុងស៊ីយេណា
- សន្តហ្វ្រង់ស័រ នៅឡាសាល
- សន្តទេវទូតទាំងឡាយ
- សន្តយ៉ូសែប
- សន្តអន់ជ្រេ
- សន្តីម៉ារី ជាអ្នកស្រុកម៉ាដាឡា
- សន្តអ៊ីញ៉ាស ជាអភិបាលក្រុងអន់ទីយ៉ូក
- សន្តីពែរប៉េទូអា និងសន្តីហ្វេលីស៊ីតា
- សន្តក្រេគ័រ
- សន្តអាថាណាស
- សន្តម៉ាតាំង
- សន្តហ្វ្រង់ស័រ និងសន្តដូនីមីកូ
- សន្តយ៉ូហាន ម៉ារីវីយ៉ានេ
- សន្តីតេរេសា នៅក្រុងអាវីឡា
- សន្តយ៉ូហានបូស្កូ

- សន្តីតេរេសា គោរពព្រះកុមារយេស៊ូ
- សន្តប៉ូលមីគី និងសហការី ជាមរណសាក្សីនៅប្រទេសជប៉ុន ។
- សន្តអន់ដ្រេគីម និងសហការី ជាមរណសាក្សីនៅប្រទេសកូរ៉េ ។
- សន្តកាព្រីអែល និងសហការី ជាមរណសាក្សីនៅប្រទេសចិន ។
- សន្តអន់ដ្រេ យូងឡាក និងសហការី ជាមរណសាក្សីនៅប្រទេសវៀតណាម ។
- សន្តីអាញ៉េសភីឡា សន្តនីកូឡាប៊ុនកើត និងសហការី ជាមរណសាក្សីនៅប្រទេសថៃ ។
- លោកយ៉ូសែប ឆ្មារសាឡាស់ ជាអភិបាលព្រះសហគមន៍ភ្នំពេញពីដើម
- លោកប៉ូល ទេពអ៊ីមសុត្ថា ជាអភិបាលព្រះសហគមន៍បាត់ដំបងពីដើម
- អស់លោកបូជាចារ្យ និងអស់លោកអ្នកបួស ដែលបានបូជាជីវិតថ្វាយព្រះគ្រីស្ត
- អស់គ្រីស្តបរិស័ទប្រទេសកម្ពុជា ដែលរួមរស់ជាមួយព្រះគ្រីស្តនៅស្ថានបរមសុខ
- អស់ប្រជាពលរដ្ឋខ្មែរដែលគ្មានទោស ហើយដែលបានបាត់បង់ជីវិតទៅហើយ ។
- អស់សន្តបុគ្គលទាំងឡាយ
- សូមព្រះយេស៊ូ ប្រោសប្រណីយើងខ្ញុំ ។

**ឆ្លើយ ៖ សូមព្រះអម្ចាស់ប្រោសរំដោះយើងខ្ញុំ (ឃ្លាខាងក្រោមឆ្លើយដូចគ្នា)**

- ឲ្យបាកផុតពីអន្តរាយគ្រប់បែបយ៉ាង
- ឲ្យបាកផុតពីបាបកម្មគ្រប់ជំពូក
- ឲ្យបាកផុតពីសេចក្តីស្លាប់អស់កល្បជានិច្ច
- ដោយព្រះគុណព្រះបុត្រា បានចាប់កំណើតជាមនុស្ស
- ដោយព្រះគុណព្រះយេស៊ូ បានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
- ដោយព្រះអំណោយដ៏ថ្លៃថ្លារបស់ព្រះវិញ្ញាណ ។

**ឆ្លើយ ៖សូមទ្រង់ព្រះមេត្តាព្រះសណ្តាប់យើងខ្ញុំ (ឃ្លាខាងក្រោមឆ្លើយដូចគ្នា)**

## បន្ថែមពាក្យអង្វរតាមកាលៈទេសៈ

- សូមព្រះជាម្ចាស់ ទ្រង់ព្រះមេត្តាប្រោសអស់បងប្អូន ដែលព្រះអង្គត្រាស់ហៅឲ្យទទួល (....) នៅពេលនេះ បានរស់នៅដោយមានព្រះជន្មព្រះអង្គ ជាប់ក្នុងខ្លួនជានិច្ច ។

- សូមព្រះយេស៊ូ ជាព្រះបុត្រានៃព្រះជាម្ចាស់ ដែលគង់នៅជាដរាប

**ឆ្លើយ ៖ សូមទ្រង់មេត្តាព្រះសណ្ដាប់យើងខ្ញុំ**

- ឱ! ព្រះគ្រីស្តអើយ សូមព្រះសណ្ដាប់យើងខ្ញុំ

**ឆ្លើយ ៖ ឱ ! ព្រះគ្រីស្តអើយ សូមព្រះសណ្ដាប់យើងខ្ញុំ**

- ឱ! ព្រះគ្រីស្តអើយ សូមទទួលពាក្យអង្វរយើងខ្ញុំ

**ឆ្លើយ ៖ ឱ! ព្រះគ្រីស្តអើយ សូមទទួលពាក្យអង្វរយើងខ្ញុំ**

- ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ!

**ឆ្លើយ ៖ ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ!**

- ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ !

**ឆ្លើយ ៖ ឱ ! ព្រះគ្រីស្តអើយ សូមអាណិតអាសូរ !**

- ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !

**ឆ្លើយ ៖ ឱ ! ព្រះអម្ចាស់អើយ សូមអាណិតអាសូរ !**

# មាតិកាបទចម្រៀងតាមតួអក្សរ

## (យកតាមចំណុចចាប់ផ្ដើមនៃបទចម្រៀង)


**ក** កាលនោះព្រះគ្រីស្ទមានព្រះបន្ទូល.............................. **ទំព័រ** ១៦៨
កាលពីដើម ខ្ញុំពុំមែនជាព្យាការី................................ ៣១៩
កាលពីមុនខ្ញុំខ្វាក់.................................................. ៣០០
កូនអើយ! ខ្ញុំអត់ទោសឲ្យអ្នក.................................. ៣០២
កោតសរសើរ...................................................... ២៣៥
កោតសរសើរព្រះអម្ចាស់......................................... ២៩២
កោតសរសើរព្រះអម្ចាស់......................................... ២៩២
ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ.................................... ៣០០
ក្នុងដំណើរជីវិត.................................................. ១៦៩
ក្រោមម្លប់បារមីព្រះយេស៊ូ...................................... ២៧៩
ក្សត្រិបវរលើលោកា............................................ ២៣៥
កុំឲ្យរន្ធត់ចិត្ត...................................................... ២៩៣

**ខ** ខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដី.................................. **ទំព័រ** ៣០១
ខ្ញុំច្រៀងកោតសរសើរ........................................... ២៧៩
ខ្ញុំជាដើមទំពាំងបាយជូរ......................................... ១៧០
ខ្ញុំជាប្រភពនៃជីវិត............................................... ១៧១
ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិត................................ ៣០២
ខ្ញុំជាអាហារដែលផ្ដល់ជីវិត...................................... ១៧១
ខ្ញុំជាអ្នកគង្វាលសប្បុរស........................................ ១៧២
ខ្ញុំជឿព្រះជាព្រះបិតា............................................ ១៥

ខ្ញុំទុកចិត្តលើព្រះជាម្ចាស់........................................ ១៧៣
ខ្ញុំនឹកស្រណោះវិហារព្រះម្ចាស់ ................................ ១២៦
ខ្ញុំនឹងក្រោកឡើង ................................................. ៣០២
ខ្ញុំនេះហើយ ជាដើមទំពាំងបាយជូរ............................ ១៧៣
ខ្ញុំបានឃើញទឹកខ្វាយចេញពីខាងស្តាំព្រះវិហារ............. ៧
ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត.................................. ១៧៤
ខ្ញុំបានទទួលព្រះកាយាព្រះគ្រីស្ត.................................. ១៧៥
ខ្ញុំមិនមែនមកលុបបំបាត់ធម្មវិន័យទេ ......................... ៣៣១
ខ្ញុំសូមប្រគល់វិញ្ញាណ.............................................. ២៩៣
ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង..................................... ៣០២
ខ្ញុំសូមលើកតម្កើង................................................ ២៣៨
ខ្ញុំសែនស្រឡាញ់បន្ទូលព្រះម្ចាស់ ............................... ១៧៧
ខ្ញុំស្រឡាញ់ព្រះបន្ទូល ............................................. ១៧៨
ខ្ញុំស្រឡាញ់ព្រះយេស៊ូ ............................................. ៣០១
ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់......................................... ១៧៨

**គ** គោរពព្រះគ្រីស្តជាអម្ចាស់ ................................ **ទំព័រ** ១៧៩
គ្មានអ្នកណា....................................................... ៣០៤
គ្រប់ពេលដែលអ្នករាល់គ្នា........................................ ២៣១
គ្រីស្តទូត១២រូប ................................................... ៣០៥
គ្រួសារយើងមានក្តីសុខ........................................... ៣១៧
គ្រួសារសុខសាន្ត.................................................. ៣០៥

**ច** ចិតសិបដង ប្រាំពីរដង.......................................... **ទំព័រ** ៣០៦

ចិត្តខ្ញុំពេញដោយអំណរ........................................ ១៨០
ចិត្តខ្ញុំរីករាយសប្បាយពន់ពេកកន្លង........................... ១៨០
ចូរកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អ...................... ១៥៥
ចូរចាកចេញពីស្រុករបស់អ្នក................................... ៣០៦
ចូរចេញទៅប្រកាស .............................................. ២៣២
ចូរច្រៀងបទថ្មីថ្វាយព្រះជាម្ចាស់............................... ១៣០
ចូរច្រៀងប្រាប់ភ្នំ.................................................. ១២៩
ចូរច្រៀងលើកតម្កើង............................................. ១៨៧
ចូរត្រេកសប្បាយញញឹមរីករាយ............................... ២០៣
ចូរនាំគ្នាទៅគ្រប់ទីកន្លែង ........................................ ៣០៦
ចូរនាំគ្នាទៅចុះ ................................................... ២៣៣
ចូរនាំមនុស្សគ្រប់ជាតិគ្រប់សាសន៍ ............................ ៣០៧
ចូរប្រុងស្មារតី .................................................... ៣០៧
ចូរពិសោធឲ្យដឹងច្បាស់ថា....................................... ១៨៥
ចូរមានចិត្តមេត្តាករុណា.......................................... ១៨៧
ចូរមានចិត្តមេត្តាដូចព្រះបិតា ................................... ៣០៨
ចូរយើងខ្នះខ្នែងប្រារព្ធពិធី...................................... ៣០៦
ចូរយើងខំរៀបចំចិត្តគំនិត...................................... ២៥២
ចូរយើងគ្រប់គ្នាក្រាបថ្វាយបង្គំ ................................. ៩៩
ចូរយើងទាំងអស់ផ្ទង់ស្មារតីនឹក ................................ ១៨២
ចូរយើងរាល់គ្នាបង្គំវន្ទា.......................................... ១៨២
ចូរយើងរួមអរសប្បាយ ........................................... ២៥៥
ចូរយើងឱនកាយក្រាបថ្វាយបង្គំ ................................ ១៨៣
ចូររៀបចំផ្លូវ....................................................... ២៦៥

ចូរលើកតម្កើងព្រះអម្ចាស់ ........................................ ១៩៣
ចូរឲ្យយើងកាន់ដៃ ............................................... ២៥៣
ចូរអបអរ ចូរសរសើរ .............................................. ២៣៧
ចូរអបអរថ្ងៃកំណើតព្រះគ្រីស្ត .................................... ២៦២
ចូរអរព្រះគុណព្រះជាម្ចាស់បួនរយហាសិបឆ្នាំ........................ ៣០៩
ចូរអ្នករាល់គ្នាមានចិត្តសប្បុរសដូចព្រះបិតា........................ ១៨៨
ចូរអ្នកស្រឡាញ់ព្រះអម្ចាស់ ...................................... ១៣១
ចូរអ្នកស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ ..................... ១៨៩
ច្រៀងលើកតម្កើង ច្រៀងកោតសរសើរ............................... ១៥៥
ច្រៀងលើកតម្កើង ច្រៀងកោតសរសើរ............................... ២៤៣
ច្រៀងសរសើរព្រះជាអម្ចាស់........................................ ៣០០
ច្រៀងអបអរ ច្រៀងសរសើរ......................................... ២៤៤
ច្រៀងអាលេលូយ៉ា! ................................................ ២៣៧
ច្រៀងអាលេលូយ៉ាថ្វាយព្រះម្ចាស់ .................................. ១៥៨

ឌ ជយោ ! ព្រះរាជវង្សព្រះបាទដាវីឌ............................ **ទំព័រ** ២៧៣
ជយោ ជយោ និទានជីវិតព្រះយេស៊ូ.................................. ១៤៨
ជាខ្ញុំ ត្រូវជួយព្រះសហគមន៍........................................ ៣១០
ជាពេលអំណរ ពេលសន្តិភាព........................................ ៣២៧
ជាមួយព្រះគ្រីស្ត .................................................... ៣០៩
ជាមួយព្រះគ្រីស្តអម្ចាស់ ........................................... ១៥០
ជូនជារាត្រី............................................................ ២៥៦
ជំនឿអ្នកស្វែងរកវីកចម្រើនឡើង.................................... ៣១៩
ជ័យជម្នះ ............................................................. ២៨០

**ដ** ដងគីរីវែងសែនឆ្ងាយ .......................................... **ទំព័រ** ៣១១
ដូចភ្នំព័ទ្ធជុំទីក្រុងយេរូសាឡឹម .................................. ១៤៨
ដូចសមុទ្រមានខ្យល់ព្យុះខ្លាំងណាស់.......................... ១៨៩
ដើមដំបូងសាវ័ក ................................................... ៣១២
ដើរតាមព្រះយេស៊ូ ............................................... ៣១៣
ដោយព្រះអំណោយទាន ....................................... ៣២៩

**ត** តើព្រះកុមារយេស៊ូជានរណា? ............................... **ទំព័រ** ២៥៨
តើព្រះជាម្ចាស់ជានរណា? ..................................... ២៦៧
តើព្រះជាម្ចាស់ទ្រង់ជានរណា? ............................... ១៩១
តើយើងនឹងបាត់នរណាឲ្យទៅ? ............................... ៣១៣
តើអ្នកមានឃើញទេ? ........................................... ៣៣២
ត្រូវតែអធិដ្ឋានជានិច្ច............................................. ៣១៣
ត្រូវស្រឡាញ់គ្នា..................................................... ៣១៣
ត្រេកអរថ្ងៃចូលឆ្នាំថ្មី.............................................. ២៩៧

**ថ** ថ្ងៃនេះ ជាថ្ងៃដែលព្រះម្ចាស់ប្រទានពរជ័យ.................. **ទំព័រ** ២៩៨
ថ្ងៃនេះយើងមានក្ដីសុខ .......................................... ៣១៤

**ទ** ទារកទើបកើត...................................................... **ទំព័រ** ៣១៤
ទីណាមានមេត្តា ..................................................... ២៩៤
ទូលព្រះបង្គំខ្ញុំ ទៅដល់ដំណាក់ព្រះម្ចាស់....................... ១៣១
ទំនុកតម្កើងលេខ ២៣ (២២) ................................ ៣៥៤
ទំនុកតម្កើងលេខ ៣៤ (៣៣) ................................ ៣៥៥

ទំនុកតម្កើងលេខ ៥១ (៥០) ................................... ៣៥៧
ទំនុកតម្កើងលេខ ៥១ (៥០) ................................... ៣៥៩
ទំនុកតម្កើងលេខ ៦៧ (៦៦) ................................... ៣៦១
ទំនុកតម្កើងលេខ ៧២ (៧១) ................................... ២៦៨
ទំនុកតម្កើងលេខ ៨៦ (៨៥) ................................... ៣៦២
ទំនុកតម្កើង ៩៧ (៩៦) ................................... ៣៦៤
ទំនុកតម្កើងលេខ ៩៧ (៩៦) ................................... ៣៦៣
ទំនុកតម្កើង ១១៧ ................................... ៣៦៥
ទំនុកតម្កើងលេខ ១២១ (១២០) ................................... ៣៦៦
ទំនុកតម្កើងលេខ ១៣០ (១២៩) ................................... ៣៦៧
ទំនុកតម្កើងលេខ ១៤២ (១៤១) ................................... ៣៦៨
ទំនុកតម្កើងលេខ ១៤៣ (១៤២) ................................... ៣៦៩
ទំនុកតម្កើងរបស់លោកម៉ូសេ ................................... ៣៥១
ទំនុកតម្កើងរបស់នាងយូឌីត ................................... ៣៥០
ទំនុកតម្កើងអង្វរព្រះវិញ្ញាណ ................................... ២៨៨

**ន** នាដែនលោកីយ៍ជីវេទនា ................................... **ទំព័រ** ២៤១
និទានជីវិតព្រះយេស៊ូ ................................... ៣១៤
និទានជីវិតព្រះយេស៊ូ ................................... ៣១៥
នេះជាឈើ ................................... ២៦៩
នេះជាតង្វាយ ................................... ១៦៤
នេះជាថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមក ................................... ២៤១
នេះជាថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមក ................................... ២៨១
នេះជាលោហិតរបស់ខ្ញុំ ................................... ៣១៥

នេះជាអាហារឧត្តម ................................................ ១៩៦
នេះធូបទៀនផ្កា.................................................... ១៦២
នៅជំនាន់ដើម..................................................... ៣១៥
នៅពេលនេះ យើងរួបរួមគ្នា ..................................... ២៣៤
នៅលើឈើឆ្កាង.................................................... ២៦៩
នៅលើមេឃកណ្ដាលអាកាសរាត្រី ............................. ២៦២
នៅវេលាដែលសូរិយាលន់លិច .................................. ១៣៣
នៅសម័យកាលនោះ .............................................. ៣៣៦

**ប** បងប្អូនធ្វើអ្វីក៏ដោយ ............................................... **ទំព័រ** ៣៣១
បន្ទូលព្រះអង្គ គឺជាចង្កៀង...................................... ៣១៦
បន្ទូលព្រះអង្គ ពន្លឺថ្លាយង់........................................ ១៣៨
បពិត្រព្រះនាងម៉ារី................................................ ២៤២
បពិត្រព្រះនាងម៉ារី................................................ ២៤៥
បពិត្រព្រះយេស៊ូ.................................................. ៣២៤
បពិត្រព្រះរាជវង្ស ................................................. ៣១៨
បពិត្រព្រះអម្ចាស់................................................. ១៩៦
បុត្រព្រះអម្ចាស់................................................... ២៦៩
បុត្រម្នាក់បានប្រសូតមកសម្រាប់យើង ......................... ២៥៧
ប្រជាជនទាំងឡាយអើយ ........................................ ៣១៦
ប្រសិនបើ.......................................................... ៣១៧
ប្រសិនបើអ្នកស្គាល់ព្រះអំណោយទាន .......................... ១៩២
ប្រែចិត្តគំនិត....................................................... ៣១៧

**ផ** ផែនដីទាំងមូលអើយ........................................ **ទំព័រ** ១៣២
ផ្ទៃមេឃ និងផែនដី............................................ ១៥៧

**ព** ពេលដែលយើងមានចិត្តអស់សង្ឃឹម ........................... **ទំព័រ** ៣០១
ពេលណាយើងស្រឡាញ់គ្នា...................................... ១៩៧
ពេលនេះឲ្យយើងច្រៀង.......................................... ៣១៩
ពេលយើងរួមគ្នា ! ............................................... ៣១៩
ព្រះគ្រីស្ទគង់ជាមួយយើង...................................... ២៨២
ព្រះគ្រីស្ទជាគង្វាលការពារខ្ញុំ.................................... ២០០
ព្រះគ្រីស្ទជាទីសង្ឃឹម.......................................... ១៣៣
ព្រះគ្រីស្ទជាពន្លឺ ដែលបំភ្លឺដំណើរជីវិត........................ ៣២១
ព្រះគ្រីស្ទជាពន្លឺបំភ្លឺលោកា..................................... ១៥៧
ព្រះគ្រីស្ទជាព្រះពិតប្រាកដ..................................... ២៧២
ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញមែន ................. ២៨៣
ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ............... ២៨៣
ព្រះគ្រីស្ទបានរំដោះយើង ...................................... ៣៤៣
ព្រះគ្រីស្ទប្រសូត................................................. ២៥៨
ព្រះគ្រីស្ទមានបន្ទូលថា ខ្ញុំជាពន្លឺក្នុងទីងងឹត.................. ២០២
ព្រះគ្រីស្ទមានព្រះបន្ទូលថា..................................... ១៨១
ព្រះគ្រីស្ទមានព្រះបន្ទូលថា..................................... ១៨៦
ព្រះជាម្ចាស់ យើងខ្ញុំសូមផ្ញើជីវិត............................. ៣៤២
ព្រះជាម្ចាស់ចាត់ព្រះបុត្រា...................................... ២២៩
ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ....................................... ២០៣
ព្រះជាម្ចាស់ទតឃើញថា ....................................... ៣២៣

ព្រះជាម្ចាស់ទ្រង់ជាពន្លឺ........................................ ២០៦
ព្រះជាម្ចាស់ទ្រង់ទទួលយើងក្នុងដំណាក់ព្រះអង្គ ............ ១៤៩
ព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់.................................. ២០៤
ព្រះជាម្ចាស់បានជ្រើសរើសយើង ............................... ២១១
ព្រះជាម្ចាស់បានត្រាស់ហៅយើង ............................... ៣២១
ព្រះជាម្ចាស់មានព្រះបន្ទូលថា.................................. ៣២៣
ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ........................... ៣០៧
ព្រះជាម្ចាស់ស្រឡាញ់យើង..................................... ២៩៨
ព្រះជាម្ចាស់ស្រឡាញ់យើង..................................... ៣២១
ព្រះជាម្ចាស់ស្រឡាញ់លោកា.................................... ៣២២
ព្រះជាអម្ចាស់ ...................................................... ៣២៣
ព្រះជាអម្ចាស់បានចាក់បង្ហូរហឫទ័យស្រឡាញ់.............. ២២៥
ព្រះជាអម្ចាស់បានសម្រេចការអស្ចារ្យ......................... ២៤០
ព្រះជាអម្ចាស់ពោរពេញដោយសេចក្ដីស្រឡាញ់............ ២២៦
ព្រះជាអម្ចាស់មានព្រះបន្ទូលថា................................ ១២៥
ព្រះជាអម្ចាស់ស្រឡាញ់លោកា ................................. ១៨៤
ព្រះនាងជាកិត្តិយស.............................................. ២៤២
ព្រះបន្ទូលព្រះគ្រីស្ដជាផ្លូវ ....................................... ២០៩
ព្រះបន្ទូលព្រះអង្គជាចង្កៀង .................................... ២០៩
ព្រះបន្ទូលព្រះអង្គមានជីវិត...................................... ២០៩
ព្រះបិតានៅស្ថានបរមសុខ....................................... ២៣០
ព្រះបិតាមានធម៌មេត្តា........................................... ៣២៥
ព្រះម្ចាស់តែមួយ .................................................. ២១០
ព្រះយេស៊ូគង់ជាមួយ.............................................. ៣២៨

ព្រះយេស៊ូគឺជាពន្លឺ.................................................. ២១២
ព្រះយេស៊ូគ្រីស្ទ.................................................. ២៩៤
ព្រះយេស៊ូគ្រីស្ទបានបូជាជីវិត.................................................. ២៧០
ព្រះយេស៊ូគ្រីស្ទមានព្រះជន្មរស់ឡើងវិញមែន.................................................. ២៨៤
ព្រះយេស៊ូគ្រីស្ទរស់ឡើងវិញមែន.................................................. ២៨២
ព្រះយេស៊ូជាប្រភពទឹក.................................................. ៣២៧
ព្រះយេស៊ូជាប្រភពនៃជីវិតយើងរាល់គ្នា.................................................. ២៥៧
ព្រះយេស៊ូទ្រង់បានបូជាព្រះជន្ម.................................................. ២៦៦
ព្រះយេស៊ូបានសុគត.................................................. ២៧២
ព្រះយេស៊ូព្រះរាជបុត្រា.................................................. ២៦៣
ព្រះយេស៊ូមានព្រះបន្ទូលថា.................................................. ១៩០
ព្រះយេស៊ូសូមកុំភ្លេចខ្ញុំ ! .................................................. ២៩៤
ព្រះយេស៊ូអើយ!.................................................. ៣២៨
ព្រះវិញ្ញាណគង់សណ្ឋិត.................................................. ៣២៨
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់.................................................. ២៩០
ព្រះសហគមន៍កាតូលិក.................................................. ៣៣៧
ព្រះអម្ចាស់ខ្ញុំ.................................................. ២១៥
ព្រះអម្ចាស់ជាកម្លាំងរបស់ខ្ញុំ.................................................. ២៩៣
ព្រះអម្ចាស់ទ្រង់សោយរាជ្យ.................................................. ២៨៥
ព្រះអម្ចាស់មានតែមួយ.................................................. ៣៣០
ព្រះអម្ចាស់មានបន្ទូលថា.................................................. ១៦០
ព្រះអម្ចាស់មានបន្ទូលថា.................................................. ២០៥
ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ.................................................. ២៨៦
ព្រះអម្ចាស់យេស៊ូប្រសូតហើយ.................................................. ២៥៩

**ភ** ភ្លើង! នៃក្តីស្រឡាញ់............................................ **ទំព័រ** ២៨៩

**ម** មកតាមខ្ញុំ ហើយនៅជាមួយខ្ញុំ.................................. **ទំព័រ** ២៩៥
មកតាមខ្ញុំ ហើយស្នាក់នៅជាមួយខ្ញុំ ............................ ២៩៥
មនុស្សឈ្លាសវៃ .................................................... ៣៤១
មនុស្សលើផែនដី.................................................... ១៣៤
ម៉ារ៉ាណាថា ......................................................... ២៥៣
មានមនុស្សច្រើនឥតគណនា.................................... ៣១៨
មានសុភមង្គលមែន................................................ ៣៣១
មានសុភមង្គលហើយ !.......................................... ២២០
មានសុភមង្គលហើយ! អស់អ្នកឯណាព្រះម្ចាស់ជ្រើសរើស. ២១៦

**យ** យប់ដ៏សុខសាន្ត..................................................... **ទំព័រ** ២៥៩
យុវជនគឺជាទំពាំងស្នងឫស្សី ...................................... ៣៣២
យើងកោតសរសើរព្រះគ្រីស្ត ..................................... ២៦៥
យើងខ្ញុំជឿជាប្រាកដ ............................................... ២១៨
យើងខ្ញុំទាំងអស់គ្នាអរវីករាយ.................................... ១៣៦
យើងខ្ញុំសច្ចា យើងខ្ញុំសន្មត់..................................... ២៩៩
យើងខ្ញុំសប្បាយរីករាយទទួល ................................... ២៦០
យើងខ្ញុំសូមកោតសរសើរព្រះម្ចាស់............................. ២២១
យើងខ្ញុំសូមក្រាបបង្គំ.............................................. ២៧៤
យើងខ្ញុំសូមដើរតាមព្រះយេស៊ូ.................................. ៣៣៤
យើងខ្ញុំសូមថ្វាយតង្វាយ........................................... ១៦៣

យើងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់ ............................ ៣៣៣
យើងខ្ញុំសូមអរព្រះគុណព្រះអម្ចាស់ ! .......................... ៣៣៤
យើងខ្ញុំសែនសប្បាយ ............................................. ១៦៦
យើងខ្ញុំឱនក្រាបប្រណម្យមាតា.................................. ២៤៦
យើងគិតដល់ជីវិត................................................. ៣៣៣
យើងជាធ្លុងតែមួយ ............................................... ៣០៩
យើងជាយុវជន សូមឲ្យយើងចេះស្រឡាញ់ ................ ៣៣១
យើងជួបជុំដោយភក្តីនៅជុំវិញព្រះអាសនៈ .................. ១៦២
យើងជឿពិត ព្រះគ្រីស្ត .......................................... ២៧០
យើងទុកចិត្តលើព្រះជាអម្ចាស់.................................. ២៩៥
យើងទាំងអស់ ដែលបានទទួលទទួលពិធីជ្រមុជទឹក ....... ២៨៦
យើងទាំងអស់អញ្ជើញមក....................................... ៣៤៥
យើងនឹងប្រោះទឹកដ៏បរិសុទ្ធលើអ្នក ............................ ៣២០
យើងបានស្រឡាញ់អ្នក .......................................... ៣៣៣
យើងមានព្រះគ្រីស្តធ្វើជាគំរូ.................................... ៣៣៣
យើងមានព្រះយេស៊ូគ្រីស្ត ....................................... ៣២៨
យើងរួបរួមគ្នា...................................................... ១៦៥
យើងរួបរួមគ្នាក្នុងព្រះសហគមន៍ ............................... ១៦៤
យើងរួបរួមគ្នាជាធ្លុងតែមួយ .................................... ៣៤០
យើងរួមគ្នាជាធ្លុងតែមួយ ........................................ ៣៣២
យើងរួមជាមួយគ្នា................................................. ៣៤១
យើងសូមកោតសរសើរព្រះនាងម៉ារី............................ ២៤៦
យើងសូមក្រាបសំពះព្រះគ្រីស្ត.................................. ១៩៩
យើងសូមជូនផ្កាមួយនេះ ........................................ ៣៣៤

យើងសូមអរព្រះគុណ........................................ ២៩៥
យើងសែនរីករាយ........................................ ២៦១
យើងសែនសប្បាយ........................................ ១៣៥
យើងអបអរ សរសើរសន្តយូសែប........................................ ២៥១
យេស៊ូកូនចៀម........................................ ២៦០

**រ** រង់ចាំព្រះគ្រីស្ត........................................ **ទំព័រ** ២៥៣
រស់ជាមួយគ្នាដូចបងប្អូនគ្នា........................................ ១៣៨
រាត្រីរងាព្រះអង្គប្រសូត........................................ ២៦១
រីករាយស្វាគមន៍........................................ ៣៣៥
រូបកាយខ្មោចខ្មាំជីវិតស៊ូទ្រាំ........................................ ១៦៣
រួមគ្នាកសាងព្រះសហគមន៍........................................ ៣៣៦
រួមគ្នាកោតសរសើរព្រះគ្រីស្ត........................................ ២៧៤

**ល** លាហើយមិត្តសម្លាញ់........................................ **ទំព័រ** ៣៣៨
លើកដៃស្តាំចេញទៅ........................................ ៣៣៨
លោកតាអាប្រាហាំ........................................ ៣៣៩
លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង........................................ ៣៣៩
លោកពុកស៊ូទ្រាំពិបាក........................................ ៣០៣
លោកយេស៊ូនេះដែលបងប្អូនបានឆ្កាង........................................ ៣៣៩
ល្អណាស់ពេលយើងទុកចិត្តទៅលើព្រះអម្ចាស់........................................ ២៩៥

**វ** វិញ្ញាណខ្ញុំសូមលើកតម្កើង........................................ **ទំព័រ** ២៣៩
វិញ្ញាណព្រះម្ចាស់........................................ ១៣៩

វិន័យ ១-១០ ................................................... ៣៨០
វិន័យរបស់ខ្ញុំ ................................................... ២១៩

ស សន្តយ៉ូសែប ដែលជារាជវង្សរបស់ព្រះបាទដាវីឌ........... **ទំព័រ** ២៥០
សន្តយ៉ូសែបជាគំរូ................................................... ២៥០
សន្និបាតព្រះសហគមន៍................................................... ៣៨១
សម្តេចក្សត្រីវរមាតា................................................... ២៣៥
សាសនានានា តែងតែអប់រំមនុស្សឲ្យស្គាល់ស្នេហ៍.............. ៣០៤
សូមក្រាបបង្គំព្រះម្ចាស់................................................... ១៤០
សូមក្រាបសំពះសម្តេចក្សត្រីម៉ារី................................ ២៤៧
សូមជួយយើងខ្ញុំឲ្យចេះគិតគូរ.................................. ៣៣៦
សូមទទួលតង្វាយពីកូនទាំងឡាយ .............................. ១៦៧
សូមទៅប្រាប់បងប្អូន ................................................... ២៨៧
សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តា.................................. ២៧៥
សូមព្រះជាម្ចាស់ប្រទានពរឆ្នាំថ្មី................................. ២៩៧
សូមព្រះជាម្ចាស់មេត្តាប្រោសភ្នែក............................. ២២២
សូមព្រះជាម្ចាស់អាសូរស្តាប់សំឡេងកូន....................... ២៧៦
សូមព្រះជាអម្ចាស់បង្រួបបង្រួមយើង.......................... ៣០៥
សូមព្រះបិតាទទួលតង្វាយ ........................................ ១៦៥
សូមព្រះវិញ្ញាណយាងមក ........................................ ២៩១
សូមព្រះអង្គគង់នៅជាមួយយើង .............................. ២៩៦
សូមព្រះអង្គគង់នៅជាមួយយើង .............................. ២៩៦
សូមព្រះអម្ចាស់ទ្រង់មេត្តា........................................ ១៩៤
សូមមេត្តាប្រោសយើងខ្ញុំ ........................................ ២៧៦

សូមយាងមក ឱ! ព្រះវិញ្ញាណនៃព្រះជាម្ចាស់................ ២៩០
សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ទ .......................... ១៥៣
សូមលើកតម្កើងព្រះជាម្ចាស់.................................... ៣៤២
សូមសម្ដេចក្សត្រី.................................................. ២៣៦
សូមអញ្ជើញមករស់ក្នុងពន្លឺ...................................... ១៥០
សូមអរព្រះគុណ.................................................... ១៤១
សូមអរព្រះគុណព្រះជាម្ចាស់.................................... ៣៤៧
សូមឲ្យចិត្តយើងបានសុខសន្តិភាព.............................. ៣៤២
សូរិយាចែងរស្មីភ្លឺថ្លា.............................................. ១៤០
សួស្ដីថ្ងៃកំណើត.................................................... ៣៤៣
សេចក្តីស្រឡាញ់ដែលព្រះជាអម្ចាស់ប្រទានមក............. ២២៤
ស្រឡាញ់ព្រះអម្ចាស់.............................................. ២១៩
ស្វាគមន៍អ្នកស្វែងរក.............................................. ៣០៤
ស្វាមីត្រូវស្រឡាញ់ភរិយា........................................ ២៩៩

**ហ** ហ៊ី ហ៊ី ហ៊ី សូមព្រះគ្រីស្ទយាងមកក្នុងព្រលឹងខ្ញុំ ............. **ទំព័រ** ១៩៩

**ឡ** ឡា ឡា ឡា ខ្ញុំសែនសប្បាយណាស់.......................... **ទំព័រ** ១២៧

**អ** អបអរសប្បាយ ................................................ **ទំព័រ** ៣២៦
អបអរសាទរ ថ្ងៃចូលឆ្នាំថ្មី ........................................ ២៩៧
អបអរសាទរចូលឆ្នាំមហាករុណាទិគុណ........................ ៣៤៤
អប្បា! ................................................................ ៣៤៤
អរគុណព្រះម្ចាស់.................................................. ២៣៤

អរព្រះគុណព្រះយេស៊ូគ្រីស្ត...................................... ២៤៧
អាលេលូយ៉ា ចូរឱនគ្រៀបត្រា.................................. ២២៧
អាលេលូយ៉ា សរសើរព្រះម្ចាស់ ................................ ២២៨
អាលេលូយ៉ា ឱ! ព្រះបិតាអើយ ................................ ១៦១
អាលេលូយ៉ា អ្នកឈ្មោះសិលា................................... ១៥៧
អាលេលូយ៉ា អ្នកណាស្តាប់ៗ .................................... ១៦០
អាលេលូយ៉ា! ចូររៀបចំផ្លូវថ្វាយព្រះម្ចាស់ .................. ១៥២
អាលេលូយ៉ា! ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់....... ១៥៦
អាលេលូយ៉ា! ចូរអ្នកស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់.. ១៥៨
អាលេលូយ៉ា! នៅថ្ងៃនេះទ្វារស្ថានបរមសុខបើកហើយ..... ១៥៤
អាលេលូយ៉ា! នៅថ្ងៃនេះព្រះពន្លឺបានបំភ្លឺមនុស្សលោក..... ១៥២
អាលេលូយ៉ា! បពិត្រព្រះនាងព្រហ្មចារិនីម៉ារី ............... ១៥៥
អាលេលូយ៉ា! បពិត្រព្រះនាងព្រហ្មចារិនីម៉ារី!.............. ១៥៦
អាលេលូយ៉ា! បពិត្រព្រះបិតា.................................. ១៥៨
អាលេលូយ៉ា! ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ........... ២៨០
អាលេលូយ៉ា! ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលច្បាស់ថា ..... ៣៤៥
អាលេលូយ៉ា! ព្រះយេស៊ូមានព្រះបន្ទូលថាខ្ញុំហ្នឹងហើយជាផ្លូវ ១៥៩
អាលេលូយ៉ា! ព្រះអម្ចាស់មានព្រះបន្ទូល...................... ១៥៩
អាលេលូយ៉ា! ព្រះអម្ចាស់មានព្រះបន្ទូលថា................... ៣៣០
អាលេលូយ៉ា! យើងច្រៀងសរសើរព្រះជាអម្ចាស់........... ១៥៩
អាលេលូយ៉ា! វិញ្ញាណព្រះម្ចាស់សណ្ឋិតលើខ្ញុំ ................ ១៥៤
អាលេលូយ៉ា! សូមលើកតម្កើងព្រះយេស៊ូ ..................... ១៥៣
អាលេលូយ៉ា! សូមលើកតម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់. ១៥២
អាលេលូយ៉ា! អញ្ជើញស្តាប់ព្រះបន្ទូលព្រះអម្ចាស់........... ១៥៩

អាលេលូយ៉ា! ឱព្រះវិញ្ញាណដ៏វិសុទ្ធ ............................ ១៥៥
អាលេលូយ៉ា! ឱព្រះអម្ចាស់អើយ! ............................ ១៦១
អាលេលូយ៉ា! ចូរអ្នកស្រឡាញ់ព្រះអម្ចាស់ ...................... ១៦០
អាលេលូយ៉ា! ព្រះអម្ចាស់យាងឡើងស្ថានបរមសុខ........... ១៥៤
អាវេ ម៉ារីយ៉ា ........................................................ ២៤៨
អូ អូ អូ យុវជន យុវនារី.......................................... ៣៤៣
អូ អូ អូ អូ ចូរយើងច្រៀងថ្វាយព្រះម្ចាស់ ................... ២៩៤
អូ...ព្រះគ្រីស្តរស់ឡើងវិញ.......................................... ២៩៤
អស់ពីដួងចិត្ត!.......................................................... ២៩៦
អ្នកជឿមកពីអ្នកបានឃើញខ្ញុំ.................................... ៣៤៦
អ្នកណាដែលកាន់តាមព្រះបន្ទូលព្រះអង្គ....................... ៣៤៦
អ្នកណាស្តាប់.............................................................. ៣៤៦
អ្នកណាអង្វររកព្រះនាម............................................ ៣៤៦
អ្នកបម្រើដ៏ប្រសើរ .................................................... ២៧៨
អំបិល និងពន្លឺ.......................................................... ៣៤៨
អំពើអាក្រក់ខ្ញុំច្រើនឥតគណនា.................................... ២៧៧
អ៊ុះឱ ! អ្នកស្រុកកាលីឡេអើយ .................................. ២៨៧
អ៊ុះឱ! ព្រះជាអម្ចាស់ ខ្ញុំស្រឡាញ់ណាស់...................... ១៤៦
អុះឱប្រជាជនទាំងឡាយ .............................................. ៣៤៨
ឲ្យយើងស្គាល់ព្រះគម្ពីរ .............................................. ៣២០

**ឱ** ឱ ! ជនកម្សត់...................................................... **ទំព័រ** ២៧៨
ឱ ! ជនទាំងឡាយ...................................................... ១៤២
ឱ ! ពួកគង្វាលសត្វអើយ .......................................... ២៦៣

ឱ ! ព្រះគ្រីស្តព្រលឹងខ្ញុំស្រេកឃ្លាន............................ ២០០
ឱ ! ព្រះគ្រីស្តអើយទ្រង់ជាផ្លូវហើយ.......................... ២០១
ឱ ! ព្រះជាម្ចាស់ ខ្ញុំសូមព្រះអង្គការពារ ...................... ១៤៤
ឱ ! ព្រះជាម្ចាស់ទ្រង់ព្រះនាមល្បី ............................. ១៥១
ឱ ! ព្រះជាម្ចាស់ប្រសើរថ្លៃថ្លា.................................. ២០៥
ឱ ! ព្រះជាម្ចាស់យើងខ្ញុំគោរព................................ ១២៨
ឱ ! ព្រះជាម្ចាស់អើយ !...................................... ២០៧
ឱ ! ព្រះជាម្ចាស់អើយ ....................................... ២១៣
ឱ ! ព្រះជាអម្ចាស់ សូមមេត្តាសង្គ្រោះយើងខ្ញុំ .............. ២២៣
ឱ ! ព្រះជាអម្ចាស់អើយ........................................ ៦
ឱ ! ព្រះនាងព្រហ្មចារិនីម៉ារី.................................. ២៤៨
ឱ ! ព្រះនាងម៉ារី................................................ ២៣៦
ឱ ! ព្រះនាងម៉ារី................................................ ២៤៩
ឱ ! ព្រះបិតាជាព្រះជាម្ចាស់.................................. ១៦៧
ឱ ! ព្រះបិតាជាអម្ចាស់......................................... ១៦៦
ឱ ! ព្រះបិតាដ៏ឧត្តមអើយ ...................................... ១៤៥
ឱ ! ព្រះវិញ្ញាណសូមយាងមក................................. ២៩៦
ឱ ! ព្រះសង្គ្រោះយើងខ្ញុំ........................................ ២៥៤
ឱ ! ព្រះអម្ចាស់ដ៏មានតេជះ.................................. ១៨៤
ឱ ! ព្រះអម្ចាស់ព្រះសង្គ្រោះ.................................. ១៧៦
ឱ ! ព្រះអម្ចាស់អើយ យើងអរសប្បាយ..................... ១៣៧
ឱ ! ព្រះអម្ចាស់អើយ .......................................... ១៩៥
ឱ ! ព្រះអម្ចាស់អើយ .......................................... ១៩៥
ឱ ! មនុស្សអើយ................................................ ៣៤៩

ឱ ! ម៉ារីយ៉ាអើយ! ............................................... ២៤៩
ឱ ! មាតានៃព្រះសង្គ្រោះ ..................................... ២៤៥
ឱ ! មេឃស្ងប់ស្ងួន្យ............................................... ២៦៤
ឱ ! ព្រះសង្គ្រោះសូមយាងមក ............................... ២៥៤
ឱ! ព្រះគ្រីស្តអើយ ............................................... ១៤៣
ឱ! ព្រះគ្រីស្តអើយ!.............................................. ២៧១
ឱ! ព្រះជាម្ចាស់ តើនរណាខ្លះអាចរស់នៅក្នុងជំណាក់...... ១៩០
ឱ! ព្រះជាម្ចាស់អើយ........................................... ១៩៨
ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ ...................................... ១៤៣
ឱ! ព្រះបិតាប្រកបដោយឫទ្ធានុភាព.......................... ២៩១
ឱ! ព្រះបិតាយើងលើកហត្ថាសូមថ្វាយជីវិត.................. ១៦៥
ឱ! ព្រះអម្ចាស់ទោះយើងខ្ញុំម្ចាស់ ............................... ២១៧
ឱ! វិញ្ញាណខ្ញុំ ចូរក្រាបបង្គំ..................................... ៣៤៩
ឱ! ព្រះជាម្ចាស់អើយ ............................................. ៣២៩
ឱ! ព្រះបិតាជីវិសុទ្ធ................................................ ៣១២
ឱព្រះជាម្ចាស់អស្ចារ្យពេកក្រៃ .................................. ២៥៦
ឱព្រះជាម្ចាស់អើយ! ............................................. ២១៤
ឱព្រះនាងម៉ារីជាមាតាព្រះគ្រីស្តជាអម្ចាស់អើយ ............ ២៤៦
ឱព្រះបិតាព្រះអង្គអាចសម្រេចគ្រប់កិច្ចការ.................. ៣៤៣
ឱព្រះបិតាអើយ!.................................................. ៣៤៨